ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



◆ សាលក្រម ឌុច ចំពោះករណី001 របស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម

◆ ការបញ្ចាំងសាលក្រម ឌុច រំពឹងថាមានសន្តិភាព

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១២៩ ខែកញ្ញា ឆ្នាំ២០១០

# ស្វែងរកការពិត

*លេខ១២៩ ខែកញ្ញា ឆ្នាំ២០១០*

## ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា


◆សាលក្រម ឌុច ចំពោះករណី០០១ របស់តុលាការ..............................១

**ផ្នែកឯកសារ**

◆កុមារពេទ្យ៦មករា..............................................................៣

◆ស្លាប់ដោយសារជំងឺ និងខ្វះអាហារ..............................................៥

◆យើងត្រូវចងចាំថាសាលាក្តីខ្មែរក្រហមគឺសម្រាប់ប្រជាជន.......................៨

◆គម្រោងចូលរួមរបស់ជនរងគ្រោះ ៖ ការបែកលិខិតឆ្លើយតប...............១០

◆តាមដងវិថីទៅរកយុត្តិធម៌..........................................................១៤

◆ខ្មែរក្រហមបោកប្រាស់.............................................................១៦

◆ខ្មែរក្រហម ៖ ការកេណ្ឌទ័ពនិងជ្រើសរើស.......................................១៨

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ការរៀបរាប់របស់គ្រូបង្រៀនប្រវត្តិសាស្ត្រ.....................................២៣

◆សំឡេងរបស់អ្នកដាក់ពាក្យបណ្ដឹងនៅ អ.វ.ត.ក ៖............................៣០

◆ពេទ្យស្រុកគិរីវង្ស.................................................................៣៤

◆ការបញ្ចាំងសាលក្រម ឌុច រំពឹងថាមានសន្តិភាព................................៣៦

◆កាលប្បវត្តិនៃដំណើរការកាត់ក្តីសេចក្តីជនជាប់ចោទ...........................៣៨

◆តើការផ្សព្វផ្សាយអំពីការថែរក្សាប្រវត្តិឧក្រិដ្ឋកម្ម.............................៤០

**ផ្នែកច្បាប់**

◆ការបង្ហាញអំពីគោលបំណងនៃអំពើប្រល័យពូជសាសន៍..........................៤២

◆យុត្តិសាស្ត្រនីតិវិធីដែលធ្វើឲ្យមានប្រសិទ្ធភាពផ្នែកប្រព័ន្ធតុលាការ......៤៦

◆ការជំរុញឲ្យមានការផ្សះផ្សា.......................................................៥៩

**វេទិកាពិភាក្សាសាធារណៈ**

◆នៅមុនថ្ងៃវិនិច្ឆ័យទោស ឌុច.......................................................៥២

◆ប្រតិកម្មរបស់អ្នកភូមិនៅខេត្តកណ្ដាលចំពោះការបញ្ចាំង.......................៥៤

◆ទស្សនៈរបស់និស្សិតខ្មែរម្នាក់ចំពោះពាក្យអង្គការ..............................៥៦

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ឪពុករបស់ខ្ញុំកាលពីកុមារភាព..................................................៥៧

◆យុត្តិធម៌និងការឈឺចាប់.........................................................៥៩




**ព្រះសង្ឃនៅវត្តកោងកាងខេត្តប៉ៃលិន**


## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ

ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន

លេខ០២៩១ពម/៩៩

ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា

និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង



**ស្នាលេខនេះ ៖** ចាន់ ដល្លា, កែវ ដាស៊ីល, ជី ទេវិទ្ធិ, ដេនីហ្វើ កា, សើ សាយព្រណា, លី រ៉ម៉ាស់, ចេង ប៊ុនយាង, ហ្គ្រីហ្គោរី ប្រកណ្ឌ, យ៉ានីក ស្មីត, សុខ វណ្ណៈ, ណាតាលី អេនដឺសាន់, វ៉ែរ៉ុន អ៊ីដាក, អាបេ ថូស៊ីហៃរ៉ូ, ដេវីដ សេហ៊ុរ, ម៉ៃឃើល សាលីបា និង ថៃលើ នីមស៍, ម៉ម សុវណ្ណ **អ្នកនិពន្ធនិងស្រាវជ្រាវ ៖** គាត លក្ខិណា, សោម ប៊ុនថន, ស៊ិន សុធីតា **អ្នកបកប្រែ ៖** ជា ដល្លា **និពន្ធនាយកទូទៅ ៖** ឆាំង យុ **ជំនួយការនិពន្ធនាយក ៖** ញាណ សុជាតិ, ទេព ម៉េងឃាន **ក្រាហ្វិកកុំព្យូទ័រ ៖** ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយ ៖** ម៉ម សុផាត Email: dccam@online.com.kh, Homepage: www.dccam.org

*សំបុត្រៈ*

# សាលក្រម ឌុច ចំពោះករណី០០១ របស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម : តើមានយុត្តិធម៌ដែរឬទេ សម្រាប់អ្នកទោស១៤០០០នាក់ដែលបានស្លាប់នៅគុកទួលស្លែង?

សាលក្រម ឌុច នេះដូចជាមិនខុសឆ្គងប៉ុន្មានទេ ។ កំហឹងនិងអារម្មណ៍ក្រេវក្រោធចំពោះចំនួនឆ្នាំនៃការដាក់ទោស ឌុច មានសន្ទុះយ៉ាងខ្លាំង ។ បើសិនជារយៈពេលដែល ឌុច ត្រូវបានឃុំខ្លួនមានចំនួនច្រើនជាងនេះបន្តិច នោះប្រហែលជាធ្វើឲ្យមានការពេញចិត្តពីសំណាក់ជនរងគ្រោះភាគច្រើន ។ ប៉ុន្តែគ្មានអ្វីមួយ ឬសាលក្រមណាមួយដែលអាចបំពេញចិត្តចំពោះការបាក់បែករបស់ជនរងគ្រោះទាំងស្រុងនោះបានទេ ។ យើងអាចដាក់ទោស ឌុច ឲ្យជាប់ទោស ១៤០០០ឆ្នាំ សម្រាប់ជីវិតជនរងគ្រោះម្នាក់ដែលបានស្លាប់ ហើយសូម្បីតែយើងធ្វើបែបនេះ ក៏យុត្តិធម៌នៅតែមិនអាចផ្តល់ឲ្យយើងបានដដែល ។ ប៉ុន្តែទោះបីជាយ៉ាងណាតុលាការបានបង្ហាញថាជនដែលបានប្រព្រឹត្តខុសត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ ។ ឥឡូវនេះ ជាពេលចាំបាច់ណាស់ក្នុងការផ្សព្វផ្សាយដល់ប្រជាជនកម្ពុជាទូទៅដើម្បីសុំការគាំទ្រចំពោះតុលាការបន្ថែមទៀត មុននឹងករណី០០២ ចាប់ផ្តើម ។ ករណី០០២ នឹងជាអង្គជំនុំជម្រះដ៏មានសារសំខាន់ជាទីបំផុតសម្រាប់ប្រវត្តិសាស្រ្តកម្ពុជា ។

## ប្រវត្តិរូបសង្ខេបរបស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច

កាំង ហ្គេកអ៊ាវ ហៅ ឌុច ចាប់កំណើតឡើងនៅថ្ងៃទី១៧ ខែវិច្ឆិកា នៅភូមិពៅវ៉ើយ ឃុំពាមបាង ស្រុកស្ទោង ខេត្តកំពង់ធំ ។ ឌុច គឺជាកូនប្រុសតែម្នាក់គត់ក្នុងចំណោមបងប្អូនប្រាំនាក់នៅក្នុងត្រកូលគ្រួសារខ្មែរកាត់ចិន ។ ឌុច ទទួលចំណាប់អារម្មណ៍លើរបប



ឌុច នៅថ្ងៃប្រកាសសាលក្រម

កុម្មុយនីស្តនៅពេលដែលគាត់កំពុងសិក្សានៅថ្នាក់វិទ្យាល័យនិងនៅពេលដែលគាត់កំពុងទទួលការបណ្តុះបណ្តាលដើម្បីក្លាយជាគ្រូបង្រៀន ។ គាត់ត្រូវបានចាប់ខ្លួនដោយរដ្ឋាភិបាល កាលពីជំនាន់សង្គមរាស្ត្រនិយមក្នុងឆ្នាំ១៩៦៨ពីបទគាំទ្រសកម្មភាពខ្មែរក្រហម ហើយគាត់ត្រូវបានដាក់ឃុំឃាំងអស់រយៈពេលជិតពីរឆ្នាំនៅគុកព្រៃស ។ ក្នុងឆ្នាំ១៩៧០ ឌុច ត្រូវបានដោះលែងឲ្យមានសេរីភាពដោយរដ្ឋាភិបាល លន់ នល់ ដែលជាយុទ្ធនាការនៃការលើកលែងទោសចំពោះអ្នកទោសនយោបាយបន្ទាប់ពីរបបសម្តេចសីហនុត្រូវបានផ្តួលរំលំ ។

ក្រោយចេញពីគុក ឌុច បានចូលរួមជាមួយចលនាខ្មែរក្រហមម្តងទៀត ។ អស់រយៈពេលពីរបីឆ្នាំក្រោយមក ឌុច បានបង្កើតនិងដឹកនាំគុកខ្មែរក្រហមចំនួនពីរនៅក្នុងខេត្តកំពង់ស្ពឺ គឺមន្ទីរ ម-១៣និង មន្ទីរ ម-៩៩ ហើយពេលនោះ ឌុច ចាប់ផ្តើមសម្រួចការងាររបស់ខ្លួនអំពីបច្ចេកទេសសួរចម្លើយ ។

មន្ទីរឃុំឃាំងស-២១ដែលមានទីតាំងនៅទីក្រុងភ្នំពេញ ត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៧៥ ក្រោមការគ្រប់គ្រងរបស់សមមិត្ត អ៊ិន លន ហៅ ណាត ដែលមានវិទ្យុទាក់ទងលេខ ២១ ។ លេខ ២១ បានក្លាយទៅជាមន្ទីរ ស-២១ នេះឯង ។ កាលនោះ ឌុច មាននាទីជាអនុប្រធានរបស់ ណាត ។ ក្នុងឆ្នាំ១៩៧៦ ឌុច ឡើងកាន់តំណែងជាប្រធាន ហើយគាត់បន្តកាន់តំណែងនោះរហូតដល់ទីក្រុងភ្នំពេញផ្តួលរំលំក្នុងឆ្នាំ១៩៧៩ ។

ក្រោយពីរបបកម្ពុជាប្រជាធិបតេយ្យផ្តួលរំលំ ឌុច បានបន្តរស់នៅជាមួយអតីតមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមនៅក្នុងជំរំជនភៀសខ្លួនជិតព្រំដែនថៃរហូតដល់ឆ្នាំ១៩៨៤ នៅពេលដែលគាត់ត្រូវបានបញ្ជូនទៅប្រទេសចិនដើម្បីបង្រៀនភាសាខ្មែរដល់ជនជាតិចិន ។ ក្រោយពី ឌុច ត្រឡប់មកពីប្រទេសចិនវិញ គាត់បានប្តូរឈ្មោះទៅជា ហង់ ពិន វិញ ហើយជាថ្មីម្តងទៀតគាត់បានក្លាយជាគ្រូបង្រៀន ។ ក្នុងឆ្នាំ១៩៩៥ ផ្ទះរបស់គាត់នៅស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ត្រូវជួបឧប្បត្តិហេតុមួយ ហើយប្រពន្ធរបស់គាត់ត្រូវបានសម្លាប់នៅក្នុងអំពើប្លន់ ឬជាសកម្មភាពសងសឹកមកលើគ្រួសាររបស់គាត់ ។ ក្រោយមក ឌុច បានប្តូរទីលំនៅទៅរស់នៅជាមួយប្អូនស្រីរបស់គាត់វិញឈ្មោះ ហង់ គីមហុង (សព្វថ្ងៃគឺជាគិលានុបដ្ឋាយិកាម្នាក់ ហើយកាលពីជំនាន់ខ្មែរក្រហម គាត់គឺជាអនុប្រធានរបស់ប្រពន្ធរបស់ ឌុច) ។ នៅពេលដែលគាត់ធ្វើជាគ្រូបង្រៀន ឌុច បានព្យាយាមធ្វើឲ្យអារម្មណ៍ស្ងប់ស្ងាត់តាមរយៈសាសនាគ្រិស្ត ដែលក្រោយមកគាត់បានប្តូរទៅកាន់សាសនាគ្រិស្តវិញ ។ ឌុច ត្រូវបានកំណត់ពីអត្តសញ្ញាណ ហើយក្រោយមកត្រូវបានចាប់ខ្លួននៅសំឡូតក្នុងឆ្នាំ១៩៩៩ បន្ទាប់មកគាត់ត្រូវបានឃុំខ្លួនអស់រយៈពេលប្រាំបីឆ្នាំដោយគ្មានជំនុំជម្រះនៅក្នុងគុកយោធាកម្ពុជា ។ ក្នុងឆ្នាំ២០០៧ ឌុច ត្រូវបានចោទប្រកាន់ ហើយនឹងបញ្ជូនទៅដាក់ក្នុងមន្ទីរឃុំឃាំងក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ឬតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ អ.វ.ត.ក គឺជាតុលាការពិសេសមួយបង្កើតឡើងដោយរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិដើម្បីវិនិច្ឆ័យទោសចំពោះការទទួលខុសត្រូវរបស់មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមនិងជនទាំងឡាយណាដែល «ទទួលខុសត្រូវខ្ពស់បំផុត» ចំពោះបទឧក្រិដ្ឋដែលកើតឡើងចន្លោះពីឆ្នាំ១៩៧៥ ដល់១៩៧៩ ។ **ឆាំង យុ**



ព្រះសង្ឃនិងប្រជាជនក្នុងខេត្តប៉ៃលិនកំពុងមើលការប្រកាសសាលក្រម ឌុច

# កុមារពេទ្យ ៦មករា

ញ៉ែម ខាន់ ហៅ ធឿន រស់នៅស្រុកត្រាំកក់ ខេត្តតាកែវ ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខាន់ ត្រូវបានអង្គការចាត់តាំងឲ្យធ្វើការនៅក្នុងកងកុមារ ប៉ុន្តែក្រោយមក ប្រធានភូមិបានជ្រើសរើស ខាន់ ឲ្យធ្វើការនៅមន្ទីរពេទ្យ៦មករាវិញ ទោះបីជាគាត់រៀនបានតិចតួចក៏ដោយ ។


ញ៉ែម ខាន់

ខាន់ មានបងប្អូនចំនួនប្រាំនាក់ មានឪពុកឈ្មោះ ញ៉ែម ស៊ី និងម្តាយឈ្មោះ ចាន់ ចែម ។ នៅឆ្នាំ១៩៧៦ ពេលដែល ខាន់ កំពុងតែរែកដីជាមួយកុមារក្នុងកងជាមួយគ្នា ស្រាប់តែមេឃុំឈ្មោះ ខែម បានប្រកាសហៅកុមារក្នុងកងទាំងអស់ឲ្យមកជួបជុំគ្នារួចប្រាប់ថាគាត់ត្រូវការជ្រើសរើសកុមារពីរនាក់ទៅធ្វើការនៅមន្ទីរពេទ្យវត្តអង្គពណ្ណរាយ ។ ពេលនោះ ខែម បានហៅឈ្មោះ ខាន់ និងកុមារម្នាក់ទៀតឈ្មោះ សាវ ទៅធ្វើការនៅមន្ទីរពេទ្យ ប៉ុន្តែក្រោយមក ខែម បានបញ្ជូនតែ ខាន់ ទៅប៉ុណ្ណោះ ចំណែក សាវ គាត់ទុកឲ្យធ្វើការក្នុងកងកុមារដដែល (សព្វថ្ងៃនេះ ខែម ស្លាប់ដោយសារជំងឺ) ។ ពេលទៅដល់ទីនោះភ្លាម ប្រធានពេទ្យបានឲ្យ ខាន់ រៀនចាក់ថ្នាំដោយប្រើម្ជុលចាក់លើខ្នើយនិងពូកជាមុនសិន ។ ទោះបីជា ខាន់ ចេះអក្សរបន្តិចបន្តួចក៏ដោយ ប៉ុន្តែក្រោយពីទទួលការបង្ហាត់បង្រៀនមក ខាន់ ក៏រៀនចេះស្ទាត់និងត្រូវបានអនុញ្ញាតឲ្យចាក់ថ្នាំឲ្យអ្នកជំងឺដោយផ្ទាល់ ។

នៅខែឧសភា ឆ្នាំ១៩៧៧ ប្រធានពេទ្យវត្តអង្គពណ្ណរាយបានបញ្ជូន ខាន់ មកធ្វើការនៅមន្ទីរពេទ្យ៦មករាវិញ ។ ខាន់ ស្នាក់នៅទីរួមខេត្តតាកែវមួយយប់សិន លុះព្រឹកឡើងទើបគាត់បន្តដំណើរទៅទីក្រុងភ្នំពេញ ។ ប៉ុន្តែពេលមកដល់ ខាន់ ត្រូវបានបញ្ជូនឲ្យមកសម្រាកនៅមន្ទីរពេទ្យព-៩ (នៅស្ពានីយរថភ្លើង) ពីរថ្ងៃ ។ នៅទីនោះ ខាន់ មានការភ្ញាក់ផ្អើលនិងភ័យខ្លាចយ៉ាងខ្លាំង ពីព្រោះគាត់បានឃើញសាកសពនិងឆ្អឹងជាច្រើនដែលប្រធានពេទ្យបានរក្សាទុកដែលសាកសពទាំងនោះសុទ្ធតែជាក្មេងស្រី ។ ដោយសារមានការងឿងឆ្ងល់ ខាន់ បានសួរទៅកាន់ពេទ្យដែលធ្វើការនៅទីនោះថា «តើគេរក្សាទុកសាកសពហើយនិងឆ្អឹងនេះធ្វើអ្វី?» គ្រូពេទ្យនោះបានឆ្លើយប្រាប់ថា «សាកសព ហើយនិងឆ្អឹងទាំងអស់នេះគេរក្សាទុកដើម្បីឲ្យគ្រូពេទ្យទាំងអស់រៀនចាក់ថ្នាំនិងរៀនពិនិត្យមើលសរសៃឈាមហើយសាកសពទាំងនេះត្រូវបានប្រធានពេទ្យចាក់ថ្នាំការពារដើម្បីកុំឲ្យស្អុយរលួយទៀតផង» ។

រយៈពេលពីរថ្ងៃក្រោយមក ប្រធានពេទ្យបានបញ្ជូនគាត់ឲ្យទៅធ្វើការនៅមន្ទីរពេទ្យ៦មករាវិញ ដោយនៅទីនោះ ខាន់ ត្រូវរៀនពីវិធីចាក់សរសៃនិងចាក់សាច់ដុំទៀត ។ ដោយសារតែ ខាន់ ធ្លាប់បានរៀនពីមុនមកគាត់អាចធ្វើកិច្ចការនេះបានល្អ ។ ប៉ុន្តែ ខាន់ ក៏មានការពិបាកផងដែរក្នុងការអានអក្សរលើដបថ្នាំព្រោះសុទ្ធតែជាអក្សរបារាំងនិងអង់គ្លេស ។ បន្ទាប់មក ខាន់ ត្រូវបានចាត់តាំងឲ្យទៅធ្វើការនៅអគារទីមួយជាមួយសមាជិកជាច្រើនទៀតដែលសុទ្ធតែជាមនុស្សស្រីក្រោមការគ្រប់គ្រងរបស់ប្រធានឈ្មោះ ហាន ដែលត្រូវជាបងធម៌របស់គាត់ ។ រៀងរាល់ថ្ងៃ ខាន់ មានតួនាទីលាងរបួសនិងចាក់ថ្នាំឲ្យអ្នកជំងឺតាំងពីព្រឹកព្រលឹមរហូតដល់ម៉ោងប្រាំ សម្រាកហូបបាយរួចបន្តយាមរហូតដល់ម៉ោង១២យប់ទើបអាចចូលសម្រាកបាន ។ ខាន់ សម្គាល់ឃើញថា អ្នកជំងឺដែលមកសម្រាកនៅទីនេះភាគច្រើនជាកងទ័ពដែលមានរបួសនៅសមរភូមិត្រូវបានដឹកតាមកប៉ាល់មកហើយមិនមានប្រជាជនមកព្យាបាលទេ ។ ចំណែកការព្យាបាលវិញមិនដែលមានអ្នកជំងឺស្លាប់ទេព្រោះ

មានថ្នាំព្យាបាលល្អៗដែលបរទេសផ្តល់ឲ្យ ហើយខុសគ្នានឹងថ្នាំនៅមន្ទីរពេទ្យវត្តអង្គពណ្ណរាយដែលផលិតចេញពីគ្រាប់ស្វែងនិងមានតែថ្នាំគ្រាប់ប៉ុណ្ណោះ ។ នៅទីនេះ មិនត្រឹមតែបំពេញការងារឲ្យហ្មត់ចត់ប៉ុណ្ណោះទេ ថែមទាំងត្រូវគោរពវិន័យឲ្យបានល្អផងព្រោះពេទ្យស្រីទាំងអស់មិនត្រូវអនុញ្ញាតឲ្យស្រឡាញ់គ្នាជាមួយអ្នកជំងឺឡើយបើមិនអីចឹងទេនឹងត្រូវយកទៅកសាងឬក៏បណ្តេញចេញតែម្តង ។ ចំណែកការហូបចុកវិញ ប្រធានពេទ្យក៏មិនអនុញ្ញាតឲ្យហូបលាយឡំជាមួយអ្នកជំងឺដែរ ។

នៅទីនេះ ខាន់ ធ្លាប់បានជួបមេដឹកនាំខ្មែរក្រហមចំនួនពីរនាក់ គឺ អៀង ធីរិទ្ធ និង ហូ (កូនរបស់ តាម៉ុក) ។ ខាន់ បន្តថា ហូ មិនសូវទៅប្រជុំនៅមន្ទីរពេទ្យនេះទេ ប៉ុន្តែ អៀង ធីរិទ្ធ បានមកប្រជុំជាញឹកញាប់ និងតែងតែលើកឡើងថា «ត្រូវខិតខំធ្វើការងារនិងមើលថែទាំអ្នកជំងឺឲ្យបានល្អ បើអ្នកណាខ្ជិលនឹងត្រូវយកទៅកសាងដោយចងភ្ជាប់នឹងសរសរ ហើយមិនឲ្យហូបបាយទៀត» ។ ក្រោយពីស្តាប់ពាក្យទាំងអស់នេះ ម្នាក់ៗភ័យខ្លាចគ្រប់គ្នា ហើយនាំគ្នាខិតខំប្រឹងប្រែងធ្វើការមិនដែលប្រឆាំងនឹងបទបញ្ជាឡើយ ។

ដោយសារបែកពីក្រុមគ្រួសារអស់រយៈពេលជាច្រើនខែឆ្នាំ ខាន់ បានសុំច្បាប់ប្រធានពេទ្យមកលេងឪពុកម្តាយនៅស្រុកកំណើតម្តង ។ ប៉ុន្តែ ប្រធានពេទ្យមិនត្រឹមតែមិនអនុញ្ញាតឲ្យទៅប៉ុណ្ណោះទេ ថែមទាំងស្តីបន្ទោសថា «ការងារកំពុងមមាញឹក ចង់ទៅលេងឪពុកម្តាយធ្វើអ្វី ។ ចាំស្បៀយអ្នកជំងឺសិន ចាំទៅលេង» ។ ដូច្នេះ ខាន់ មិនហ៊ានជំទាស់នឹងការហាមឃាត់នេះឡើយ ព្រោះខ្លាចប្រធានពេទ្យហៅគាត់ទៅកសាង ។ ប៉ុន្តែនៅឆ្នាំ១៩៧៩ ពេលដែល ខាន់ ត្រឡប់មកស្រុកកំណើតវិញ និងបានឃើញគំនរឆ្អឹងនិងលលាដ៏ក្បាលមនុស្សជាច្រើននៅក្នុងមន្ទីរក្រាំងតាចាន់នោះ ទើប ខាន់ ជឿថារបបនេះពិតជាសម្លាប់មនុស្សយ៉ាងសាហាវព្រៃផ្សៃមែន ។ ដូច្នេះ ខាន់ យល់ថាដើម្បីរកយុត្តិធម៌ជូនជនរងគ្រោះដែលបានស្លាប់នៅក្នុងរបបនោះនិងជនរងគ្រោះដែលនៅរស់ជីវិតត្រូវតែនាំយកមេដឹកនាំខ្មែរក្រហមទាំងនេះមកកាត់ទោសទៅតាមច្បាប់ ។

សព្វថ្ងៃនេះ ទោះបីជា ខាន់ ចេះជំនាញពេទ្យកាលពីសម័យខ្មែរក្រហមក៏ដោយ ក៏គាត់មិនដែលហ៊ានយកវិជ្ជាពេទ្យដែលគាត់បានរៀននៅពេលនោះមកព្យាបាលអ្នកភូមិដែរ ព្រោះគាត់មិនបានចូលរៀននៅសាលានិងមិនបានអនុវត្តជាង៣០ឆ្នាំមកហើយ ។

ហេតុដូច្នេះ ខាន់ គ្រាន់តែប្រកបមុខរបរធ្វើស្រែចម្ការដើម្បីចិញ្ចឹមជីវិតតែប៉ុណ្ណោះ ។ **ចាន ផល្លា**


ជំនួបជាមួយគណៈប្រតិភូបរទេស


អៀង ធីរិទ្ធ ឆ្នាំ២០០៩

# ស្លាប់ដោយសារជំងឺ និងខ្វះអាហារ

រស់ ចាន់ថន កើតនៅសង្កាត់ទួលគោក ក្រុងភ្នំពេញ។ ចាន់ថន មានឪពុកឈ្មោះ ឯក សាត បានស្លាប់ដោយសារអត់អាហារនិងជំងឺ ចំណែកម្តាយឈ្មោះ មាឃ នាង បានស្លាប់ក្រោយពេលរបបខ្មែរក្រហមដួលរលំ។

ចាន់ថន បានរស់នៅជាមួយបងប្អូនចំនួនប្រាំពីរនាក់ ប៉ុន្តែគាត់ខិតខំរៀនរហូតក្លាយទៅជាគ្រូបង្រៀនប្រវត្តិវិទ្យាមួយរូប។

ចាន់ថន នៅចាំបានថា នៅវេលាម៉ោង៧ព្រឹក ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ទាហានខ្មែរក្រហមស្លៀកពាក់ខោអាវពណ៌អាចម៍សេះមួយក្រុមបានជិះឡានហ្ស៊ីបពណ៌ខ្មៅមួយគ្រឿងនិងមីក្រូស្រែកប្រកាសប្រាប់ប្រជាជនតាមផ្ទះក្នុងទីក្រុងភ្នំពេញថា «ពុកម៉ែ បងប្អូន ទាំងអស់ត្រូវនាំគ្នាចេញពីក្រុងភ្នំពេញសិន ព្រោះទាហានអាមេរិកនឹងមកទម្លាក់គ្រាប់បែកឥឡូវហើយ»។ ពុដូច្នេះ គ្រួសារ ចាន់ថន បានប្រញាប់ប្រញាល់រៀបចំខោអាវនិងរបស់របរប្រើប្រាស់បន្តិចបន្តួច រួចក៏នាំគ្នាធ្វើដំណើរតាមផ្លូវសហព័ន្ធរុស្ស៊ី។ មកដល់ខាងមុខសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ចាន់ថន ឃើញក្រុមនិស្សិតជាច្រើននាំគ្នារត់ចេញពីក្នុងបន្ទប់រៀនដោយទឹកមុខសប្បាយរីករាយមកឈរ ហើយស្រែកអបអរសាទរជ័យជម្នះរបស់កងទ័ពខ្មែរក្រហមដែលចូលមកដល់ទីក្រុងភ្នំពេញ។ ចាន់ថន នឹកក្នុងចិត្តថាប្រហែលជាក្រុមនិស្សិតទាំងនោះមិនដឹងថាខ្មែរក្រហមកំពុងដេញប្រជាជនចេញពីផ្ទះទេ ហើយគាត់ក៏បន្តដំណើរទៅមុខរហូតដល់ពោធិ៍ចិនតុង។ នៅទីនោះ ចាន់ថន ឃើញប្រជាជនរាប់រយគ្រួសារកំពុងធ្វើដំណើរកកកុញលើផ្លូវនិងឃើញកងទ័ពខ្មែរក្រហមជាច្រើននាក់ដើរស្រែកប្រកាសប្រាប់ប្រជាជនទាំងនោះថា «ទៅមុខៗ!មិនចាំបាច់យករបស់របរទៅតាមខ្លួនច្រើនទេ ព្រោះចាកចេញតែបីថ្ងៃនឹងត្រឡប់មកវិញហើយ»។



រស់ ចាន់ថន

ដោយសារតែមនុស្សច្រើនកកកុញនិងមិនអាចប្រជ្រៀតទៅមុខទៀត ទើបក្រុមគ្រួសារ ចាន់ថន នាំគ្នាទៅឈប់សម្រាកនៅជិតផ្លូវរទេះភ្លើងមួយយប់។ ព្រឹកឡើងទើប ចាន់ថន បន្តដំណើរទៅមុខទៀត ហើយគាត់ឃើញសាកសពជាច្រើននៅតាមបណ្តោយផ្លូវ។

រយៈពេលប្រហែលពីរថ្ងៃក្រោយមក ក្រុមគ្រួសាររបស់ ចាន់ថន ធ្វើដំណើរមកដល់វត្តទឹកថ្លា ជាមួយនឹងប្រជាជនជម្លៀសជាច្រើនគ្រួសារទៀត។ នៅទីនោះដោយសារ ចាន់ថន ឃ្លានខ្លាំងពេក គាត់ក៏ប្រាប់ម្តាយដើម្បីរកបាយហូប ប៉ុន្តែម្តាយរបស់គាត់និយាយលួងលោមគាត់ថា «នៅទីនេះមានមនុស្សច្រើនណាស់ យើងមិនអាចឈប់ដាំបាយហូបបានទេ កូនទ្រាំបន្តិចទៅ យើងនឹងទៅដល់ផ្ទះហើយ»។

មួយរយៈក្រោយមក គ្រួសាររបស់ ចាន់ថន បានមកដល់ភូមិកំណើតឪពុករបស់គាត់នៅស្រុកសំរោង។ នៅក្នុងភូមិ បងប្អូន ចាន់ថន ដែលជាប្រជាជនមូលដ្ឋានបានណែនាំឪពុកម្តាយរបស់ ចាន់ថន កុំឲ្យនិយាយពីប្រវត្តិរបស់ខ្លួនដើម្បីកុំឲ្យអង្គការសង្ស័យនិងតាមដាន។ មិនយូរប៉ុន្មាន ប្រធានភូមិឈ្មោះ អ៊ុយ

ក៏បញ្ជូនក្រុមគ្រួសាររបស់ ចាន់ថន ឲ្យនៅរស់នៅខាងភ្នំជីសូរដោយគាត់បានផ្ដាំផ្ញើម្ចាស់ផ្ទះឲ្យជួយដោះស្រាយរបបអាហារឲ្យក្រុមគ្រួសារ ចាន់ថន ផង ។ ប៉ុន្ដែក្រោយមក អង្គការបានផ្លាស់គ្រួសាររបស់ ចាន់ថន ឲ្យមករស់នៅភូមិក្រួសវិញ ។

នៅឆ្នាំ១៩៧៦ អង្គការបានចាត់តាំងឪពុករបស់ ចាន់ថន ទៅកាប់ដីធ្វើចម្ការ និងរែកទឹក ស្រោចបន្លែឲ្យបាន៤០អម្រែកក្នុងមួយថ្ងៃ ។ ទោះបីជាការងារលំបាកយ៉ាងណាក៏ដោយ ក៏ឪពុករបស់ ចាន់ថន ខំប្រឹងធ្វើដោយមិនហ៊ានតវ៉ាឡើយ ព្រោះខ្លាចអង្គការដាក់ទណ្ឌកម្ម ឬចោទប្រកាន់ ។ ថ្ងៃមួយ ដោយសារឪពុក ចាន់ថន ឃ្លានខ្លាំងពេកគាត់បានទៅលួចបេះក្ដួរស្រូវយកមកបុករួច ហើយលីងហូបដោយមិនឲ្យអង្គការដឹងឡើយ ។ ប៉ុន្ដែបន្ទាប់ពីហូបរួចបានមួយរយៈ ឪពុក ចាន់ថន ចាប់ផ្ដើមមានជំងឺដុះសាច់ក្នុងពោះវៀនធ្ងន់ធ្ងរ ។ ឃើញដូច្នេះប្រធានសហករណ៍ ក៏អនុញ្ញាតឲ្យឪពុក ចាន់ថន មកសម្រាកព្យាបាលនៅពេទ្យត្រពាំងអម្ពិល ។ ក្រោយមក ទើបម្ដាយរបស់ ចាន់ថន បានទទួលដំណឹងនេះនិងសូមអនុញ្ញាតពីប្រធានកងនាំកូនទៅមន្ទីរពេទ្យត្រពាំងអម្ពិលដែរ ។

នៅទីនោះ ឪពុករបស់ ចាន់ថន បាននិយាយទៅម្ដាយគាត់ថា «យកខ្ញុំចេញពីពេទ្យទៅ! ខ្ញុំមិនចង់រស់នៅទីនេះទេ ព្រោះពេទ្យចាក់ថ្នាំឲ្យខ្ញុំរហូតកើតជំងឺសម្រាកខ្ញុំមិនអាចទ្រាំបានទេ» ។ បន្ទាប់ពីឮពាក្យអង្វរនេះ ម្ដាយរបស់ ចាន់ថន បានទៅសុំប្រធានពេទ្យដើម្បីយកប្ដីត្រឡប់ទៅផ្ទះដែលមានចម្ងាយផ្លូវប្រមាណតែបីគីឡូម៉ែត្រប៉ុណ្ណោះ ។ ប៉ុន្ដែដើរមិនទាន់បានប៉ុន្មានផង ឪពុករបស់ ចាន់ថន បានឈប់ពាក់កណ្ដាលផ្លូវ រួចនិយាយប្រាប់ទៅកូនទាំងអស់ថា «ឪពុកមិនអាចបន្ដដំណើរទៅមុខបានទេព្រោះគ្មានកម្លាំង» ។ ឮដូច្នេះម្ដាយ ចាន់ថន ត្រូវតែឈប់សម្រាកនៅតាមផ្លូវមួយរយៈហើយក៏បន្ដដំណើរទៅទៀតរហូតដល់យប់ងងឹតទើបដើរមកដល់ផ្ទះ ។

រៀងរាល់ថ្ងៃ ក្រោយពេលម្ដាយរបស់ ចាន់ថន ត្រឡប់មកពីធ្វើការងារវិញ គាត់តែងតែឮប្ដីទាររកបាយហូប ។ ឮដូច្នេះម្ដាយ ចាន់ថន បានយកខ្សែដៃដែលលាក់ទុកជាប់នឹងខ្លួនជាយូរមកហើយទៅដូរអង្ករមួយកំប៉ុងពីប្រជាជនមូលដ្ឋានមកដាំឲ្យគាត់ហូប ។ ប៉ុន្ដែដោយសារឪពុក របស់ ចាន់ថន មិនបានបរិភោគអាហារយូរថ្ងៃមកហើយ ទើបបណ្ដាលគាត់ស្លាប់ទៅ ។ បន្ទាប់ពីឪពុក ចាន់ថន ស្លាប់បានមួយថ្ងៃ ប្អូនប្រុសពីរនាក់របស់ ចាន់ថន ចាប់ផ្ដើមឈឺហើមពេញខ្លួនទាំងអស់ បណ្ដាលឲ្យប្អូនពៅរបស់គាត់ស្លាប់ដែរ ។ ក្រោយពីទទួលបានដំណឹងនេះ អ៊ំប្រុសរបស់ ចាន់ថន បានមកលេងម្ដាយ ចាន់ថន និងលួចមាន់មកឲ្យម្ដាយគាត់ផង ។ ប៉ុន្ដែម្ដាយ ចាន់ថន រង់ចាំរហូតដល់យប់ជ្រៅពេលកងឈ្លបដេកលក់ទើបគាត់ហ៊ានលួចស្ងោរមាន់និងដាស់កូនឲ្យហូប ។

អង្គការបានចាត់តាំងម្ដាយ ចាន់ថន ឲ្យទៅធ្វើកន្ទេលជាមួយយាយចាស់នៅក្នុងភូមិ ចំណែក ចាន់ថន នៅក្មេង អង្គការអនុញ្ញាតឲ្យគាត់នៅផ្ទះជាមួយបងប្អូនប្រុសគាត់ ។ នៅទីនោះ ចាន់ថន ឃើញមានប្រជាជនថ្មីចូលមករស់នៅជាច្រើនគ្រួសារ ប៉ុន្ដែអង្គការបានហាមឃាត់មិនឲ្យប្រជាជនទាំងនោះនិយាយគ្នា ឬជជែកគ្នាឡើយ ហើយរៀងរាល់យប់តែងតែមានកងឈ្លបលួចចាំស្ដាប់នៅក្រោមផ្ទះជានិច្ច ។ ក្រោយមក អង្គការចាត់តាំងឲ្យ ចាន់ថន ទៅនៅកងកុមារ និងបង្ខំឲ្យរែកដី កាប់ព្រៃ ក្រោមការគ្រប់គ្រងរបស់ប្រធានកងឈ្មោះ ចេង ។ ថ្ងៃមួយ កុមារឈ្មោះ ប្រុស បានទៅលួចអង្ករពីរោងបាយ ប៉ុន្ដែក្រោយមកអង្គការបានដឹងរឿងនេះ ហើយក៏ចាប់ ប្រុស យកមកដាក់ទណ្ឌកម្មដោយកប់ដីត្រឹមក រួចហៅកុមារក្នុងកងទាំងអស់មកមើល ។ ប៉ុន្ដែ ដោយសារតែ ប្រុស នៅតែនៅលួចរបស់របររបស់អង្គការ ទើបកងឈ្លបយកទៅបាញ់សម្លាប់ចោល ។

នៅចុងឆ្នាំ១៩៧៨ អង្គការបានផ្លាស់ ចាន់ថន ឲ្យទៅដកស្ទូង និងលើកទំនប់នៅកោះរោង ក្នុងស្រុកបុរីជលសារ ។ នៅពេលធ្វើការងាររួច ចាន់ថន និងកុមារទាំងអស់ក្នុងកងបានដេកនៅក្នុងរោងប្រក់តង់លើទំនប់តែម្ដង ។ នៅពេលយប់មួយ ចាន់ថន ឮសូរសំឡេងយន្ដហោះទម្លាក់គ្រាប់បែក និងឃើញភ្លើងភ្លឺចិញ្ចាចនៅខេត្តតាកែវ ។ ព្រឹកឡើង ចាន់ថន ឃើញកងទ័ពខ្មែរក្រហមជាច្រើននាក់រត់ត្រឡប់មកពីព្រំដែនវៀតណាម រួចនិយាយប្រាប់កម្មាភិបាលនៅក្នុងភូមិថា «យើងចាញ់ទាហានវៀតណាមហើយឲ្យក្មេងៗទៅរកឪពុកម្ដាយរបស់គេវិញទៅ» ។ បន្ទាប់ពីឮដំណឹងនេះប្រធានកងបានរៀបចំខោអាវដាក់ក្នុងសាក់កាដូរួចរត់ចេញពីកងបាត់ ។ ចំណែក ចាន់ថន និងកុមារផ្សេងទៀតបាននាំគ្នាត្រឡប់ទៅជួបឪពុកម្ដាយរៀងៗខ្លួន ។ មកដល់ផ្ទះ ចាន់ថន មិនដឹងថា

ម្ដាយនៅទីណាទេ ព្រោះគាត់បានចាកចេញពីភូមិយូរហើយ ។ រយៈពេលមួយខែក្រោយមក ចាន់ថន បានដើរទៅដល់ភូមិក្រាំងធ្នង់ ដើម្បីសាកសួរពីដំណឹងរបស់ម្ដាយគាត់ ទើបប្រជាជននៅទីនោះប្រាប់ថា អង្គការបញ្ជូនម្ដាយគាត់ទៅរស់នៅភូមិគោលហើយ ។ ចាន់ថន ដើរទៅមុខរហូតដល់យប់ក៏ឃើញកងវៀតណាមបើករថក្រោះជាច្រើនគ្រឿងចូលមកតាមច្រកភ្នំដិន ។ ពេលនោះ ចាន់ថន សួរបុរសពីរនាក់ដែលនៅយាមចាំស្រូវ រកភូមិគោល ប៉ុន្តែគ្មាននរណាស្គាល់ភូមិនោះទេ ។ ដោយសារនៅពេលនោះមានរថក្រោះខ្វាត់ខ្វែង ទើបអ្នកភូមិក្បែរនោះហៅ ចាន់ថន ឲ្យសម្រាកនៅផ្ទះគាត់មួយយប់សិន ។ ព្រឹកឡើង ចាន់ថន បានបន្តដំណើរទៅដល់ភូមិទឹកអំបិលស្រុកសំរោង ទើបបានជួបម្ដាយគាត់ ។

មួយរយៈក្រោយមក កងទាហានខ្មែរក្រហមបាក់ទ័ពបានរត់ទៅប្រមូលផ្ដុំគ្នានៅភូមិទឹកអំបិលកាន់តែច្រើន រួចប្រកាសប្រាប់ថា យុវជនទាំងអស់ត្រូវតែស្ម័គ្រចិត្តចូលបម្រើកងទ័ពដើម្បីវាយខ្មាំង ។ ព្ធដូច្នេះ ម្ដាយរបស់ ចាន់ថន បានប្រាប់ឲ្យបងប្រុស របស់ ចាន់ថន រត់ទៅពួននៅក្នុងចំបើង ចំណែកយុវជនផ្សេងទៀតជឿតាមការឃោសនានេះបានចូលធ្វើទ័ព ហើយបាត់ខ្លួនរហូតមកដល់សព្វថ្ងៃ ។

នៅពេលដែលវៀតណាមបានចូលដល់ភូមិ ប្រជាជនទាំងអស់បាននាំគ្នាត្រឡប់មកកាន់ស្រុកកំណើតរៀងៗខ្លួនវិញ ។ នៅពេលនោះ ពូ នឹម ជាឈ្លបខ្មែរក្រហម និង ធ្លាប់ធ្វើទារុណកម្មទៅលើអ្នកភូមិត្រូវប្រជាជនស្ទាក់ចាប់តាមផ្លូវ និងនាំគ្នាព្រួតវាយរហូតដល់ស្លាប់ ។

នៅឆ្នាំ១៩៨៥ ម្ដាយរបស់ ចាន់ថន បានស្លាប់ ហើយគាត់បានរស់នៅជុំគ្នាជាមួយបងប្អូនចំនួនប្រាំនាក់ ។ ទោះបី ចាន់ថន មានជីវភាពខ្វះខាតយ៉ាងណាក៏ដោយ ក៏គាត់ខិតខំរៀនរហូតប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិនៅវិទ្យាល័យខេត្តតាកែវរួចហើយប្រឡងចូលធ្វើជាគ្រូបង្រៀនប្រវត្តិវិទ្យារហូតមកដល់សព្វថ្ងៃនេះ ។

**សុិន សុធីតា**



រស់ ចាន់ថន ពេលកំពុងបង្រៀនដល់សិក្ខាកាមដែលជាគ្រូប្រវត្តិសាស្ត្រ

# យើងត្រូវចងចាំថាសាលាក្តីខ្មែរក្រហមគឺសម្រាប់ប្រជាជន

គោលដៅរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺនាំយកយុត្តិធម៌ទៅឲ្យជនរងគ្រោះនៃរបបខ្មែរក្រហម ។ អាស្រ័យហេតុនេះ តុលាការគួរតែយកចិត្តទុកដាក់ទៅលើទស្សនៈនិងអារម្មណ៍របស់អ្នកដែលគួរតែទទួលបាន ។ តុលាការគួរតែចងចាំថា នៅក្នុងចំណោមការស៊ើបអង្កេតដំណើរការនីតិវិធីការិយាធិបតេយ្យនិងច្បាប់ ការផ្តល់យុត្តិធម៌ដល់ជនរងគ្រោះនៃរបបដ៏គួរឲ្យខ្លាចនៅសតវត្សរ៍ទី២០ គឺជាគោលដៅចម្បង ។ នៅអំឡុងពេលជំនុំជម្រះករណី០០១ ដែលមានជាប់ពាក់ព័ន្ធនឹង ឌុច ជាអតីតមេដឹកនាំមន្ទីរស-២១ នៅក្នុងភ្នែករបស់អ្នកអង្កេតការមានឃើញមានភាពអយុត្តិធម៌ ។ វាមិនមែនជាភាពអយុត្តិធម៌នៃច្បាប់ឬដំណើរការនីតិវិធីដែលប្រហែលជាត្រូវបានរំពឹងទុកថាកើតមាននៅក្នុងបន្ទប់សវនាការទេ វាគឺជាភាពអយុត្តិធម៌នៃឋានៈនិងកិត្តិយស ។ នៅក្នុងពេលបំពេញបេសកកម្មដើម្បីនាំយកយុត្តិធម៌ទៅឲ្យជនរងគ្រោះនៃរបបខ្មែរក្រហមពេលខ្លះតុលាការបានភ្លេចនូវការផ្តល់កិត្តិយសនិងការគោរពដល់ជនរងគ្រោះ ។ កញ្ចក់ដ៏ធំនៅក្នុងបន្ទប់សវនាការអាចនឹងយកមកបកស្រាយបញ្ជាក់ ។ កញ្ចក់ដ៏ខ្ពស់បានខណ្ឌចែកចៅក្រមនិងមេធាវីដែលមានសម្លៀកបំពាក់សមរម្យនិងមានប្រាក់ខែច្រើនដែលអង្គុយនៅលើវេទិកាពិភាក្សា ពីជនរងគ្រោះនៃរបបខ្មែរក្រហមដែលស្លៀកសម្លៀកបំពាក់ធម្មតា និងមានជីវភាពក្រីក្រ ។ នៅក្នុងវប្បធម៌ខ្មែរ កិត្តិយសនិងឋានៈរវាងបុគ្គលអាចត្រូវបានកំណត់ទៅតាមអ្នកដែលអង្គុយខ្ពស់ជាង ។

កញ្ចក់ដែលសន្ធឹងលើវេទិកាឈើដែលមានមន្ត្រីតុលាការជាច្រើនអង្គុយ បានបង្កើតជារបាំងមួយរវាងមន្ត្រីនិងប្រជាជនកម្ពុជារាប់ពាន់នាក់ដែលបានចូលរួមនៅក្នុងសវនាការជំនុំជម្រះលើករណីឌុច ពីខែមីនារហូតដល់ខែវិច្ឆិកាឆ្នាំ២០០៩ ។ មានអ្នកខ្លះយល់ឃើញថាការដាក់កញ្ចក់នេះគឺដើម្បីរក្សាសុវត្ថិភាពនិងសណ្តាប់ធ្នាប់ ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏មានការយល់ឃើញថាជនរងគ្រោះអាចបង្កើតអំពើហិង្សានិងអាចរំខានដល់ដំណើរនីតិវិធី ។ ប្រជាជនដែលទទួលបទពិសោធន៍ដ៏អាក្រក់គឺជាជនរងគ្រោះគួរតែទទួលបានការការពារនិងការគោរពមិនមែនមន្ត្រីតុលាការទេ ។

ឧទាហរណ៍ផ្សេងទៀតដែលប៉ះពាល់ដល់ជនរងគ្រោះគឺការដឹកប្រជាជនដែលដឹកនាំដោយការិយាល័យកិច្ចការសាធារណៈពីខេត្តឆ្ងាយៗពីម៉ោងបីព្រឹកដែលត្រូវចំណាយពេលពាក់កណ្តាលនៃកម្មវិធីនិងការដាក់កំហិតទៅលើការស្លៀកពាក់និងរបៀបអង្គុយនៅក្នុងបន្ទប់សវនាការ ។ ការដឹកប្រជាជននៅពាក់កណ្តាលយប់អាចប៉ះពាល់ដល់សុខភាពផ្លូវកាយនិងផ្លូវចិត្តរបស់ជនរងគ្រោះ ។ ជាងនេះទៅទៀត ការគេងមិនគ្រប់គ្រាន់និងជំងឺដែលបណ្តាលមកពីការធ្វើដំណើរកាន់តែធ្វើឲ្យប្រជាជនមានការលំបាកក្នុងការតាមដានដំណើរនីតិវិធីដែលមានភាពស្មុគស្មាញស្រាប់ ។ នៅក្នុងប្រទេសកម្ពុជាដែលមានប្រជាជនស្ទើរតែមួយភាគបីរស់នៅក្រោមបន្ទាត់ភាពក្រីក្រហើយស្ទើរតែ៧០ភាគរយនៃប្រជាជនរកបានតិចជាងពីរដុល្លារក្នុងមួយថ្ងៃ សម្លៀកបំពាក់ដែលល្អបំផុតរបស់អ្នកភូមិគឺប្រហែលជាអាវយឺតនេះហើយ ។ ខណៈពេលដែលរបៀបរបបនៃការស្លៀកពាក់បានដាក់កំហិតដល់ការតុបតែងខ្លួនគឺជារឿងដែលអាចទទួលយកបាន ប៉ុន្តែការដាក់កំហិតដល់មិនឲ្យពាក់អាវយឺតហាក់បីដូចជាតឹងរ៉ឹងជ្រុល ។ លើសពីនេះទៅទៀត បន្ទាប់ពីប្រជាជនឆ្លងកាត់កន្លែងត្រួតពិនិត្យដើម្បីឆ្ពោះទៅកាន់បន្ទប់សវនាការជួនកាលអ្នកទាំងនោះត្រូវបានស្តីបន្ទោសដោយការអង្គុយមិនសមរម្យទៀតផង ។

របាំងនិងការអនុវត្តរបស់តុលាការបានធ្វើឲ្យប្រជាជនមានភាពភ័យខ្លាចព្រមទាំងបង្ហាញពីភាពខុសគ្នារវាងចំណេះដឹង ការយល់ដឹង និងសិទ្ធិរបស់មន្ត្រីដែលអង្គុយយ៉ាងស្រួលនៅក្នុងរបាំងកញ្ចក់និងប្រជាជនដែលមើលពីខាងក្រៅទៅ ។ ដោយសារតែពាក្យបច្ចេកទេសមានលក្ខណៈច្បាប់ហើយការនិយាយត្រូវតែសមរម្យ តុលាការបានអនុវត្តការងាររបស់ខ្លួនដោយប្រើប្រាស់ភាសាច្បាប់ព្រហ្មទណ្ឌដែលមានតែអ្នកដែលមានចំណេះដឹងខ្ពស់ទើបអាចយល់ទាំងស្រុង ។ នៅពេលខ្លះ ប្រជាជនជាច្រើនដែលមិនមានកម្រិតសិក្សាដល់ថ្នាក់វិទ្យាល័យមានការលំបាកក្នុងការស្វែងយល់ពីការសន្ទនារវាងព្រះរាជអាជ្ញាមេធាវីការពារក្តីនិងចៅក្រមស៊ើបអង្កេត ។

សាលក្រម កាំង ហ្កេកអ៊ាវ ហៅ ឌុច នឹងចេញនៅថ្ងៃទី២៦ ខែកក្កដា ។ វាគឺជាការចេញសាលក្រមដំបូងដែលធ្វើឡើងដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានិងជាសាលក្រមដែលមានការទទួលស្គាល់ទាក់ទងនឹងឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ អ្នកនៅរស់នៃរបបខ្មែរក្រហមបានរង់ចាំពេលវេលានេះអស់រយៈពេលជាងបីទសវត្សរ៍មកហើយ ។ ដោយសុខភាពចុះទ្រុឌទ្រោម និងអាយុចំណាស់របស់ជនត្រូវចោទព្រមទាំងថវិកាដ៏មានកម្រិតនិងបញ្ហាដែលកើតមាននៅតុលាការវាគឺជាពេលវេលាមួយដែលអ្នកនៅរស់អាចមើលឃើញមេដឹកនាំនៃរបបខ្មែរក្រហមត្រូវបានកាត់ទោស ។ ករណី០០២ដែលមានជាប់ពាក់ព័ន្ធនឹងមេដឹកនាំខ្ពស់បំផុតដែលនៅរស់ទាំងបួននាក់ត្រូវបានរំពឹងថានឹងមិនអាចចាប់ផ្តើមបានទេរហូតដល់ដើមឆ្នាំ២០១២ហើយការចេញសាលក្រមទៅលើករណីនោះនឹងមិនអាចចេញមុនឆ្នាំ២០១៣បានទេ ។ វាគឺជាពេលវេលាមួយដែលមិនធ្លាប់មានពីមុនដែលតុលាការអាចធ្វើការជាមួយ និងភ្ជាប់ទំនាក់ទំនងជាមួយប្រជាជនដែលតុលាការបង្កើតឡើយ ។ អាស្រ័យហេតុនេះ តុលាការគួរតែរៀបចំនិងយកចិត្តទុកដាក់ជាពិសេសទៅលើជនរងគ្រោះចូលរួមក្នុងការចេញសាលក្រម ។ ការយកចិត្តទុកបែបនេះនឹងបង្ហាញពីការគោរពនិងការផ្តល់កិត្តិយសរបស់តុលាការទៅឲ្យជនរងគ្រោះ ។ ការធ្វើបែបនេះមិនត្រឹមតែអាចផ្តល់ការចងចាំដ៏ល្អដល់អ្នកនៅរស់និងប្រជាជនកម្ពុជាទាំងអស់ប៉ុណ្ណោះទេ វាថែមទាំងអាចបង្ហាញដល់សហគមន៍អន្តរជាតិដែលនឹងស្តាប់សាលក្រមដោយមិនមានចម្ងល់ថាតុលាការបានយកចិត្តទុកដាក់ទៅលើអ្នកនៅរស់និងកិត្តិយសរបស់អ្នកទាំងនោះផង ។ ដើម្បីផ្តល់កិត្តិយសនិងការគោរពដល់ជនរងគ្រោះដែលធ្លាប់ទទួលការឈឺចាប់ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអាចធ្វើការរៀបចំតិចតួចដែលមានន័យ ។ តុលាការអាចក្រាលព្រំក្រហមនៅតាមច្រកចូលទៅបន្ទប់សវនាការដែលមានកៅអីចំនួន៥០០ ។ នៅប្រទេសកម្ពុជា ព្រំក្រហមតំណាងឲ្យការគោរពនិងការផ្តល់កិត្តិយស ។ តុលាការក៏អាចរៀបចំកន្លែងអង្គុយជាសាធារណៈនិងច្រកចូលដោយដាក់កម្រងផ្កានិងបូ ។ តុលាការក៏អាចបង្កើតបដាពិសេសដែលផ្តោតទៅលើការលើកទឹកចិត្តដល់ជនរងគ្រោះដើម្បីជាការរំឭកដល់ប្រវត្តិសាស្ត្រ ។ ការធ្វើនិងការរៀបចំបែបនេះគ្រាន់តែត្រូវចំណាយថវិកាតិចតួចពីថវិកាសរុបប៉ុណ្ណោះប៉ុន្តែវាអាចបន្សល់ទុកនូវឥទ្ធិពលមួយដល់អ្នកនៅរស់ ។

ជាចុងក្រោយ តុលាការនឹងត្រូវគេចងចាំមិនត្រឹមតែចំពោះមធ្យោបាយដែលតុលាការដោះស្រាយសំណុំរឿងឧក្រិដ្ឋកម្មច្បាប់និងដំណើរការនីតិវិធីប៉ុណ្ណោះទេ ថែមទាំងត្រូវបានគេចងចាំនូវរបៀបដែលតុលាការធ្វើទៅលើជនរងគ្រោះនៃរបបខ្មែរក្រហមទាំងអស់ទៀតផង ។ សរុបមក តុលាការត្រូវបានបង្កើតឡើងដើម្បីជនរងគ្រោះ ។

**កែវ ជាស៊ីល និងក្រុមគម្រោងឯកសាររស់**



ប្រជាជនមកពីខេត្តស្វាយរៀង និងកណ្តាលជួបជុំគ្នាមុននឹងចូលក្នុងបន្ទប់សវនាការ

# គម្រោងចូលរួមរបស់ជនរងគ្រោះ : ការចែកលិខិតឆ្លើយតប របស់តុលាការជូនដល់អ្នករស់រានមានជីវិតនៅខេត្តពោធិ៍សាត់

កាលពីថ្ងៃទី៨ដល់ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១០គម្រោងការចូលរួមរបស់ជនរងគ្រោះនៃមជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើដំណើរទៅកាន់ខេត្តពោធិ៍សាត់ដើម្បីធ្វើការចែកលិខិតឆ្លើយតបរបស់តុលាការជូនដល់អ្នកដែលបានដាក់ពាក្យប្តឹងជាបណ្តឹងធម្មតា ។ កាលពីពីរឆ្នាំមុន អ្នកទាំងអស់នោះបានដាក់ពាក្យបណ្តឹងធម្មតាទៅកាន់ការិយាល័យសហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

កាលពីខែឧសភា ឆ្នាំ២០០៨ សមាជិកក្រុមនៅក្នុងគម្រោងការចូលរួមរបស់ជនរងគ្រោះបានធ្វើដំណើរទៅកាន់ខេត្តពោធិ៍សាត់ ហើយបានជួយអ្នកដែលរស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន១៥៨នាក់ដាក់ពាក្យបណ្តឹងទៅតុលាការកាត់ទោសអតីតមេដឹកនាំខ្មែរក្រហមដែលអ្នកទាំងអស់នោះបានរៀបរាប់អំពីឧក្រិដ្ឋកម្មដែលគាត់បានជួបប្រទះឬមនុស្សជាទីស្រឡាញ់របស់គាត់បានជួបប្រទះនៅក្នុងរបបខ្មែរក្រហម ។ ក្រៅពីអ្នកទាំង១៥៨នាក់ក៏មានអ្នករស់រានមានជីវិតមួយចំនួនដែលរស់នៅក្នុងខេត្តពោធិ៍សាត់បានធ្វើដំណើរមកការិយាល័យមជ្ឈមណ្ឌលឯកសារកម្ពុជាដែលមានទីតាំងនៅរាជធានីភ្នំពេញដើម្បីឲ្យសមាជិកនៅក្នុងគម្រោងការចូលរួមរបស់ជនរងគ្រោះបំពេញព័ត៌មាននៅក្នុងទម្រង់បែបបទជនរងគ្រោះ ។ នៅខែមិថុនា ឆ្នាំ២០១០ សមាជិកក្រុមនៅក្នុងគម្រោងការចូលរួមរបស់ជនរងគ្រោះបានត្រឡប់ទៅជួបអ្នកដែលរស់រានមានជីវិតពីរបបខ្មែរក្រហមទាំងអស់នោះវិញព្រមទាំងបានជម្រាបប្រាប់គាត់ទាំងអស់គ្នាអំពីការចាត់វិធានការរបស់ការិយាល័យសហព្រះរាជអាជ្ញាចំពោះរឿងរ៉ាវឧក្រិដ្ឋកម្មដែលគាត់បានជួបប្រទះកាលពីសាមសិបឆ្នាំមុន ។ តាំងពីដំបូង អ្នកនៅរស់រានមានជីវិតជាច្រើននៅក្នុងចំណោមអ្នកទាំងនោះត្រូវបានចាត់ទុកថាជាអ្នកដែលនឹងដាក់ពាក្យបណ្តឹងដោយសារតែគាត់ទាំងអស់នោះធ្លាប់បានចូលរួមបង្កើត «ញត្តិរេណសិរ្ស» កាលពីដើមទសវត្សរ៍ឆ្នាំ៨០ ។ ញត្តិរេណសិរ្សបានបង្ហាញរៀបរាប់អំពីការខូចខាតនិងបាត់បង់ជីវិតមនុស្សជាលក្ខណៈបុគ្គលនិងសមូហភាពកាលពីរបបខ្មែរក្រហម ។ ក្នុងអំឡុងពេលប្រហែលមួយអាទិត្យ សមាជិកក្រុមនៅក្នុងគម្រោងការចូលរួមរបស់ជនរងគ្រោះបានធ្វើការចែកលិខិតឆ្លើយតបនេះជូនដល់អ្នកដែលបានដាក់ពាក្យបណ្តឹងចំនួន១៥៩នាក់នៅក្នុងស្រុកចំនួនប្រាំនៅក្នុងខេត្តពោធិ៍សាត់ ។

ស្រដៀងគ្នាទៅនឹងការធ្វើដំណើរលើកមុនៗដែរ សមាជិកក្រុមនៅក្នុងគម្រោងការចូលរួមរបស់ជនរងគ្រោះក៏បានធ្វើការសម្ភាសន៍ដោយថតជាសំឡេងនិងវីដេអូអំពីមតិឆ្លើយតបរបស់អ្នកដែលរស់រានមានជីវិតពីរបបខ្មែរក្រហម ។ ក្នុងនោះមានអ្នកដែលបានដាក់ពាក្យបណ្តឹងចំនួន ៤០ នាក់ក្នុងចំណោម១៥៩នាក់បានផ្តល់បទសម្ភាសន៍ ។ ជាការគួរឲ្យសោកស្តាយ មានអ្នកដាក់ពាក្យបណ្តឹងម្នាក់ក្នុងចំណោម១៥៩នាក់បានស្លាប់បាត់បង់ជីវិតមុនពេលដែលទទួលបានការឆ្លើយតបពី អ.វ.ត.ក បន្ទាប់ពីគាត់បាន


អ្នកដាក់ពាក្យបណ្តឹងជួបជុំគ្នាក្នុងសាលារៀន

ចូលរួមដាក់ពាក្យបណ្ដឹង ។ សម្រាប់អ្នកដែលបានស្លាប់ យុត្តិធម៌ត្រូវបានបដិសេធចោលជារៀងរហូត ។ មនុស្សភាគច្រើនដែលជាសមាជិកក្រុមនៅក្នុងគម្រោងការចូលរួមរបស់ជនរងគ្រោះដែលបានសម្ភាសបានយល់ឃើញថាដំណើរការតាមផ្លូវច្បាប់ហាក់ដូចជាចំណាយពេលច្រើនហើយគាត់ទាំងអស់គ្នាមានការបារម្ភថានឹងមិនអាចនៅចាំដល់ពេលដែលតុលាការបញ្ចប់ទេ ។

មិនតែប៉ុណ្ណោះក៏មានអ្នកដែលរស់រានមានជីវិតមួយចំនួនដែលពុំទាន់បានទទួលការឆ្លើយតបពី អ.វ.ត.ក ដោយសារតែអ្នកទាំងនោះបានស្នើសុំវិធានការការពារខ្លួនពីតុលាការដែលការស្នើសុំនេះកំពុងតែត្រូវបានដោះស្រាយដោយអង្គភាពគាំពារសាក្សីនៃ អ.វ.ត.ក ។ ទោះបីជាគាត់ទាំងអស់គ្នាត្រូវរង់ចាំអស់រយៈពេលពីរឆ្នាំបន្ទាប់ពីការដាក់ពាក្យបណ្ដឹងរបស់គាត់ក៏ដោយ ក៏អ្នកដែលបានដាក់ពាក្យបណ្ដឹងភាគច្រើនសម្ដែងការសប្បាយនៅពេលដែលតុលាការធ្វើការឆ្លើយតបមកគាត់ទាំងអស់គ្នាវិញ ។ ជាងនេះទៅទៀតអ្នកទាំងអស់នោះភាគច្រើនយល់ឃើញថាលិខិតឆ្លើយតបនេះបានបង្ហាញពីការទទួលស្គាល់នូវការឈឺចាប់របស់គាត់ទាំងអស់គ្នាពីសំណាក់ អ.វ.ត.ក និងជាភ័ស្តុតាងមួយបង្ហាញថា អ.វ.ត.ក កំពុងតែធ្វើការជូនជនរងគ្រោះ ។ អ្នកដែលនៅរស់រានមានជីវិតភាគច្រើនបានរៀបរាប់នៅក្នុងបទសម្ភាសន៍ថា ប្រជាជនដែលជម្លៀសមកពីភូមិភាគបូព៌ាទៅខេត្តពោធិ៍សាត់ត្រូវបានឲ្យរស់នៅក្នុងលក្ខខណ្ឌដ៏លំបាកដែលលក្ខខណ្ឌរស់នៅនោះមានសភាពពិបាកជាងប្រជាជនមូលដ្ឋាននិងប្រជាជនថ្មីដែលមកពីខេត្តពោធិ៍សាត់ទៅទៀត ។ អ្នកទាំងអស់នោះបានពន្យល់ថា អ្នកភូមិភាគបូព៌ាទាំងនោះត្រូវបានខ្មែរក្រហមសម្គាល់ដោយអ្នកទាំងនោះបង់កក្រមាពណ៌ខៀវហើយត្រូវបានខ្មែរក្រហមដាក់ឲ្យរស់នៅដាច់ដោយឡែកពីប្រជាជនមូលដ្ឋាននិងប្រជាជនថ្មីដែលបានមកដល់ខេត្តពោធិ៍សាត់ ។ បើតាមការរៀបរាប់នៅក្នុងបទសម្ភាសន៍រហូតដល់ចុងឆ្នាំ១៩៧៨ អ្នកភូមិភាគបូព៌ាទាំងអស់នេះត្រូវបានចម្រាញ់យកទៅសម្លាប់ដោយសារតែអ្នកទាំងអស់នោះត្រូវបានខ្មែរក្រហមចោទប្រកាន់ថាជាប់ពាក់ព័ន្ធជាមួយវៀតណាម ។ បើតាមអ្នកផ្ដល់បទសម្ភាសន៍មួយរូបបានប្រាប់ឲ្យដឹងថាមានបុរសម្នាក់មកពីខេត្តពោធិ៍សាត់ ហើយបានរៀបការជាមួយនារីម្នាក់ដែលត្រូវបានជម្លៀសមកពីខេត្តស្វាយរៀង ។ ប្រពន្ធរបស់គាត់ត្រូវបានខ្មែរក្រហមរំលោភហើយសម្លាប់ចោល ។ ចាប់តាំងពីពេលនោះមកបុរសម្នាក់នោះបានបដិសេធមិនត្រឡប់មកកាន់ខេត្តពោធិ៍សាត់វិញដោយសារតែការចងចាំដ៏ឈឺចាប់មួយនេះ ។ នៅថ្ងៃទី១៣ខែមិថុនា គម្រោងឯកសាររស់របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំកិច្ចពិភាក្សាក្នុងភូមិជាមួយសហគមន៍ខ្មែរក្រោមអំពីការវិវត្តន៍នៃដំណើរការតុលាការនៃ អ.វ.ត.ក ។ លោក វ៉ាន់ថាន់ ពៅដារ៉ា នាយករងមជ្ឈមណ្ឌលឯកសារកម្ពុជាគឺជាអ្នកសម្របសម្រួលនៅក្នុងកិច្ចពិភាក្សានោះដោយមានការចូលរួមផងដែរពីមន្ត្រី (អ.វ.ត.ក) ។ ដោយក្នុងនោះរួមមាន លោក អេនឌ្រូ ខាលី ដែលជាសហព្រះរាជអាជ្ញាអន្តរជាតិ, មេធាវី, ដើមបណ្ដឹងរដ្ឋប្បវេណី, អ្នកសារព័ត៌មានព្រមទាំងអ្នកដែលរស់នៅក្នុងសហគមន៍ខ្មែរក្រោម ។ អ្នកដាក់ពាក្យបណ្ដឹងដែលជាខ្មែរក្រោមដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានជួយបំពេញពាក្យបណ្ដឹងកាលពីមុន ក៏បានចូលរួមនៅក្នុងវេទិកានេះដែរ ។ ដូច្នេះគាត់ទាំងអស់គ្នាបានដឹងអំពីការវិវត្តរបស់ អ.វ.ត.ក ។ នៅក្នុងកិច្ចពិភាក្សានោះបានបង្កឱកាសដល់បងប្អូនខ្មែរក្រោមបានចែករំលែករឿងរ៉ាវរបស់គាត់និងបានបង្ហាញពីចម្ងល់របស់គាត់សួរទៅកាន់លោកសហព្រះរាជអាជ្ញាក៏ដូចជាទៅកាន់ភ្ញៀវអន្តរជាតិដទៃទៀតផងដែរ ។

**ឧបសគ្គ**

វាហាក់ដូចជាពុំមានឧបសគ្គជាក់លាក់ណាមួយបានកើតឡើងនោះទេ ដោយសារតែកាលៈទេសៈមួយចំនួន ។ ទីមួយ មជ្ឈមណ្ឌលឯកសារកម្ពុជាមានទំនាក់ទំនងល្អជាមួយបុគ្គលិករដ្ឋនៅតាមតំបន់នៅថ្នាក់ភូមិ ឃុំ ក៏ដូចជាថ្នាក់ស្រុក ។ ទីពីរ សមាជិកក្រុមនៅក្នុងគម្រោងការចូលរួមរបស់ជនរងគ្រោះធ្វើការចែកលិខិតឆ្លើយតបរបស់តុលាការនៅតាមទីកន្លែងដែលគម្រោងនេះធ្លាប់បានធ្វើការជាមួយអ្នកភូមិកាលពីប៉ុន្មានឆ្នាំកន្លងមកហើយ ដូចនេះសមាជិកក្រុមមានភាពជិតស្និទ្ធជាមួយអ្នកភូមិហើយនិងមេភូមិ ។ ទីបី មានអ្នកភូមិមួយចំនួនបានស្គាល់ទស្សនាវដ្ដី «ស្វែងរកការពិត» រួចមកហើយ ជាងនេះទៅទៀត គាត់ទាំងនោះធ្លាប់បានផ្ដល់បទសម្ភាសន៍ឲ្យដល់បុគ្គលិកមជ្ឈមណ្ឌលកឯកសារកម្ពុជាក្នុងរយៈពេលជាង១៥ឆ្នាំមកហើយ ។ ជាចុងក្រោយ សមាជិកនៅក្នុងគម្រោងក៏បានធ្វើការទំនាក់ទំនងជាបន្តបន្ទាប់ជាមួយប្រធានភូមិនិងប្រធានឃុំមុនពេល

មានកិច្ចប្រជុំនៅទីនោះដែរ ។ សមាជិកនៅក្នុងគម្រោងបានធ្វើការខិតខំប្រឹងប្រែងយ៉ាងខ្លាំងទោះបីក្នុងកាលៈទេសៈលំបាកក៏ដោយ ដើម្បីចែកលិខិតឆ្លើយតបជូនដល់អ្នកដែលបានដាក់ពាក្យបណ្ដឹង ។ នៅថ្ងៃខ្លះ បុគ្គលិកនៅក្នុងគម្រោងបានធ្វើការរហូតដល់យប់ហើយនៅថ្ងៃខ្លះទៀតត្រូវធ្វើការពីព្រលឹមនៅពេលដែលអ្នកដាក់ពាក្យបណ្ដឹងសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីពុំមានពេលទំនេរនៅពេលថ្ងៃ ដើម្បីផ្ដល់បទសម្ភាសន៍សម្រាប់បំពេញព័ត៌មានបន្ថែមនៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់គាត់ ។ មានពេលខ្លះទៀត សមាជិកនៅក្នុងក្រុមតម្រូវឲ្យចែកជាពីរក្រុមផ្សេងគ្នា ដើម្បីធ្វើការនៅទីតាំងផ្សេងគ្នាដោយសារតែភាពចាំបាច់នៃពេលវេលា ។ ជាក់ស្ដែងនៅថ្ងៃមួយ ប្រធានក្រុមបានខកខានមិនបានចូលរួមជាមួយសមាជិកក្រុមដោយគាត់ជាប់ភារកិច្ចធ្វើជាអ្នកបកប្រែភាសាដល់ភ្ញៀវអន្តរជាតិ, មន្ត្រីមកពី អ.វ.ត.ក ហើយនិងសហព្រះរាជអាជ្ញាអន្តរជាតិដែលបានចូលរួមនៅក្នុងវេទិការពិភាក្សាក្នុងភូមិនៅខេត្តពោធិ៍សាត់ជាមួយសហគមន៍ខ្មែរក្រោម ។

## រឿងរ៉ាវសង្ខេបមួយចំនួនពីខេត្តពោធិ៍សាត់

**នួន សឿន អាយុ៩១ឆ្នាំ** ៖ នៅឆ្នាំ១៩៧៤នៅពេលដែលខ្មែរក្រហមកាន់កាប់បានខេត្តពោធិ៍សាត់ សឿន ហើយនិងសមាជិកនៅក្នុងក្រុមគ្រួសារគាត់ទាំងអស់ត្រូវបានជម្លៀសចេញពីខេត្តពោធិ៍សាត់ទៅកាន់ខេត្តកំពង់ឆ្នាំង ។ គាត់និងអ្នកភូមិដទៃទៀតប្រហែលជាង៣០០នាក់ដែលក្នុងនោះរួមមានព្រះសង្ឃដែលត្រូវបានខ្មែរក្រហមផ្សឹកផងនោះត្រូវបានបញ្ជាឲ្យជីកប្រឡាយទឹកនៅក្នុងខេត្តកំពង់ឆ្នាំង ។

នៅទីនោះមានមិត្តរួមការងាររបស់គាត់ម្នាក់ត្រូវបានខ្មែរក្រហមសម្លាប់បន្ទាប់ពីគាត់បានដួលសន្លប់ដោយសារតែកង្វះអាហារនិងការអស់កម្លាំង ។ ជនដែលបានគំរាមដល់សមាជិកក្រុមដទៃទៀតឲ្យខិតខំប្រឹងប្រែងធ្វើការងារបើមិនដូច្នោះទេនឹងជួបប្រទះវាសនាដូចបុរសម្នាក់នោះអ៊ីចឹង ។

ក្រោយមកនៅក្នុងឆ្នាំ១៩៧៧ សឿន បានមើលឃើញហេតុការណ៍សម្លាប់មនុស្សជាង២០នាក់ដែលក្នុងនោះមានបីនាក់គឺជាបងប្អូនជីដូនមួយរបស់គាត់ ។ មុនពេលសម្លាប់ជនរងគ្រោះទាំងអស់នោះត្រូវបានបញ្ជាឲ្យជីករណ្ដៅសម្រាប់ខ្លួនឯង ។ ជាសំណាងល្អ បងប្អូនជីដូនមួយរបស់គាត់ពីរនាក់បានរត់គេចខ្លួនរួច ។ ប៉ុន្តែជាអកុសលបងប្អូនជីដូនមួយរបស់គាត់ម្នាក់ទៀតត្រូវបានខ្មែរក្រហមចាក់ដល់ស្លាប់ ។

រហូតមកដល់បច្ចុប្បន្ននេះ សឿន មិនដែលបានដឹងពីថាហេតុអ្វីបានជាបងប្អូនជីដូនមួយរបស់គាត់ត្រូវបានសម្លាប់នោះទេ ។ នៅចុងឆ្នាំ១៩៧៨ សឿន ត្រូវបានខ្មែរក្រហមវាយធ្វើបាបនិងបង្អត់អាហារដោយសារតែគាត់បានលួចដកមើមដំឡូងដោយគ្មានការអនុញ្ញាត ។ ពីរបីខែក្រោមមក គាត់បានធ្លាក់ខ្លួនឈឺជាទម្ងន់ហើយត្រូវបានយកទៅកប់ ទោះបីជាគាត់គ្រាន់តែសន្លប់ក៏ដោយ ។ ក្រោយមក សឿន បានដឹងខ្លួនវិញនៅតាមផ្លូវហើយគាត់បានរួចរស់ជីវិត ។ សឿន ទទួលស្គាល់ថាបច្ចុប្បន្ននេះជនសង្ស័យទាំងប្រាំរូបដែល អ.វ.ត.ក នឹងកាត់ទោសស្ថិតនៅក្នុងវ័យចាស់ជរានិងមានជំងឺទៀតផង ហើយគាត់យល់ស្របទៅនឹងការសម្រេចចិត្តរបស់ អ.វ.ត.ក ប្រសិនបើតុលាការសម្រេចធ្វើការដោះលែងគាត់ទាំងអស់គ្នា ។

**ម៉ែន បុស អាយុ៦៦ឆ្នាំ** ៖ នៅចុងឆ្នាំ១៩៧៨ បុស បានមើលឃើញការសម្លាប់មនុស្សជាងម្ភៃនាក់ដែលត្រូវបានខ្មែរក្រហមជម្លៀសមកពីខេត្តស្វាយរៀង ។ បុស ត្រូវបានបញ្ជាឲ្យចម្អិនអាហារឲ្យគាត់ទាំងអស់នោះហូប ប៉ុន្តែគាត់ទាំងអស់នោះ


អ្នកភូមិម្នាក់កំពុងផ្ដល់បទសម្ភាសន៍

ត្រូវបានខ្មែរក្រហមសម្លាប់មុនពេលទទួលបានរបបអាហារចុងក្រោយរបស់គាត់ទៅទៀត ។

បុស បានរៀបរាប់ថា ជនរងគ្រោះដ៏អភ័ព្វទាំងអស់នោះដែលក្នុងនោះមានកុមារផងដែរត្រូវបានខ្មែរក្រហមបញ្ជាឲ្យលុតជង្គង់នៅមាត់រណ្តៅដែលបានជីករួច ។ អ្នកទាំងអស់នោះត្រូវបានវាយសម្លាប់ម្តងមួយៗនឹងដំបងឫស្សី បុស មានការភ័យតក់ស្លុតជាខ្លាំងនៅពេលដែលគាត់បានស្នើសុំទៅមេកងរបស់គាត់ឲ្យចាត់ចែងការងារផ្សេងឲ្យគាត់ធ្វើវិញ ។ នៅរសៀលនាថ្ងៃដដែលគាត់បានផ្តល់អាហារទៅឲ្យបុរសម្នាក់មកពីខេត្តស្វាយរៀងដោយសារតែបុរសម្នាក់នោះបានទទូចសុំពីគាត់ ។ បុរសម្នាក់នោះបានប្រាប់ទៅ បុរស ថាគាត់គឺជាមនុស្សតែម្នាក់គត់ក្នុងចំណោមមនុស្ស២០នាក់ផ្សេងទៀតដែលត្រូវបានខ្មែរក្រហមយកទៅសម្លាប់ដោយសារតែពេលនោះគាត់បានធ្វើពុតជាស្លាប់ ។

ជាងនេះទៅទៀត បុស ក៏បានឃើញផ្ទាល់ភ្នែកអំពីការសម្លាប់ក្មួយប្រុសរបស់គាត់ពីរនាក់ដែលមានអាយុប្រហែលជាប្រាំមួយទៅប្រាំបីឆ្នាំ ។

យោធាខ្មែរក្រហមបានចាក់សម្លាប់ក្មួយប្រុសទាំងពីររបស់គាត់នឹងចំពុះទុងកាំភ្លើង ។ បុស បាននិយាយប្រាប់សមាជិកក្រុមនៅក្នុងគម្រោងការចូលរួមរបស់ជនរងគ្រោះថា បន្ទាប់ពីកងទ័ពវៀតណាមបានចូលមករំដោះបានខេត្តពោធិ៍សាត់គាត់បានបាត់បង់បងប្អូនបង្កើតទាំងអស់ចំនួន១១នាក់និងឪពុកម្តាយព្រមទាំងក្មួយប្រុសស្រីចំនួន២០នាក់ទៀត ។

បច្ចុប្បន្ន បុស រស់នៅតែម្នាក់ឯងក្នុងនាមជាកូនកំព្រា ។ បុស មានការឈឺចាប់ណាស់នៅក្នុងរបបខ្មែរក្រហមហើយគាត់កំពុងតែទន្ទឹងរង់ចាំការទទួលបានយុត្តិធម៌តាមរយៈការតាមដានអំពីដំណើរកាត់ក្តីតាមផ្លូវច្បាប់របស់ អ.វ.ត.ក ។

**ដូន ផន អាយុ៩៧ឆ្នាំ** : នៅភូមិរបស់គាត់ខ្មែរក្រហមបានកាន់កាប់តាំងពីឆ្នាំ១៩៧៥មុនពេលដែលខ្មែរក្រហមកាន់កាប់បានទីក្រុងភ្នំពេញទៅទៀត ។ នៅពេលដែលខ្មែរក្រហមបានចូលមកដល់ភ្លាមខ្មែរក្រហមបានធ្វើការជម្លៀសអ្នកភូមិចេញពីភូមិហើយបានបញ្ជាឲ្យអ្នកភូមិធ្វើការជម្រះគម្ពោតព្រៃនិងដើមឈើដើម្បីយកដីដាំដំណាំជាពិសេសនៅខ្ពង់រាប ។ នៅឆ្នាំ១៩៧៦ ខ្មែរក្រហមបានសម្លាប់បងប្អូនប្រុសរបស់ ផន ឈ្មោះ ចាន់រ៉ា និង ពេជ្រដោយសារតែអ្នកទាំងពីរបានលួចរត់មកជួបម្តាយនៅឯផ្ទះចំនួនពីរដងដោយពុំមានការអនុញ្ញាត ។ ក្រោយមកទៀត យោធាខ្មែរក្រហមឈ្មោះ គឿន បានសម្លាប់ម្តាយរបស់គាត់ដោយចោទថាម្តាយរបស់គាត់មិនព្រមបោះបង់ចោលកម្មសិទ្ធឯកជន ។

ជាងនេះទៅទៀត នៅចុងឆ្នាំ១៩៧៦ឪពុករបស់ ផន ឈ្មោះ ណាប៊ុន ក៏ត្រូវបានយោធាខ្មែរក្រហមសម្លាប់ផងដែរដោយមូលហេតុថាគាត់បានលួចមកជួបប្រពន្ធដោយគ្មានការអនុញ្ញាត ។ យោធាខ្មែរក្រហមម្នាក់ក្នុងចំណោមនោះគឺជាបងប្អូនជីដូនមួយរបស់ ផន ដែលបានសម្លាប់ឪពុកម្តាយរបស់គាត់ ។ បន្ទាប់ពីរបបខ្មែរក្រហមត្រូវបានផ្តួលរំលំ ផន បានសួរបញ្ជាក់ទៅបងប្អូនជីដូនមួយរបស់គាត់ថា តើគាត់ពិតជាបានសម្លាប់ឪពុករបស់ ផន ពិតមែនឬទេ ។ ប៉ុន្តែ ផន មិនបានទទួលចម្លើយអ្វីទាំងអស់ទាក់ទងនឹងបញ្ហានេះ ។ ផន ក៏បានប្រាប់សមាជិកក្រុមនៅក្នុងគម្រោងការចូលរួមរបស់ជនរងគ្រោះដែរថានៅក្នុងសុបិនរបស់គាត់ម្តាយគាត់បានប្រាប់គាត់មិនឲ្យធ្វើការសងសឹកទេ ។ ចំណែកឯ ផន វិញក៏ធ្លាប់បានជាប់គុកចំនួនពីរលើកផងដែរ ដែលម្តងនោះគាត់សឹងតែត្រូវបានខ្មែរក្រហមសម្លាប់ដោយសារតែការលួចដកដំឡូងយកមកហូប ។ គាត់ធ្លាប់បានសុំឲ្យបងប្អូនជីដូនមួយរបស់គាត់ម្នាក់ទៀតជួយលាក់រឿងនេះ ជាលទ្ធផលចុងក្រោយបងប្អូនជីដូនមួយរបស់គាត់នោះបានរាយការណ៍បណ្តាលឲ្យខ្មែរក្រហមឃាត់ខ្លួនគាត់ជាលើកទីពីរ ។

លើសពីនេះទៅទៀត ប្រពន្ធរបស់ ផន ក៏បានបាត់បង់ជីវិតនៅក្បែរសហករណ៍ដោយសារតែហូបអាហារមិនគ្រប់គ្រាន់ ។ ផន សព្វថ្ងៃរស់នៅក្នុងភូមិជាមួយ គឿន ដែលជាអ្នកសម្លាប់ម្តាយរបស់គាត់ ។ ផន បានបោះបង់ចោលការសងសឹកហើយតែងតែតាមដានការវិវត្តរបស់ អ.វ.ត.ក តាមរយៈកញ្ចក់ទូរទស្សន៍ជានិច្ច ។ ផន យល់ឃើញថា យុត្តិធម៌សម្រាប់គាត់មានន័យថាជនសង្ស័យទាំងអស់ដែលជាប់ឃុំឃាំងត្រូវបានរកឃើញថាមានកំហុសហើយអ្នកទាំងអស់នោះត្រូវបានតុលាការផ្តន្ទាទោស ។ គាត់ជឿជាក់យ៉ាងមុតមាំថាអ.វ.ត.ក នឹងអាចនាំមកនូវយុត្តិធម៌ជូនគាត់ក៏ដូចជាជនរងគ្រោះកម្ពុជាដ៏ទៃទៀតដែរ ។ **ឌី ធេវិទ្ធិ**

# តាមដានទិដ្ឋីឆ្ពោះរកយុត្តិធម៌

ប្រជាជនកម្ពុជាបានជាប់ទ្រឹងនៅក្នុងសុបិនអាក្រក់មួយដែលនិងមិនអាចដោះខ្លួនរួច ។ ខ្ញុំពិបាកស្រមៃឃើញថាអំពើឃោរឃៅជិនាន់ខ្មែរក្រហមមានទំហំធំប៉ុនណានោះទេ ព្រោះតែសម័យនោះមានលក្ខណៈស្មុគស្មាញពេក ។ សម័យនោះគ្មានសេចក្តីមេត្តាគ្មានការសន្តោសប្រណីនិងគ្មានច្បាប់អ្វីទាំងអស់ ។ អំពើព្រៃផ្សៃនោះធ្វើឲ្យខ្ញុំឆ្ងល់អំពីភាពល្អនៃភាពជាមនុស្ស ។ សកម្មភាពនៃអំពើប្រល័យពូជសាសន៍និងធ្វើឲ្យយើងឆ្ងល់រហូតថាតើវាកើតឡើងយ៉ាងដូចម្តេច ។ យើងសួរសំណួរនេះដើម្បីបន្ធូរកំហឹងក្រេវក្រោធក្នុងចិត្តរបស់យើងព្រោះយើងស្ទើរមិនជឿនូវអ្វីដែលបានកើតឡើង ។

គុកទួលស្លែងពោរពេញទៅដោយភាពរន្ធត់ ។ អ្វីៗទាំងអស់នៅតែមិនអាចសម្រេចបានបន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យដួលរលំ ។ ខ្ញុំនៅតែឃើញស្នាមឈាមនៅលើកម្រាលឥដ្ឋរបស់ជនស្លូតត្រង់ដែលទទួលរងនូវភាពឈឺចាប់ ។

ខ្ញុំឃើញវិធីសាស្ត្រធ្វើទារុណកម្ម ឃើញបន្ទប់តូចចង្អៀតនិងឃើញរូបភាពរបស់ជនរងគ្រោះ ។ កែវភ្នែករបស់ជនរងគ្រោះបានសម្លឹងមកយើងខ្ញុំគ្រប់ពេលវេលា ។ ខ្ញុំឃើញពីភាពទុក្ខសោកនិងភាពឈឺចាប់ពន់ពេកដែលអ្នកទាំងនោះបានជួប ។ ជនរងគ្រោះទាំងនោះដឹងថាគាត់មិនអាចធ្វើអ្វីបានទាំងអស់ ។ ខ្ញុំចាប់ផ្តើមស្អប់និងមានកំហឹងចំពោះរបបនោះ ។ ជនរងគ្រោះទាំងអស់នោះមិនគួរទទួលនូវការឈឺចាប់បែបនេះទេ ។ អ្នកទោសមិនគួរជួបរឿងបែបនេះឡើយ ។ ខ្មែរក្រហមមានភាពងងឹតងងល់ចំពោះអ្វីដែលខ្លួនមិនជឿចំពោះអ្នកផ្សេងទៀតដែលនាំអ្នកទោសទាំងនោះទៅរកភាពបាត់បង់ជារៀងរហូត ។ ខ្មែរក្រហមមិនខ្វល់ថាតើអ្នកទោសទាំងនោះជាជនស្លូតត្រង់ឬយ៉ាងណាទេ ។ នៅឯវាលពិឃាតជើងឯក ខ្ញុំបានដើរមើលជុំវិញវាលពិឃាតនៃព្រលឹងរបស់អ្នកស្លាប់ដែលកប់នៅក្នុងដី ។ អ្នកទោសភាគច្រើនត្រូវបាននាំមកទីនេះបន្ទាប់ពីទទួលបានចម្លើយអស់ហើយទីបញ្ចប់ត្រូវបានសម្លាប់នៅទីនេះ ។ ខ្ញុំមានអារម្មណ៍ស្រាលខ្លួននិងមិនអាចនិយាយអ្វីបានទាំងអស់ព្រោះតែគ្មានអ្វីសេសសល់ទៀតទេ ។ ជីវិតរបស់ប្រជាជនកម្ពុជាបានបាត់បង់ជារៀងរហូតហើយបន្សល់ទុកត្រឹមតែបំណែកសម្លៀកបំពាក់តែប៉ុណ្ណោះដែលអ្នកទាំងនោះធ្លាប់ស្លៀកពាក់កាលពីនៅរស់ ។ ខ្ញុំឃើញមានលលាដ៏ក្បាលរបស់ជនរងគ្រោះដែលជាកុមារ បុរស ស្ត្រី ចាស់ជរារាយពាសពេញយ៉ាងអាណោចអាធ័ម ។ ខ្ញុំចាប់មានអារម្មណ៍រំជួលក្នុងចិត្តក្រោយពេលដែលខ្ញុំដឹងការពិតកាន់តែច្រើនឡើង ។ ខ្ញុំចង់បានយុត្តិធម៌សម្រាប់ប្រជាជនជនខ្មែរ ។

ខ្ញុំបានទៅមើលតុលាការខ្មែរក្រហមដើម្បីមើលសាលក្រមរបស់ ឌុច ដែលទន្ទឹងរងចាំយ៉ាងយូរជាមួយនឹងប្រជាជនរាប់រយនាក់រួមមាន ដើមបណ្តឹងរដ្ឋប្បវេណី ព្រះសង្ឃ អ្នកសារព័ត៌មាននិងអ្នកផ្សេងទៀត ។ បរិយាកាសនៅក្នុងបន្ទប់សវនាការមានសភាពទុក្ខសោកនិងគ្មានក្តីសង្ឃឹមហើយហាក់បីដូចជាគ្មានវិប្បដិសារីចំពោះជនរងគ្រោះទាល់តែសោះ ។ ហើយវិប្បដិសារីនោះនៅតែមិនគ្រប់គ្រាន់ដដែលសម្រាប់ជនរងគ្រោះ ។

បន្ទាប់ពីសាលក្រមដែលមានការចម្រូងចម្រាសត្រូវបាន


ជុំ ម៉ាញ នៅក្នុងបន្ទប់តូចដែលគាត់ធ្លាប់ជាប់ឃុំនៃមន្ទីរស-២១

ប្រកាស អ្នកស្តាប់នៅក្នុងបន្ទប់សវនាការចាប់ផ្តើមមានអារម្មណ៍ជ្រួលច្របល់ដោយអារម្មណ៍ផ្សេងៗ ។

អ្នកខ្លះយំ អ្នកខ្លះខឹង អ្នកខ្លះចង់និយាយរៀបរាប់រឿងរ៉ាវរបស់ខ្លួនឲ្យគេដឹងដោយសារតែឈឺចាប់ពេកហើយអ្នកខ្លះទៀតមិនខ្វល់ពីសាលក្រមទាំងនោះទេ ។ ខ្លួនខ្ញុំផ្ទាល់មិនដឹងជាមានអារម្មណ៍បែបណាដែរ ។ ខ្ញុំគ្រាន់តែសម្លឹងមើលទៅទិដ្ឋភាពមនុស្សម្នាទាំងឡាយដែលកំពុងជន្ទំគ្នាដើម្បីស្តាប់ពីប្រតិកម្មទាក់ទងទៅនឹងសាលក្រម ។ សារៈសំខាន់របស់តុលាការបានសាបរលាបបន្តិចព្រោះដំណើរការទាំងមូលហាក់បីដូចជាទិដ្ឋភាពមួយជាជាងផ្លូវមួយទៅរកយុត្តិធម៌ ។ ខ្ញុំមានការភាន់ច្រឡំនិងអស់សង្ឃឹមយ៉ាងខ្លាំងដោយសារតែលទ្ធផលដែលមិនពេញចិត្តរបស់តុលាការ ។ តែភ្លាមនោះខ្ញុំចាប់ផ្តើមដឹងថាតុលាការខ្លួនឯងមិនសូវមានសារៈសំខាន់ដូចអ្វីដែលជានិមិត្តសញ្ញារបស់តុលាការនោះទេ ។ ពិតមែនហើយ អ្នករួចរស់រានមានជីវិតបានស្វែងរកយុត្តិធម៌នៅក្នុងតុលាការហើយអ្នកទាំងនោះភាគច្រើនមានភាពអស់សង្ឃឹមយ៉ាងខ្លាំងតែការពិតគឺថាអ្នកទាំងនោះនឹងមិនពេញចិត្តទាំងស្រុងទេចំពោះដំណើរការនេះ ។ គ្មានអ្វីអាចធ្វើឲ្យអ្នកដែលស្លាប់ហើយរស់រានមានជីវិតបានឡើយ ។ យើងទាំងអស់គ្នាស្វែងរកការព្យាបាលរបួសផ្លូវចិត្តប៉ុន្តែវិធីតែមួយគត់គឺត្រូវតែប្រឈមមុខនឹងការឈឺចាប់នោះ ។ តុលាការបានបំភ្លេចអតីតកាលហើយអនុញ្ញាតឲ្យជនរងគ្រោះប្រឈមមុខនឹងការពិត ។ តុលាការនោះបានផ្តល់ដល់ជនរងគ្រោះនូវឱកាសមួយដើម្បីប្រាប់រឿងរ៉ាវរបស់អ្នករស់មានជីវិតទាំងនោះនិងធ្វើឲ្យរឿងរ៉ាវរបស់អ្នកទាំងនោះត្រូវបានគេដឹងឮ ។ ប្រជាជនកម្ពុជាត្រូវតែចាត់ទុកតុលាការនោះថាជាមូលដ្ឋានគ្រឹះមួយសម្រាប់ថ្ងៃអនាគត ។ ការស្តារឡើងវិញនៃប្រទេសកម្ពុជាបានចាប់ផ្តើមឡើងពីគ្រឹះដំបូងនៃរបួសហើយឥឡូវកំពុងតែបង្រៀនខ្លួនឯងដើម្បីព្យាបាលរបួសនោះ ។ វាជាដំណើរការមួយដ៏វែងដែលយើងទាំងអស់គ្នាត្រូវតែរួមចំណែកដើម្បីស្តារប្រទេសឡើងវិញនូវអ្វីដែលបានទទួលរងឈឺចាប់ ។ ប្រទេសកម្ពុជាបានបាត់បង់ច្រើនរួចមកហើយ ប៉ុន្តែមិនកម្ពុជាត្រូវរងគ្រោះដោយសារបញ្ហាខ្មែរក្រហមទៀតទេ ។ របបខ្មែរក្រហមនេះបានប្រើប្រាស់អំណាចច្រើនមកហើយពីកម្ពុជាដើម្បីធ្វើសកម្មភាពម្តងទៀត ។ កម្ពុជាដឹងច្បាស់ថាក្មេងជំនាន់មុន គឺជាអនាគតនិងនាំយកយុត្តិធម៌សម្រាប់ប្រជាជនរបស់ខ្លួន ។

ទាំងអស់គ្នាជាមួយនឹងឧត្តមគតិរបស់មនុស្សជំនាន់ក្រោយនឹងជាមួយនិងភាពប៉ិនប្រសប់របស់មនុស្សជំនាន់ថ្មី យើងអាចកសាងប្រទេសកម្ពុជាឲ្យប្រសើរឡើងវិញនៅថ្ងៃស្អែក ។

ខ្ញុំមិនចង់ស្អប់ហើយក៏មិនចង់ខឹងទៀតដែរ ។ ភាពខ្មៅងងឹតចង់គ្របដណ្តប់មកលើខ្ញុំហើយធ្វើឲ្យស្ថិតក្នុងភាពអន្ធការ ។ ភាពអន្ធការចង់ឲ្យខ្ញុំផ្តាច់ខ្លួនពីពិភពខាងក្រៅហើយធ្លាក់ចូលទៅក្នុងភាពអាណិតអាសូរចំពោះខ្លួនខ្ញុំ ។ ប៉ុន្តែខ្ញុំមិនចង់ឲ្យភាពអន្ធការនោះកើតឡើងទេ ។ ខ្ញុំដឹងថាឥឡូវនេះយើងមានជម្រើសមួយចំពោះអ្វីដែលធ្វើជាមួយនិងភាពរំជួលចិត្តរបស់យើង ។ យើងត្រូវតែជឿថាចិត្តដ៏បរិសុទ្ធរបស់យើងនិងលុបលើភាពអាក្រក់ទាំងឡាយ ។ ក្នុងនាមជាមនុស្សយើងអាចមានអ្វីច្រើនទៀត ដែលអាចនឹងបន្ទាចយើង ប៉ុន្តែយើងមិនអាចបាត់បង់នូវអ្វីដែលយើងត្រូវការបានទេ ។ យើងត្រូវតែវាយប្រយុទ្ធជាមួយសត្រូវដែលឥតស្រមោលបន្តទៀតជាមួយនឹងអាវុធដ៏មានប្រសិទ្ធភាពរបស់យើងគឺការពិតនិងក្តីស្រឡាញ់ ។ ការដែលមានអារម្មណ៍ពិតប្រាកដអាចលើសពីអ្វីដែលយើងអាចទ្រាំបានហើយធ្វើឲ្យយើងចុះខ្សោយបាន ប៉ុន្តែពេលដែលយើងជ្រើសរើសវិធីធ្វើឲ្យមានការផ្លាស់ប្តូរភាពខ្សោយរបស់ យើងអាចក្លាយជាកម្លាំងដ៏មហិមា ។


ដេនីហ្វើ ឈរថតពីមុខផ្នូរ ប៉ុល ពត នៅអន្លង់វែង

**ដេនីហ្វើ កា**

# ខ្មែរក្រហមបោកប្រាស់

សើន ទូលស័ ជាអ្នករស់រានមានជីវិតជនជាតិចាមម្នាក់ ដែលបានរួចផុតជីវិតពីរបបខ្មែរក្រហម ។ ទូលស័ បានរៀននៅសាលាតែពីរខែប៉ុណ្ណោះក្នុងមួយជីវិតរបស់គាត់ ។

ក្នុងឆ្នាំ១៩៦៧ ឪពុកម្តាយបានបញ្ជូនកុមារ ទូលស័ ទៅចុះឈ្មោះចូលរៀនជាមួយក្មេងដទៃទៀតនៅក្នុងភូមិ ។ ពីរខែក្រោយមក ឪពុកម្តាយរបស់ ទូលស័ មិនមានលទ្ធភាពផ្គត់ផ្គង់ការសិក្សាបន្តទៅទៀតបានទើបបង្ខំឲ្យ ទូលស័ បញ្ឈប់ការសិក្សា ។ ទូលស័ បានរំឭកពីទស្សនៈបុរាណរបស់ឪពុកម្តាយរបស់គាត់ក្នុងការមិនបញ្ជូនកូនទៅរៀនដោយគិតថាអ្នកស្រែមិនអាចក្លាយជាអ្នកដឹកនាំបាន ។ ទូលស័ បានរៀបរាប់ថា «ឪពុកម្តាយខ្ញុំគិតថាការសិក្សាមិនសូវសំខាន់ទេ ព្រោះបើទោះបីជារៀនចេះក៏គ្មានធ្វើអ្វីក្រៅពីជួយធ្វើកិច្ចការផ្ទះដែរ» ។ ក្រោយពីឈប់រៀន ទូលស័ បានព្យាយាមរៀនសូត្រពីរៀមច្បងដែលអាចអាននិងសរសេរភាសាខ្មែរបានហើយខិតខំត្រងត្រាប់រៀនស្តាប់រហូតដល់ចេះអាននិងសរសេរបាន ។ ទូលស័ រំឭកថា កាលនោះឪពុកម្តាយរបស់គាត់ជាកម្មករចម្ការកៅស៊ូ ហើយប្រាក់កម្រៃដែលទទួលបានគឺសម្រាប់តែហូបចុកបន្តិចបន្តួចប៉ុណ្ណោះ ។ ក្រោយមកពេល ទូលស័ ចម្រើនវ័យធំបន្តិចឪពុកម្តាយក៏នាំ ទូលស័ ឲ្យទៅធ្វើការនៅចម្ការកៅស៊ូជាមួយគ្នាដើម្បីជួយផ្គត់ផ្គង់សេដ្ឋកិច្ចគ្រួសារ ។

នៅឆ្នាំ១៩៧០ នៅពេលសង្គ្រាមរវាងរដ្ឋាភិបាល លន់ នល់ និងកុម្មុយនីស្តខ្មែរក្រហមឆាបឆេះឡើង ការចៀរជ័រកៅស៊ូហាក់មានការរអាក់រអួល ។

រហូតដល់ឆ្នាំ១៩៧២ តំបន់ចម្ការកៅស៊ូទាំងមូលត្រូវបានកងទ័ពខ្មែរក្រហមនិងយៀកកុងគ្រប់គ្រងទាំងស្រុង ។ ការឃោសនាឲ្យចូលបដិវត្តន៍នៅតែបន្តទៅទៀតដោយរៀបរាប់ពីភាពសម្បូរសប្បាយក្នុងការរស់នៅ ការបំបាត់អ្នកមាននិងអ្នកក្រ ការធ្វើឲ្យស្មើភាពនិងសេរីភាពគ្រប់យ៉ាងដែលនិងអាចទទួលបានបើសិនជាកងទ័ពកុម្មុយនីស្តខ្មែរក្រហមកាន់កាប់ប្រទេស ។ ការឃោសនានេះបានទាក់ទាញកម្មករកសិករក្រីក្រយ៉ាងខ្លាំង ហើយអ្នកទាំងនោះរួមទាំងឪពុកម្តាយរបស់ ទូលស័ ផងចាប់ផ្តើមស្រឡាញ់និងគាំទ្រខ្មែរក្រហមពេញទំហឹង ។ម៉្យាងវិញទៀត កម្មករ-កសិករ រំពឹងថាសម្តេច សីហនុនឹងត្រឡប់មកគ្រប់គ្រងអំណាចវិញ បើសិនជាកងទ័ពកុម្មុយនីស្តឈ្នះរបប លន់ នល់ ។

ទូលស័ រៀបរាប់បន្តទៀតថាការរស់នៅមានសភាពធម្មតារហូតដល់ឆ្នាំ១៩៧៥ ពេលដែលខ្មែរក្រហមទទួលបានជ័យជម្នះទូទាំងប្រទេស ។ ការជម្លៀសប្រជាជនពីទីរួមខេត្តក្រុងនិងទីប្រជុំជនានាចាប់ផ្តើមឡើង ។ ប្រជាជនដែលធ្វើដំណើរពីទីកន្លែងផ្សេងៗបានមកដល់ភូមិស្ថានរបស់ ទូលស័ ក្នុងខេត្តកំពង់ធំ ។ ពេលមកដល់ស្រុកកំណើត កម្មាភិបាលខ្មែរក្រហមបានបញ្ចុះបញ្ចូលអំពីការរស់នៅយ៉ាងសុខសាន្តរបស់អ្នកមូលដ្ឋាននិងភាពឈឺចាប់ដែលអ្នកទាំងនោះបានឆ្លងកាត់ ។ កម្មាភិបាលខ្មែរក្រហមបានរៀបរាប់ប្រាប់ប្រជាជនដែលទើបតែជម្លៀសមកដល់ថ្មីអំពីការឈឺចាប់ដែលបន្តមកពីការទម្លាក់គ្រាប់បែករបស់អាមេរិកនិងការជិះជាន់កេងប្រវ័ញ្ចពីសំណាក់អ្នកមានអំណាចរបស់រដ្ឋាភិបាល លន់ នល់ ។

ទូលស័ បាននិយាយថាកម្មាភិបាលខ្មែរក្រហមនោះបានរៀបរាប់ថា «អង្គការនឹងចែកផ្ទះមួយខ្នងដែលមានបណ្តោយបួនម៉ែត្រមានទទឹងបួនម៉ែត្រសម្រាប់ប្រជាជនមួយគ្រួសារនឹងមានក្អួយមុង កន្ទេល ពាងទឹក ឆ្នាំងបាយសម្រាប់ដាំស្ល គ្រប់គ្រាន់» ។ កម្មាភិបាលខ្មែរក្រហមក៏បានរៀបរាប់ពីគោលការណ៍របស់អង្គការផងដែរដែលតម្រូវឲ្យមនុស្សគ្រប់រូបត្រូវតែស្មោះត្រង់នឹងអង្គការ «ប្រជាជនទាំងអស់ត្រូវតែបោះបង់ចោលនូវកម្មសិទ្ធិដីធ្លីហើយត្រូវតែស្តាប់តាមបទបញ្ជារបស់អង្គការ ។ អង្គការជាឪពុកម្តាយរបស់អ្នកទាំងអស់គ្នា ។ មិនត្រូវគោរពអ្នកណាក្រៅតែពីអង្គការឡើយ ។ អង្គការនឹងបំបាត់សាសនាទាំងអស់លែងឲ្យមានតទៅទៀតហើយអ្វីៗគ្រប់បែបយ៉ាងត្រូវតែគោរពតាមអង្គការ» ។ ក្រោយពីប្រជុំចប់ មេកងបានប្រាប់ប្រជាជនឲ្យទៅផ្ទះរៀងៗខ្លួន ។ តែតាមការពិតការរៀបរាប់របស់កម្មាភិបាលខ្មែរក្រហមនោះគ្រាន់តែជាពាក្យកុហកតែប៉ុណ្ណោះ ។ ប្រជាជនទាំងអស់មិនទទួលបានតាមការ

សន្យាទេ។ គ្រួសាររបស់ ទូល័ស និងប្រជាជនដទៃទៀត មិនមានផ្ទះនៅត្រឹមត្រូវ មិនមានពាងទឹក មុង ភួយ គ្រប់គ្រប់គ្រាន់ តាមការឃោសនានោះទេ។ នេះគ្រាន់តែជាការបោកប្រាស់ប្រជាជនប៉ុណ្ណោះ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក៏គ្រួសាររបស់គាត់មិនហ៊ានប្រកែកតវ៉ាជាមួយអង្គការ។ អ្នកដែលតវ៉ាត្រូវអង្គការហៅទៅរៀនសូត្រហើយបាត់ខ្លួនរហូត។ ក្រោយមក ជនជាតិចាមចំនួនម្ភៃគ្រួសារត្រូវខ្មែរក្រហមជម្លៀសមករស់នៅភូមិរបស់ ទូល័ស ដែរ។ ការហូបចុកកាន់តែមានសភាពខ្វះខាតទៅៗ ធ្វើឲ្យកូនរបស់គាត់ម្នាក់ស្លាប់ដោយសារអត់ឃ្លាន។ ក្រោយមក អង្គការក៏ជម្លៀស ទូល័ស និងក្រុមគ្រួសារឲ្យទៅរស់នៅស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាមវិញ។ ជិតមួយឆ្នាំក្រោយមក អង្គការបានបញ្ជូនជនជាតិចាមប្រហែលជា៥០គ្រួសារទៀតឲ្យមករស់នៅស្រុកត្បូងឃ្មុំដែរ។ នៅយប់មួយ ពេលប្រពន្ធរបស់គាត់ឈឺពោះឆ្លងទន្លេ ទូល័ស បញ្ជូនប្រពន្ធទៅមន្ទីរពេទ្យ។ គ្រូពេទ្យបានយកថ្នាំដែលដាក់ក្នុងដបទឹកក្រូចមកចាក់ឲ្យប្រពន្ធគាត់បណ្តាលឲ្យប្រពន្ធរបស់គាត់ឈឺស្ពឹកមួយចំហៀងខ្លួនរហូតដល់ស្លាប់ហើយ ទូល័ស ឃើញអ្នកជំងឺជាច្រើនបានស្លាប់ក្នុងមន្ទីរពេទ្យនោះ។ ទូល័ស បាននិយាយថា «ខ្ញុំអាណិតប្រពន្ធខ្ញុំណាស់ដែលស្លាប់ដោយការព្យាបាលពីគ្រូពេទ្យគ្មានជំនាញច្បាស់លាស់»។ ទូល័ស ត្រូវមានភារកិច្ចមើលថែទាំកូនតូចក្រោយពីប្រពន្ធរបស់គាត់ស្លាប់ទៅ។ កម្មាភិបាលខ្មែរក្រហមបានបញ្ជាឲ្យ ទូល័ស ធ្វើការងារកាន់តែច្រើនឡើងៗហើយតម្រូវឲ្យគាត់យកកូនដែលទើបនឹងកើតទៅទុកក្នុងកងយាយៗ។ នៅយប់មួយវេលាម៉ោង១២អាធ្រាត្រនាចុងឆ្នាំ១៩៧៨ អង្គការបានហៅ ទូល័ស ទៅប្រជុំដើម្បីបូកសរុបទិន្នផលស្រូវដែលទទួលបាន និងរៀបចំផែនការផ្ទេរដីដាំដុះស្រូវថា តើទិន្នផលស្រូវបានប៉ុន្មាន ហើយថា តើធ្វើយ៉ាងម៉េចដើម្បីឲ្យស្រូវប្រមូលបានច្រើនជាងមុន?

មួយរយៈខ្លីក្រោយមក កងទ័ពវៀតណាមក៏ចូលដល់ស្រុកត្បូងឃ្មុំ ហើយក្រុមគ្រួសាររបស់គាត់ត្រូវជម្លៀសឲ្យទៅរស់នៅស្រុកបារាយណ៍ខេត្តកំពង់ធំវិញ។ ក្រោយមក ទូល័ស បានប្តូរទៅរស់នៅខេត្តបន្ទាយមានជ័យហើយបានរៀបការជាមួយប្រពន្ធម្នាក់ទៀតដោយប្រកបមុខរបរជាអ្នកធ្វើតុទូដើម្បីផ្គត់ផ្គង់ចិញ្ចឹមគ្រួសាររបស់គាត់រហូតមកដល់សព្វថ្ងៃ។ **លី រ៉ៃម៉ាស់**



បុរសជនជាតិចាម

# ខ្មែរក្រហម :
# ការកេណ្ឌទ័ពនិងការជ្រើសរើស ការបណ្ដុះបណ្ដាលនិងការអភិវឌ្ឍ

***(តពីលេខមុន)***

*ខាងក្រោមគឺជាអត្ថបទដកស្រង់ខ្លីរបស់លោក ឆេនដ៍ល័រ ក្រោមចំណងជើងថា «គម្រោងផែនការរបស់ ប៉ុល ពត នៅពេលអនាគត : ឯកសារសម្ងាត់នៃការដឹកនាំរបស់របបកម្ពុជាប្រជាធិបតេយ្យឆ្នាំ១៩៧៦-១៩៧៧ ដែលចម្លងចេញពីផ្នែកខាងមុខនៃផែនការបួនឆ្នាំដែលព្រាងឡើងនៅឆ្នាំ១៩៧៦» ។*

***ផ្នែកទី៣***

***វិស័យវប្បធម៌ អក្សរសាស្ត្រ សិល្បៈ បច្ចេកវិទ្យា វិទ្យាសាស្ត្រ ការអប់រំប្រជាជន ឃោសនាការ និងព័ត៌មាន***

*១) វិស័យវប្បធម៌បដិវត្តន៍ អក្សរសាស្ត្រ និង សិល្បៈរបស់វណ្ណៈកម្មករ-កសិករស្របទៅតាមគោលជំហរវណ្ណៈអធនរបស់បក្ស*

*ក) បន្តការតស៊ូដើម្បីលុបបំបាត់ ជីករំលើងនិងបំបាត់កាកសំណល់វប្បធម៌ អក្សរសាស្ត្រ និងសិល្បៈរបស់ពួកមូលធនអាណានិគមនិងរាល់ដំណែលរបស់វណ្ណៈសក្តិភូមិ ។ ការនេះនឹងត្រូវអនុវត្តយ៉ាងខ្លាំងក្លា ស៊ីជម្រៅនិងជាបន្តបន្ទាប់ពីមួយចំណុចទៅមួយចំណុចចាប់ផ្ដើមពីឆ្នាំ១៩៧៧តទៅ ។*

*ខ) បន្តដើម្បីពង្រឹងនិងពង្រីកការកសាងវប្បធម៌ អក្សរសាស្ត្រ និងសិល្បៈបដិវត្តន៍របស់វណ្ណៈកម្មករ-កសិករឲ្យស្របតាមគោលជំហរអធនរបស់បក្ស ។ បង្កើតការងារឆ្ពោះទៅមុខដើម្បីពង្រឹងនិងធ្វើឲ្យរីកចម្រើនជឿនលឿន រួចពង្រីកកម្លាំងនេះដូចបានដាក់កំណត់ជាប្រចាំឆ្នាំពីឆ្នាំ១៩៧៧ ទៅ១៩៨០ ដើម្បីឆ្លើយតាមសំណូមពររបស់មហាជនជាកម្មករ-កសិករក្នុងការធ្វើឲ្យលូតលាស់ចំណេះដឹងនិងសតិអារម្មណ៍ខាងវប្បធម៌និងនយោបាយ ។ ជាពិសេសការពង្រឹង ពង្រីកបទចម្រៀង និងកំណាព្យ ដែលឆ្លុះបញ្ចាំងពីបែបបទល្អនៅក្នុងកាលៈទេសៈតស៊ូនយោបាយឬដោយកម្លាំងអាវុធនៅក្នុងសង្គ្រាមបដិវត្តន៍ ដើម្បីរំដោះជាតិនិងប្រជាជនក្នុងអំឡុងបដិវត្តន៍ប្រជាធិបតេយ្យជាតិ ព្រមទាំងបទចម្រៀងពិពណ៌នាគំរូល្អនានាក្នុងពេលបដិវត្តន៍កសាងសង្គមនិយម ។*

*២) វិស័យសិក្សាធិការ អប់រំ ឃោសនាការ និងព័ត៌មាន*

*១) ប្រព័ន្ធអប់រំ*

*◆ អប់រំបឋម--មុខវិជ្ជាទូទៅ--៣ឆ្នាំ*

*◆ អប់រំថ្នាក់មធ្យម*

*ក) មុខវិជ្ជាទូទៅ--៣ឆ្នាំ*

*ខ) មុខវិជ្ជាបច្ចេកទេស--៣ឆ្នាំ*

*◆ ការអប់រំថ្នាក់ខ្ពស់លើមុខវិជ្ជាបច្ចេកទេស--៣ឆ្នាំ*

*១.១) វិធីសាស្ត្រអប់រំប្រចាំថ្ងៃ*

*◆រៀនពាក់កណ្ដាលថ្ងៃធ្វើការពាក់កណ្ដាលថ្ងៃផលិតសម្ភារផ្សេងៗ*

*◆នៅក្នុងការអប់រំដំបូងវាមានសារសំខាន់ដើម្បីផ្ដោតការយកចិត្តទុកដាក់ឈានទៅលុបបំបាត់ភាពមិនចេះអក្សររបស់ប្រជាជន ។ ការដាក់ផែនការសម្រាប់ប្រព័ន្ធអប់រំ*

*◆ ការអប់រំថ្នាក់បឋម ពីឆ្នាំ១៩៧៧តទៅ*

*◆ ការអប់រំមធ្យមសិក្សាជាពិសេសលើផ្នែកបច្ចេកទេសត្រូវតែចាប់ផ្ដើមព្រមគ្នាឲ្យដល់កម្រិតមួយនៅឆ្នាំ១៩៧៧ ។*

*ក្នុងប្រព័ន្ធអប់រំរបស់យើងមិនមានការប្រឡងនិងសញ្ញាប័ត្រទេ ។ វាជាប្រព័ន្ធមួយសិក្សាតាមរយៈសមូហភាពនិងក្នុងចលនាដ៏រឹងមាំរបស់បដិវត្តន៍សង្គមនិងការកសាងរបបសង្គមនិយមផ្អែកលើមូលដ្ឋានដាក់លាក់ជាពិសេសនៅតាមសហករណ៍រោងចក្រនិងអង្គភាពកងទ័ព ។*

*១.២) មុខវិជ្ជាទូទៅ*

*◆ រៀនអាន និងសរសេរ*

*◆ គណិតវិទ្យា*

*◆ ភូមិវិទ្យា (ជាសំខាន់ទៅលើភូមិវិទ្យារបស់ជាតិ)*

*◆ ប្រវត្តិវិទ្យានៃការតស៊ូបដិវត្តន៍របស់ប្រជាជន ការតស៊ូបដិវត្តន៍ដើម្បីជាតិ ការតស៊ូបដិវត្តន៍ដើម្បីប្រជាធិបតេយ្យ ការតស៊ូបដិវត្តន៍ដើម្បីបដិវត្តន៍សង្គមនិងការតស៊ូដើម្បីកសាងសង្គម*

និយម ។

◆ វិទ្យាសាស្ត្រធម្មជាតិ រូបវិទ្យា គីមីវិទ្យា (ជាមូលដ្ឋាន)

◆ នយោបាយរបស់បក្ស ស្មារតី និង អត្តការ

១.៣) កសាងពង្រឹង និងពង្រីកឋានន្តរស័ក្តិរបស់កម្មាភិបាល

យើងត្រូវតែជ្រើសរើស (ប្រជាជនដែលមាន) ប្រវត្តិប្រកាន់ខ្ជាប់ចលនាបដិវត្តន៍និងមានគុណភាពអាចក្លាប់បានមាគាអប់រំរបស់បក្សនិងដែលអាចអនុវត្តន៍បានយ៉ាងខ្ជាប់ខ្ជួនព្រមទាំងពង្រឹងនិងពង្រីកជាលំដាប់នូវសមត្ថភាពរបស់ខ្លួនក្នុងចលនាសង្គមជាក់ស្តែង ។

## ២) ការណែនាំប្រជាជន ឃោសនាការ និងព័ត៌មាន

ក) ផ្សព្វផ្សាយតាមវិទ្យុៈ បង្កើតវគ្គស្តាប់វិទ្យុជាទូទៅដោយប្រើប្រាស់ឧបករណ៍បំពងសំឡេងនៅតាមកន្លែងនិងកងចល័តសំខាន់ៗទាំងអស់ ។

ខ) ភាពយន្តនៃចលនាបដិវត្តន៍ក្នុងពេលបច្ចុប្បន្ននិងអតីតកាលជាពិសេសនៅក្នុងពេលបច្ចុប្បន្ន ។ បង្កើតកងតូចៗដើម្បីថតខ្សែភាពយន្តឲ្យបានច្រើនបញ្ចាំងឲ្យប្រជាជនទស្សនាជាសាធារណៈ ។

គ) សិល្បៈម្តងមួយដំហានៗបន្តិចម្តងៗគឺគ្រប់គ្រាន់ដើម្បីកុំឲ្យរំខានកម្លាំងបង្កបង្កើនផលផលិតកម្ម ។

ឃ) កាសែត ៈ ទស្សនាវដ្តីរូបភាព ទស្សនាវដ្តីនយោបាយនិងចំណេះដឹងទូទៅ ។

**ដំណើរការ ៈ**

◆ ប្រុងប្រយ័ត្នក្នុងការកសាងពង្រឹង និងពង្រីកតួនាទីនានាដោយជ្រើសរើសប្រជាជនដែលមានប្រវត្តិស្អិតទីងបដិវត្តន៍ដែលអាចធ្វើតាមគោលនយោបាយរបស់បក្ស ដើម្បីអប់រំប្រជាជននិងផ្សព្វផ្សាយបទឃោសនានិងព័ត៌មានទាំងឡាយ ។

◆ បង្កើតអត្ថបទបោះពុម្ពជាភាសាបរទេសជាពិសេស ភាសាអង់គ្លេសដោយចាប់ផ្តើមនៅពាក់កណ្តាលឆ្នាំ១៩៧៧តទៅ ។

## ៣) បច្ចេកទេសវិទ្យាសាស្ត្រ

ក) ថ្នាលបុកកន្លែងធ្វើការដកពិសោធន៍នៅសហករណ៍និងតាមរោងចក្រសំខាន់ៗ

ខ) សាលាបច្ចេកទេសកម្រិតបឋមនិងរាយរងតាមកន្លែងពាណិជ្ជកម្មនានាដូចជា ៈ

◆ អង្ករ និងធុញ្ញជាតិដទៃ

◆ កៅស៊ូ និងដំណាំឧស្សាហកម្ម

◆ ព្រៃឈើ និងឈើហូបផ្លែ

◆ ការបង្កាត់ពូជសត្វពាហនៈ

◆ ត្រីទឹកសាប និងទឹកប្រៃ

◆ ថាមពល

◆ ចំណេះដឹងខាងវេជ្ជសាស្ត្រ ។ល ។

គ) សាលាបច្ចេកទេសចម្រុះតាមកម្រិតបឋមនិងមធ្យម ។

**ដំណើរការ ៈ** បង្កើតកម្រឹតទាំងនេះឲ្យស្របគ្នាពីឆ្នាំ១៩៧៧ទៅយោងទៅតាមផែនការនិងកម្មវិធីប្រចាំឆ្នាំ ។

ការវាយតម្លៃរបស់ មូសយ៉ាកូវ និង ឈីហ្គាស ទៅលើផ្នែកមួយនៃផែនការបួនឆ្នាំសន្និដ្ឋានថា ផែនការនេះមិនបានដាក់កំហិតឲ្យច្បាស់ថាតើវត្ថុបំណងអ្វីដែលត្រូវធ្វើឲ្យបានសម្រេចដើម្បីដាក់ប្រព័ន្ធអប់រំថ្មីនេះឲ្យគេអនុវត្តយ៉ាងពេញលេញទេ ។ ផែនការនេះមិនបានរៀបរាប់ញែកពីដំណើរការចាំបាច់នានាដែលពាក់ព័ន្ធដល់ការជ្រើសរើសគ្រូបង្រៀនទាំងនោះនិងការបណ្តុះបណ្តាលតាមកម្រិតបន្តបន្ទាប់ទៀតដើម្បីបំពាក់បំប៉នយុវជន ហើយក៏មិនបាននិយាយដល់សម្ភារនិងកម្មវិធីសិក្សាដែរ ។ ផែនការនេះអំពាវនាវឲ្យធ្វើការបែងចែកពេលវេលារបស់សិស្សដោយពាក់កណ្តាលថ្ងៃប្រើទៅលើការសិក្សអប់រំផ្ទាល់ខ្លួននិងពាក់កណ្តាលទៀតទៅលើការងារផលិតកម្មនេះបើតាមសម្តីអះអាងរបស់អ្នកនៅរស់រាន ។ មូសយ៉ាកូវ និង ឈីហ្គាស បានទាញទស្សនៈថាសាលារៀនថ្មីទាំងនេះត្រូវបង្កើតដើម្បីតែបង្រៀនប្រជាជនពីរបៀបសរសេរនិងអានឲ្យបានត្រឹមត្រូវក្នុងនាមជាកសិករប៉ុណ្ណោះ ៈ

> *សិស្សត្រូវរៀនអានតាមគ្រូនិងមិនមានការរិះគន់ ដោយមើលឃើញអ្វីថាតាមហ្នឹងហើយមិនឲ្យចោទសួរពីអត្ថន័យនិងប្រភពរបស់អត្ថបទឡើយ ។ ប្រជាជនមូលដ្ឋានជាច្រើនបានទទួលការអប់រំបែបពុទ្ធសាសនាជាប្រពៃណីនៅតាមវត្តអារាមឬនៅតាមផ្ទះបើអ្នកទាំងនោះជាស្ត្រីដែលជាទីកន្លែងបង្រៀនឲ្យទន្ទេញចាំមាត់ ។ អ្នករៀនអានទាំងនេះនឹងទទួលយកទស្សនៈបដិវត្តន៍ដែលល្អតែនៅហ្នឹងមុខដោយគ្មានងឿងឆ្ងល់ពីអត្ថន័យនៅខាងក្នុងឡើយ ។ ផ្ទុយទៅវិញអ្នករៀនអានដ៏គ្រោះថ្នាក់បំផុតគឺអ្នកទាំងឡាយណាដែល*

*ធ្វើការពិនិត្យទិតៀនលើខ្សែបន្ទាត់និងគោលដៅរបស់បក្ស ។*

ខៀវ សំផន បាននិយាយនៅឆ្នាំ១៩៧៧ថា «គោលដៅរបស់យើងគឺដាក់ការសិក្សារៀនសូត្រឲ្យស្និទ្ធនឹងការបង្កើនផលយើងរៀនសូត្រជំនាញបច្ចេកទេសនិងអនុវត្តក្នុងពេលចុះធ្វើការ» បាវចនាចែងថាយើងគួរតែរៀនសូត្រនៅពេលធ្វើការតាមវាលស្រែនិងថាធ្វើការកាន់តែច្រើន អ្នកនឹងបានយល់ដឹងជំនាញទាក់ទងនឹងបដិវត្តន៍កាន់តែពូកែ ។ បដិវត្តន៍ទាំងនេះគឺត្រូវរៀនសូត្រផងនិងចូលរួមដោយផ្ទាល់ក្នុងការងារបង្កបង្កើនផលសម្រាប់សហករណ៍ផង ។ ដើម្បីសម្រេចតាមគោលដៅនេះ សាលារៀនត្រូវបានដាក់ឲ្យមាននៅតាមសហករណ៍និងរោងចក្រ ។ ខ្សែបន្ទាត់បក្សរបស់ខ្មែរក្រហមជំរុញឲ្យដាក់កុមារនិងអ្នកមិនសូវចេះដឹងកាន់តួនាទីថ្មីៗដែលនឹងក្លាយជាវិធីដ៏ល្អដោយមិនដឹងខ្លួនសម្រាប់ឲ្យកម្មាភិបាលទទួលបានជំនាញចាំបាច់ទាំងនោះ ។ ដូច ខៀវ សំផន កត់សម្គាល់ថា ៖

> *នៅភ្នំពេញ កាលពីពេលមុនតើគេដែលឃើញប្រជាជនខ្មែរកាន់បញ្ជាម៉ាស៊ីនក្រឡឹងឬទេ? កម្រណាស់ ។ គ្មានជនជាតិខ្មែរណាបញ្ជានិងគ្រប់គ្រងគ្រឿងម៉ាស៊ីនទេ ។ មានតែជនបរទេសប៉ុណ្ណោះអ្នកធ្វើ ។ ចូរមើលឥឡូវនេះកូនខ្មែរមាននៅគ្រប់ទីកន្លែង ។ យើងអាចធ្វើបាន ។ យើងមានមោទនភាពនឹងរបត់ថ្មីនេះណាស់ ។ ហេតុដូច្នេះហើយ នេះគឺជាទំព័រសករាជថ្មីមួយក្នុងការកសាងជំនាញបច្ចេកទេសរបស់ជាតិ ។ វណ្ណៈកម្មករ-កសិករយើងដោយនៅក្រោមការដឹកនាំរបស់អង្គការបដិវត្តន៍ក្តាប់មានភាពស្ទាត់ជំនាញខាងបច្ចេកទេសយ៉ាងឆាប់រហ័ស ក្រោយពេលដែលអង្គការទទួលបានអំណាចនយោបាយ ។ កំពង់ផែរបស់យើងមានប្រសិទ្ធភាពជាងមុននិងមានភាពស្អិតស្អួរជាងមុន ។ ដោយមានប្រសិទ្ធភាព កំពង់ផែនោះមិននៅដើរយឺតជាងកំពង់ផែធំៗរបស់ពិភពលោកពេកទេ ។ ការនេះបង្ហាញថា ជំនាញខាងបច្ចេកទេសមិនមែនជាកត្តាកំណត់ទេ ។ តាមការពិតកត្តាសំខាន់នោះគឺជាគោលជំហរនយោបាយនិងមនោគមន៍វិជ្ជារបស់បងប្អូនកម្មករកំពង់ផែ ។ គោលជំហររបស់គេគឺខ្ពង់ខ្ពស់ មនោគមន៍វិជ្ជាគឺរឹងមាំ ឯសតិស្មារតីទទួលខុសត្រូវខ្ពស់និងគំនិតស្នេហាជាតិមិនមានអ្វីគួរឲ្យមន្ទិលឡើយ ។ ទាំងអស់នេះហើយអាចបំពេញបានច្រើនលើសពីការខ្វះខាតជំនាញបច្ចេកទេសទាំងនេះបាន ។*

## ខ្មែរក្រហម ៖ ការបណ្តុះបណ្តាល

ការអប់រំទាំងអស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យគឺជាផ្នែកមួយដែលគ្មានការរីកចម្រើន ។ ហើយដែលគោលនយោបាយមជ្ឈិមនៃរបបកម្ពុជាប្រជាធិបតេយ្យប្រហែលជាលើកឡើងថា «កម្មាភិបាលថ្នាក់តំបន់ភាគច្រើនបានគិតថា ការអប់រំខ្ពស់ជារឿងគ្មានប្រយោជន៍ ហើយមនុស្សដែលត្រូវបានគេទទួលយកគឺជាមនុស្សមិនមានការអប់រំ» ។ គ្រូជាច្រើនត្រូវបានជ្រើសរើសជាទ្រង់ទ្រាយធំចេញពីប្រជាជនមូលដ្ឋាន បន្ថែមពីលើនោះទៀតខ្មែរក្រហមបានធ្វើការអនុម័តលើសៀវភៅអានដែលត្រូវបានបែងចែកទៅឲ្យគ្រូមូលដ្ឋានទាំងអស់នោះមិនមែនឲ្យទៅសិស្សឡើយ ។ វគ្គនៃកម្មវិធីសិក្សាគ្របដណ្តប់ទៅលើការអាន សរសេរ គណិតវិទ្យានិងភូមិសាស្ត្រ ។ វាជាការពិតដែលគោលនយោបាយខ្មែរក្រហមត្រូវតែលុបបំបាត់ថ្នាក់រៀនក្រោយមធ្យមសិក្សាក៏ដូចជាសាលារៀនស្ទើរតែគ្រប់កម្រិតដែលខ្ពស់ជាងមតេយ្យ ហើយមិនដែលសូម្បីធ្វើការពិភាក្សាទៅលើការរៀបចំឡើងវិញនូវផ្នែកខាងក្រោនៃកម្មាភិបាលថ្នាក់ខ្ពស់រហូតដល់ឆ្នាំ១៩៧៨ ។ ខ្មែរក្រហមធ្វើការកត់សម្គាល់ថាគោលបំណងនេះគឺដើម្បីទាក់ទាញអ្នកបញ្ញវន្តក្នុងការតទល់ជាមួយវៀតណាមនិងសង្គ្រាមដែលគេបានរំពឹងទុកថានឹងមកដល់នាពេលខាងមុខ ។ គោលនយោបាយខ្មែរក្រហមបានចែងយ៉ាងច្បាស់នៅក្នុងផែនការបួនឆ្នាំដោយការលុបបំបាត់ភាពមិនចេះអក្សរជាមួយនឹងបំណងក្នុងការបំពាក់ការអប់រំជាមូលដ្ឋាននៅក្នុងរោងចក្រនិងសហករណ៍ ហើយនិងធ្វើឲ្យមានគុណភាពនៃកម្មវិធីស្រែចម្ការ ។ នៅខែតុលា ឆ្នាំ១៩៧៨ មានការបើកអង្គមីទ្ទីងមួយស្តីអំពីការអភិវឌ្ឍប្រព័ន្ធអប់រំថ្មី ដោយរួមបញ្ចូលកម្មវិធីមហាវិទ្យាល័យដែលបញ្ញវន្តថ្មីនឹងត្រូវបញ្ចូលទៅក្នុងកម្មវិធីនោះ ។

ប៉ុល ពត ខ្លួនឯងបាននិយាយនិងសម្តែងនូវការសប្បាយរីករាយចំពោះភ្ញៀវដែលមកចូលរួម ។ នៅក្នុងសេចក្តីថ្លែងសុន្ទរកថានេះ ប៉ុល ពត បានគូសបញ្ជាក់ថាក្នុងរយៈពេលដប់ឆ្នាំទៀតសិស្សដែលមិនបានចូលរៀនគួរតែចាកចេញឲ្យឆ្ងាយពីភាពមិនចេះអក្សរដើម្បីឲ្យក្លាយទៅជាអ្នកដែលទទួលបាននូវការអប់រំ

បញ្ចប់កម្រិតវិស្វកម្មតាមរយៈការសិក្សា «ចំណេះដឹងសំខាន់ៗ និងអនុវត្តការងារឲ្យបានសម្បូរបែប» ។

ដើម្បីត្រូវបានជ្រើសរើសយកការអប់រំនេះគឺត្រូវបានគេពិចារណាតាំងពីដំបូងដោយកូនកសិករក្រីក្រដែលត្រូវតែមានប្រវត្តិត្រឹមត្រូវនិងមានទំនាក់ទំនងការងារបដិវត្តន៍ជាមួយនឹងបក្ស ។ បន្ថែមពីនោះទៀត ខ្មែរក្រហមអះអាងថាក្មេងៗរបស់ថ្នាក់ដឹកនាំមជ្ឈិមកម្ពុជាប្រជាធិបតេយ្យបានចូលរៀននៅសាលាពិសេសមួយស្ថិតនៅក្បែរមន្ទីរបឹងត្របែក ហើយត្រូវបានគេធ្វើការកត់សម្គាល់ផងដែរថា ទាំង អៀង សារី និង ខៀវ សំផន មានកូនកំពុងចូលរៀននៅសាលាពិសេសនោះ ។ តាមរយៈការកសាងប្រទេសលើកម្មវិធីសិក្សានិងដំណើរការអប់រំដែលខ្មែរក្រហមហៅថា «ការជ្រាប» ប្រជាជននឹងរៀនជាបណ្ដើរៗពីមនោគមន៍វិជ្ជារបស់បក្សដូចជាអ្នកដែលងប់ងុលនឹងបដិវត្តន៍ ដែលនៅទីបញ្ចប់អ្នកទាំងនោះត្រូវបានអប់រំដោយគោលនយោបាយត្រឹមត្រូវ ។

## ជំរំបំពាក់បំប៉ននយោបាយសម្រាប់យុវជនក្រីក្រ

កសិករដែលមិនមានការអប់រំត្រូវបានបញ្ជូនទៅកាន់កន្លែងបំពាក់បំប៉នមនោគមន៍វិជ្ជាដើម្បីលើកសរសើរពីអ្វីដែលកសិករល្ងង់ខ្លៅត្រូវបានទាក់ទាញឲ្យចូលក្នុងការឃោសនាជាតិដ៏ទូលំទូលាយជាមួយនឹងការអប់រំដែលអាចយកមកអនុវត្តន៍នូវអ្វីដែលកសិករក្រីក្រនិងអ្នកដែលមិនមានចំណេះដឹងទាំងអស់នោះចាប់អារម្មណ៍ ។ នៅក្នុងជំរំកែប្រែទាំងនោះបានបង្ហាញថាពោរពេញទៅដោយអំពើហិង្សានិងមនុស្សល្ងង់ ហើយខ្មែរក្រហមបានបង្រៀនឲ្យអ្នកទាំងនោះចេះដឹកនាំ រៀបចំ ត្រួតត្រា និងបំផ្លាញ ។ មនុស្សល្ងង់ទាំងអស់នេះទទួលបញ្ជាដោយគ្មានសួរនាំអ្វីទាំងអស់ ។ ខ្មែរក្រហមបានបង្កើតនូវ «កំហឹងនិងការច្រណែនឲ្យទៅអ្នកទាំងនោះ ដូច្នេះការសម្លាប់នឹងអាចកើតឡើង ។ ខ្មែរក្រហមបានបង្រៀនអ្នកទាំងនេះមិនឲ្យខ្វល់ខ្វាយនិងត្រូវអង់អាចក្លាហាន ។ ឡ ជាអ្នករស់ជីវិតពីសម័យខ្មែរក្រហមបានរំឭកថា នៅពេលគាត់ធ្វើជាយោធា គាត់ត្រូវបានបង្រៀនពីរបៀបថាតើត្រូវធ្វើយ៉ាងណាដើម្បីកាត់ផ្ដាច់ភាពអាណិតអាសូរចេញពីសត្រូវ ។ នៅទួលស្លែង (ស-២១) ឡ និយាយថា ខ្មែរក្រហមបានអនុវត្តន៍ការបណ្ដុះបណ្ដាលច្រើន ហើយប្រាប់យើងថាយើងត្រូវតែក្លាហាននិងសម្លាប់ចំពោះអ្នកណាក៏ដោយដែលមានកំហុស ដែលមានន័យថា យើងត្រូវតែលះបង់មនោសញ្ចេតនាចំពោះអ្នកដទៃ ។

នៅខែមីនា ឆ្នាំ១៩៧៥ ពេលដែលគាត់ចូលជាមួយខ្មែរក្រហម វ៉ែន ខឿន បាននិយាយថា មុនពេលគាត់ត្រូវបាននាំចូលជាសមាជិកបក្សដែលមិនផ្លូវការ គាត់ត្រូវទទួលការអប់រំផ្នែកនយោបាយរយៈពេលជាងដប់ថ្ងៃនៅក្នុងមន្ទីរតាមភូមិក្នុងតំបន់២៥ ។ រយៈពេលខ្លីក្រោយមក គាត់ត្រូវបានបញ្ចូលទៅក្នុងកងពល១២ (ក្រោយមកមានឈ្មោះថាកងពល៧០៣) ដើម្បីទទួលការបណ្ដុះបណ្ដាលផ្នែកយោធាបន្ថែមមួយខែទៀតនៅសាលាបច្ចេកទេសកងពលលេខ១២ ។ នៅខែធ្នូ ឆ្នាំ១៩៧៥ វ៉ែន ត្រូវបានបញ្ជូនទៅកាន់សាលាបច្ចេកទេសរយៈពេលប្រាំខែដើម្បីចូលរួមការបណ្ដុះបណ្ដាលបន្ថែមនៅតាខ្មៅដែលជាកន្លែងកម្មាភិបាលទួលស្លែងជាច្រើនត្រូវបានបណ្ដុះបណ្ដាល ។ នៅទីនេះ គាត់ត្រូវបានបង្រៀនជាច្រើនអំពីការអប់រំផ្នែកនយោបាយនិងយុទ្ធសាស្ត្រយោធានិងការចូលរួមនៅឯការប្រជុំស្វ័យទិតៀននិងនយោបាយដែលមិនអាចខកខាន ។ ដើម្បីបំពេញបន្ថែមទៅលើការបំពាក់បំប៉នផ្នែកនយោបាយ វ៉ែន ត្រូវទទួលការហ៊ឹកហ៊ឺនផ្នែកកាយសម្បទាដូចជាការលត់ដំធ្វើពលកម្ម ការអត់ធន់នឹងភាពនឿយហត់ ការអត់ឃ្លាននិងការបង្ខំឲ្យដេកមិនគ្រប់គ្រាន់ ។ លោកបណ្ឌិត ហ៊ិនតុន បានលើកឡើងថា ខ្មែរក្រហមកំពុងធ្វើបែបនេះដើម្បីរកឲ្យឃើញ «ស្មារតីអ្នកបដិវត្តដ៏ពិតប្រាកដនិងស្មោះត្រង់ទាំងស្រុងទៅនឹងរបបកម្ពុជាប្រជាធិបតេយ្យ» ។ សម្រាប់កម្មាភិបាលខ្មែរក្រហមដែលកំពុងធ្វើការនៅទួលស្លែង អ្នកទាំងនេះបានទទួលរងនូវស្ថានភាពលំបាកនិងការអប់រំអំពីគោលនយោបាយ ។ អ្នកទាំងនេះកំពុងតែបន្តទទួលនូវការអប់រំផ្នែកមនោគមន៍វិជ្ជានៃគោលនយោបាយរបស់បក្សជាមួយនឹងការធ្វើការនៅក្នុងស្ថានភាពដ៏គួរឲ្យភ័យខ្លាច ឯកោ និងការថប់អារម្មណ៍ ។

អតីតអ្នកយាមគុកទួលស្លែងម្នាក់បានរៀបរាប់ថា «ខ្ញុំគិតថាយើងនឹងក្លាយទៅជាមនុស្សឆ្កួតនៅពេលនោះដោយសារតែការបំពាក់បំប៉ននយោបាយរបស់ខ្មែរក្រហម ។ យើងបានជឿជាក់នូវអ្វីដែលគេបាននិយាយ ។ យើងធ្វើអ្វីដែលគេបានបញ្ជាឲ្យយើងធ្វើ ។ យើងបានព្យាយាមបំភ្លេចនូវអ្វីដែលគេបានប្រាប់យើងឲ្យ

បំភ្លេច ។ យើងមិនបានគិតអំពីក្រុមគ្រួសាររបស់យើងទេ ដោយជំនួសមកវិញយើងបានត្រឹមតែព្យាយាមធ្វើការអស់ពីកម្លាំងកាយចិត្តដើម្បីបម្រើឲ្យបដិវត្តន៍ខ្មែរក្រហម» ។ មេរៀនទូទៅដែលត្រូវបង្រៀនដល់កម្មាភិបាលដែលជាអ្នកសួរចម្លើយ អ្នកសម្លាប់មនុស្ស ឬកម្មាភិបាលមូលដ្ឋាន គឺត្រូវធ្វើឲ្យអ្នកទោស អ្នកដែលត្រូវទទួលទារុណកម្ម អ្នកចំណូលថ្មី ឬជនក្បត់ អ្នកមិនមានលក្ខណៈច្បាស់ថាតើខ្លួននៅរស់ឬក៏ស្លាប់ ហើយក្នុងគោលបំណងធ្វើឲ្យអ្នកទាំងនោះសង្ឃឹមថាខ្លួនអាចនឹងនៅរស់ ។ អ្នកសួរចម្លើយ និងកម្មាភិបាលដែលធ្វើការនៅទួលស្លែងបានទទួលរងដូចជាអ្វីដែលលោកបណ្ឌិត ហ៊ិនតុន បានបកស្រាយថាជាការបណ្តុះបណ្តាលផ្នែកនយោបាយនិងមនោគមន៍វិជ្ជាដ៏ទូលំទូលាយដែលជារឿយៗនិងប្រញឹកក្នុងការរៀនសូត្រ ។ យោងទៅតាមបណ្ឌិត ហ៊ិន តុន ជាលទ្ធផលនៃការបណ្តុះបណ្តាលដ៏តឹងរ៉ឹង កម្មាភិបាលទួលស្លែងទាំងនោះបាត់បង់នូវសីលធម៌និងក្លាយជាមិនមានសុវភ័យខ្លាចដោយសារការរស់នៅក្នុងស្ថាប័នអំពើហិង្សាដែលបំពាក់បំប៉ននយោបាយនិងការបណ្តុះបណ្តាលព្រមទាំងអង្កេតយ៉ាងខ្ជាប់ខ្ជួន ឬចូលរួមនៅក្នុងការធ្វើបាបអ្នកទោស ។ អ្នកទាំងនោះមិនសូវអាណិតទៅលើការឈឺចាប់របស់ជនរងគ្រោះទេ ។

**ជំរំបំពាក់បំប៉នសម្រាប់យុវជនដែលមានការអប់រំ**

មានការកត់សម្គាល់ឃើញថា នៅក្នុងតំបន់ខ្លះ កម្ពុជាប្រជាធិបតេយ្យប្រឹងប្រែងលើកទឹកចិត្តទៅដល់ស្ថាប័ន «កម្មវិធីអប់រំឡើងវិញសម្រាប់បញ្ញវន្តដែលមានសមត្ថភាពដើម្បីផ្លាស់បញ្ញវន្តទាំងនោះទៅក្នុងរបបថ្មីមួយនិងប្រើប្រាស់ចំណេះដឹងរបស់បញ្ញវន្តទាំងនោះដើម្បីយកទៅអប់រំនិងបណ្តុះបណ្តាលអ្នកដទៃទៀត ។ នន់ សួន អ្នករស់រានមានជីវិតម្នាក់ដែលអត់ធ្មត់យ៉ាងខ្លាំងក្រោមរបបខ្មែរក្រហមបានកត់សម្គាល់ថា បន្ទាប់ពីគាត់ទ្រាំទ្រការធ្វើទារុណកម្មក្នុងគុក ដោយសារតែគាត់ជាអ្នកមានអំណាចម្នាក់នៅក្នុងរបបលន់ នល់ គាត់ត្រូវតែចូលរួមការអប់រំសម្រាប់បញ្ញវន្តដែលបក្សកុម្មុយនីស្តកម្ពុជានៅពេលនោះបានគិតថា ពួកគេនឹងអាចប្រើប្រាស់ជំនាញរបស់គាត់នាពេលអនាគតបន្ទាប់ពីទទួលការបំពាក់បំប៉នមនោគមន៍វិជ្ជាក្នុងការជួយបក្សកុម្មុយនីស្តកម្ពុជា ។ យោងតាមការបកស្រាយរបស់ សួន ការអប់រំនេះគឺជាមណ្ឌលមួយសម្រាប់បញ្ញវន្តដែលខ្មែរក្រហមមិនទុកចិត្ត ។ វិស្សុករូបនេះបានធ្វើការកត់សម្គាល់ថាការអប់រំនយោបាយគឺការអប់រំសំខាន់បំផុតពីព្រោះការអប់រំនេះធ្វើឡើងក្នុងមួយថ្ងៃៗដោយប្រើរយៈពេលពីរទៅបីម៉ោង ។

មានមណ្ឌលកែប្រែសំខាន់ពីរជាពិសេសកន្លែង «ប្រជាជនថ្មីទាំងនោះ» (រួមមានបញ្ញវន្ត ប្រជាជនដែលចូលរួមបដិវត្តន៍ក្រោយខែមេសា ឆ្នាំ១៩៧៥) ដែលខ្មែរក្រហមគិតថាកំពុងគំរាមកំហែងនឹងត្រូវបញ្ជូនទៅកាន់វិទ្យាស្ថានបច្ចេកវិជ្ជាខ្មែរ-សូវៀតឬក៏មណ្ឌលកែប្រែបឹងត្របែកមណ្ឌល ។ ក្រោយមក មណ្ឌលទាំងពីរនេះគឺជាមណ្ឌលអប់រំកម្រិតខ្ពស់សម្រាប់បញ្ញវន្តខ្មែរដែលវិលត្រឡប់មកពីបរទេសដែលអ្នកទាំងនោះបានទៅរៀនសូត្រនៅប្រទេសសង្គមនិយម បានបម្រើជាមន្ត្រីការទូតរបស់រដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជានៅឆ្នាំ១៩៧០-១៩៧៥ ឬជាអ្នកដែលប្រកាន់ឆ្វេងនិយមបានត្រឡប់មកប្រទេសកម្ពុជាបន្ទាប់ពីថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ។ ទីនេះជាមណ្ឌលអប់រំកែប្រែដ៏ធំសម្រាប់បញ្ញវន្តដែលចង់និងស្ម័គ្រចិត្តទទួលការបណ្តុះបណ្តាលសំខាន់ផ្សេងៗដើម្បីក្លាយទៅជាអ្នកដឹកនាំនៅក្នុងបដិវត្តន៍ថ្មីនេះ ។ ***(នៅមានត)***

**ហ្វ្រីហ្គារី ប្រុកណូ**

**ឃ្លាំមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាតាមគេហទំព័រ**

ដើម្បីឲ្យសាធារណជនទូទៅមានលទ្ធភាពក្នុងការតាមដានមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសមញ្ញក្នុងតុលាការកម្ពុជាគេហទំព័រ *www.cambodiatribunal.org* ត្រូវបានបង្កើតឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា និងសាលាច្បាប់នៃសាកលវិទ្យាល័យណតវើស្ទើន សហរដ្ឋអាមេរិក និងក្រោមសហប្រត្តិបត្តិការជាមួយ *Illinois Holocaust Museum and Educational Center* ។ មុននិងផ្សព្វផ្សាយ គេហទំព័រនេះត្រូវបានត្រួតពិនិត្យដោយសាស្ត្រាចារ្យច្បាប់ *David Scheffer* អតីតឯកអគ្គរដ្ឋទូតគោចរណ៍របស់សហរដ្ឋអាមេរិកទទួលបន្ទុកកិច្ចការឧក្រិដ្ឋកម្មសង្គ្រាមកាលពីជំនាន់រដ្ឋការប្រធានាធិបតី ប៊ីល គ្លីនតុន និងលោកឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ។

# ការរៀបរាប់របស់គ្រូបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

ចាប់តាំងពីចុងឆ្នាំ២០០៩ មជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងអប់រំ យុវជន និងកីឡា បានអញ្ជើញគ្រូបង្គោលថ្នាក់ជាតិមកពីក្រសួងអប់រំ និងគ្រូបង្គោលថ្នាក់ខេត្តមកពី១៧ខេត្ត-ក្រុង ក្នុងប្រទេសកម្ពុជាឲ្យមកចូលរួមវគ្គបណ្តុះបណ្តាលពីវិធីសាស្ត្របង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅតាមមណ្ឌលដែលបានកំណត់រៀងៗខ្លួន ។ គោលបំណងនៃវគ្គបណ្តុះបណ្តាលនេះធ្វើឡើងដើម្បីឲ្យលោកគ្រូ-អ្នកគ្រូទទួលបានចំណេះដឹងពីវិធីសាស្ត្របង្រៀនថ្មី និងជាពិសេសមានឱកាសពិភាក្សា ផ្ទេរចំណេះដឹងទៅវិញទៅមកព្រមទាំងបានស្គាល់តំបន់ផ្សេងៗផង ។

នៅក្នុងវគ្គបណ្តុះបណ្តាលលើកទីបី នៅខែមិថុនា ឆ្នាំ២០១០ នៅខេត្តស្វាយរៀង ខេត្តពោធិ៍សាត់ និងសៀមរាប មានលោកគ្រូ-អ្នកគ្រូបង្គោលថ្នាក់ខេត្តមកពីខេត្តផ្សេងៗបានមកជួបប្រជុំគ្នា និងនិយាយរៀបរាប់ពីរឿងរ៉ាវនិងបទពិសោធន៍ផ្ទាល់ខ្លួនរបស់គាត់ដែលបានឆ្លងកាត់ក្នុងរបបខ្មែរក្រហមប្រាប់គ្នាទៅវិញទៅមក ។

**ខេត្តស្វាយរៀង**

សឿ ហាច ជាអតីតកងទ័ពព្រៃ និងសព្វថ្ងៃជាគ្រូបង្រៀនប្រវត្តិសាស្ត្រមកពីខេត្តបាត់ដំបងបានរៀបរាប់ថាៈ «ខ្ញុំតែងតែនិយាយរឿងរ៉ាវរបស់ខ្ញុំប្រាប់ទៅសិស្សក្នុងថ្នាក់ ប៉ុន្តែសិស្សមួយចំនួនឆ្លើយតបមកខ្ញុំវិញ ថាមិនមានរឿងរ៉ាវកើតឡើងដូចលោកគ្រូនិយាយនោះទេ» ។ ទោះបីសិស្សឆ្លើយយ៉ាងនេះក៏ដោយ ក៏ខ្ញុំមិនបង្ខំឲ្យសិស្សជឿដែរ ប៉ុន្តែខ្ញុំបានជំរុញសិស្សទាំងនោះទៅសាកសួរឪពុកម្តាយឬចាស់ទុំនៅក្នុងភូមិរបស់ខ្លួន ព្រមទាំងឲ្យអានឯកសារបន្ថែមទៀត ។


សឿ ហាច

ខ្ញុំកើតនៅភូមិក្រពើ ឃុំភ្នំសំពៅ ស្រុកបាណន់ (ពីមុនស្រុកបាត់ដំបងនិងពីឆ្នាំ១៩៧៥ - ១៩៧៩ ខ្មែរក្រហមប្តូរឈ្មោះទៅជាស្រុកភ្នំសំពៅវិញ) ខេត្តបាត់ដំបង ។ កាលពីកុមារ ខ្ញុំនៅផ្ទះជួយធ្វើស្រែចម្ការឪពុកម្តាយនិងឃ្វាលគោរហូតដល់អាយុ១២ឆ្នាំ ទើប ចូលរៀននៅសាលាបឋមសិក្សាគំរូភ្នំសំពៅ ។ នៅពេលទៅរៀនម្តងៗខ្ញុំតែងតែខ្ចប់បាយទុកហូបពេលម៉ោងឈប់សម្រាកថ្ងៃត្រង់ នៅសាលាព្រោះផ្លូវត្រឡប់មកផ្ទះលំបាកនិងម៉្យាងទៀតមាន ភ្លៀងធ្លាក់ខ្លាំងផងនៅរដូវវស្សា ។

នៅឆ្នាំ១៩៦៨ ខ្ញុំប្រឡងជាប់ចូលរៀននៅអនុវិទ្យាល័យនេតយ៉ង់ (ក្រោយមកប្តូរទៅជាវិទ្យាល័យនេតយ៉ង់) ទើបខ្ញុំផ្លាស់មកស្នាក់នៅវត្តដំរីសក្នុងក្រុងបាត់ដំបងវិញ ។ រៀងរាល់ឆ្នាំខ្ញុំតែងតែរៀនបាននិទ្ទេសល្អ និងជាសិស្សពូកែនៅក្នុងថ្នាក់ ។ ក្រោយមក សាលាក៏ជ្រើសរើសខ្ញុំឲ្យដឹកនាំសិស្សក្នុងថ្នាក់ធ្វើបាតុកម្មប្រឆាំងនឹងរដ្ឋាភិបាលលន់ នល់ ។ នៅចុងឆ្នាំ១៩៧៤ ពេលខ្ញុំកំពុងរៀនត្រៀមប្រឡងសញ្ញាប័ត្រទុតិយភូមិ សភាពការណ៍ក្នុងខេត្តចាប់ផ្តើមជ្រួលច្របល់កាន់តែខ្លាំង ដោយពេលនោះរដ្ឋាភិបាលបានស្វែងរកចាប់ខ្លួនខ្ញុំ និងមិត្តភក្តិនៅក្នុងថ្នាក់មួយចំនួនទៀត ។ ដោយសារខ្លាចរដ្ឋាភិបាលចាប់បាន ខ្ញុំក៏រត់គៀសខ្លួនទៅរស់នៅនិងរកស៊ីដឹកត្បូងជាមួយបងប្រុសនៅប៉ៃលិន ។ នៅឆ្នាំ១៩៧៥ ខ្ញុំឃើញចៅហ្វាយខេត្តបាត់ដំបង ហ៊ុល ទន ព្រមទាំងរថក្រោះ និងកងទ័ពរាប់រយនាក់បានមកដល់ប៉ៃលិន រួចប្រកាសថា «សូមប្រជាជនទាំងអស់ចាកចេញ ព្រោះខ្មែរក្រហមនឹងចូលមកសម្លាប់ជាមិន

ខាន» ។ ពួដូច្នេះ ខ្ញុំប្រមូលលុយបានចំនួន៨០ម៉ឺនរៀល និង រៀបចំអីវ៉ាន់ រួចជិះម៉ូតូតាមក្រោយក្បួនទ័ពចូលប្រទេសថៃ ។ ប៉ុន្តែនៅពេលទៅដល់ព្រំដែន កងទ័ពថៃបានហាមឃាត់ និងបានដកយករថក្រោះ និងកាំភ្លើងពីទាហាន លន់ នល់ អស់ ។ ឃើញសកម្មភាពប្រែប្រួល ដូច្នេះ ខ្ញុំក៏សម្រេចចិត្តត្រឡប់មកក្រោយវិញ ។ ខ្ញុំរន្ធត់ចិត្តយ៉ាងខ្លាំងពេលខ្ញុំមកជិតដល់ប៉ៃលិន ព្រោះខ្ញុំឃើញសាកសពមនុស្សប្រាំនាក់ហើមនៅតាមបណ្តោយផ្លូវ ។ នៅថ្ងៃបន្ទាប់ ខ្មែរក្រហមបានប្រកាសឲ្យប្រជាជនទាំងអស់ចាកចេញពីផ្ទះ ខណៈនោះបងប្រុសខ្ញុំក៏ប្រាប់ខ្ញុំឲ្យត្រឡប់មកស្រុកកំណើតមុន ។

នៅពេលរសៀល ពេលខ្ញុំដើរមកវត្តកោងកាងក៏សុំឡានអ្នកធ្វើផ្លូវមួយគ្រឿងជិះមកភ្នំសំពៅ ។ ប៉ុន្តែមកដល់ភូមិត្រែងក៏ត្រូវខ្មែរក្រហមដកហូតឡាន រួចបញ្ជាឲ្យអ្នកជិះទាំងអស់ចុះមកដី ។ បន្ទាប់មក កងទ័ពខ្មែរក្រហមបានធ្វើការឆែកឆេរនិងប្រមូលអ្នកធ្លាប់ធ្វើជាទាហាន លន់ នល់ ទុកមួយកន្លែង ។ ខ្ញុំក៏យកសម្ភារទាហានដែលខ្ញុំយកមកជាមួយទាំងអស់បោះចោល រួចចូលប្រជ្រៀតជាមួយអ្នកស្រុកដើម្បីធ្វើដំណើរទៅមុខបន្តទៀត ។ មកដល់ឃុំស្នឹងយោធាខ្មែរក្រហមបានឃាត់ប្រជាជនម្តងទៀត ដោយបំបែកប្រជាជនមួយក្រុមឲ្យទៅភូមិរូង ចំណែកខ្ញុំទៅរស់នៅភូមិពាក់ស្បែក ។ នៅទីនោះ ខ្មែរក្រហមហាមមិនឲ្យប្រជាជនដើរឆ្ងាយទេរួចហើយគំរាមថា បើចេញទៅព្រៃខាងក្រៅភូមិ ហើយយោធាចាប់បាននឹងសម្លាប់ចោលមិនខាន ។ ខ្ញុំរស់នៅទាំងអារម្មណ៍ភ័យខ្លាចប៉ុន្តែក្រោយមកដោយសារមានការខ្វះខាតអាហារបណ្តាលឲ្យប្រជាជនស្លាប់និងធ្លាក់ខ្លួនឈឺជាបន្តបន្ទាប់ ទើបប្រធានភូមិជ្រើសរើសអ្នកស្ម័គ្រចិត្តចេញក្រៅភូមិរកស្បៀង ។ ពេលនោះ ប្រធានឃុំបានចេញលិខិតដើរផ្លូវឲ្យខ្ញុំមួយច្បាប់ ។ ខ្ញុំបានយកលុយមួយចំនួនរបស់ខ្ញុំទៅទិញអង្ករ ប៉ុន្តែគ្មាននរណាលក់ឲ្យខ្ញុំទេព្រោះគេឈប់ចាយលុយហើយ ។ ខ្ញុំក៏ធ្វើដំណើរមករកឪពុកម្តាយនៅភូមិក្រពើវិញ ប៉ុន្តែគាត់ត្រូវខ្មែរក្រហមជម្លៀសឲ្យទៅរស់នៅវាលស្រែអស់ហើយ ។ ទោះជាយ៉ាងណាក៏ដោយ ក៏ខ្ញុំទៅជួប គាត់ដែរបន្ទាប់មកទើបយកអង្ករបានមួយចំនួនត្រឡប់ទៅប្រគល់ឲ្យអង្គការនៅភូមិពាក់ស្បែកវិញ ។

បួនថ្ងៃក្រោយមក ដោយសារទ្រាំទ្រនឹងការអត់អាហារមិនបាន ខ្ញុំក៏សម្រេចចិត្តលួចរត់ចេញពីភូមិពាក់ស្បែកមករស់នៅជាមួយឪពុកម្តាយវិញ ។ ក្នុងភូមិក្រពើ ខ្មែរក្រហមអនុញ្ញាតឲ្យប្រជាជនហូបឯកជន ប៉ុន្តែត្រូវចូលរួមធ្វើការងារក្រុមសាមគ្គីឬប្រវាស់ដៃដែលមានសមាជិកដប់នាក់ ។ មិនយូរប៉ុន្មាន ខ្មែរក្រហមបានប្រមូលទ្រព្យសម្បត្តិប្រជាជនដាក់ជារបស់សមូហភាពនិងរៀបចំជាកងចល័តភូមិ ។ បីខែក្រោយមក ខ្មែរក្រហមចាប់ផ្តើមជ្រើសរើសខ្ញុំ សិស្ស និស្សិត គ្រូបង្រៀន និងអ្នកចេះដឹងឲ្យចូលទៅក្នុងកងចល័តភូមិភាគ រួចបញ្ជូនទៅច្រូតស្រូវនៅវាលឡូញដែលស្ថិតនៅក្នុងទំនប់អាងកំពីងពួយ ។ រៀងរាល់ពេលល្ងាចក្រោយពេលកងចល័តធ្វើការងាររួចរាល់ និងហូបបាយរួច ខ្មែរក្រហមចាប់ផ្តើមប្រជុំរួមដោយមានការចូលរួមពីគណៈសហករណ៍ គណៈស្រុកនិងគណៈតំបន់ដើម្បីនិយាយអំពីការបង្កបង្កើនផលនិងជ័យជម្នះរបស់បដិវត្តន៍រហូតដល់យប់ជ្រៅដោយមានកងឈ្លបដើរឃ្លាំមើលនរណាងងុយដេកដើម្បីយកទៅរៀនសូត្រឬសម្លាប់ចោល ។ ចំណែកកងចល័តមួយចំនួនទៀតបានធ្លាក់ខ្លួនឈឺ និងស្លាប់ជាបន្តបន្ទាប់ ដោយសារធ្វើការងារធ្ងន់ធ្ងរ និងអត់អាហារបរិភោគ ។ ឃើញដូច្នេះ ខ្ញុំក៏យកកំបោរសមកលាបក្លៀកឲ្យក្តៅខ្លួន រួចនិយាយកុហកប្រធានកងថា គ្រុនក្តៅ ដើម្បីសុំប្រធានកងមកសម្រាកព្យាបាលនៅសហករណ៍ភូមិវិញ ។

ម្តាយខ្ញុំបានជួយលាក់ខ្ញុំឲ្យរស់នៅក្នុងភូមិ ប៉ុន្តែក្រោយមកដោយសារភ័យខ្លាចអង្គការដឹង គាត់ក៏បញ្ជូនខ្ញុំដែលនៅលីវឲ្យចេញទៅធ្វើការងារឆ្ងាយពីភូមិម្តងទៀត រួចស្នើសុំប្រធានភូមិរៀបការប្រពន្ធនៅក្នុងភូមិដើម្បីឲ្យខ្ញុំក្លាយជាកងឈ្លប និងអាចរស់នៅក្នុងភូមិបាន ។ ក្រោយពេលរៀបការរួច ខ្ញុំមិនបានរស់នៅជុំគ្នាទេដោយខ្មែរក្រហមបំបែកខ្ញុំទៅខាងកងភ្ជួរ ចំណែកប្រពន្ធខ្ញុំទៅកងដកស្ទូង ។ ខ្ញុំបាន ជួបមុខប្រពន្ធតែនៅពេលដែលអង្គការធ្វើមីទ្ទីងនៅក្នុងសហករណ៍ភូមិឬឃុំប៉ុណ្ណោះហើយពេលនោះកងឈ្លបតែងតាមដានចំពោះអ្នកណាដែលជជែកគ្នាមិនស្តាប់អង្គប្រជុំដើម្បីយកទៅរៀនសូត្រ ។

ថ្ងៃមួយ អង្គការចែកពោតឲ្យខ្ញុំមួយផ្លែ ខ្ញុំក៏សុំអនុញ្ញាតប្រធានកងយកពោតមួយកំណាត់ទៅឲ្យប្រពន្ធហូបនៅកងដកស្ទូង ។ ពេលនោះ ប្រពន្ធខ្ញុំក៏និយាយមកកាន់ខ្ញុំថា «យើងរៀបការជាមួយ

គ្នាហើយ តែយើងរស់នៅបែកពីគ្នាហាក់ដូចជាមិនមែនប្តីប្រពន្ធនឹងគ្នាអីចឹងដូច្នេះពេលជួបបងម្តងៗខ្ញុំមានអារម្មណ៍ខ្មាសបងណាស់» ។ ឮពាក្យនេះភ្លាម ខ្ញុំនិយាយលួងលោមគាត់ថា «អូនកុំគិតអ្វីផ្តេសផ្តាសធ្វើដូចម្តេចបើសង្គមយើងដូច្នេះ ។ អូនត្រូវខិតខំធ្វើការងារទៅ» ។

នៅរដូវវស្សា កងភ្លូររបស់ខ្ញុំទទួលបានតែរបបបបររាវៗប៉ុណ្ណោះ ដូច្នេះពេលចេញទៅភ្លូរស្រែម្តងៗ ខ្ញុំតែងតែដើររើសក្តាមមកហូបជាមួយអំបិលដែលសុំពីខាងរោងបាយហូបបន្ថែមទៀត ។

នៅភូមិ អង្គការបានតាមដាននិងចាប់អតីតទាហាន និងអ្នកនយោបាយរបបចាស់យកទៅបាត់ជាបន្តបន្ទាប់ ។ ឃើញដូច្នេះ ខ្ញុំក៏សុំអនុញ្ញាតប្រធានសហករណ៍ទៅឃ្វាលគោនិងចូលទៅដុតធ្យូងនៅក្នុងព្រៃ ដើម្បីកុំឲ្យកងឈ្លបសង្ស័យខ្ញុំជាសិស្ស ។ រយៈពេលពីរខែទើបខ្ញុំត្រឡប់មកលេងភូមិម្តងដែលជារឿយៗខ្ញុំតែងតែនិយាយបញ្ជោរនិងយករបស់របរដែលរកបានក្នុងព្រៃមកជូនប្រធានសហករណ៍ជានិច្ច ដើម្បីឲ្យគាត់ជួយលាក់អត្តសញ្ញាណរបស់ខ្ញុំ ។

នៅថ្ងៃមួយ ពេលប្រធានសហករណ៍ប្រកាសជ្រើសរើសអ្នកស្ម័គ្រចិត្តទៅធ្វើការនៅសហករណ៍អូរតាគី ពេលនោះខ្ញុំនិងប្រពន្ធក៏យល់ព្រមទៅដោយសង្ឃឹមថាទទួលបានរបបអាហារគ្រប់គ្រាន់ជាងមុនមិនខាន ។ នៅទីនោះ ក្នុងមួយក្រុមដែលមានមនុស្សដប់នាក់ អង្គការចែកចុងអង្ករឲ្យដប់កំប៉ុងដែលមានលាយសត្វខ្ទួតមួយៗ និងកន្ទក់សម្រាប់ដាំបាយហូប ។ ប៉ុន្តែបន្ទាប់ពីសម្រិតរួចហើយនៅសល់គ្រាប់អង្ករតែកន្លះកំប៉ុងប៉ុណ្ណោះ ។ នៅថ្ងៃបន្ទាប់ ប្រធានកងប្រើខ្ញុំឲ្យលីបាវអង្ករពីរោងបាយទៅរោងចិញ្ចឹមជ្រូក ទើបខ្ញុំដឹងថា អង្ករនោះសម្រាប់ដាំឲ្យជ្រូកស៊ី ។ រាល់ថ្ងៃដោយសារធ្វើការងារធ្ងន់ធ្ងរ និងគ្មានអាហារហូប ខ្ញុំក៏សម្រេចចិត្តបេះផ្សិតពុលមកដុតបរិភោគដើម្បីឲ្យស្លាប់ ប៉ុន្តែត្រូវបានខ្មែរក្រហមបញ្ជូនទៅសង្គ្រោះនៅពេទ្យសង្គមកិច្ច ។ ក្រោយមក ខ្ញុំនិងប្រពន្ធក៏សម្រេចចិត្តរៀបចំអីវ៉ាន់ ត្រឡប់មកភូមិវិញ ប៉ុន្តែកម្មាភិបាលនៅភូមិអូរតាគីឈ្មោះ រុំ បានឃាត់ខ្លួន និងធ្វើការឆែកឆេរ ។ ឃើញដូច្នេះ ខ្ញុំក៏យកក្រដាសវាយអង្គុលីលេខដែលខ្ញុំរើសបាននៅជិតរោងចិញ្ចឹមជ្រូកមកបង្ហាញ តារុំ រួចខ្ញុំនិយាយកុហកថាជាលិខិតខុទ្ទេសនាមទើបគាត់អនុញ្ញាតឲ្យទៅសហករណ៍ភូមិក្រពើវិញ ។

នៅពេលយប់ងងឹត ខ្ញុំតែងតែឃើញកងឈ្លបដើរស្រាវជ្រាវនិងចាប់ខ្លួនទាហាន សិស្ស និស្សិត អ្នកជាប់ខ្សែស្រឡាយវៀតណាម អ្នកជាប់ពាក់ព័ន្ធជាមួយសេ.អ៊ី.អា និងកា.ហ្សេ.បេ យកទៅសម្លាប់នៅអូរតូចចម្ងាយមួយគីឡូម៉ែត្រពីសហករណ៍ភូមិក្រពើជាបន្តបន្ទាប់ ។ មួយរយៈក្រោយមក មេកងមកលួចខ្សឹបប្រាប់ខ្ញុំថា «ហាច ឯងគេចខ្លួនទៅ ព្រោះកងឈ្លបកំពុងតាមចាប់ខ្លួនហើយ» ។ ឮដូច្នេះ ខ្ញុំបានរត់ទៅលាក់ខ្លួននៅក្នុងល្អាងភ្នំមួយដោយមិនប្រាប់ឲ្យប្រពន្ធខ្ញុំដឹងឡើយ ។ នៅទីនោះ ខ្ញុំឃើញមនុស្សចម្លែកពីរ-បីនាក់រស់នៅ ប៉ុន្តែក្រោយពីស្គាល់គ្នាទើបដឹងថាជាអ្នករត់គេចខ្លួនពីការតាមចាប់របស់កងឈ្លបខ្មែរក្រហមដូចខ្ញុំដែរ ។

រៀងរាល់ថ្ងៃ ខ្ញុំតែងតែចេញទៅលួចដកដំឡូងក្នុងចម្ការអ្នកស្រុកយកមកហូបចម្អែតក្រពះជានិច្ច ។

ក្រោយមក មានមនុស្សកាន់តែច្រើនរត់មករស់នៅក្នុងល្អាងនេះដែរទើបយើងបង្កើតទៅជាក្រុមចោរព្រៃមួយក្រុម ។ ថ្ងៃមួយកងរបស់ខ្ញុំបានប៉ះទង្គិចជាមួយនឹងយោធាភូមិភាគពាយ័ព្យមួយក្រុមក្រោមការដឹកនាំរបស់តាដាក់ដែលរត់គេចខ្លួនពីការតាមចាប់របស់យោធាភូមិភាគនិរតី ក្រោយមក ក៏រួបរួមគ្នារួចជ្រើសរើស តាដាក់ ជាប្រធានកងចោរព្រៃ ។ ពេលខ្វះដោយសារអាហារក្រុមរបស់យើងខ្វះខាតយើងបានស្លៀកពាក់ឯកសណ្ឋានយោធាខ្មែរក្រហម រួចទៅស្នើអង្ករពីសហករណ៍នានាមកចែកគ្នាហូប ។

នៅទីនោះ ដោយសារ តាដាក់ ធ្លាប់ដឹងពីទីតាំងយោធារបស់ខ្មែរក្រហម ទើបគាត់រៀបចំផែនការលួចកាំភ្លើងពីកងយោធាខ្មែរក្រហមបានពីរឡាន ។ បន្ទាប់មក ក្រុមរបស់យើងបានធ្វើសកម្មភាពប្លន់កាំភ្លើងពីកងឈ្លបខ្មែរក្រហមដែលយាមការពារភូមិបានជាច្រើនដើមទៀត ។ ក្រោយមក ដោយសារ តាដាក់ ខ្វះសមត្ថភាពក្នុងការគ្រប់គ្រង ក្រុមក៏ជ្រើសរើសខ្ញុំជាប្រធានវិញ ។ រហូតដល់ខែមករា ឆ្នាំ១៩៧៩ ខ្ញុំក៏ដឹកនាំក្រុមមកចុះចូលជាមួយកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ហើយស្នើសុំចេញទៅវាយខ្មែរក្រហមបន្តទៀត ។ ប៉ុន្តែកងទ័ពរណសិរ្សបានដកកាំភ្លើង

ហើយបញ្ជូនឲ្យមកហ៊ឹកហាត់នៅបន្ទាយព្រៃមាន់ ។ មួយរយៈក្រោយមក ខ្ញុំក៏រត់ចេញពីបន្ទាយមកជួបជុំឪពុកម្តាយនិងប្រពន្ធនៅស្រុកកំណើតវិញ ។ នៅក្នុងភូមិមានបុរសវៀតណាមម្នាក់បានលួចស្រឡាញ់ប្រពន្ធខ្ញុំ ឃើញដូច្នេះខ្ញុំក៏វាយបុរសនោះឲ្យមានរបួស រួចហើយនាំប្រពន្ធរត់ទៅរស់នៅជំរំដោយដាក់ពាក្យធ្វើជាបុគ្គលិកពេទ្យនៅអង្គការយូនីសេហ្វ ។ នៅឆ្នាំ១៩៨០ ប្រពន្ធខ្ញុំកើតពិសធ្ងន់ធ្ងររហូតដល់ស្លាប់ ដោយទុកឲ្យខ្ញុំចិញ្ចឹមកូនពីរនាក់តែម្នាក់ឯង ។ ក្រោយមក ដោយសារនៅជំរំខ្វះគ្រូ ទើបខ្ញុំដាក់ពាក្យបង្រៀនផ្នែកប្រវត្តិវិទ្យា និងភូមិវិទ្យា ។

នៅពេលកងទ័ពខ្មែរក្រហមធ្វើសមាហរណកម្ម ទើបខ្ញុំផ្លាស់មកធ្វើការនៅផ្នែកយុវជន (ក្រុមកាយឫទ្ធិ) នៅក្រសួងអប់រំ យុវជន និងកីឡាក្នុងក្រុងភ្នំពេញ ។ ក្រោយមក ខ្ញុំក៏ផ្លាស់ទៅបង្រៀននៅវិទ្យាល័យភ្នំសំពៅ ខេត្តបាត់ដំបងវិញ ។

## ខេត្តសៀមរាប

ប៊ុន សុផល ជាគ្រូមូលដ្ឋានមកពីអនុវិទ្យាល័យភ្លៀត ខេត្តបន្ទាយមានជ័យរៀបរាប់ទាំងកែវភ្នែករលីងលោងថា ៖ ឪពុកម្តាយខ្ញុំនិងបងប្អូនខ្ញុំចំនួនប្រាំបួននាក់ទៀតបានស្លាប់នៅក្នុងរបបខ្មែរក្រហមខ្ញុំគ្មានសល់អ្វីទាំងអស់ខ្ញុំក្លាយជាក្មេងកំព្រាចាប់តាំងពីអាយុប្រាំបួនឆ្នាំ ប៉ុន្តែខ្ញុំខំតស៊ូរៀនរហូតបានធ្វើជាគ្រូបង្រៀន ។ រយៈពេលជាងម្ភៃឆ្នាំហើយដែលខ្ញុំបាននិយាយពីការបាត់បង់សមាជិកគ្រួសារនិងរឿងរ៉ាវពិតរបស់ខ្ញុំទាំងអារម្មណ៍ក្តុកក្តួលប្រាប់ទៅសិស្សក្នុងថ្នាក់ដែលធ្វើឲ្យសិស្សជាច្រើនបានយល់ដឹងពីរបបខ្មែរក្រហម ហើយសិស្សមួយចំនួនទៀតបានយំនៅពេលស្តាប់ខ្ញុំរៀបរាប់ ។

ឪពុកម្តាយខ្ញុំមានដើមកំណើតនៅប្រទេសចិន ។ ក្រោយពីរៀបការរួច គាត់ទាំងពីរនាក់បានមករស់នៅ និងរកស៊ីលក់ការ៉េមនៅទីក្រុងភ្នំពេញ ។ ឪពុកម្តាយខ្ញុំមានកូនទាំងអស់ដប់មួយនាក់ ។ នៅឆ្នាំ១៩៧៥ យោធាខ្មែរក្រហមបានជម្លៀសគ្រួសារខ្ញុំឲ្យទៅរស់នៅភូមិទឹកជោរ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ ។ ពេលនោះ ឪពុកខ្ញុំក៏ចាប់ផ្តើមមានជំងឺធ្ងន់ធ្ងរ ហើយដោយសារនៅទីនោះគ្មានថ្នាំសម្រាប់ព្យាបាលគាត់ក៏បានស្លាប់ទៅ ។ ខ្មែរក្រហមបានឲ្យខ្ញុំនៅកងកុមារដើររើសអាចម៍គោ ធ្វើជី ចំណែកបងៗខ្ញុំទាំងអស់ត្រូវចូលធ្វើការងារនៅក្នុងកងចល័ត ។ នៅទីនោះបានពីរឆ្នាំម្តាយរបស់ខ្ញុំចាប់ផ្តើមឈឺធ្ងន់រហូតដល់ស្លាប់ ។ ក្រោយពីម្តាយខ្ញុំស្លាប់ទៅ បងៗខ្ញុំនៅកងចល័តចំនួនប្រាំមួយនាក់ក៏ឈឺស្លាប់ជាបន្តបន្ទាប់ដែរ ចំណែកបងប្រុសពីរនាក់ទៀតដែលជានិស្សិតបានបាត់ខ្លួនរហូតនៅសល់តែបងស្រីខ្ញុំម្នាក់ប៉ុណ្ណោះហើយមានជំងឺហើមខ្លួនទៀត ។

ក្រោយរបបខ្មែរក្រហមដួលរលំ ខ្ញុំនិងបងស្រីបានត្រឡប់មករស់នៅទីរួមស្រុកស្វាយស៊ីសុផុន ខេត្តបន្ទាយមានជ័យ ។ ប៉ុន្តែដោយសារគ្មានកន្លែងស្នាក់នៅ ខ្ញុំនិងបងស្រីបានទៅរស់នៅជាមួយបងស្រីជីដូនមួយម្នាក់ ។ នៅពេលនោះ ដោយគ្មានអ្នកអាចពឹងពាក់បាន ខ្ញុំបានដើរលក់បារីនៅចំណតរថយន្តនិងដើរលក់ប៉េងប៉ោះដើម្បីសន្សំលុយចូលរៀននៅសាលាបឋមសិក្សាសិរីសោភ័ណ ។ មុនពេលទៅសាលា ខ្ញុំតែងតែឆ្លៀតពេលអូសទឹកលក់ឲ្យប្រជាជនហើយពេលខ្លះខ្ញុំត្រូវយួរធុងទឹកឡើងទៅលើផ្ទះជាន់ខ្ពស់ៗទៀតផង ។


ប៊ុន សុផល

ក្រោយមក ខ្ញុំរៀនរហូតប្រឡងជាប់សញ្ញាប័ត្រទុតិយភូមិ រួចប្រឡងចូលរៀនគ្រូនៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តបាត់ដំបង ។ ក្រោយពេលរៀនចប់នៅឆ្នាំ១៩៩៧ ខ្ញុំក៏ចេញមកបង្រៀននៅវិទ្យាល័យបន្ទាយមានជ័យ ក្រោយមកទើបក្រសួងផ្លាស់ខ្ញុំឲ្យមកធ្វើជានាយកនៅអនុវិទ្យាល័យភ្លៀតវិញ ។

នៅពេលបង្រៀន ខ្ញុំតែងតែនិយាយពីការបាត់បង់សមាជិកគ្រួសារនិងរឿងរ៉ាវពិតរបស់ខ្ញុំទាំង

អារម្មណ៍ក្តុកក្តួល ប្រាប់ទៅសិស្សក្នុងថ្នាក់ពីការឈឺចាប់ ការបាត់បង់សមាជិកគ្រួសារនិងការរងទុក្ខវេទនារបស់គ្រួសារខ្ញុំ ក៏ដូចជាគ្រួសារជនរងគ្រោះកម្ពុជាទាំងអស់ដែលធ្វើឲ្យសិស្សជាច្រើនបានយល់ដឹងពីរបបខ្មែរក្រហម ហើយសិស្សមួយចំនួនទៀតបានស្រក់ទឹកភ្នែកនៅពេលស្តាប់ខ្ញុំរៀបរាប់ ។ រហូតមកដល់សព្វថ្ងៃនេះ ខ្ញុំនៅតែស្រក់ទឹកភ្នែកនិងឈឺចាប់នៅពេលរំឭកឡើងវិញពីឪពុកម្តាយ និងបងប្អូនខ្ញុំដែលបានស្លាប់ទៅ ។

## ខេត្តពោធិ៍សាត់

ខឹម ប៊ុនថៃ ជាគ្រូមូលដ្ឋានមកពីវិទ្យាល័យប្រមោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់ ។ ប៊ុនថៃ បានរៀបរាប់ថាៈ សិស្សនៅក្នុងថ្នាក់របស់ខ្ញុំភាគច្រើនជាកូនរបស់អតីតអ្នកតស៊ូខ្មែរក្រហម ប៉ុន្តែក្មេងទាំងនោះមិនបានដឹងពីរឿងរ៉ាវឪពុកម្តាយរបស់ខ្លួន និងរបបខ្មែរក្រហមទេ ដូច្នេះនៅពេលបង្រៀនម្តងៗ ខ្ញុំតែងតែនិយាយពីរឿងរ៉ាវរបស់ខ្ញុំដែលធ្វើការនៅក្នុងកងកុមារក្នុងរបបខ្មែរក្រហមប្រាប់ទៅសិស្សក្នុងថ្នាក់ជានិច្ច ទោះបីខ្ញុំមិនបង្រៀនដល់មេរៀនទាក់ទងនឹងរបបខ្មែរក្រហមដែលមាននៅក្នុងកម្មវិធីសិក្សារបស់ក្រសួងអប់រំក៏ដោយ ។

ខ្ញុំកើតនៅភូមិព្រៃកន្ទួត ឃុំតាលោ ស្រុកបាកាន ខេត្តពោធិ៍សាត់ ។ ចំណែកឪពុកម្តាយខ្ញុំជាកសិកររស់នៅភូមិទ្រាលើ ស្រុកសំរោង ខេត្តតាកែវ ។ នៅឆ្នាំ១៩៦០ បន្ទាប់ពីគាត់រៀបការរួចនិងពុំមានដីគ្រប់គ្រាន់សម្រាប់ធ្វើស្រែ ឪពុកម្តាយខ្ញុំបានសម្រេចចិត្តមកទិញដីនៅភូមិព្រៃកន្ទួត ឃុំតាលោ ស្រុកបាកាន ខេត្តពោធិ៍សាត់រស់នៅវិញ ។

ឪពុកម្តាយខ្ញុំប្រកបមុខរបរធ្វើស្រែចម្ការរហូតដល់ឆ្នាំ១៩៧០ ទើបខ្មែរក្រហមបានចូលមកដល់ភូមិព្រៃកន្ទួត បង្កើតជាក្រុមប្រវាស់ដៃ ។ ពេលនោះ ខ្មែរក្រហមអនុញ្ញាតឲ្យប្រជាជនហូបបាយនៅតាមផ្ទះរៀងៗខ្លួននៅឡើយ ។ នៅឆ្នាំ១៩៧២ ខ្មែរក្រហមចាប់ផ្តើមប្រមូលស្រូវអង្ករបស់ប្រជាជនទាំងអស់ដាក់ចូលជាសហករណ៍ និងបានដើរបំផុសបុរសនៅក្នុងភូមិឲ្យចូលរួមចលនាតស៊ូរំដោះប្រទេសពីរបប លន់ នល់ ។ ខ្មែរក្រហមបានបែងចែកប្រជាជនជាក្រុមៗ ដើម្បីធ្វើការងារនៅក្នុងភូមិ ដោយពេលនោះខ្ញុំក៏ត្រូវចូលធ្វើការនៅក្នុងកងកុមារដែរ ។ នៅថ្ងៃមួយ ពេលខ្ញុំចេញទៅឃ្វាលគោ ខ្ញុំបានឃើញអ្នកភូមិប្រហែលដប់នាក់ មកប្រជុំរួមនៅចុងភូមិនិយាយពីរឿងនយោបាយនិងចលនារំដោះប្រទេសពីរបប លន់ នល់ ។ ចំណែកគ្រួសារខ្ញុំមិនត្រូវបានហៅទៅប្រជុំជាមួយទេ ព្រោះខ្ញុំមានពូធ្វើជាទាហាននៅក្នុងទីក្រុងភ្នំពេញ ចំណែកជីតារបស់ខ្ញុំធ្លាប់ធ្វើជាទាហានបារាំង និងធ្វើជាប៉ូលិសនៅជំនាន់សង្គមរាស្ត្រនិយម ។

នៅឆ្នាំ១៩៧៣ ខ្ញុំជាមួយនឹងក្មេងៗជាច្រើននាក់ទៀតចូលរៀននៅក្រោមផ្ទះរបស់ប្រជាជន ឬក្រោមដើមឈើជាមួយគ្រូដែលខ្មែរក្រហមជ្រើសរើសចេញពីអ្នកចេះអក្សរនៅក្នុងភូមិ ។ រាល់ថ្ងៃ គ្រូបង្រៀនតែព្យញ្ជនៈនិងស្រះប៉ុណ្ណោះ ហើយក្រោយពេលរៀនចប់ខ្ញុំត្រូវដើរប្រមូលស្លឹកឈើធ្វើជី ឬទៅឃ្វាលគោ ។

នៅខែមិថុនា ឆ្នាំ១៩៧៥ ពូខាងម្តាយរបស់ខ្ញុំម្នាក់ជាជាងជួលជុលឡាននិងជាអ្នកបើកឡានឲ្យយោធាខ្មែរក្រហមនៅចម្ការចេកបានទៅយកខ្ញុំពីភូមិព្រៃកន្ទួតមករស់នៅក្នុងកងកុមារនៅវត្តលលកស ។ ប៉ុន្តែបួនខែក្រោយមក ដោយសារខ្ញុំនឹកឪពុកម្តាយខ្ញុំខ្លាំងពេក ខ្ញុំនិងបងប្អូនជីដូនមួយក៏នាំគ្នាលួចរត់ចេញពីកងទៅដើររើសដូងទុំដើម្បីដូរយកបាយប្រជាជនហូបនិងចូលដេកនៅក្នុងព្រៃ ។ ពេលឮដំណឹងនេះ ពូរបស់ខ្ញុំក៏បញ្ជូនខ្ញុំឲ្យទៅរស់នៅភូមិជាមួយឪពុកម្តាយវិញ ។ រយៈពេលមួយខែក្រោយមកទើបពូខាងឪពុករបស់ខ្ញុំម្នាក់ទៀតធ្វើទាហាននៅក្នុងទីក្រុងភ្នំពេញបានយកឡានទៅដឹកជីតា បងប្អូន និងឪពុកម្តាយខ្ញុំទាំងអស់ត្រឡប់មករស់នៅស្រុកកំណើតនៅភូមិទ្រាលើ ខេត្តតាកែវវិញ ។

មួយរយៈក្រោយមក ទើបតារបស់ខ្ញុំម្នាក់ទៀតដែលធ្វើជាប្រធានរោងចក្រកែវនៅចម្ការដូងមកប្រាប់ឪពុកម្តាយខ្ញុំនៅភូមិថា ពូរបស់ខ្ញុំត្រូវអង្គការចាប់ខ្លួនហើយ បន្ទាប់ពីគាត់ត្រឡប់មកពីភ្នំពេញបានមួយសប្តាហ៍ ដោយអង្គការចោទថា គាត់មិនអាចលះបង់មនោសញ្ចេតនាពីគ្រួសារបាននិងនៅស្រឡាញ់របបឯកជន ។ ក្រោយមកអង្គការតាមដានចាប់ខ្លួនតាខ្ញុំទៀត ព្រោះគាត់ជាអ្នកបញ្ជាឲ្យពូខ្ញុំទៅទទួលគ្រួសារខ្ញុំ ប៉ុន្តែដោយសារគាត់ជាមនុស្សចាស់ទើបគេអនុគ្រោះ ។

នៅក្នុងភូមិទ្រា អង្គការបានចាត់តាំងឪពុកខ្ញុំឲ្យចូលទៅកងដាំបន្លែ ម្តាយខ្ញុំនៅធ្វើការងារដកស្ទូងក្នុងស្រ្តី ចំណែកខ្ញុំ

នៅកងកុមាររែកកណ្តាប់និងរើសអាចម៍គោធ្វើជី ។ រហូតដល់រដូវវស្សា ឆ្នាំ១៩៧៧ ប្រធានកងបានចាត់តាំងខ្ញុំឲ្យទៅឃ្វាលគោ ។

ថ្ងៃមួយ ខ្ញុំនិងមិត្តភក្តិពីរនាក់ទៀតដឹកគោដល់ព្រៃក ក៏ឃើញដើមដំឡូងដុះនៅលើភ្លឺប្រឡាយ ។ ពេលនោះ ខ្ញុំទៅដកបានមើមទំហំប៉ុនម្រាមដៃចំនួនពីរមើមមកហូប ស្រាប់តែកងឈ្លបខ្មែរក្រហមចាប់មិត្តភក្តិខ្ញុំពីរនាក់យកទៅវាយធ្វើបាប ចំណែកខ្ញុំបានរត់គេចទៅលាក់ខ្លួននៅក្រោលគោចុងភូមិចំនួនពីរយប់ ។ ពេលនោះ ឪពុកខ្ញុំបានទៅតាមរកខ្ញុំឃើញ រួចវាយខ្ញុំយ៉ាងធ្ងន់ធ្ងររហូតធ្លាក់ឈាម ដើម្បីសម្តែងការស្មោះត្រង់ចំពោះអង្គការ ។ ក្រោយមក អង្គការបានដោះលែងខ្ញុំ រួចបញ្ជូនខ្ញុំឲ្យទៅរស់នៅភូមិសែនភាសដែលនៅជាប់នឹងមាត់បឹងរយៈពេលបួនខែ ។

នៅរដូវប្រាំង អង្គការបានអនុញ្ញាតឲ្យខ្ញុំមករស់នៅក្នុងភូមិមួយរយៈ ក៏ដាក់ផែនការបន្តឲ្យខ្ញុំ និងកុមារក្នុងភូមិទៅចាប់កណ្តុរនៅវាលស្រែប្រាំងទំនប់ត្នោតទេរឲ្យបានម្នាក់៧០ក្បាលក្នុងមួយថ្ងៃបើរកមិនបានគ្រប់ចំនួនអង្គការនឹងកាត់បន្ថយរបបអាហារ ។ នៅពេលចេញទៅរកកណ្តុរម្តងៗ ខ្ញុំតែងតែយកសត្វឆ្កែមួយក្បាលទៅជាមួយជានិច្ចព្រោះវាអាចខាំកណ្តុរបានប្រមាណជាង៣០០ក្បាលក្នុងមួយថ្ងៃ ។ ដូច្នេះខ្ញុំយកកណ្តុរដែលនៅសេសសល់ទាំងប៉ុន្មានទៅចែកឲ្យក្មេងៗដែលរកកណ្តុរមិនបាន ។

រស់នៅកងកុមារបានមួយរយៈ ខ្ញុំក៏ឮដំណឹងថាម្តាយខ្ញុំឈឺធ្ងន់ ។ ពេលនោះ ខ្ញុំបានទៅសុំប្រធានកងទៅមើលគាត់ ប៉ុន្តែប្រធានកងបដិសេធ ។ ទោះបីប្រធានកងមិនអនុញ្ញាតក៏ដោយ ក៏នៅពេលយប់ងងឹត ខ្ញុំលួចយកង្កៀតកណ្តុរនិងត្រីរស់ចំនួនពីរដែលខ្ញុំចាប់បាននៅវាលស្រែ រួចហើយរត់កាត់វាលស្រែយកទៅឲ្យម្តាយនៅមន្ទីរពេទ្យក្នុងវត្តសំរោងដែលមានចម្ងាយប្រហែលដប់គីឡូម៉ែត្រពីកងខ្ញុំ ។ មកដល់មន្ទីរពេទ្យភ្លាម ខ្ញុំមើលម្តាយពុំស្គាល់ទេ ព្រោះគាត់មានរូបរាងស្គមនៅសល់តែស្បែកដណ្តប់ឆ្អឹងប៉ុណ្ណោះ ។ ម្តាយរបស់ខ្ញុំបានសម្លឹងមកខ្ញុំ និងបានស្រែកហៅឈ្មោះខ្ញុំទើបខ្ញុំស្គាល់សំឡេងរបស់គាត់ ។ ខ្ញុំនៅសម្រាកជាមួយម្តាយរបស់ខ្ញុំរហូតដល់ម៉ោងបួនព្រឹកទើបរត់ត្រឡប់មកកងវិញ ។ ខណៈនោះ ប្រធានកងឃើញខ្ញុំ រួចសួរខ្ញុំថា មិត្តឯងទើបត្រឡប់មកពីណា? ខ្ញុំក៏ឆ្លើយកុហកថា មកពីនោម ទើបរួចខ្លួនពីការចោទប្រកាន់ ។

នៅថ្ងៃមួយពេលខ្ញុំត្រឡប់មកលេងផ្ទះ ប្រធានភូមិក៏បានមកយកឆ្កែរបស់ខ្ញុំទៅធ្វើម្ហូប ប៉ុន្តែខ្ញុំបានបដិសេធដោយលើកឡើងថា បើពូយកឆ្កែខ្ញុំទៅ ខ្ញុំមិនមានអ្វីហូបទៀតទេ ព្រោះរាល់ថ្ងៃវាចាប់កណ្តុរឲ្យខ្ញុំ ។ ទោះបីខ្ញុំនិយាយអង្វរយ៉ាងណាក៏ដោយ ក៏ប្រធានភូមិមិនស្តាប់ខ្ញុំដែរ រួចហើយគាត់ក៏ហៅឪពុកខ្ញុំពីកងដាំបន្លែមកវាយឆ្កែខ្ញុំដោយផ្ទាល់ដៃ ។ ប៉ុន្តែ ឪពុកខ្ញុំវាយមិនចំឆ្កែរបស់ខ្ញុំទេ ដោយធ្វើឲ្យវារត់ចូលព្រៃបាត់ ។ ឃើញដូច្នេះ ខ្ញុំក៏រត់ទៅតាមរកឆ្កែរបស់ខ្ញុំទាំងយប់ងងឹត ។ ព្រឹកឡើង ប្រធានកងបានបញ្ជូនខ្ញុំឲ្យទៅដាំដំឡូងមីនៅភូមិទួលវិហារជាប់ព្រំប្រទល់ខេត្តកំពង់ស្ពឺវិញ ។ មួយរយៈក្រោយមក ដោយសារនឹកម្តាយខ្លាំង ខ្ញុំក៏លួចរត់ចេញពីកង ។ នៅតាមផ្លូវប្រមាណជាងម្ភៃគីឡូម៉ែត្រ ខ្ញុំបានចូលទៅសុំដំឡូងពីអ្នកចាំចម្ការបានកន្ទះស្បោងយកមកផ្ទះ ។ ខ្ញុំមកលួចរស់នៅជាមួយម្តាយដោយមិនឲ្យប្រធានកងដឹងឡើយ ហើយរៀងរាល់ថ្ងៃម្តាយខ្ញុំតែងទៅសុំរបបពីរោងបាយមកឲ្យខ្ញុំជានិច្ច ប៉ុន្តែចុងភៅបដិសេធ ដូច្នេះគាត់ក៏រំលែករបបគាត់ពាក់កណ្តាលមកឲ្យខ្ញុំ ។

ក្រោយមក មេភូមិបានដឹងរឿងនេះ រួចហៅខ្ញុំឲ្យទៅជួបនៅផ្ទះរបស់គាត់ ហើយសួរខ្ញុំថា ហេតុអ្វីបានជាមិត្តឯងចេះតែរត់មកផ្ទះ? តើមិត្តឯងចង់ស្លាប់ឬចង់រស់? បន្ទាប់មក មេភូមិកំណត់ឲ្យខ្ញុំដើរប្រមូលអាចម៍គោឲ្យបាន៣០០គីឡូក្រាមក្នុងមួយថ្ងៃ បើប្រមូលមិនបានគ្រប់ចំនួន អង្គការមិនបើករបបឲ្យទេ ។ ដូច្នេះរាល់យប់ខ្ញុំមិនដែលដេកគ្រប់គ្រាន់ទេ ខ្ញុំតែងតែក្រោកដើរប្រមូលអាចម៍គោនៅតាមរោងចិញ្ចឹមគោឲ្យបានមុនគេ ព្រោះក្មេងនៅក្នុងភូមិខ្លះក៏អង្គការកំណត់ឲ្យធ្វើការងារដូចខ្ញុំដែរ ។ នៅពេលព្រឹក ខ្ញុំត្រូវរែកអាចម៍គោទាំងនេះ និងលាមកមនុស្សទៅចាក់លាយជាមួយដីដំបូកក្នុងរណ្តៅធំមួយ រួចហើយប្រធានកងបញ្ជាឲ្យខ្ញុំចុះទៅកូរឲ្យសព្វដើម្បីយកទៅដាក់ស្រែ ។

នៅដើមឆ្នាំ១៩៧៨ អង្គការបានជ្រើសរើសខ្ញុំ និងក្មេងៗវ័យជំទង់គ្រប់ឃុំក្នុងស្រុកសំរោងបានចំនួនពីរឡានដឹកយកទៅដាក់ពង្រាយនៅតាមបណ្តោយផ្លូវនៅខាងជើងទីរួមខេត្តតាកែវ (ផ្លូវទៅផ្ទះតាម៉ុក) ដើម្បីចាំទទួលគណៈប្រតិភូ ។ រយៈពេលមួយម៉ោង

ក្រោយមក ឡានហ្ស៊ីបមួយគ្រឿងបើកមកដល់ បន្ទាប់មកខ្ញុំឃើញនិរសារនិងមនុស្សប្រុសម្នាក់សម្បុរស (តាម៉ុក) ចុះពីលើឡានរួចសួរទៅអ្នកគ្រប់គ្រងយុវជនទាំងនេះថា តើកម្លាំងនេះបានប៉ុន្មាន? រួចហើយគាត់បន្តថា កម្លាំងនេះយកទៅបំប៉ននៅទន្លេសាបបីខែអាចវាយយួនបានហើយ ។ ក្រោយពីចប់កម្មវិធីនៅពេលយប់ អ្នកបើករថយន្តក៏ដឹកខ្ញុំនិងយុវជនទាំងអស់ទៅសម្រាកនៅអគ្គគារសោម ដោយនៅទីនោះអគ្គការចែកបាយនិង ខសាច់ជ្រូកហូបឆ្អែតគ្រប់ៗគ្នា ។ រយៈពេលបីថ្ងៃក្រោយមក អ្នកបើកបរឡានបានដឹកយុវជនទាំងនេះបន្តទៅមុខទៀត ។ ប៉ុន្តែពេលនោះខ្ញុំក៏លួចលោតចុះពីរថយន្ត រួចដើររយៈពេលពីរថ្ងៃទើបមកដល់ផ្ទះវិញ ។

នៅពេលឃើញខ្ញុំក្លាម ម្តាយខ្ញុំបានលាក់ខ្ញុំនៅក្នុងផ្ទះដោយមិនឲ្យប្រជាជនក្នុងភូមិជាមួយដឹងឡើយ ។ ប៉ុន្តែក្រោយមក ប្រធានភូមិដឹងរួចសួរខ្ញុំថា ហេតុអ្វីបានទៅកន្លែងស្រួលហើយបែជារត់មកផ្ទះវិញ? ខ្ញុំក៏ឆ្លើយប្រាប់តាមត្រង់ថា ខ្ញុំមិនអាចបែកពីម្តាយបានទេ ។ ខ្ញុំរស់នៅភូមិបានមួយខែ ប្រធានឃុំបានបញ្ជូនខ្ញុំនិងយុវជនប្រមាណ១៥០ទៀតទៅសមរភូមិភ្នំដិន ដោយពេលនោះគាត់ព្រមានខ្ញុំថា «បើឃើញឯងរត់ត្រឡប់មកភូមិម្តងទៀតនឹងយកទៅវាយចោលមិនខាន» ។ ទៅដល់ភ្នំដិន អង្គការមិនទាន់ចាត់តាំងខ្ញុំនិងយុវជនទាំងនោះទៅវាយជាមួយវៀតណាមភ្លាមទេ គឺបញ្ជូនឲ្យទៅហ្វឹកហាត់ពីវិធីសាស្ត្របាញ់កាំភ្លើងនៅបន្ទាយក្បែរដើង ។ រៀងរាល់ថ្ងៃ ខ្ញុំពួសួរគ្រាប់កាំភ្លើង និងគ្រាប់ផ្លោងកងវរំពង ដូច្នេះនៅពេលហ្វឹកហាត់ម្តងៗមេបញ្ជាការតែងតែមកនិយាយបំផុសស្មារតីឲ្យខ្ញុំនិងយុវជនក្លាហានហ៊ានលះបង់និងហ៊ានបាញ់សម្រុកវាយខ្មាំងជានិច្ច ។ ហ្វឹកហាត់បានរយៈពេលបីខែ មេបញ្ជាការក៏បញ្ជូនខ្ញុំនិងយុវជនទាំងអស់ឡើងទៅវាយវៀតណាម ។

ប៉ុន្តែនៅពេលនោះដោយសារខ្ញុំមាឌតូចមិនអាចលីកាំភ្លើងអាការួច ទើបពេលប្រយុទ្ធម្តងៗខ្ញុំអូសកាំភ្លើងទៅគងលើមែកឈើដើម្បីបាញ់ខ្មាំង ។ ចំណែកយុវជនដែលមានមាឌធំជាងខ្ញុំបន្តិច មេបញ្ជាឲ្យកាន់កាំភ្លើងបេ ។ ប៉ុន្តែដោយសារយុវជនទាំងនោះមិនមានកម្លាំងគ្រប់គ្រាន់ដើម្បីលីកាំភ្លើង ទើបត្រូវកងទ័ពវៀតណាមបាញ់ផ្តាច់ក្បាលស្លាប់អស់ជាច្រើននាក់ ។ ឃើញដូច្នេះ ខ្ញុំនិងអ្នកនៅក្នុងកងជាមួយម្នាក់ទៀតភិតភ័យយ៉ាងខ្លាំងរួចហើយក៏បោះកាំភ្លើងចោល លួចរត់ត្រឡប់មកផ្ទះវិញ ។ ខ្ញុំដើររយៈពេលដប់ថ្ងៃទើបមកដល់ផ្ទះ ។ ប៉ុន្តែ ខ្ញុំមិនឃើញប្រជាជនរស់នៅក្នុងភូមិទៀតទេ គឺឃើញតែសត្វដើរពាសពេញភូមិប៉ុណ្ណោះ ។ ពេលនោះ ខ្ញុំបានកៀងសត្វជាច្រើនយក្បាលដាក់ទ្រុង និងកើបអង្ករពីរោងសហករណ៍យកមកទុកនៅផ្ទះខ្ញុំវិញ ។ នៅពេលព្រឹកឡើងខ្ញុំឃើញប្រជាជននិងឪពុកម្តាយរបស់ខ្ញុំបានមកដល់ភូមិដោយប្រាប់ថា វៀតណាមជិតចូលមករំដោះហើយ ។ នៅពេលឮដំណឹងនេះ ប្រជាជននៅក្នុងភូមិទាំងអស់អបអរសប្បាយរីករាយយ៉ាងខ្លាំង និងរៀបចំពិធីរៀបការជាច្រើនគូនៅក្នុងភូមិ ។

ពេលដែលវៀតណាមបានដកកងទ័ពចេញអស់ ស្រាប់តែខ្ញុំឃើញកងឈ្លបខ្មែរក្រហមប្រាំមួយនាក់ចូលមកចាប់អ្នកដែលបានរៀបការទាំងអស់នោះ និងប្រជាជនរស់នៅដើមភូមិមួយចំនួនយកទៅវាយសម្លាប់ និងអារកជាមួយនឹងកាំបិតត្នោតនៅវាលស្រែ ។ ព្រឹកឡើង ខ្ញុំចេញទៅឃ្វាលគោក៏ឃើញឈ្លបខ្មែរក្រហមកំពុងរត់ឆ្ពៃឆ្ពានៅមាត់ព្រៃក្បែរភូមិ មួយសន្ទុះក្រោយមកខ្ញុំក៏ឮសំឡេងវាយប្រយុទ្ធគ្នាផ្ទុះឡើង ទើបគ្រួសារខ្ញុំបានរួចពីការសម្លាប់ ។

ខ្ញុំរស់នៅជាមួយឪពុកក្នុងភូមិទ្រាវហូតដល់ឆ្នាំ១៩៨០ ទើបខ្ញុំយកឆ្អែរបស់ខ្ញុំមករស់នៅជាមួយពូក្នុងទីក្រុងភ្នំពេញ ។ ខ្ញុំបានចូលរៀននៅវិទ្យាល័យព្រះស៊ីសុវត្ថិ រួចប្រឡងចូលរៀនផ្នែកគ្រូ ។ បន្ទាប់ពីរៀនចប់ ក្រសួងបានចាត់តាំងឲ្យខ្ញុំទៅបង្រៀននៅវិទ្យាល័យប្រមោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់ ។

នៅពេលបើកវគ្គបណ្តុះគ្រូបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យម្តងៗ មានគ្រូប្រវត្តិសាស្ត្រមកពីខេត្តផ្សេងៗបានជួបជុំគ្នានិងបានរៀបរាប់ពីបទពិសោធន៍ខុសៗគ្នារបស់គាត់ដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហម ចំណែកគ្រូមួយចំនួនដឹងតាមរយៈឪពុកម្តាយរបស់គាត់និយាយរៀបរាប់ប្រាប់គ្នាទៅវិញទៅមក ។ ការរៀបរាប់នេះបានរំឭកឡើងវិញនូវអ្វីដែលលោកគ្រូអ្នកគ្រូបានចងចាំ ហើយបានរួមចំណែកយ៉ាងសំខាន់ក្នុងការថែរក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនិងការផ្សះផ្សាជាតិ ។

**សោម ប៊ុនថន**

# សំឡេងរបស់អ្នកដាក់ពាក្យបណ្តឹងទៅ អ.វ.ត.ក : ដប់ថ្ងៃនៅជាមួយក្រុមជួយជនរងគ្រោះដាក់ពាក្យបណ្តឹងទៅតុលាការនៅខេត្តកំពង់ធំ និងសៀមរាប

ពីថ្ងៃទី២១ដល់៣១ ខែឧសភា ខ្ញុំបានចូលរួមជាមួយសមាជិកក្រុមជួយជនរងគ្រោះដាក់ពាក្យបណ្តឹងទៅតុលាការរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាចំនួនប្រាំបីនាក់ហើយធ្វើដំណើរទៅភាគខាងជើងនៃប្រទេសកម្ពុជាគឺខេត្តកំពង់ធំនិងសៀមរាប ។

គោលបំណង ក្នុងដំណើរនេះគឺដើម្បីប្រគល់លិខិតជូនដំណឹងពីការិយាល័យសហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ទៅឲ្យអ្នកដាក់ពាក្យបណ្តឹងនៅតំបន់ទាំងនេះ ។ អ្នក ដាក់ពាក្យបណ្តឹងគឺជាអ្នកនៅរស់ពីរបបកម្ពុជាប្រជាធិបតេយ្យដែលបានដាក់ពាក្យបណ្តឹងប្រឆាំងនឹងខ្មែរក្រហមតាំងពីពីរឆ្នាំមុនម៉្លេះ ។ លិខិតរបស់ អ.វ.ត.ក បានជូនដំណឹងទៅកាន់អ្នកដាក់ពាក្យបណ្តឹងថា តុលាការបានទទួលពាក្យបណ្តឹងរបស់អ្នកទាំងនោះអរគុណអ្នកទាំងនោះចំពោះការរួមវិភាគទាននិងប្រាប់អ្នកទាំងនោះ អំពីដំណើរការរបស់តុលាការដែលបានមកពីលទ្ធផលនៃការរួមវិភាគទានរបស់អ្នកទាំងនោះ ។ នៅអំឡុងពេលដប់ថ្ងៃនេះក្រុមជួយជនរងគ្រោះដាក់ពាក្យបណ្តឹងទៅតុលាការបានធ្វើបទសម្ភាសន៍ដោយថតជាសំឡេងនិងវីដេអូជាមួយអ្នកភូមិដែលចង់ឲ្យបទពិសោធន៍និងទស្សនៈគាត់ត្រូវបានបង្រួតទុក ។

គោលដៅផ្ទាល់របស់ខ្ញុំ គឺដើម្បីដឹកនាំការធ្វើបទសម្ភាសន៍ជាមួយអ្នកដាក់ពាក្យបណ្តឹងដើម្បីសិក្សាបន្ថែមថាតើអ្នកទាំងនោះយល់យ៉ាងដូចម្តេចចំពោះដំណើរការកាត់សេចក្តីនៅ អ.វ.ត.ក បទពិសោធន៍ផ្ទាល់ខ្លួនរបស់អ្នកទាំងនោះនៅអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ និងចង់ដឹងពីទស្សនៈរបស់អ្នកទាំងនោះចំពោះយុត្តិធម៌ ការដាក់ទោសនិងការអភ័យទោស ។ គោលបំណងគឺដើម្បីយល់ដឹងកាន់តែច្បាស់ថាតើតុលាការមានអត្ថន័យយ៉ាងដូចម្តេចចំពោះអ្នកដែលនៅរស់ តើអ្នកទាំងនោះយល់ដឹងពីដំណើរការនីតិវិធីដល់កម្រិតណា និងពិនិត្យទៅលើទស្សនៈបុគ្គលម្នាក់ៗចំពោះយុត្តិធម៌និងការផ្សះផ្សាសង្គម ។

ក្រុមជួយជនរងគ្រោះដាក់ពាក្យបណ្តឹងទៅតុលាការបានដែលត្រូវចំណាយពេលបីម៉ោងកន្លះក្នុងការបើកបរពីភ្នំពេញទៅភាគខាងជើងមានលក្ខណៈពិសេសដោយសារតែវាជាស្រុកកំណើតរបស់ ការំង ហ្កេកអ៊ាវ ហៅ ឌុច និង សាឡុត ស ដែលស្គាល់ជាប៉ុល ពត ។ ខេត្តនេះមានឈ្មោះល្បីដោយសារទំនប់ដែលត្រូវបានសាងសង់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ទំនប់នេះកើតឡើងដោយសារការបង្ខំឲ្យធ្វើពលកម្ម ការបង្អត់អាហារ និងការធ្វើបាបជាច្រើននៅក្នុងអំឡុងរបបខ្មែរក្រហម ។ នៅអំឡុងពេលធ្វើការយើងបានធ្វើដំណើរជុំវិញខេត្តកំពង់ធំនិងសៀមរាបដោយចូលទៅដល់ភូមិផ្សេងៗគ្នាជារៀងរាល់ថ្ងៃ ។ យើងតែងតែជួបជាមួយអ្នកដាក់ពាក្យបណ្តឹងនៅផ្ទះរបស់មេភូមិ ។

នៅក្នុងការប្រជុំ យើងអាចនាំយកនូវសេចក្តីជូនដំណឹងពី អ.វ.ត.ក សៀវភៅណែនាំអំពីករណី ០០២ លិខិតពីលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ព្រមទាំងទឹកដាច្រើនដប ។ ទាំងនេះគឺជាការងាររដដែលៗដែលយើងត្រូវរៀបចំសម្រាប់ប្រាំបួនថ្ងៃបន្ទាប់ នោះគឺជាការរៀបចំការពិភាក្សាអំពី អ.វ.ត.ក និងខ្មែរក្រហម ។

ប្រធានក្រុមលោក ដី ទេរិទ្ធិ គឺជាវាគ្មិនសំខាន់នៅក្នុងកិច្ចប្រជុំ ។ បន្ទាប់ពីចូលរួម លោកបានចាប់ផ្តើមកិច្ចប្រជុំដោយសួរទៅអ្នកភូមិថាតើអ្នកទាំងនោះនៅចាំមជ្ឈមណ្ឌលឯកសារកម្ពុជានិងការដាក់ពាក្យបណ្តឹងប្រឆាំងនឹងខ្មែរក្រហមដែរឬទេ ។ អ្នកដាក់ពាក្យបណ្តឹងភាគច្រើនដែលយើងបានជួបនៅចងចាំមជ្ឈមណ្ឌលឯកសារកម្ពុជា ប៉ុន្តែប្រជាជនជាច្រើនផ្សេងទៀតបានភ្លេចនូវពាក្យបណ្តឹងដែលខ្លួនបានបំពេញកាលពីឆ្នាំ២០០៨ ។ នៅថ្ងៃទីបី ស្ត្រីម្នាក់បានប្រាប់យើងអំពីការភ្លេចភ្លាំងរបស់គាត់បណ្តាលមកពីរវល់ការងារ ។ គាត់បានសួរទៅក្រុមគម្រោងជួយជនរងគ្រោះដាក់ពាក្យបណ្តឹងទៅតុលាការថា «តើយើងអាចតាមដាននូវអ្វីដែល

កំពុងតែកើតឡើងយ៉ាងដូចម្តេចបានប្រសិនបើយើងត្រូវចំណាយពេលពេញមួយថ្ងៃដើម្បីឃ្វាលក្របីនោះ ។ អ្នកភូមិជាច្រើនដែលយើងបាននិយាយជាមួយបានសង្កត់ធ្ងន់អំពីជីវភាពលំបាក និងខ្វះខាតរបស់ខ្លួនដើម្បីបញ្ជាក់ពីហេតុផលថាហេតុអ្វីបានជាពួកគាត់មិនអាចតាមដានដំណើរការជំនុំជម្រះ ។ ទោះបីជាអ្នកភូមិភាគច្រើនមានលទ្ធភាពអាចមើលទូរទស្សន៍និងស្តាប់វិទ្យុក៏ដោយ ប៉ុន្តែពួកគាត់ត្រូវចំណាយពេលជាច្រើនដើម្បីគ្រួសារ ។ នៅក្នុងបរិបទនេះមជ្ឈមណ្ឌលឯកសារកម្ពុជាបានដើរតួនាទីយ៉ាងសំខាន់ក្នុងការភ្ជាប់ទំនាក់ទំនងរវាងប្រព័ន្ធច្បាប់ និងជនរងគ្រោះ ។

## ការប្រាប់ប្រជាជនអំពី អ.វ.ត.ក និង ករណី០០២

បន្ទាប់ពីបានរំឭកជនរងគ្រោះអំពីមជ្ឈមណ្ឌលឯកសារកម្ពុជា និងពន្យល់អំពីគោលបំណងនៃការជួបប្រជុំ លោក ជី ទេរិទ្ធិ ចាប់ផ្តើមនិយាយអំពីប្រវត្តិរបស់មេដឹកនាំខ្មែរក្រហមដែលត្រូវកាត់ទោសក្នុងករណី០០២ ។ ចំពោះអ្នកដាក់ពាក្យបណ្តឹងជាច្រើនការឃើញរូបថតរបស់ នួន ជា, អៀង សារី, អៀង ធីរិទ្ធ និង ខៀវ សំផន គឺជាលើកដំបូងដែលធ្វើឲ្យគាត់ស្គាល់ឈ្មោះរបស់អ្នកទាំងនោះ ។ ស្រុកស្មោងជាកន្លែងដែលយើងស្នាក់ពីរបីថ្ងៃដំបូងគឺជាទីកន្លែងកំណើតរបស់ ឌុច ។ ក្រុមគម្រោងជួយជនរងគ្រោះដាក់ពាក្យបណ្តឹងទៅតុលាការបានសួរទៅក្រុមអ្នកដាក់ពាក្យបណ្តឹងដែលរស់នៅតំបន់នោះថាតើពួកគាត់ធ្លាប់ស្គាល់ ឬដែលឃើញ ឌុច ឬទេ? ទោះបីជាមានអ្នកធ្លាប់ស្គាល់ឈ្មោះ ឌុច ប៉ុន្តែមានអ្នកខ្លះទៀតមិនចាំថាខ្លួនធ្លាប់ឃើញ ឌុច ទេ ។ យើងបានជួបជាមួយមេភូមិដែលនិយាយថា គាត់ធ្លាប់ស្គាល់ និងឃើញ ឌុច ។



អ្នកភូមិកំពុងអានសំបុត្រពី អ.វ.ត.ក

បន្ទាប់ពីបកស្រាយថាតើ អ.វ.ត.ក កំពុងធ្វើអ្វី និងសង្ខេបពីករណី០០២ ក្រុមការងារបានចែកលិខិតដែលមកពីការិយាល័យសហព្រះរាជអាជ្ញាដល់អ្នកដាក់ពាក្យបណ្តឹង ។ បន្ទាប់ពីទទួលលិខិតនោះ អ្នកដាក់ពាក្យបណ្តឹងម្នាក់ៗតម្រូវឲ្យបំពេញបែបបទមួយដើម្បីបញ្ជាក់ថាអ្នកដាក់ពាក្យបណ្តឹងនោះបានទទួលលិខិតនោះហើយ ។ អ្នកដាក់ពាក្យបណ្តឹងភាគច្រើនមិនចេះអក្សរ ដូច្នេះក្រុមការងារបានជួយអានលិខិតជូនដំណឹងពីតុលាការ និងជួយអ្នកទាំងនោះបំពេញបែបបទថែមទៀត ។ ជាលទ្ធផលនៃការរស់នៅក្នុងសង្គ្រាម និងអស្ថិរភាពជាច្រើនទសវត្សរ៍ មនុស្សនៅជំនាន់នេះទទួលការអប់រំតិចតួច ឬមិនដែលទទួលបានការអប់រំជាផ្លូវការឡើយ ។

## របកគំហើញតាមរយៈសម្ភាសន៍

អ្នកដាក់ពាក្យបណ្តឹងមកពីខេត្តកំពង់ធំ និងសៀមរាបតែងតែស្វាគមន៍នូវការធ្វើបទសម្ភាសន៍ ។ ទស្សនៈនិងយោបល់ផ្ទុយគ្នាដែលបានមកពីបទសម្ភាសន៍អាចបង្ហាញថា អ្នកផ្តល់បទសម្ភាសន៍បើកចំហនូវអារម្មណ៍របស់ខ្លួន ។ អ្នកភូមិខ្លះបានចែករំលែកបទពិសោធន៍ជាច្រើនរបស់គាត់ អ្នកភូមិជាច្រើនទៀតបានប្រាប់យើងអំពីពេលវេលាដែលលំបាកនិងអាក្រក់ជាងគេ ។ ស្របនឹងអ្វីដែលត្រូវបានរកឃើញ ដោយលោក ជី ទេរិទ្ធិ អ្នកដាក់ពាក្យបណ្តឹងមានសេចក្តីរីករាយនឹងទទួលបានការជូនដំណឹងនិងមានអារម្មណ៍ថាខ្លួនមានសំឡេងនៅក្នុងការកាត់សេចក្តីដែរ ។

តាមរយៈបទសម្ភាសន៍ចំនួន១៥អាចបង្ហាញយ៉ាងច្បាស់ថា អ្នកដាក់ពាក្យបណ្តឹងមានទស្សនៈផ្សេងគ្នាទៅលើការដាក់ទោស ។ ដោយឃើញនៅក្នុងករណីជាច្រើន អ្នកភូមិបាននិយាយថាបានអភ័យទោសឲ្យខ្មែរក្រហម ។ នេះគឺជំនឿរបស់ ពត សម ដែលជា

ស្ត្រីអាយុ៥៦រស់នៅខេត្តសៀមរាប ។ ឪពុកម្តាយរបស់គាត់ត្រូវបានសម្លាប់ ។ គាត់បាននិយាយថា «មិនត្រូវសងសឹកទេ ។ ភ្លាមៗបន្ទាប់ពីរបបខ្មែរក្រហមដួលរលំ ខ្ញុំនៅតែខឹងនៅឡើយ ប៉ុន្តែក្រោយមក ខ្ញុំបានប្រណិប័តន៍តាមព្រះពុទ្ធសាសនាដើម្បីបន្ធូរកំហឹងវិញ ។ ខ្ញុំគ្រាន់តែមិនចង់ឲ្យរបបខ្មែរក្រហមកើតឡើងម្តងទៀតប៉ុណ្ណោះ» ។

មាស គីនយន់ ដែលជាស្ត្រីម្នាក់អាយុ៦០ឆ្នាំខេត្តកំពង់ធំគឺជាអ្នកជឿទៅលើព្រះពុទ្ធសាសនា ហើយជឿថា «ត្រូវតែមានយុត្តិធម៌» ។ គាត់បានប្រាប់ក្រុមការងារថា ជនត្រូវចោទដែលជាអតីតខ្មែរក្រហម «មិនបានឆ្លើយនឹងសំណួរទាំងអស់ទេ» ។ គីនយន់ក៏ដូច ពត សម និងអ្នកផ្តល់បទសម្ភាសន៍ផ្សេងទៀតដែរ គាត់មិនបានចាត់ទុកថាកំហឹងគឺជាការឆ្លើយតបដ៏សមស្របមួយទេ ។ ប៉ុន្តែគីនយន់ ដែលជាស្ត្រីម្នាក់ដែលមានសាច់ញាតិជាច្រើនស្លាប់ក្នុងរបបខ្មែរក្រហមនៅតែមានជំងឺផ្លូវចិត្ត ។ គាត់បានប្រាប់យើងថា ចាប់តាំងពីរបបខ្មែរក្រហមដួលរលំគាត់នៅតែរស់នៅក្នុងភាពភ័យខ្លាចជានិច្ច ។ គាត់បាននិយាយថា «វាគ្មានហេតុផលអ្វីដែលធ្វើឲ្យគាត់ភ័យខ្លាចទៀតទេ ប៉ុន្តែនោះគឺជាភាពភ័យខ្លាចនៅក្នុងចិត្តរបស់គាត់» ។

យិន យ៉ាត បុរសអាយុ ៦៥ឆ្នាំ ជាអតីតប្រធានភូមិដូនល្អ បាននិយាយថា គាត់មានសេចក្តីរីករាយដែល អ.វ.ត.ក នឹង «ជួយប្រជាជនស្វែងរកឃាតករ» ។ គាត់បានបន្តទៀតថា គាត់ «សង្ឃឹមថា អ.វ.ត.ក នឹងស្វែងរកឃាតករខ្មែរក្រហមបន្ថែមដើម្បីធ្វើឲ្យអ្នកទាំងនោះទទួលនូវអ្វីដែលគេគួរតែទទួល» ។ គាត់យល់ឃើញថា ការកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដែលត្រូវបានពន្យារពេលដ៏យូរនឹងនាំយកយុត្តិធម៌ទៅឲ្យជនរងគ្រោះ ។ ការធ្វើបែបនេះគឺមិនត្រឹមតែដើម្បីដាក់ទោសអតីតមេដឹកនាំដែលបានប្រព្រឹត្តអំពើដែលសាហាវឃោរឃៅប៉ុណ្ណោះទេ តែថែមទាំងដើម្បីបង្ហាញជាផ្លូវការថា អ្នកទាំងនោះជាអ្នកណា ហើយបានធ្វើអ្វីខ្លះទៀតផង ។

មានប្រជាជនមួយចំនួនមិនបានផ្តល់យោបល់អ្វីទៅលើសំណួរដែលទាក់ទងនឹងអ.វ.ត.ក និងការកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមឡើយ ។ អ្នកទាំងនោះគ្រាន់តែនិយាយថា «វាអាស្រ័យទៅលើតុលាការ» សម្រេចថានឹងធ្វើអ្វី ។ វាមិនមានភាពច្បាស់លាស់ថាតើការឆ្លើយតបបែបនេះបង្ហាញពីការជឿទុកចិត្តទៅលើតុលាការ ការមិនជឿទុកចិត្ត ការដកខ្លួនមិនចូលរួមក្នុងដំណើរការនីតិវិធី ឬការបញ្ចៀសមិនចង់បង្ហាញពីអារម្មណ៍របស់ខ្លួនទេ ។

ការរកឃើញដ៏គួរឲ្យចាប់អារម្មណ៍មួយគឺថា អ្នកនៅរស់ភាគច្រើនមិនចង់ឲ្យមានការកាត់ទោសសមាជិកខ្មែរក្រហមទេ ។ ខណៈពេលដែលអ្នកដាក់ពាក្យបណ្តឹងទាំងអស់មានអារម្មណ៍ពេញចិត្តថា នៅទីបញ្ចប់ មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមនឹងត្រូវបានកាត់ទោស មានតែអ្នកផ្តល់បទសម្ភាសន៍បីនាក់ក្នុងចំណោមអ្នកផ្តល់បទសម្ភាសន៍១៥នាក់ប៉ុណ្ណោះដែលចង់ឲ្យមានការកាត់ទោសមេដឹកនាំខ្មែរក្រហមបន្ថែម ។ បុរសម្នាក់ឈ្មោះ គ្រូច នឿម មកពី សង្កាត់ស្រងែ (ក្រុងសៀមរាប) បាននិយាយថា ការមិនគាំទ្រឲ្យកាត់ទោសខ្មែរក្រហមបន្ថែមគឺដោយសារតែ «នៅមានអតីតខ្មែរក្រហមជាច្រើនរស់នៅក្នុងស្រុកនេះ ។ អ្នកទាំងនោះសុទ្ធតែទទួលបញ្ជាពីថ្នាក់លើ ដូច្នេះតុលាការមិនគួរកាត់ទោសអ្នកទាំងនោះទេ» ។

ការផ្តោតមួយទៀតទៅលើបទសម្ភាសន៍គឺការអប់រំអំពីប្រល័យពូជសាសន៍និងខ្មែរក្រហម ។ ខ្ញុំបានសួរអ្នកផ្តល់បទសម្ភាសន៍ទាំងអស់ថាតើអ្នកទាំងនោះមានបានដើរតួនាទីជាអ្នកអប់រំប្រជាជនអំពីរបបកម្ពុជាប្រជាធិបតេយ្យដែរឬទេ ។ អ្នកដាក់ពាក្យបណ្តឹងភាគច្រើនបាននិយាយថាគាត់បានរួមចំណែកតាមរយៈការចែករំលែកបទពិសោធន៍ផ្ទាល់ខ្លួនដែលគាត់ប្រាប់ទៅសាច់ញាតិនិងគ្រួសាររបស់គាត់ ។ យិន យ៉ាត និង ប៊ុត បាន បានសង្កត់ធ្ងន់ពីសារសំខាន់នៃការអប់រំពីអ្វីដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហមនៅក្នុងភូមិរបស់គាត់ ។ យិន យ៉ាត ដែលរស់នៅក្នុងភូមិដូនល្អបានប្រាប់ទៅក្រុមការងារថាការពិភាក្សាអំពីខ្មែរក្រហមគឺជាផ្នែកសំខាន់មួយនៃការជួបប្រជុំនៅក្នុងភូមិ ។ គាត់បាននិយាយថា «ខ្ញុំតែងតែលើកឡើងពីបញ្ហានៃការសម្លាប់នៅរាល់ពេលប្រជុំនៅក្នុងភូមិម្តងៗ ។ នៅអំឡុងពេលប្រជុំ ខ្ញុំបានសួរទៅអ្នកទាំងនោះអំពីការអភិវឌ្ឍជាវិជ្ជមានដែលកើតមានឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ យើងបានពិភាក្សាថាតើការពិភាក្សាអាក្រក់ដោយរបៀបណា ។ ភាពរីកចម្រើនមានសភាពគួរឲ្យកត់សម្គាល់ ហើយមានការអភិវឌ្ឍជាច្រើននៅក្នុងភូមិ» ។

ការអភិវឌ្ឍដែល យិន យ៉ាត បាននិយាយគឺការរស់នៅ ផ្លូវ ផ្ទះ និងសាលារៀននៅក្នុងមួយដែរ ។ ប៊ុត បានប្រធានភូមិសំព្រោចបានប្រាប់យើងថា «ការអប់រំនៅសាលារៀនមានសារសំខាន់បំផុត» ។ ចំពោះសំណួរដែលទាក់ទងនឹងការអប់រំអំពីរបបខ្មែរក្រហមនៅក្នុងសាលារៀននៅក្នុងភូមិគាត់បានប្រាប់ក្រុមការងារថា «មានគ្រូបង្រៀនម្នាក់នៅក្នុងសាលារៀនបាននិយាយអំពីរបបកម្ពុជាប្រជាធិបតេយ្យហើយវាពិតជាមានប្រសិទ្ធភាពមែន» ។ នេះគឺជាដំណឹងល្អដែលថាមជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងតែផ្តួចផ្តើមគំនិតអំពីការអប់រំអំពើប្រល័យពូជសាសន៍ ។

ទោះបីជាមានចំណុចវិជ្ជមាននិងការចង់បង្រៀនក្មេងៗអំពីខ្មែរក្រហមក៏ដោយ ក៏ក្មេងៗនៅខេត្តកំពង់ធំ និងសៀមរាបនៅតែមានចម្ងល់និងមិនជឿដដែល ។ មិនត្រឹមតែមានក្មេងជាច្រើនមិនដឹងពីអ្វីដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហមប៉ុណ្ណោះទេ តែមានក្មេងៗជាច្រើនទៀតមិនទាំងជឿថារឿងរ៉ាវដែលអ្នកជំនាន់មុនប្រាប់ពួកគេជារឿងមិនពិតទៀតផង ។ អ្នកដាក់ពាក្យបណ្តឹងមួយចំនួនបាននិយាយថា ក្មេងៗឬសូម្បីតែខ្លួនគាត់ផ្ទាល់ក៏មិនហ៊ានជឿទៅលើអ្វីដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែរ ។

នៅពេលដែលយើងសួរថាហេតុអ្វីមានការបកស្រាយពន្យល់ផ្សេងៗគ្នា ។ នៅពេលប្រជុំមួយ ស្ត្រីម្នាក់បាននិយាយថា «វាមានការលំបាកសម្រាប់ឲ្យក្មេងៗជឿទៅលើរឿងរ៉ាវដែលបានកើតឡើងពីព្រោះមនុស្សវ័យចំណាស់អាចនឹងប្រាប់អ្នកទាំងនោះពីរឿងអ្វីក៏បាន» ។ សាំង សំហោ រស់នៅស្រុកស្ទោង ខេត្តកំពង់ធំ និយាយថា «វាដោយសារតែក្មេងជំនាន់ក្រោយមិនបានឃើញរឿងទាំងនេះដោយផ្ទាល់ ។ បច្ចុប្បន្ន អ្នកទាំងនេះរស់នៅដោយសុខសប្បាយ ដូច្នេះគេមិនជឿលើអ្វីដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហមទេ» ។ នេះប្រហែលជាដោយសារតែគាត់មិនអាចធ្វើឲ្យក្មេងៗជឿថារឿងរ៉ាវរបស់គាត់គឺជាការពិត ។ ក្រោយមកគាត់និយាយថា «តួនាទីក្នុងការអប់រំក្មេងៗស័ក្តិសមនឹងធ្វើឡើងដោយអង្គការនៅក្រៅប្រទេសនិងរដ្ឋាភិបាល» ។ អ្នកនៅរស់ជាច្រើនជឿថា ក្មេងៗជំនាន់ក្រោយមិនអាចជឿលើរបបកម្ពុជាប្រជាធិបតេយ្យទេ ពីព្រោះក្មេងៗជំនាន់ក្រោយមិនបានជួបប្រទះដោយផ្ទាល់ ។

ទោះបីជាយ៉ាងណាក៏ដោយ នៅតែមានមធ្យោបាយជាច្រើនដែលធ្វើឲ្យក្មេងជំនាន់ក្រោយជឿថាពិតជាមានខ្មែរក្រហមហើយខ្មែរក្រហមពិតជាបានប្រព្រឹត្តអំពើព្រៃផ្សៃមែន ។ អ្នកផ្តល់បទសម្ភាសន៍ ពត សម បាននិយាយថា «មិនជឿខ្ញុំ ប៉ុន្តែនៅពេលដែលអ្នកទាំងនោះឃើញអ្វីដែលខ្ញុំបាននិយាយនៅក្នុងទូរទស្សន៍ក្មេងៗនឹងជឿ» ។

ប្រធានភូមិ ប៊ុត បាន បានរកឃើញមធ្យោបាយផ្សេងដើម្បីបង្ហាត់បង្រៀនក្មេងជំនាន់ក្រោយ «ក្មេងៗមិនជឿទាំងស្រុងទៅលើអ្វីដែលយើងបាននិយាយទេ ដូច្នេះយើងផ្តល់ជាឧទាហរណ៍ឲ្យអ្នកទាំងនេះដូចជាទំនប់ដែលបង្កើតឡើងនៅក្នុងរបបខ្មែរក្រហមនិងព័ត៌មានដែលបានមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ។ នៅពេលដែលក្មេងៗឃើញក្មេងៗទាំងនោះនឹងចាប់ផ្តើមជឿ» ។

មានប្រភពជាច្រើនដែលអាចយកមកបង្រៀនក្មេងៗអំពីកម្ពុជាប្រជាធិបតេយ្យដូចជា ៖ សាលារៀន រឿងរ៉ាវរបស់គ្រួសារ ពិធីរំឭក ដូចជា (ទិវាចងកំហឹងទី២០ឧសភា) ការប្រជុំភូមិ ទូរទស្សន៍និងវិទ្យុ និងការផ្តួចផ្តើមពីអង្គការក្រៅរដ្ឋាភិបាល ។ ប្រភពទាំងនេះនឹងបន្តដំណើរការនិងផ្សព្វផ្សាយអំពីរបបកម្ពុជាប្រជាធិបតេយ្យទៅដល់ក្មេងៗនៅកម្ពុជា ។

## ***សេចក្តីសន្និដ្ឋាន***

ក្រុមជួយជនរងគ្រោះដាក់ពាក្យបណ្តឹងទៅតុលាការរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាមានជំនាញក្នុងការរៀបចំដំណើរការទំនាក់ទំនងជាមួយអ្នកភូមិ និងបង្កើតជាបរិយាកាសល្អនិងសមរម្យ ។ ជាមួយនឹងការចេញសាលក្រមទៅលើករណី ឌុច នៅថ្ងៃទី២៦ ខែកក្កដា ការជូនដំណឹងរបស់តុលាការគឺជាការរំឭកដល់អ្នកប្តឹងរឿងរ៉ាវរបស់ពួកគេគឺជាហេតុផលដែលធ្វើឲ្យការកាត់ទោសសម្រេចទៅបាន ។ របបខ្មែរក្រហមបានកន្លងហួសជាងសាមសិបឆ្នាំមកហើយប៉ុន្តែអ្នកភូមិដែលខ្ញុំបានសម្ភាសន៍នៅតែជឿថា ការជំនុំជម្រះនៅតែមានសារសំខាន់ ។ វាគឺជាដំណើរដ៏វែងឆ្ងាយមុននឹងឆ្ពោះទៅដល់ដំណើរនីតិវិធី ប៉ុន្តែអ្នកដាក់ពាក្យបណ្តឹងដែលនៅរស់ជាច្រើននឹងឃើញលទ្ធផលនៃសក្ខីកម្មរបស់ពួកគេ ។

**យ៉ានីក ស្ទីត**

# អតីតពេទ្យស្រុកគីរីវង្ស

ជាទូទៅមេដឹកនាំប្រទេសជាច្រើនបានយកចិត្តទុកដាក់យ៉ាងខ្លាំងលើសេវាសុខាភិបាលសាធារណៈនិងជំរុញឲ្យសិស្សនិសិត្សអ្នកវិទ្យាសាស្ត្រ និង ស្ថាប័នពេទ្យ ស្រាវជ្រាវលើផ្នែកវេជ្ជសាស្ត្រទំនើបដើម្បីបម្រើដល់សុខភាពប្រជាជន ។

នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យមេដឹកនាំប្រទេសបានបង្ខំឲ្យប្រជាជនធ្វើការជាទម្ងន់តែមិនបានផ្តល់អាហារឲ្យហូបគ្រប់គ្រាន់ព្រមទាំងសម្លាប់អ្នកចេះដឹងនិងគ្រូពេទ្យស្ទើរតែទាំងអស់ហើយបែរជាជ្រើសរើសយកកូនកសិករក្មេងៗដែលភាគច្រើនជានារីនិងមិនចេះអក្សរមកធ្វើពេទ្យជំនួសវិញ ។


ប៉ាំ ញ៉ាន

ប៉ាំ ញ៉ាន មិនបានចូលរៀននៅសាលាទាល់តែសោះប៉ុន្តែគាត់បានចូលបម្រើពេទ្យខ្មែរក្រហមតាំងពីឆ្នាំ១៩៧២ ។ ញ៉ាន រៀបការប្តី ឈ្មោះ ស៊ុម សំម៉ន នៅឆ្នាំ១៩៦៨តាមការទុកដាក់របស់ឪពុកម្តាយ ។ នៅពេលរដ្ឋប្រហារឆ្នាំ១៩៧០ សំម៉ន បានរត់ចូលព្រៃម៉ាគីតាមការអំពាវនាវរបស់សម្តេចសីហនុតាមវិទ្យុពីប៉េកាំង ។ នៅពាក់កណ្តាល ឆ្នាំ១៩៧២ សំម៉ន បានដឹកនាំកងទ័ពខ្មែរក្រហមមួយក្រុមចូលមកបោះទីតាំងនៅក្នុងវត្តអង្គជ័យ ។ រហូតដល់ម៉ោង៦ល្ងាច បន្ទាប់ពី ព្យុះស្គរផ្ទុះអាវុធចេញពីក្នុងវត្តហើយ ទើបនិរសាររបស់ប្តី ញ៉ាន មក ប្រាប់ ញ៉ាន ថា «ប្តីរបស់គាត់ត្រូវព្រះសង្ឃក្នុងវត្តបាញ់សម្លាប់ហើយ» ។ ក្រោយពីស្លាប់ប្តីមក អង្គការបានលើកទឹកចិត្ត ញ៉ាន ឲ្យចូលបម្រើបដិវត្តន៍ដោយមានតួនាទីជានារីពេទ្យប្រចាំស្រុកគីរីវង្សដែលមានបុគ្គលិកពេទ្យទាំងអស់ប្រមាណជា២៦នាក់ក្នុងនោះមានពេទ្យប្រុសប្រាំពីរនាក់ផងនៅក្រោមឱវាទ ។

នៅទីនោះ ញ៉ាន មានតួនាទីព្យាបាលជំងឺឲ្យយោធាដែលរបួសប៉ុន្តែពុំសូវសម្បូរថ្នាំពេទ្យល្អៗសម្រាប់ព្យាបាលទេ ហើយពេលខ្លះ ពេទ្យបានឡើងបេះផ្លែដូងដើម្បីយកមកព្យាបាលឲ្យអ្នកជំងឺជំនួសឲ្យសេរ៉ូមទៀតផង ។ ដោយសារខ្វះខាតថ្នាំដូច្នេះ ទើបនារីពេទ្យបានផលិតថ្នាំគ្រាប់ដែលផ្សំពីឫសឈើព្រៃ គ្រាប់ស្លែង មើមក្តួច ដំឡូងមីយកទៅត្រាំទឹក បន្ទាប់មកស្រង់យកមកបុកឲ្យហ្មត់ដើម្បីលាយជាមួយទឹកឃ្មុំ រួចហើយសូនជាគ្រាប់ថ្នាំមូលៗដោយខ្លួនឯង ។ ថ្នាំដែលផលិតចេញពីរុក្ខជាតិនេះហៅថា «ថ្នាំអាចម៍ទន្សាយ» សម្រាប់ព្យាបាលតែអ្នកជំងឺគ្រុនតែប៉ុណ្ណោះ ប៉ុន្តែក្រោយមក ដោយសារអ្នកជំងឺកាន់តែកើនច្រើនឡើងៗ ទើបពេទ្យយកថ្នាំនេះទៅព្យាបាលអ្នកជំងឺគ្រប់មុខ ។

នៅឆ្នាំ១៩៧៦ប្រជាជនចាប់ផ្តើមកើតជំងឺហើមដោយសារតែខ្វះជាតិអាហារហើយពេទ្យពិបាកក្នុងការព្យាបាលឲ្យអ្នកជំងឺបានជាសះស្បើយណាស់ព្រោះខ្វះខាតថ្នាំនិងសម្ភារពេទ្យ ។ អ្នកជំងឺជាច្រើនបានស្លាប់ហើយសាកសពអ្នកទាំងនេះត្រូវប្រធានមន្ទីរពេទ្យបញ្ជាឲ្យបុគ្គលិកយកទៅកប់ចោលតែម្តង ។ រយៈពេលប្រហែលមួយខែម្តង ញ៉ាន តែងតែឃើញ តាម៉ុក ចុះមកពិនិត្យមើលអ្នកជំងឺនៅមន្ទីរពេទ្យគីរីវង្សជានិច្ច ហើយពេលខ្លះ គាត់បាននាំភ្ញៀវចិនមកជាមួយទៀតផង ។ នៅចុងឆ្នាំ១៩៧៦ អង្គការបានរៀបការឲ្យ ញ៉ាន ជាមួយឈ្មោះ សំ ណែត កាន់ផ្នែកសេដ្ឋកិច្ចដោយមានការចូលរួមពីបុគ្គលិកពេទ្យប្រធានមន្ទីរពេទ្យគីរីវង្សឈ្មោះ យាយកេន (ត្រូវជាប្អូនស្រីបង្កើតរបស់តាម៉ុក) ផង និងគណៈស្រុកគីរីវង្សឈ្មោះ តាទិត្យ (ត្រូវជាប្អូនថ្លៃតាម៉ុក) ។ បន្ទាប់ពីរៀបការរួច អង្គការបានបញ្ជូន ញ៉ាន ឲ្យទៅរស់នៅជាមួយប្តីរបស់គាត់ហើយនៅទីនោះ ញ៉ាន ជាអ្នកដាំបាយឲ្យប្រជាជនសហករណ៍ហូប ។ រហូតដល់ឆ្នាំ១៩៧៨ ថ្ងៃខ្លះ ញ៉ាន គ្មានអង្ករសម្រាប់ដាំបបរឲ្យប្រជាជនហូបទេព្រោះអង្គការមិនបានបើកឲ្យខាងសហករណ៍គាត់ ។

ឃើញដូច្នេះ ញ៉ាន បានចែកដំឡូងនិងគ្រាប់ពោតដែលមាននៅក្នុងរោងបាយឲ្យប្រជាជនហូបជំនួសវិញ ប៉ុន្តែរបបទាំងនេះមិនគ្រប់ទេ ទើបបណ្តាលឲ្យប្រជាជនទាំងនោះស្លាប់យ៉ាងច្រើន ។ ញ៉ាន មានកូនចំនួន៧នាក់ ចំណែកប្តីរបស់គាត់ស្លាប់ដោយសារជំងឺតាំង

ពីឆ្នាំ១៩៨២ ។ សព្វថ្ងៃ ញ៉ន មាន អាយុ៦០ឆ្នាំរស់នៅស្រុកគិរីវង្ស ខេត្តតាកែវ ។

## ហាយ យីម

ហាយ យីម បានឈប់រៀននៅថ្នាក់ទី១០ (សង្គមចាស់) ដោយសារតែម្ដាយស្លាប់ចោលពេលសម្រាលកូនទីបីរួច ។ នៅឆ្នាំ ១៩៧៥ អង្គការបានបញ្ចូល យីម ជាកងចល័តនារី ។ រយៈពេលប្រមាណបួនខែក្រោយមក អង្គការជ្រើសរើសកូនកសិករក្នុងភូមិឲ្យទៅធ្វើពេទ្យស្រុកនៅស្រុកគិរីវង្សដែលពេលនោះក៏មានឈ្មោះ យីម ទៅជាមួយដែរ ។ ក្មេងជាច្រើនដែលដឹងដំណឹងនេះសប្បាយចិត្តយ៉ាងខ្លាំង ប៉ុន្តែ យីម បែរជាការភ័យខ្លាចដោយសារខ្លួនមិនចេះអក្សរ ។ នៅពេល យីម ទៅដល់មន្ទីរពេទ្យស្រុកគិរីវង្សដំបូង គាត់ឃើញបុគ្គលិកពេទ្យចាស់និងថ្មីសរុបទាំងអស់ប្រហែល២៥នាក់ ដោយមាន យាយកេន ជាប្រធានពេទ្យ ។ យាយ កេន បានឲ្យ យីម ដើរមើលគ្រូពេទ្យព្យាបាលឲ្យអ្នកជំងឺរយៈពេលដប់ថ្ងៃ បន្ទាប់មកឲ្យគ្រូពេទ្យបង្រៀនគាត់ពីវិធីព្យាបាលអ្នកជំងឺរយៈពេលមួយអាទិត្យបន្ថែមទៀត ទើបអនុញ្ញាតឲ្យ យីម ចែកថ្នាំ និងចាក់ថ្នាំឲ្យអ្នកជំងឺ ។

នៅឆ្នាំ១៩៧៧ យីម ឃើញអ្នកជំងឺហើមចូលមកព្យាបាលនៅមន្ទីរកាន់តែច្រើន ហើយស្លាប់ដោយសារខ្វះថ្នាំព្យាបាលនិងគ្មានអាហារហូបគ្រប់គ្រាន់ ។ នៅទីនោះ យីម គិតថាថ្នាក់លើបានដឹងពីការស្លាប់នេះហើយ ប៉ុន្តែគាត់មិនដែលឃើញនរណាមកដោះស្រាយរឿងនេះទេហើយពីមួយថ្ងៃទៅមួយថ្ងៃអ្នកជំងឺស្លាប់កាន់តែច្រើនឡើងៗ ។ នៅចុងឆ្នាំដដែល ពេលយាយ កេន ផ្លាស់ទៅតាមប្ដីឈ្មោះ តាទិត្យ ជាគណៈស្រុកគិរីវង្ស ឬ (ស្រុក១០៩) ទើប យីម ឃើញប្រធានមន្ទីរគិរីវង្សថ្មីឈ្មោះ វ៉ាន់ មកគ្រប់គ្រងជំនួសវិញ ។



ថ្នាំព្យាបាលរោគរបស់ខ្មែរក្រហម

យីម នៅព្យាបាលអ្នកជំងឺរហូតដល់កងទ័ពវៀតណាមវាយចូលមកក្នុងប្រទេសកម្ពុជា ទើបរត់ទៅព្រំដែនខ្មែរថៃ ដោយសារតែគាត់ភ័យខ្លាចពាក្យចចាមអារ៉ាមថា «យួនចាប់វះពោះច្រកស្មៅ» ក្រោយមកទើបគាត់សម្រេចចិត្តត្រឡប់មកស្រុកកំណើតវិញ ។

សព្វថ្ងៃ យីម មានកូនប្រាំមួយនាក់ ។ យីម រស់នៅស្រុកគិរីវង្ស ។ យីម បានប្រាប់ថា ទោះបីរបបខ្មែរក្រហមដួលរលំទៅហើយក៏ដោយ ក៏ពេទ្យខ្លះ នៅបន្តអាជីពរបស់ខ្លួនដដែលដូចជា វ៉ាន់ ស៊ាងលី ជាពេទ្យឆ្មបជួយសម្រាលកូនឲ្យ គាត់ និងអ្នកភូមិស្ទើរតែគ្រប់គ្នា ។ ប៉ុន្តែ យីម មិនដែលយកចំណេះវិជ្ជារបស់គាត់ទៅព្យាបាលប្រជាជនទេ ព្រោះគាត់មិនបានចូលរៀននៅសាលាពេទ្យ ហើយគាត់មកប្រកបមុខរបរធ្វើស្រែចម្ការដើម្បីចិញ្ចឹមជីវិតវិញ ។ **សុខ ខណ្ណា**

# ការបញ្ចាំងសាលក្រម ឌុច រំពឹងថានឹងមានសន្តិភាព

នៅថ្ងៃចេញសាលក្រម ខ្ញុំបានព្យាយាមសង្កេតពិនិត្យទៅលើគ្រប់ព្រឹត្តិការណ៍និងអ្វីដែលខ្ញុំចាប់អារម្មណ៍ដើម្បីសរសេរ ។ ខ្ញុំបានចាប់ផ្តើមសរសេរ បន្ទាប់មក ខ្ញុំក៏ឈប់សរសេរបីបួនដងក្រោយមក ទើបខ្ញុំចាប់ផ្តើមសរសេរកថាខណ្ឌថ្មីមួយទៀត ។ ក្មេងស្រីម្នាក់ដែលចូលចិត្តបង្ហាញពីអារម្មណ៍របស់ខ្លួនតាមរយៈការសរសេរជាជាងការនិយាយបែរជាមិនអាចសរសេរ ។ នេះប្រហែលជាត្រូវចាំដល់ពេលដែលខ្ញុំនៅបានពេញមួយថ្ងៃ ទើបខ្ញុំមានអ្វីត្រូវសរសេរ ។ ប៉ុន្តែឥឡូវនេះ ខ្ញុំមានពាក្យជាច្រើនត្រូវសរសេរ ។ នៅពេលជាមួយគ្នានេះដែរ ខ្ញុំចង់ផ្តាំផ្ញើអត្ថបទនេះនិងរូបភាពរបស់ខ្ញុំទៅឲ្យស្ត្រីពីរនាក់ក្មេងៗនេះនិងអ្នកភូមិទាំងអស់ដែលបានមើលសាលក្រមជាមួយខ្ញុំ ។

ដោយមានហេតុផលមួយចំនួនស្ត្រីពីរនាក់នោះដើរមករកខ្ញុំបន្ទាប់ពីមើលការប្រកាសសាលក្រមចប់ ។ ស្ត្រីម្នាក់បានចាប់ដៃខ្ញុំហើយចាប់ផ្តើមនិយាយខ្មែរ ។ ខ្ញុំបានព្យាយាមពន្យល់ថាខ្ញុំមិនយល់ថាគាត់ចង់និយាយពីអ្វីទេ ប៉ុន្តែគាត់នៅតែព្យាយាមនិយាយ ទោះបីជា គាត់ដឹងថាខ្ញុំកំពុងតែនិយាយភាសាអង់គ្លេសក៏ដោយ ។ គាត់នៅតែបន្តចាប់ដៃខ្ញុំដែលធ្វើឲ្យខ្ញុំមិនអាចធ្វើអ្វីឡើយ ។ ខ្ញុំត្រូវតែស្វែងយល់ថាគាត់កំពុងតែនិយាយអ្វី ។ ខ្ញុំបានលើកម្រាមដៃមួយដោយសង្ឃឹមថា គាត់នឹងយល់ថាខ្ញុំចង់ឲ្យគាត់ចាំខ្ញុំមួយភ្លែតដើម្បីឲ្យខ្ញុំទៅរកអ្នកបកប្រែ ។ អ្នកបកប្រែបានប្រាប់ខ្ញុំថា គាត់


ណាតាលី អេនជីសាន់

កំពុងតែឈឺជើង ។ គាត់កំពុងតែព្យាយាមចង់និយាយប្រាប់ខ្ញុំថា នៅពេលដែលគាត់កំពុងអង្គុយស្តាប់សាលក្រម ជើងរបស់គាត់បានចាប់ផ្តើមឈឺ ដូច្នេះទើបគាត់ចង់សុំថ្នាំពីខ្ញុំ ។ ប៉ុន្តែ ខ្ញុំអត់មានថ្នាំទេ ។ ខ្ញុំបានសួរបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា និងអ្នកដែលខ្ញុំគិតថាអាចមានថ្នាំ អាស្ពីរីន ឬថ្នាំបំបាត់ការឈឺចាប់ ប៉ុន្តែមិនមាននរណាម្នាក់មានថ្នាំទេ ។ ខណៈពេលដែលខ្ញុំកំពុងតែអង្គុយចាំបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាម្នាក់ទៀតដែលខ្ញុំគិតថាមានថ្នាំ ស្ត្រីទាំងពីរនិងខ្ញុំបានទៅអង្គុយនៅក្នុងវត្ត ។

ស្ត្រីដដែលដែលចាប់ដៃខ្ញុំដំបូងបានបន្តនិយាយជាមួយខ្ញុំដោយពេលខ្លះគាត់បានច្របាច់ជើងរបស់គាត់ដើម្បីបន្ថយការឈឺចាប់ ។ យើងបានអង្គុយរង់ចាំ ប៉ុន្តែ យើងមិនឃើញបុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលយើងកំពុងអង្គុយចាំទេ ។ ភ្លាមនោះ ស្ត្រីម្នាក់នោះបានចាប់ដៃខ្ញុំឲ្យក្រោកឡើង បន្ទាប់មកគាត់និងមិត្តភក្តិរបស់គាត់បានហៅខ្ញុំទៅញ៉ាំអាហារ ។ អាហារថ្ងៃត្រង់ត្រូវបានរៀបចំនៅក្នុងវត្តសម្រាប់អ្នកភូមិដែលតាមដានមើលសាលក្រម ។ មិនមានជនបរទេសណាទៅញ៉ាំទេ អ្នកទាំងនោះគ្រាន់តែជួយរៀបចំប៉ុណ្ណោះ ។ ខ្ញុំមិនបានរៀបគម្រោងថានឹងញ៉ាំទេ ពីព្រោះខ្ញុំដឹងថាប្រសិនបើខ្ញុំញ៉ាំ ខ្ញុំអាចនឹងឈឺ ។ ខ្ញុំធ្លាប់ឈឺម្តងហើយនៅពេលដែលខ្ញុំត្រឡប់មកពីខេត្តលើកដំបូងហើយខ្ញុំក៏មិនចង់ឈឺម្តងទៀតដែរ ។ អាហារត្រូវបានរៀបចំនៅក្នុងភូមិ ដូច្នេះ ខ្ញុំមិនដឹងថាទឹកចេញពីប្រភពណា ឬទឹកសម្លត្រូវបានដាំឆ្អិនល្មមដើម្បីសម្លាប់បាក់តេរី ឬប៉ារ៉ាសិតនៅឡើយទេ ។ នំបញ្ចុកដែលត្រូវញ៉ាំត្រូវបានចាប់ដោយដៃអ្នកភូមិជាច្រើនដើម្បីយកមកដាក់ក្នុងចាន ។ ខ្ញុំពិតជាចង់គេចវេះមិនចង់ញ៉ាំទេ ។ ខ្ញុំព្យាយាមពន្យល់ថាខ្ញុំមិនឃ្លានទេហើយជំរុញឲ្យអ្នកទាំងនោះញ៉ាំ ប៉ុន្តែអ្នកទាំងនោះនៅតែនាំខ្ញុំទៅកន្លែងញ៉ាំ ។ ខ្ញុំដឹងថា ស្ត្រីទាំងនោះមានចិត្តល្អណាស់ ដូច្នេះនៅពេលដែលអ្នកទាំងនោះនាំខ្ញុំទៅដល់កន្លែងញ៉ាំ ខ្ញុំគិតថាការទទួលនូវបំណងល្អរបស់អ្នកទាំងនោះមានសារសំខាន់ជាងបន្តភាពភ័យខ្លាចរបស់ខ្ញុំ ។ ខ្ញុំបានអង្គុយចុះញ៉ាំជាមួយពួក

គាត់ ។ ខ្ញុំបានឃើញស្រមោចមួយក្បាលវារនៅលើនំបញ្ចុក របស់ខ្ញុំ ប៉ុន្តែមុនពេលដែលខ្ញុំចាប់វាចេញ ស្ត្រីដែលអង្គុយនៅជិតខ្ញុំបានយកចានខ្ញុំទៅដាក់សម្ល ។ ស្រមោចបានលាយឡំជាមួយនឹងសម្ល ។ ខ្ញុំក៏គិតថាស្រមោចតែមួយមិនអាចធ្វើបាបអ្នកណាបានឡើយ ។ បន្ទាប់ពីខ្ញុំញ៉ាំបានពាក់កណ្តាលចាន ខ្ញុំបានលើកដៃសំពះដោយឱនក្បាលចុះបន្តិចនិងនិយាយ «អរគុណ» ទៅកាន់មនុស្សទាំងអស់ដែលនៅជុំវិញខ្ញុំ ។ បន្ទាប់មក ខ្ញុំក៏ទៅបន្តស្វែងរកថ្នាំឲ្យស្ត្រីនោះ ។ ខ្ញុំបានទៅរកបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាផ្សេងទៀតបុគ្គលិកនោះបាននិយាយប្រាប់ខ្ញុំថាគាត់តែងតែដាក់ថ្នាំបំបាត់ការឈឺចាប់នៅក្នុងកាបូប ប៉ុន្តែ គាត់ទើបតែដកថ្នាំចេញ ។ ខ្ញុំក៏ត្រឡប់ទៅប្រាប់ស្ត្រីនោះវិញថាខ្ញុំមិនមានថ្នាំទេ ។ ខ្ញុំមានអារម្មណ៍ចុះចាញ់ហើយ ។ នៅពេលដែលខ្ញុំកំពុងតែអង្គុយជាមួយអ្នកទាំងនោះខ្ញុំនៅតែសង្ឃឹមថាអាចរកថ្នាំបាន ។ ភ្លាមនោះមិត្តភក្តិម្នាក់ អឡេនដូ បានលេចមុខឡើង គាត់បានឲ្យថ្នាំខ្ញុំពីរគ្រាប់ដែលដាក់នៅក្នុងថង់ប្លាស្ទិច ។

ខ្ញុំមិនដឹងថា អឡេនដូ បានធ្វើដំណើរទៅទិញថ្នាំជាមួយក្មេងម្នាក់ដែលស្គាល់កន្លែងលក់ថ្នាំទេ ។ ក្មេងនោះបាននាំ អឡេនដូ ទៅផ្ទះ មួយដែលមានលក់ថ្នាំបំបាត់ការឈឺចាប់ ។

យើងបានឲ្យថ្នាំគាត់ហើយ បន្ទាប់មកយើងក៏ឲ្យលុយទៅក្មេងម្នាក់នោះដើម្បីទិញថ្នាំទៀត ពីព្រោះជើងរបស់មិត្តភក្តិគាត់ក៏ឈឺដែរ ។ នៅពេលដែលយើងអង្គុយជាមួយគ្នា ពេលខ្លះស្ត្រីទាំងនោះបាននិយាយញញឹមនិងស្ទាបសក់ឬមុខរបស់ខ្ញុំព្រមទាំងរៀបរាប់ពីការឈឺចាប់នៅលើជើងរបស់គាត់ ។ ខ្ញុំសង្ឃឹមថា ខ្ញុំយល់នូវ



ណាតាលី ជាមួយអ្នកភូមិនៅស្រុកកោះធំ ខេត្តកណ្តាល

អ្វីដែលស្ត្រីទាំងនោះនិយាយទាំងអស់ហើយខ្ញុំអាចនិយាយត្រឡប់ទៅវិញ ប៉ុន្តែខ្ញុំបានត្រឹមតែកាន់ដៃរបស់គាត់យ៉ាងណែនដោយសង្ឃឹមថាសកម្មភាពរបស់ខ្ញុំអាចបញ្ជូនពររបស់ខ្ញុំឲ្យគាត់ប៉ុណ្ណោះ ។

ខ្ញុំនៅតែមិនដឹងថាខ្ញុំយល់យ៉ាងដូចម្តេចចំពោះសាលក្រម ។ ឌុច ត្រូវទទួលខុសត្រូវចំពោះការធ្វើទារុណកម្មនិងការស្លាប់របស់ប្រជាជនរាប់សែននាក់ ។ ខ្ញុំបានដើរនៅក្នុងមន្ទីរស-២១ ដែលឌុច ធ្លាប់គ្រប់គ្រងហើយខ្ញុំបានឃើញស្នាមឈាមចាស់ដែលមិនរលុប រូបថតអ្នកដែលត្រូវបានធ្វើទារុណកម្មរួមទាំងកូនក្មេងផង ។ តើខ្ញុំគិតថាសាលក្រមមិនមានយុត្តិធម៌ឬ? តើខ្ញុំគិតថាមិនមានអ្វីអាចបំពេញចិត្តប្រជាជនកម្ពុជា ដូច្នេះសាលក្រមបញ្ជាក់ថា ឌុចមានទោសនិងការផ្តន្ទាទោសគ្រាន់តែជានិមិត្តសញ្ញាមួយឬ? តើខ្ញុំគិតថាការដាក់ឲ្យជាប់ពន្ធនាគារមិនមែនជាការផ្តន្ទាទោសដែលអាចផ្តល់ផលប្រយោជន៍ជាងការដាក់ឲ្យ ឌុច អានចម្លើយសារភាពរបស់អ្នកទោសដែលគាត់បានធ្វើទារុណកម្មជារៀងរាល់ថ្ងៃ ឬបង្ខំឲ្យ ឌុច ធ្វើការផ្សេងដើម្បីធ្វើឲ្យគ្រួសាររបស់ជនរងគ្រោះពេញចិត្តឬ? ខ្ញុំមិនដឹងទេ ។ អ្វីដែលខ្ញុំដឹងគឺកម្ពុជាជាប្រទេសមួយដែលនៅតែទទួលរងការឈឺចាប់ពីអ្វីដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម ។ ក្មេងជំទង់ជាច្រើននៅតែមានជំងឺសតិអារម្មណ៍ធុញថប់និងប្រើថ្នាំដោយសារតែអ្វីដែលជាស្ថានភាពរស់នៅ ។ ខ្ញុំសង្ឃឹមថាពិភពលោកនឹងយល់ថាដោយរស់ជាសហគមន៍អ្វីដែលយើងធ្វើអាចផ្តល់ឥទ្ធិពលដល់ប្រទេសផ្សេង ។ យើងទាំងអស់គ្នាមិនមែនរស់តែម្នាក់ឯងទេ ។ ខ្មែរក្រហមមិនមែនឡើងកាន់អំណាចដោយសារតែព្រឹត្តិការណ៍ដែលកើតឡើងនៅក្នុងកម្ពុជាទាំងស្រុងទេ ។ ព្រឹត្តិការណ៍ពិភពលោកនិងនយោបាយក៏ជាផ្នែកមួយដែរ ។

ខ្ញុំសង្ឃឹមថាពិភពលោកនឹងមិនអនុញ្ញាតឲ្យអំពើសាហាវឃោរឃៅនេះកើតឡើងម្តងទៀតទេ ។ ខ្ញុំសូមផ្ញើអត្ថបទនេះនិងរូបភាពទៅដល់ស្ត្រីដ៏ស្រស់ស្អាតពីរនាក់ដែលស្រឡាញ់ប្រទេសកម្ពុជាដើម្បីឲ្យការឈឺចាប់របស់គាត់មានភាពធូរស្រាល ។ អ្នកទាំងនោះចង់ជាសះស្បើយចង់ឲ្យមានគេស្តាប់អ្វីដែលគាត់និយាយចង់បានសន្តិភាព ។ ខ្ញុំសង្ឃឹមថានៅថ្ងៃណាមួយសន្តិភាពនឹងនាំយកអ្នកទាំងនេះនិងប្រទេសនេះចេញពីអតីតកាលដែលពោរពេញដោយការធ្វើទារុណកម្ម ។ **ណាតាលី អេនជីសាន់**

# កាលប្បវត្តិនៃដំណើរការកាត់សេចក្តីជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច

**ឆ្នាំ២០០៧**

◆**ថ្ងៃទី៣១ ខែកក្កដា** : កាំង ហ្គេកអ៊ាវ ហៅ ឌុច ត្រូវបានផ្ទេរពីតុលាការយោធារបស់រដ្ឋាភិបាលកម្ពុជាទៅកាន់អង្គជំនុំជម្រះក្នុងតុលាការកម្ពុជា ។ ពេលនេះ ឌុច គឺជាជនសង្ស័យទីមួយដែលត្រូវបានចោទប្រកាន់ដោយអង្គជំនុំជម្រះនេះពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយសហចៅក្រមស៊ើបអង្កេត ។

◆**ថ្ងៃទី១ ខែសីហា** : ឌុច បានសម្រេចចិត្តជ្រើសរើសមេធាវីពីររូប ។

◆**ថ្ងៃទី៨ ខែសីហា** : អតីតមេធាវីសញ្ជាតិបារាំងម្នាក់ដែលធ្លាប់ការពារក្តីក្នុងករណីភេរវកម្មដែលបានវាយប្រហារសហរដ្ឋអាមេរិកកាលពីថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០១ បានក្លាយជាមេធាវីការពារក្តីឲ្យ ឌុច នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

◆**ថ្ងៃទី២៣ ខែសីហា** : សហមេធាវីរបស់ ឌុច ពីររូបគឺលោក ការ សាវុត្ថ និង ហ្វ្រង់ស្វ័រ រូហ្ស បានធ្វើការប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន ។

◆**ថ្ងៃទី៤ ខែកញ្ញា** : អង្គបុរេជំនុំជម្រះអញ្ជើញអង្គការនានានិងសាធារណៈជនធ្វើសារណាសង្ខេបទាក់ទងនឹងបណ្តឹងឧទ្ធរណ៍របស់ កាំង ហ្គេកអ៊ាវ ទល់នឹងដីកាឃុំខ្លួនបណ្តោះអាសន្នរបស់សហចៅក្រមស៊ើបអង្កេត ។

◆**ថ្ងៃទី២៤ ខែតុលា** : អង្គបុរេជំនុំជម្រះកំណត់ថ្ងៃសវនាការជាសាធារណៈក្នុងរឿងបណ្តឹងឧទ្ធរណ៍របស់ ឌុច ។

◆**ថ្ងៃទី៣ ខែធ្នូ** : អង្គជំនុំជម្រះច្រានចោលបណ្តឹងឧទ្ធរណ៍របស់ ឌុច ។ អង្គជំនុំជម្រះបញ្ជាក់ថាការឃុំខ្លួន ឌុច ជាការចាំបាច់ដើម្បីការពារសុវត្ថិភាពរបស់គាត់និងដើម្បីធានាវត្តមានរបស់គាត់ពេលដែលមានមានការចាំបាច់ក្នុងអង្គសវនាការ ។

**ឆ្នាំ២០០៨**

◆**ថ្ងៃទី២៧ ខែកុម្ភៈ** : ឌុច ត្រូវបាននាំទៅមើលគុកទួលស្លែងនិងជើងឯកជាលើកដំបូងតាំងពីរបបកម្ពុជាប្រជាធិបតេយ្យដួលរលំមកដើម្បីពន្យល់ប្រាប់សហចៅក្រមស៊ើបអង្កេតអំពីអ្វីដែលគាត់ធ្លាប់បានធ្វើកាលពីអតីតកាល ។ អ្នកសារព័ត៌មានទាំងអស់ត្រូវបានហាមឃាត់ក្នុងការចូលរួមដំណើរការនេះ ។

◆**ថ្ងៃទី១៥ ខែឧសភា** : សហចៅក្រមស៊ើបអង្កេតជូនដំណឹងដល់គ្រប់ភាគីទាំងអស់ថាខ្លួនបានបញ្ចប់សំណុំរឿងទីមួយទាក់ទងនឹង ឌុច ។

◆**ថ្ងៃទី១៨ ខែកក្កដា** : សហព្រះរាជអាជ្ញាបានដាក់សំណុំរឿងដីកាសន្និដ្ឋានស្ថាពរចំពោះករណី ឌុច ដោយបង្ហាញ «នូវការយល់ឃើញដ៏ទូលំទូលាយមួយនូវអ្វីដែលសហព្រះរាជអាជ្ញាចាត់ទុកថាជាភស្តុតាងដែលពាក់ព័ន្ធមាននៅក្នុងសំណុំរឿង» ។

◆**ថ្ងៃទី៨ ខែសីហា** : សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយដោយបញ្ជូនទៅរកការកាត់ទោស ឌុច ដោយចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនិងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើសន្ធិសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ ។

◆**ថ្ងៃទី១២ ខែសីហា** : សហចៅក្រមស៊ើបអង្កេតបានបញ្ជូនដីកាដំណោះស្រាយចោទប្រកាន់ជនជាប់ចោទ ឌុច ទៅជំនុំជម្រះ ។

◆**ថ្ងៃទី៥ ខែកញ្ញា** : សហព្រះរាជអាជ្ញាដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿង ឌុច ។

◆**ថ្ងៃទី១២ ខែធ្នូ** : អង្គជំនុំជម្រះវិសាមញ្ញចេញសេចក្តីប្រកាសព័ត៌មានស្តីពីដំណាក់កាលនានានៃកិច្ចដំណើរនីតិវិធីសំណុំរឿង ឌុច ។

**ឆ្នាំ២០០៩**

◆**ថ្ងៃទី១៧ ខែកុម្ភៈ** : សវនាការជំនុំជម្រះសេចក្តីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាលើកទីមួយទៅលើឧក្រិដ្ឋកម្មនៃរបបខ្មែរក្រហមក្នុងទសវត្សរ៍៧០ បានបើកជាផ្លូវការ ។

◆**ថ្ងៃទី២៤ ខែកុម្ភៈ** : អៀង ធីរិទ្ធ ប្រាប់អង្គជំនុំជម្រះថាគាត់

ជាមនុស្សស្លូតត្រង់ ហើយគាត់បានធ្វើការបន្ទោសទៅលើ នួន ជា និង ឌុច ដែលបានសម្លាប់កូនសិស្សរបស់គាត់និងជនរងគ្រោះឯទៀត ។

◆**ថ្ងៃទី៣០ ខែមីនា** ៖ សវនាការ ឌុច ចាប់ផ្តើម ។ ឌុច បានធ្វើការសុំទោសដល់ពលរដ្ឋកម្ពុជាជាទូទៅហើយប្រកាសថាគាត់ជាអ្នកទទួលខុសត្រូវចំពោះអំពើកាប់សម្លាប់នៅក្នុងមន្ទីរស-២១ ប៉ុន្តែគាត់បានបញ្ជាក់ទៀតថា គាត់ធ្វើតាមតែបញ្ជារបស់មេដឹកនាំរបស់គាត់តែប៉ុណ្ណោះ ។ គាត់នឹងមានបញ្ហាសុវត្ថិភាពផ្ទាល់ខ្លួន បើសិនជាគាត់មិនគោរពបទបញ្ជា ។

◆**ថ្ងៃទី២៧ ខែមេសា** ៖ អង្គជំនុំជម្រះសាលាដំបូងសម្រេចពន្យារពេលកាលកំណត់លើសេចក្តីសម្រេចសំណើសុំដោះលែង កាំង ហ្កេកអ៊ាវ ដោយមានលក្ខខណ្ឌក្នុងអំឡុងពេលសវនាការជំនុំជម្រះ ។

◆**ថ្ងៃទី១៩ ខែឧសភា** ៖ អង្គជំនុំជម្រះសាលាដំបូងសម្រេចបដិសេធលើសំណុំរឿងសុំដោះលែងជនជាប់ចោទ កាំង ហ្កេកអ៊ាវ នៅក្រៅឃុំដោយមានលក្ខខណ្ឌ ។

◆**ថ្ងៃទី២៧ ខែកក្កដា** ៖ មកដល់ថ្ងៃនេះគឺជាថ្ងៃទី៥០ នៃដំណើរការសវនាការជំនុំជម្រះក្តី ឌុច ។

◆**ថ្ងៃទី២៦ ខែសីហា** ៖ អង្គជំនុំជម្រះប្រកាសថាសវនាការជំនុំជម្រះក្តី ឌុច មានអ្នកមកទស្សនាជាង២០០០០នាក់ ។

◆**ថ្ងៃទី១៧ ខែកញ្ញា** ៖ ការបង្ហាញភស្តុតាងក្នុងសវនាការជំនុំជម្រះក្តីរបស់ ឌុច បានបញ្ចប់ ។

**ឆ្នាំ២០១០**

◆**ថ្ងៃទី១៤ ខែមករា** ៖ សហចៅក្រមស៊ើបអង្កេតបានជូនដំណឹងដល់គ្រប់ភាគីនិងមេធាវីរបស់អ្នកទាំងនោះថា សហចៅក្រមស៊ើបអង្កេតយល់ឃើញថាការស៊ើបអង្កេតសំណុំរឿង០០២ ដែលទាក់ទងនឹងជនជាប់ចោទទាំងប្រាំដូចជា អៀង សារី, អៀង ធីរិទ្ធ, នួន ជា, ខៀវ សំផន, និង កាំង ហ្កេកអ៊ាវ ។

◆**ថ្ងៃទី២៦ ខែកក្កដា** ៖ សាលក្រម ឌុច ត្រូវបានប្រកាសនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ **ញាណ សុជាតិ**



ឌុច និងសហមេធាវីជាតិ ការ សាវុត្ថ

# តើការផ្សព្វផ្សាយអំពីការថែរក្សាប្រវត្តិឧក្រិដ្ឋកម្មរបស់របបខ្មែរក្រហមតាមរយៈវិស័យទេសចរណ៍គឺរឿងសមហេតុផលដែរទេ?

**ទស្សនៈករណីយកិច្ច**

ឆ្លើយតបទៅនឹងបទពិសោធន៍ផ្នែកសកលអភិសមាចារ (ការប្រព្រឹត្តរៀបរយគួរឲ្យពេញចិត្ត) និងគោលការណ៍ពីរនៃយុត្តិធម៌ នោះគឺសង្គមត្រូវទិតៀននិងវិនិច្ឆ័យមនុស្សដែលប្រព្រឹត្តខុសនៅក្នុងសង្គម ។ បើមិនដូច្នេះទេ យុត្តិធម៌នឹងមិនមានហើយពិភពលោកនឹងមានគ្រោះថ្នាក់និងច្របូកច្របល់ពេញទៅដោយឧក្រិដ្ឋជន ។

ខ្មែរក្រហមដែលបានសម្លាប់ប្រជាជនជិតពីរលាននាក់ចាប់ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ មិនបានផ្តល់ហេតុផលអ្វីអំពីការគ្រប់គ្រងតាមរបបមូលវិវដ្តនិយមរបស់ខ្លួនឡើយ ។ ប៉ុន្តែវាប្រហែលជាឆ្លើយតបទៅនឹងទ្រឹស្តីរបស់លោក កន់ ដែលថា ការបំភ្លឺឲ្យច្បាស់គឺជាការដាក់ឲ្យរួចផុតពីភាពមិនយល់ដឹងដោយហេតុថាពុំមាននរណាម្នាក់ដឹង ឬអាចផ្តល់ចម្លើយថាហេតុអ្វីបានជាមេដឹកនាំខ្មែរក្រហមដូចជា ប៉ុល ពត ជាដើមប្រព្រឹត្តអំពើឧក្រិដ្ឋដូច្នេះ ហើយមេដឹកនាំទាំងនោះបានបង្កើតច្បាប់របស់ខ្លួនដោយខ្លួនឯងធ្វើការសម្រេចចិត្តដោយខ្លួនឯងដោយមិនមានការខ្លាចរអារសោះឡើយ ។ តើពួកមេដឹកនាំទាំងនោះគិតថា ពួកគេកំពុងតែធ្វើរឿងដែលល្អត្រឹមត្រូវឬ? ពួកគេបានបន្សល់ទុកនូវវិនាសកម្ម សោកនាដកម្ម និងទុក្ខលំបាកវេទនាជាច្រើន ។

ផ្ទុយទៅវិញ ជនរងគ្រោះដែលធ្លាប់រស់នៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហមមិនបានទទួលអ្វីអំពីខ្មែរក្រហមឡើយ ក្រៅពីទុក្ខលំបាកវេទនាហួសនិស្ស័យនិងគំនរឆ្អឹងនិងលលាដ៏ក្បាលយ៉ាងច្រើន ។

បញ្ហានេះគឺជាកិច្ចការរបស់រដ្ឋាភិបាលនិងប្រជាជនកម្ពុជាផ្ទាល់ដែលត្រូវការការពារប្រវត្តិសាស្ត្ររបស់ខ្លួនដោយហេតុថានេះគឺជាប្រវត្តិសាស្ត្ររបស់ខ្លួនឯង ។ រដ្ឋាភិបាលនិងប្រជាជនកម្ពុជាមានកាតព្វកិច្ចដែលត្រូវធ្វើក្នុងការថែរក្សាប្រវត្តិសាស្ត្រដ៏សោកសង្រេងនេះដោយអនុលោមតាមទ្រឹស្តីភាសិតដែលថាមិនត្រូវបំភ្លេចអតីតកាល ។ ប្រវត្តិសាស្ត្រនេះបម្រើដល់ប្រយោជន៍នៃការអប់រំដ៏រឹងមាំមួយ ដើម្បីឲ្យប្រជាជនរៀនសូត្រនិងចងចាំ ។

**ទស្សនៈអត្ថប្រយោជន៍និយម**

ប្រសិនបើការផ្សព្វផ្សាយប្រវត្តិសាស្ត្រខ្មែរក្រហមមានអត្ថប្រយោជន៍ចំពោះអ្នកទេសចរប្រជាជនក្នុងស្រុកនិងសហគមន៍នោះដូច្នេះ ការផ្សព្វផ្សាយនេះគឺជារឿងត្រឹមត្រូវមួយដែលត្រូវធ្វើ ។ ដូច្នេះបើទោះបីជាការផ្សព្វផ្សាយនេះនាំឲ្យប្រជាជនចងចាំនូវព្រឹត្តិការណ៍អាក្រក់ដ៏គួរភ័យខ្លាចក៏ដោយ ក៏មិនជាបញ្ហាអ្វីដែរដោយហេតុថាការងារនេះនាំឲ្យមានសុភមង្គលដ៏ធំធេងដល់មនុស្សជាច្រើន ។

សុភមង្គលទូទៅតែងបន្សល់នូវលក្ខណៈវិនិច្ឆ័យចុងក្រោយបំផុតនៃភាពមិនប្រពៃឬប្រពៃនៃទង្វើសកម្មភាពដូច្នេះតាមច្បាប់អត្ថប្រយោជន៍និយមការយកលលាដ៏ក្បាលជនរងគ្រោះនៃរបបកុម្មុយនីស្តមកដាក់តាំងបង្ហាញជាសាធារណៈតាំងពីឆ្នាំ១៩៧៩ ដើម្បីជាតឹកតាងបញ្ជាក់ពីភាពយង់ឃ្នងនៃរបបនោះគឺជារឿងល្អស្របតាមលក្ខណៈសីលធម៌ដែលសមនឹងធ្វើ ។ តាមរយៈការណែនាំបង្ហាញពីវិសោធនកម្ម ការរុះរើលលាដ៏ក្បាលដែលជាគន្លឹះនៃការចងចាំមួយដ៏សំខាន់អំពីអំពើឃោរឃៅដែលប្រព្រឹត្តដោយអតីតមេដឹកនាំខ្មែរក្រហមនៃប្រទេសកម្ពុជា គឺជារឿងត្រឹមត្រូវដែលគួរតែធ្វើពីព្រោះវាផ្តល់ចំណេះដឹងដល់អ្នកទេសចរដែលនាំឲ្យប្រជាជនកម្ពុជានិងអ្នកទស្សនាជាជនជាតិបរទេសរាប់សែននាក់ទៅសារមន្ទីរទួលស្លែងបានទស្សនាសំណល់លលាដ៏និងឆ្អឹងដ៏គួរ


ផែនទីកម្ពុជាធ្វើឡើងដោយលលាដ៏និងឆ្អឹង

ឲ្យញញើតនេះនៅលើជញ្ជាំងទំហំ១២ម៉ែត្រការ៉េ ។ នៅមានការដាក់បង្ហាញផ្សេងទៀតនៅក្នុងសារមន្ទីរនិងនៅទីតាំងប្រវត្តិសាស្ត្រដទៃទៀតសម្រាប់អ្នកទេសចរបានដឹងនិងដើម្បីឲ្យអ្នកទាំងនោះអាចទទួលបាននូវការយល់ដឹងកាន់តែប្រសើរអំពីអ្វីដែលពួកគេបានដកស្រង់ចេញពីការធ្វើទស្សនកិច្ចនេះដូចជាតាមរយៈភាពយន្តឯកសារ ពិព័រណ៍រូបថត និងការប្រមូលទិន្នន័យជាដើម ។ អ្នកមកទស្សនាសារមន្ទីរកាន់តែកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំក្នុងនោះរួមមាន សិស្ស និស្សិត អ្នកស្រាវជ្រាវ អ្នករស់រានមានជីវិត ។ល ។ ដោយសារហេតុផលផ្សេងៗគ្នាគឺអ្នកខ្លះមកទស្សនាក្នុងគោលបំណងដើម្បីការសិក្សាចំណេះដឹងទូទៅនិងសម្រាប់អ្នកខ្លះទៀតដើម្បីជាការរំឭកចងចាំដល់សាច់ញាតិមិត្តភក្តិដែលបានស្លាប់ដោយសារជំងឺ ការអត់អាហារ ធ្វើការហួសកម្លាំង និងការសម្លាប់ ។ ដូច្នេះការផ្សព្វផ្សាយប្រាកដជាផ្ដល់នូវបទពិសោធន៍ល្អឲ្យដល់អ្នកទេសចរផ្សេងៗគ្នាទាំងជាតិនិងអន្តរជាតិ ។

## ទស្សនៈគុណធម៌

១) នៅត្រង់ចំនុចនេះវិធីតែមួយគត់ដើម្បីឆ្ពោះទៅមុខគឺត្រូវបំភ្លេចនូវអ្វីដែលបានកើតឡើងហើយ កុំជីរុញលើកតម្កើងឧក្រិដ្ឋកម្មដែលបង្ហាញនូវអំពើដ៏អាក្រក់ដែលមនុស្សបានធ្វើឡើងយ៉ាងឃោរឃៅ ។ ការចងចាំរឿងរ៉ាវនេះគឺដូចជាការផ្ដល់សិទ្ធិអំណាចឲ្យអំពើនេះ ។ ហេតុអ្វីបានជាយើងត្រូវចងចាំរឿងរ៉ាវដែលគួរឲ្យរន្ធត់នេះ?

មនុស្សគ្រប់គ្នាកើតមកសុទ្ធតែមានបាប ។ ការស្លាប់របស់មនុស្សមួយលានប្រាំពីរសែននាក់ដោយសារការអត់ឃ្លានជំងឺ ការធ្វើការហួសកម្លាំង និងការកាប់សម្លាប់ក្នុងរបបខ្មែរក្រហមគឺត្រូវតែស្លាប់ពីព្រោះតែកម្មពៀររបស់អ្នកទាំងនោះ ។ ហេតុអ្វីបានជាត្រូវចំណាយលុយដើម្បីថែរក្សានិងផ្សព្វផ្សាយអំពីរឿងរ៉ាវដែលគួរឲ្យស្អប់ខ្ពើមបែបនេះ? គួរតែយកចិត្តទុកដាក់ទៅលើអ្នកដែលបានរួចជីវិតចេញពីរបបនេះដោយស្វែងរកមធ្យោបាយដើម្បីព្យាបាលជំងឺប៉ះទង្គិចផ្លូវចិត្តដែលអាចមានបង្កផលប៉ះពាល់ទៅលើពួកគេពីរបបនោះនិងជួយអ្នកទាំងនោះឲ្យបំភ្លេចនូវរាល់អំពើហិង្សាទាំងឡាយដែលបានកើតឡើងកាលពីអតីតកាលគឺធ្វើឲ្យពួកគេគិតអំពីជីវិតទៅអនាគតវិញប្រសើរជាង ។

ប្រសិនមនុស្សម្នាក់ធ្វើអំពើអាក្រក់នោះធម្មជាតិឬព្រះជាម្ចាស់នឹងធ្វើឲ្យមនុស្សនោះទទួលផលមកវិញតាមវិធីណាមួយយូរឬឆាប់តាមអំពើអាក្រក់ដែលគាត់បានធ្វើមិនខាន ។ យើងគួរតែទទួលយកនិងបំភ្លេចចោលដោយចាត់ទុកថាអ្វីដែលនឹងកើតឡើងគឺជាផ្នែកមួយនៃធម្មជាតិ ។

២) អតីតកាលគឺជាអតីតកាលហើយគ្មានអ្វីអាចយកបានទេមកវិញទេ ។ ប៉ុន្តែអតីតកាលអាចធ្វើឲ្យមនុស្សដឹងនូវអ្វីដែលបានកើតឡើងដែលអាចនឹងជួយឲ្យមនុស្សធ្វើឲ្យប្រាកដប្រជាថាឧក្រិដ្ឋកម្មបែបនេះនឹងមិនកើតឡើងសាជាថ្មីម្ដងទៀតទេ ។ ដើម្បីធានាអះអាងថាបទឧក្រិដ្ឋកម្មនឹងមិនកើតឡើងម្ដងទៀតនោះគឺជាការចាំបាច់ដែលត្រូវតែផ្សព្វផ្សាយឲ្យបានទូលំទូលាយទូទាំងសកលលោកអំពីឧក្រិដ្ឋកម្មដែលបានកើតឡើងនិងត្រូវរក្សារឿងរ៉ាវនេះទុកជាប្រវត្តិសាស្ត្រដើម្បីឲ្យក្មេងជំនាន់ក្រោយដកស្រង់បទពិសោធន៍ ។ តាមរយៈការផ្សព្វផ្សាយការបង្កើតសកម្មភាពដើម្បីឲ្យអនុវត្តដូចជាការតាំងពិព័រណ៍រូបថតរបស់ជនរងគ្រោះឯកសារអក្សរសាស្ត្រស្ដីអំពី របបនេះដូចជា (សៀវភៅអានផ្ដល់ការ បង្រៀន...) ការថែរក្សារណ្ដៅសាកសពរួម និងទីតាំងប្រល័យពូជសាសន៍ទាំងឡាយគួរតែអាចនិងត្រូវបានជំរុញផ្សព្វផ្សាយដើម្បីសម្រេចគោលដៅទៅបានតាមរយៈការអនុវត្ត ។ ហើយតាមរយៈការអនុវត្តយុត្តិធម៌ត្រូវតែធ្វើចំពោះអ្នកកាន់កាប់ខ្មែរក្រហមក្នុងដំណើរការស្វែងរកភាពត្រឹមត្រូវឲ្យជនរងគ្រោះដើម្បីឲ្យជនរងគ្រោះរស់នៅក្នុងជីវិតរីករាយហើយចំពោះប្រជាជនឯទៀតដូចជាអ្នកទេសចរគួររៀនសូត្រអំពីរឿងរ៉ាវទាំងនេះដោយរំឭកនិងដាស់តឿនដល់អ្នកដទៃទុកជាមេរៀនមួយនិងកុំឲ្យកើតមានម្ដងទៀត ។

មនុស្សម្នាក់ត្រូវទទួលសងនូវបទឧក្រិដ្ឋដែលខ្លួនបានធ្វើដើម្បីឲ្យអ្នកដែលទទួលរងទុក្ខពីអំពើអវិជ្ជមានផ្សេងៗបានធូរស្បើយក្នុងចិត្តដោយបានដឹងថាអ្នកប្រព្រឹត្តខុសត្រូវទទួលការតបស្នងវិញពីឧក្រិដ្ឋកម្មរបស់ខ្លួនហើយ អ្នកដែលធ្លាប់ទទួលរងការឈឺចាប់នឹងមិនមានការឈឺចាប់ម្ដងទៀតទេអំពីស្រមោលពីអតីតកាល ។ យើងត្រូវតែរៀនសូត្រអំពីរឿងរ៉ាវនេះនិងត្រូវតែចេះថែរក្សាដើម្បីជីវិតប្រកបដោយគុណធម៌និងភាពសុខដុមរបស់សង្គម ។ **សេី សាយ្យាណា**

# ការបង្ហាញអំពីគោលបំណងនៃអំពើប្រល័យពូជសាសន៍ ៖ យុត្តិសាស្ត្រអន្តរជាតិ និងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាលើសំណុំរឿង០០២

### (តចប់) ១) លក្ខណៈទូទៅនៃអំពើសាហាវឃោរឃៅ

តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា បានរកឃើញថា ចេតនាប្រល័យពូជសាសន៍របស់ជនដៃដល់ត្រូវបានទាញចេញដោយផ្អែកពី «លក្ខណៈទូទៅនៃអំពើសាហាវឃោរឃៅ» ដែលត្រូវបានប្រព្រឹត្ត ។ ករណីដែលមិនមានការរួមផ្សំផ្សេងទៀត អាចផ្តល់នូវភាពជាក់លាក់ទាក់ទងនឹងខ្លឹមសារច្រើនជាងការទាញពី «បរិបទ» និង «ស្ថានភាព» ។

នៅក្នុងករណី មូហ៊ីម៉ាណា តុលាការអន្តរជាតិនៅក្នុងប្រទេសរ៉្វាន់ដា បានធ្វើកំណត់សម្គាល់ ថាចំណុចដែលទាក់ទងនឹង «លក្ខណៈទូទៅ» នៃអំពើសាហាវឃោរឃៅ មានរួមបញ្ចូលទាំងស្ថានភាពទំហំនិងទីតាំងភូមិសាស្ត្រអាវុធដែលប្រើប្រាស់នៅក្នុងការវាយប្រហារ និងទំហំនៃការខូចខាតទៅលើរូបរាងកាយ ។ ចំណុចនេះ បានបង្ហាញថាលក្ខណៈទូទៅនៃអំពើសាហាវឃោរឃៅ ដូចជាសេចក្តីថ្លែងការណ៍គឺជាចំណុចជាក់ស្តែងដែលតុលាការរកឃើញថាមានការជាប់ទាក់ទងទៅនឹងការទាញទៅដល់ចេតនាប្រល័យពូជសាសន៍ ជាជាងចំណុចមូលដ្ឋានឯករាជ្យមួយដែលអាចបង្ហាញពីបំណងពិរុទ្ធភាពដែលជាប់ពាក់ព័ន្ធរបស់ជនត្រូវចោទ ។ ដូច្នេះ កត្តាមួយចំនួនដែលត្រូវបានបង្ហាញនៅក្នុងករណី មូហ៊ីម៉ាណា ដោយមានឃ្លាដែលនិយាយទាក់ទងនឹង «លក្ខណៈទូទៅ» ដូចជា ទំហំនៃបទល្មើសបច្ចុប្បន្នត្រូវបានដាក់នៅក្នុងយុត្តិសាស្ត្រ ខណៈពេលដែលអ្នកដទៃទៀតនៅតែគិតថាតុលាការអន្តរជាតិ ប្រហែលជាអាច ឬមិនអាចលើកពីករណីនេះដោយផ្អែកទៅលើថាវាមានជាប់ពាក់ព័ន្ធនឹងសំណុំរឿង (ឧទាហរណ៍ ប្រភេទនៃសព្វាវុធដែលប្រើប្រាស់នៅក្នុងការវាយប្រហារ) ។ ប្រហែលជានៅក្នុងការទទួលស្គាល់ការស៊ើបអង្កេតនៃ «បរិបទទូទៅ» និង «លក្ខណៈទូទៅ» របស់ឧក្រិដ្ឋកម្មទាំងពីរនេះពិតជាមិនអាចបែងចែកបាន ការលើកឡើងសាជាថ្មីទាក់ទងនឹងគំរូសម្រាប់ទាញទៅដល់ចេតនាប្រល័យពូជសាសន៍ បានបំបាត់នូវរាល់អំណះអំណាងអំពី «លក្ខណៈទូទៅនៃអំពើសាហាវឃោរឃៅ» ។

### ២) អំពើបំផ្លាញ និងរើសអើង

នៅក្នុងករណី ជេលីស៊ីក សាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីបានបែងចែករវាងគោលដៅកំណត់ជាប្រព័ន្ធទៅលើក្រុមមនុស្សដែលទទួលបានការការពារដែលត្រូវបានគេហៅថា «ការប្រព្រឹត្តសកម្មភាពឧក្រិដ្ឋកម្មដោយផ្ទាល់ទៅលើក្រុមជដែល» និង «ការប្រព្រឹត្តសកម្មភាពបំផ្លាញនិងរើសអើង» ប្រឆាំងនឹងក្រុមនោះ ។ ខណៈពេលដែលតុលាការបានយកកត្តាពីរនេះមកអះអាងចំពោះការទាញទៅដល់ចេតនាប្រល័យពូជសាសន៍តុលាការបានផ្តោតទៅលើការពិភាក្សាវែកញែកអំពីការកំណត់គោលដៅជាប្រព័ន្ធខ្លាំងជាងនិងមិនវែកញែកពីសកម្មភាពបំផ្លាញនិងរើសអើង ។ វាមិនមានភាពច្បាស់លាស់នៅក្នុងយុត្តិសាស្ត្រដែលមានស្រាប់គឺថា តើកត្តាទាំងពីរខុសប្លែកពីគ្នាដែរឬទេ ហើយតើកត្តាទាំងពីរខុសប្លែកពីគ្នាដោយរបៀបណាពី ព្រោះមិនមានករណីណាមួយធ្លាប់បានអនុញ្ញាតឲ្យតុលាការអន្តរជាតិពិនិត្យបកស្រាយលម្អិតទៅលើភាពខុសគ្នាដែលត្រូវបានគេរំពឹងទុក ។ ខណៈពេលដែលមានការបន្តស្វែងរកទៅលើការកំណត់គោលដៅជាប្រព័ន្ធសំណុំរឿងជាបន្តបន្ទាប់របស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសយូហ្គោស្លាវីមិនបានលើកឡើងពីកត្តាសកម្មភាពបំផ្លាញ និងរើសអើងឡើយ ។

### ៣) ការប្រើប្រាស់យុត្តិសាស្ត្រអន្តរជាតិដែលធ្លាប់កើតមានពីមុននៅប្រទេសកម្ពុជា

ខាងក្រោមនេះ គឺជាការពិនិត្យជាមូលដ្ឋានទៅលើវិធីសាស្ត្រនៃការវិភាគតាមផ្លូវច្បាប់ដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងយកមកប្រើប្រាស់ដើម្បីដោះស្រាយសំណុំរឿងប្រល័យពូជសាសន៍០០២ ។ នៅក្នុងការជជែកដេញដោលមុនពេលបង្កើត

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អ្នកច្បាប់ធ្លាប់បានធ្វើការជំទាស់អស់រយៈពេលយ៉ាងយូរ ថាតើអំពើឃោរឃៅដែលឧក្រិដ្ឋជនបានប្រព្រឹត្តនៅក្នុងប្រទេសកម្ពុជាដោយខ្មែរក្រហមគឺជាអំពើប្រល័យពូជសាសន៍ដែរឬអត់? ប្រសិនបើដូច្នេះ តើនឹងប្រើប្រាស់បទល្មើសមួយណា ។ ដូចដែលធ្លាប់បានធ្វើរួចមកហើយ ដោយតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉ាន់ដា និង តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសយូហ្គោស្លាវីនៅក្នុងរឿងក្តីនៅរ៉ាន់ដា និង ស្រ៊ីព្រីនីកា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងត្រូវផ្សារភ្ជាប់ការស៊ើបអង្កេតនូវចំណុចចាប់ផ្តើម ដើម្បីស្វែងរកថាតើអំពើប្រល័យពូជសាសន៍ត្រូវបានប្រព្រឹត្តនៅក្នុងប្រទេសកម្ពុជាធ្លាប់កើតមានឬអត់មុនពេលដោះស្រាយសំណួរផ្សេងទៀតដែលថាតើចុងចោទនឹងត្រូវបានតុលាការដាក់ឲ្យទទួលខុសត្រូវជាបុគ្គលចំពោះសកម្មភាពរបស់ខ្លួនដែរឬទេ ។

### សេចក្តីថ្លែងការណ៍

ដោយដឹងពីភាពសម្ងាត់នៃរបបខ្មែរក្រហម វាមិនទំនងជាមានសេចក្តីថ្លែងការណ៍ជាសាធារណៈច្រើនដែលធ្វើឡើងដោយកម្មាភិបាលជាន់ខ្ពស់ខ្មែរក្រហមដែលអាចបង្ហាញពីចេតនាប្រល័យពូជសាសន៍ទេ ។ សេចក្តីថ្លែងការណ៍ដែលធ្លាប់កើតមានមិនទំនងជាច្បាស់លាស់ដូចចំណុចដែលលើកឡើងដោយតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉ាន់ដាឡើយ ។ ប៉ុន្តែ ព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាប្រហែលជាអនុម័តយុត្តិសាស្ត្រដែលស្រដៀងនឹងយុត្តិសាស្ត្រដែលកំពុងតែប្រើប្រាស់ដោយព្រះរាជអាជ្ញានៅតុលាការព្រហ្មទណ្ឌអន្តរជាតិដែរនិងចង្អុលបង្ហាញពីសេចក្តីថ្លែងការណ៍ដែលធ្វើឡើងដោយកម្មាភិបាលថ្នាក់ក្រោមដែលបង្កឲ្យមេដឹកនាំជាន់ខ្ពស់ទទួលការជំនុំជម្រះ ។ វាមិនមានភាពច្បាស់លាស់ថាតើយុត្តិសាស្ត្រអាចធ្វើឲ្យតុលាការទទួលបានជោគជ័យឬក៏អត់ទេ ។

### ទំហំ

អំពើសាហាវឃោរឃៅដែលធ្វើឡើងដោយខ្មែរក្រហមគឺមិនអាចកំណត់បានទេ ប៉ុន្តែយ៉ាងហោចណាស់ចំពោះការធ្វើទៅលើជនជាតិចាមមូស្លីមអាចធ្វើឲ្យយើងទាញទៅដល់ចេតនាប្រល័យពូជសាសន៍បាន ។ ទោះបីជាចំនួនមិនអាចធ្វើការកំណត់ចំនួនជាក់លាក់ក៏ដោយ លោក ឆាំង យុ មជ្ឈមណ្ឌលឯកសារកម្ពុជាបានប៉ាន់ប្រមាណថា មានប្រជាជនចាមពីមួយសែនទៅបួនសែននាក់ស្លាប់នៅក្នុងរបបខ្មែរក្រហម ។ ចំនួនស្លាប់នៃជនជាតិចាមជាក់លាក់កាន់តែគួរឲ្យភ្ញាក់ផ្អើលទៅទៀតនៅពេលដែលយើងគិតថាមានប្រជាជនចាមតែ២៥០,០០០នាក់ប៉ុណ្ណោះដែលនៅរស់មកដល់សព្វថ្ងៃ ។ មានអ្នកខ្លះប៉ាន់ប្រមាណថាមានប្រជាជនចាមប្រមាណ ១០០,០០០នាក់នៅក្នុងចំណោម ២៥០,០០០នាក់នៅក្នុងឆ្នាំ១៩៧៥ ត្រូវបានសម្លាប់ក្នុងរយៈបួនឆ្នាំនៅក្រោមការគ្រប់គ្រងដោយខ្មែរក្រហម ។

ភ័ស្តុតាងទាក់ទងនឹងជនជាតិភាគតិចវៀតណាម និងពុទ្ធសាសនិកមិនមានភាពច្បាស់លាស់ទេ ។ ជាមួយនឹង «ការសម្លាប់អ្នកនៅសល់របស់ខ្មែរក្រហម» ភ័ស្តុតាងប្រវត្តិសាស្ត្របានបង្ហាញថាភាគច្រើននៃជនជាតិភាគតិចវៀតណាមគឺជាគោលដៅដែលខ្មែរក្រហមត្រូវកម្ចាត់ ។ ទោះបីជាយ៉ាងណាក៏ដោយ នៅមិនទាន់មានចំនួនប៉ាន់ប្រមាណជាក់លាក់ទៅលើចំនួនស្លាប់នៃជនជាតិភាគតិចវៀតណាមទេ ។ ចំពោះពុទ្ធសាសនិក ទំហំនៃបំណងពិរុទ្ធប្រល័យពូជសាសន៍មានកំណត់ដោយសារតែចំនួនអ្នកគោរពសាសនា (ឧទាហរណ៍ ព្រះសង្ឃ និងភិក្ខុ) ។

### ការកំណត់គោលដៅជាក់លាក់

ចំពោះករណីជាច្រើន កត្តាកំណត់គោលដៅជាក់លាក់បានរារាំងដល់ការស្វែងរកចេតនាប្រល័យពូជសាសន៍នៅក្នុងបរិបទខ្មែរក្រហម ។ មានការសង្កេតឃើញថា ចាម «បានទទួលការឈឺចាប់យ៉ាងធំធេង» នៅក្រោមច្បាប់របស់ខ្មែរក្រហម «ពីព្រោះរបបនេះបានបំបែកគ្រួសារ ហាមឃាត់មិនឲ្យនិយាយភាសារបស់ខ្លួននិងប្រពៃណី ហើយសម្លាប់មេដឹកនាំរបស់អ្នកទាំងនោះ» ។ បន្ថែមពីលើនេះទៅទៀត ជនជាតិភាគតិចវៀតណាមជាគោលដៅនៃការកម្ចាត់ ។ ហើយទាំងសាសនាមូស្លីមនិងសាសនាព្រះពុទ្ធបានទទួលរងការវាយប្រហារជាខ្លាំង ។ ទាំងអស់នេះ គឺជាធាតុផ្សំនៃចេតនាដែលតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសយូហ្គោស្លាវី និងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉ាន់ដាបានរកឃើញថាមានទាក់ទងទៅនឹងចេតនាប្រល័យពូជសាសន៍នៅក្នុងអតីតកាល ។

ប៉ុន្តែខណៈដែលយុត្តិសាស្ត្រតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា និងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសយូហ្គោស្លាវី បានបង្ហាញថាចំណុចសំខាន់ក្នុងការកំណត់គោលដៅ គឺមិនត្រូវបានតម្រូវឲ្យប្រើប្រាស់ជាមួយធាតុផ្សំនេះដើម្បីបង្កើតភាពជាប់ពាក់ព័ន្ធ ការខ្វះនូវចំណុចដែលថាមេដឹកនាំខ្មែរក្រហមបានកំណត់គោលដៅចំពោះប្រជាជនចាម-មូស្លីម, ជនជាតិភាគតិចវៀតណាម និងអ្នកដែលគោរពសាសនាព្រះពុទ្ធនឹងផ្តល់ការលំបាកដល់ព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក្នុងការបង្ហាញពីបំណងជាក់លាក់របស់មេដឹកនាំខ្មែរក្រហមដែលចង់បំផ្លាញក្រុមទាំងនេះ ។

ការកំណត់គោលដៅយ៉ាងទូលាយទៅលើផ្នែកជាច្រើននៃសង្គមបានបង្ហាញថា ខ្មែរក្រហមប្រហែលជាមិនបានផ្តោតទៅលើក្រុមជាក់លាក់ណាមួយដែលត្រូវការពារដោយអនុសញ្ញាអំពើប្រល័យពូជសាសន៍ទេ ។ ខណៈពេលដែលអ្នកសង្កេតការណ៍បានអះអាងថា ជនជាតិភាគតិចវៀតណាម និងចាមមូស្លីមត្រូវបានកំណត់គោលដៅដោយខ្មែរក្រហមការទាញទៅដល់ការកំណត់គោលដៅនេះមានភាពខ្សោយជាងស្ថានភាពនៅប្រទេសរ៉្វាន់ដា, ដាហ្វ័រ និង ស្រ៊ីព្រីនីកា ដែលនៅទីនោះក្រុមទទួលបានការការពារនៅជិតគោលដៅនៃការធ្វើទុក្ខបុកម្នេញ ។

គួរកត់សម្គាល់ថា ទោះបីជាព្រះរាជអាជ្ញាររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសយូហ្គោស្លាវីនៅក្នុងករណីក្រាទីក ក៏បានប្រឈមមុខនឹងការលំបាកក្នុងការកំណត់គោលដៅដែរ ពីព្រោះក្រុមដែលត្រូវបានកំណត់មានចំនួនកំណត់ទៅតាមតំបន់ ភូមិសាស្ត្រតូចមួយនៅ ស្រ៊ីព្រីនីកា ដែលក្នុងនោះមានចំនួនប្រជាជនច្រើនជាង៣៦,០០០នាក់ រស់នៅមុនពេលមានការសម្លាប់រង្គាល ហើយដែលតំបន់មួយនោះមានផ្ទៃដីត្រឹមតែ៥២៧គីឡូម៉ែត្រការ៉េប៉ុណ្ណោះ ។ ព្រះរាជអាជ្ញាបានដោះស្រាយនូវបញ្ហានេះ ដោយរៀបចំក្រុមដែលពាក់ព័ន្ធសាឡើងវិញ ពីព្រោះមានតែជនជាតិមូស្លីមនៅបូស្នៀរស់នៅតំបន់នោះប៉ុណ្ណោះ ។ នេះគឺជាការបែងចែក ដែលសាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិបានទទួលស្គាល់ ។ តាមរយៈអ្វីដែលធ្លាប់មានពីមុននេះ សហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ប្រហែលជាអាចសម្រេចការងារបានល្អជាងមុនប្រសិនបើសហព្រះរាជអាជ្ញាអាចបញ្ជាក់ ឬបំបែកតំបន់ផ្សេងគ្នាដែលមានចាម និងវៀតណាមរស់នៅ ។ ខណៈពេលដែលករណី ក្រាទីកប្រហែលជាមិនអាចយកប្រើប្រាស់នៅចំណុចនេះ ពីព្រោះតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី បានលើកឡើងថាទីតាំងភូមិសាស្ត្រគួរតែត្រូវបានកំណត់ដោយយោងទៅតាមអំណាចគ្រប់គ្រងរបស់ជនដៃដល់ហើយខ្មែរក្រហមគ្រប់គ្រងទឹកដីកម្ពុជាស្ទើរតែគ្រប់តំបន់ករណីនេះអាចនឹងផ្តល់ជាគំរូមួយដល់ព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

ដូចដែលបានរៀបរាប់ខាងលើ សហព្រះរាជអាជ្ញាទំនងជាមិនចោទប្រកាន់ខ្មែរក្រហមថា មានបំណងសម្លាប់ព្រះសង្ឃទេ ប៉ុន្តែបែរជាពឹងផ្អែកទៅលើអង្គហេតុដែលថារបបនោះ «មិនអនុញ្ញាតឲ្យព្រះសង្ឃ ក៏ដូចជាអ្នកកាន់ព្រះពុទ្ធសាសនាប្រណិប័តន៍សាសនាដែរ ហើយបានសម្លាប់អ្នកដែលនៅរឹងទទឹង» ។ ដោយផ្អែកទៅលើយោបល់ជំទាស់របស់ចៅក្រម ហ្សាហាប៊ូឌិន នៅក្នុងករណី ក្រាទីក ព្រះរាជអាជ្ញា អះអាងថាការសម្លាប់ទាំងនេះ រួមជាមួយការបង្ហាញពីបំណងរបស់ខ្មែរក្រហមចង់លុបបំបាត់ការប្រណិប័តន៍របស់សាសនិកជននៅក្នុងតំបន់ដែលខ្លួនគ្រប់គ្រង បានបង្ហាញពីបំណងប្រល័យពូជសាសន៍ទៅលើអ្នកកាន់ព្រះពុទ្ធសាសនា ។ គំនិតដ៏ឆ្លាតនេះស្ថិតនៅក្រោយយុត្តិសាស្ត្រដែលមានស្រាប់ ។ ដើម្បីសម្រេចបានជោគជ័យ ទ្រឹស្តីបែបនេះតម្រូវឲ្យអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទទួលស្គាល់ការគាត់តែងសាជាថ្មីទាក់ទងនឹងក្រុមដែលពាក់ព័ន្ធ (ឧទាហរណ៍ ព្រះសង្ឃជាជាងអ្នកដែលគ្រាន់តែគោរពព្រះពុទ្ធសាសនា) ឬការគាត់តែងពីបំណងប្រល័យពូជសាសន៍ដែលមិននិយាយពីទស្សនៈប្រពៃណីដូចជាការបំផ្លាញលើរូបរាងកាយ ហើយការធ្វើបែបនេះប្រហែលជាអាចធ្វើឲ្យមានការគិតទៅដល់ «ការប្រល័យពូជសាសន៍វប្បធម៌» ។

ជាទីបញ្ចប់ ព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទំនងជាត្រូវតែយកឈ្នះទៅលើការអះអាងដែលថា ការដៅមុខសញ្ញាទៅលើក្រុមទទួលបានការការពារគឺដោយសារតែមូលហេតុយោធាខ្មែរក្រហម និងគោលដៅនៃមនោគមន៍វិជ្ជា ។ ជាក់ស្តែង ព្រះរាជអាជ្ញាទំនងជាត្រូវជួបប្រទះនឹងការអះអាង

ដែលថាការដាក់មុខសញ្ញាទៅលើចាមមូស្លីមមួយចំនួនគឺដោយសារតែការរឹងទទឹងប្រឆាំងនឹងកំណែទម្រង់នយោបាយរបស់របប ។ មេធាវីការពារក្តីប្រាកដជាលើកឡើងពីការបះបោររបស់ចាមដែលបណ្តាលឲ្យមានការស្លាប់ប្រជាជនចាមមួយចំនួនធំ គឺទាក់ទងនឹងទិសដៅនយោបាយរបស់ខ្មែរក្រហម ។ ដើម្បីឆ្លើយតបនឹងការអះអាងនេះ ព្រះរាជអាជ្ញាទំនងជាត្រូវលើកឡើងថា ខ្មែរក្រហមបានដាក់មុខសញ្ញាទៅលើអ្នកតស៊ូ និងអ្នកដែលមិនបានតស៊ូ (ដូចជាស្ត្រី មនុស្សចាស់ និងក្មេងៗ) ដូចគ្នា ។

មិនមានការពិចារណាកាលពីមុនណាបង្ហាញយ៉ាងដាក់លាក់ថា មិនអាចមានការអះអាងថាអំពើប្រល័យពូជសាសន៍ធ្លាប់កើតមាននៅក្នុងរបបខ្មែរក្រហមទេ ។ ជាងនេះទៅទៀត ការពិនិត្យពីខាងក្រោយយ៉ាងល្អិតល្អន់ថា តើគួរយកតម្រាប់តាមការអនុវត្តរបស់អន្តរជាតិ និងអ្វីដែលធ្លាប់មានពីមុនមកដើម្បីទាញទៅដល់បំណងប្រល័យពូជសាសន៍នៅក្នុងករណីនេះគឺមានលក្ខណៈមិនច្បាស់នៅឡើយទេ ពីព្រោះឯកសារចោទប្រកាន់របស់ព្រះរាជអាជ្ញា និងភ័ស្តុតាងដាក់លាក់មួយចំនួនដែលពឹងផ្អែកទៅលើឯកសារទាំងនោះនៅមិនទាន់បង្ហាញចេញមកក្រៅនៅឡើយ ។ អត្ថបទនេះ នឹងមិនដោះស្រាយចំពោះបញ្ហានេះទេ ។ ផ្នែកនេះគ្រាន់តែបង្ហាញពីបញ្ហាសំខាន់ និងផ្តល់ជាការវាយតម្លៃដំបូងថាតើអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងដោះស្រាយបញ្ហានេះដោយរបៀបណា ។

បន្ថែមពីលើនេះទៅទៀត ផ្នែកនេះមានជាប់ពាក់ព័ន្ធនឹងសំណួរចម្បងថាតើខ្មែរក្រហមមានប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ប៉ុន្តែមិនបានស្វែងរកថាតើចុងចោទនៅក្នុងករណី០០២ មានបំណងប្រល័យពូជសាសន៍ឬទេ ។ អាចមានការផ្តោតទូទៅមួយចំនួនទៅលើការទទួលខុសត្រូវរបស់បុគ្គលនៅក្នុងបរិបទប្រទេសកម្ពុជា ។ ភាពខុសគ្នារវាងយុត្តិសាស្ត្រផ្ទៃក្នុងរបស់ខ្មែរក្រហមនិងរបបហ៊ីទូ ដើម្បីគោលដៅសម្លាប់ដែលបានរៀបរាប់ខាងលើបង្ហាញថាការបង្ហាញពីភាពឃោរឃៅរបស់មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម មានលក្ខណៈងាយស្រួលជាងការបង្ហាញនៅរ៉្វាន់ដា ។ ភាពគ្មានវិន័យ ច្របូកច្របល់ និង ភាពដើមនៃអំពើប្រល័យពូជសាសន៍នៅរ៉្វាន់ដាបានបង្ខំឲ្យតុលាការព្រហ្មទណ្ឌអន្តរ ជាតិសម្រាប់ប្រទេសរ៉្វាន់ដា ពឹងផ្អែកទៅលើការអះអាងពីអំពើពិរុទ្ធប្រល័យពូជសាសន៍ ឬបង្កើតជាភ័ស្តុតាងដាក់លាក់ដែលថាជនត្រូវចោទបានចូលរួមដោយផ្ទាល់នៅក្នុងសកម្មភាពប្រល័យពូជសាសន៍ (ដូចជាការសម្លាប់ ការចាប់រំលោភ និងការចែកចាយសព្វាវុធទៅឲ្យអ្នកដែលមានបំណងប្រល័យពូជសាសន៍ដាក់លាក់) ។ ស្រដៀងគ្នានឹងមន្ត្រីយោធានៅ ស៊ែបប៊ី ដែលត្រូវបានចោទប្រកាន់ដោយតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី មេដឹកនាំខ្មែរក្រហមនៅក្នុងករណី០០២ មានតំណែងខ្ពស់នៅក្នុងយោធា និងនៅក្នុងរចនាសម្ព័ន្ធស៊ីវិល ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ប្រហែលជាស្វែងរកកិច្ចការបែបនេះដើម្បីទាញទៅដល់បំណងប្រល័យពូជសាសន៍របស់មេដឹកនាំជាន់ខ្ពស់នៅក្នុងបរិបទ ឬកាលៈទេសៈដែលប្រព្រឹត្តឡើងដោយកម្មាភិបាលថ្នាក់ក្រោម ។ ការចោទប្រកាន់អំពើប្រល័យពូជសាសន៍ដ៏ជោគជ័យ នៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីមានជាប់ពាក់ព័ន្ធនឹងមន្ត្រីយោធាថ្នាក់ទាបដែលត្រូវបានតុលាការកំណត់ថាបានជួយ និងជំរុញឲ្យមានអំពើប្រល័យពូជសាសន៍ ប៉ុន្តែមិនបានប្រព្រឹត្តដោយផ្ទាល់ ។ មានការកំណត់ពីចេតនានៃការជួយ និងជំរុញមួយចំនួន ប៉ុន្តែ វាមិនសូវជាត្រូវបានគេទទួលស្គាល់ថាវាអាចធ្វើជាជំនួយសម្រាប់ដាក់ឲ្យជនណាម្នាក់ទទួលខុសត្រូវដោយផ្ទាល់ទៅលើការបញ្ជាបានឡើយ ។

**វ៉ៃអ៊ិន អ៊ី.ផាក**

## កម្មវិធីអប់រំអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

វិទ្យុផ្សាយសំឡេងសហរដ្ឋអាមេរិកជាភាសាខ្មែរនឹងធ្វើការចាក់ផ្សាយកម្មវិធីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ» ដែលនិពន្ធដោយលោក ឌី ខាំបូលី ដែលអ្នកទាំងអស់គ្នាអាចស្តាប់ផងចម្លងនិងអានសាច់រឿងដែលមាននៅក្នុងសៀវភៅនេះតាមរយៈគេហទំព័រ *http://www.voanews.com/ khmer/democratic-kampuchea.cfm* របស់វិទ្យុផ្សាយសំឡេងសហរដ្ឋអាមេរិកជាភាសាខ្មែរ ។

**មជ្ឈមណ្ឌលឯកសារកម្ពុជា**

# យុត្តិសាស្ត្រនីតិវិធីដែលធ្វើឱ្យមានប្រសិទ្ធភាពផ្នែកប្រព័ន្ធតុលាការដែលមិនយកមកប្រើ

តុលាការព្រហ្មទណ្ឌអន្តរជាតិតែងតែធ្វើការរិះគន់អំពីភាពខ្វះខាតនៃប្រសិទ្ធភាព ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ក៏ដូចគ្នាដែរ ខណៈពេលដែលទាំងម្ចាស់ជំនួយនិងជនរងគ្រោះបានធ្វើការរិះគន់អំពីដំណើរការការិយាធិបតេយ្យនិងភាពយឺតយ៉ាវក្នុងការនាំយកអ្នកដែលត្រូវទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលកើតមាននៅអំឡុងរបបខ្មែរក្រហមទៅកាត់ទោស ។ ជាងនេះទៅទៀត ជនត្រូវចោទ និងជនរងគ្រោះផ្សេងទៀតកំពុងតែមានអាយុចំណាស់ដែលធ្វើឲ្យតុលាការមិនត្រឹមតែត្រូវរក្សាភាពដែលធ្វើឲ្យគេជឿទុកចិត្តនិងថវិកាតែថែមទាំងត្រូវធានាថាដំណើរការនីតិវិធីនឹងបញ្ចប់មុនពេលភាគីដែលជាប់ពាក់ព័ន្ធស្លាប់ ។ ទោះបីជា អ.វ.ត.ក មានរចនាសម្ព័ន្ធប្លែកពីគេក៏ អ.វ.ត.ក គួរតែអនុម័តយុត្តិសាស្ត្រនីតិវិធីដែលប្រើប្រាស់ដោយតុលាការព្រហ្មទណ្ឌអន្តរជាតិដើម្បីជាផលចំណេញដល់តុលាការ ។

យុត្តិសាស្ត្រនៃការកំណត់ដោយតុលាការគឺជាគោលការណ៍នីតិវិធីដែលត្រូវបានប្រើប្រាស់នៅក្នុងយុត្តិសាស្ត្រច្បាប់ខមិនឡូនិងច្បាប់ស៊ីវិលដើម្បីជំរុញប្រសិទ្ធិភាពនៃប្រព័ន្ធតុលាការ ។ វាក៏មានវត្តមាននៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិដែរ ។ ការកំណត់ដោយតុលាការគឺជាការទទួលស្គាល់អង្គហេតុដែលហួសពីការជជែកវែកញែកដោយមិនចាំបាច់មានភស្តុតាងដើម្បីបញ្ចៀសនូវការអះអាងដែលមិនចាំបាច់និងដដែលៗ ។ ការធ្វើបែបនេះអាចជំរុញល្បឿននៃការជំនុំជម្រះក្តីហើយនៅក្នុងបរិបទតុលាការព្រហ្មទណ្ឌអន្តរជាតិវាអាចកាត់បន្ថយយុត្តិសាស្ត្រដំបូងដែលតែងតែប្រើប្រាស់ដើម្បីវាយតម្លៃទៅលើការទទួលខុសត្រូវជាបុគ្គលដូចជា ការកសាងអង្គហេតុទាក់ទងនឹងប្រវត្តិសាស្ត្រ ។ ផលប្រយោជន៍មួយទៀតគឺថាការកំណត់ដោយតុលាការអាចយកមកប្រើប្រាស់នៅពេលធ្វើការសម្រេចចិត្តនិងដើម្បីបង្កើតកំណត់ត្រាប្រវត្តិសាស្ត្រ ។ តាមការពិតរបាយការណ៍ជំនាញរបស់អង្គការសហប្រជាជាតិឆ្នាំ១៩៩៩ដែលទាក់ទងនឹងដំណើរនិងមុខងាររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិបានស្នើមានការប្រើប្រាស់ការកំណត់ដោយតុលាការច្រើនជាងមុនដើម្បីជំរុញប្រសិទ្ធភាពនៃតុលាការ ។

អ.វ.ត.ក មានលក្ខណៈខុសប្លែកពីតុលាការព្រហ្មទណ្ឌអន្តរជាតិដទៃដោយសារតែបានរួមបញ្ចូលនូវច្បាប់កម្ពុជានិងអន្តរជាតិដែលបង្កើតឲ្យមានតុលាការចម្រុះដែលជាអង្គភាពឯករាជ្យមួយនៅក្នុងរចនាសម្ព័ន្ធតុលាការកម្ពុជា ។ ជាលទ្ធផល ដោយស្របទៅតាមការងាររបស់ អ.វ.ត.ក និងយុត្តិសាស្ត្រជាបន្តបន្ទាប់នៅពេល



ចៅក្រមកំពុងដើរចូលបន្ទប់សវនាការ

កំណត់វិធាននីតិវិធី អ.វ.ត.ក ត្រូវតែពិនិត្យលើវិធានផ្ទៃក្នុងមុន បន្ទាប់មក ត្រូវពិនិត្យលើក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាហើយនៅទីបញ្ចប់ត្រូវពិនិត្យលើបទដ្ឋានអន្តរជាតិ ។ វិធានផ្ទៃក្នុងមិនបានផ្ដល់សេចក្ដីណែនាំជាក់លាក់ទាក់ទងនឹងគោលការណ៍នៃការកំណត់ដោយតុលាការទេ ហើយក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាដែលដោះស្រាយនឹងការកំណត់របស់តុលាការសម្រាប់នីតិវិធីក្នុងស្រុកក៏ដូច្នោះដែរ ។

អាស្រ័យហេតុនេះ អ.វ.ត.ក ប្រហែលជាត្រូវពិនិត្យមើលយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិផ្សេងទៀត ដើម្បីស្វែងរកការណែនាំស្ដីពីបែបបទនៃការកំណត់ដោយតុលាការ ។

**ការកំណត់ដោយតុលាការ ៖ បទដ្ឋានអន្តរជាតិ**

តុលាការអន្តរជាតិរួមទាំងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូននិងតុលាការព្រហ្មទណ្ឌអន្តរជាតិនានាសុទ្ធតែមានវិធាននីតិវិធីរបស់ខ្លួនដែលអនុញ្ញាតឲ្យតុលាការអាចធ្វើការកំណត់បាន ។




ជាក់ស្ដែង តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដានិងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីបានបង្កើតវិធានដូចគ្នាពីរគឺៈ

ទីមួយ តុលាការត្រូវតែធ្វើការកំណត់ទៅលើអង្គហេតុទូទៅ

ទីពីរ តុលាការប្រហែលជាត្រូវធ្វើការកំណត់ដោយឆន្ទានុសិទ្ធិទៅលើអង្គហេតុដែលត្រូវបានសម្រេចកាលពីមុនដោយដំណើរការណ៍នីតិវិធីផ្សេងទៀត ។ ផ្នែកទាំងពីរនៃវិធាននេះត្រូវបានយកមកប្រើប្រាស់ដើម្បីពន្លឿនដំណើការនីតិវិធីដែលអាចប្រឈមមុខនឹងភាពយឺតយ៉ាវដោយសារតែការអះអាងដែលមិនចាំបាច់និងដដែលដែលហួសពីការជជែកវែកញែក ។ ការធ្វើការកំណត់ទៅលើអង្គហេតុទូទៅគឺជាការអនុវត្តន៍ដែលត្រូវបានប្រើប្រាស់នៅក្នុងយុត្តាធិការក្នុងស្រុកនិងតុលាការព្រហ្មទណ្ឌអន្តរជាតិ ។ ដោយប្រើប្រាស់យន្តកម្មនេះតុលាការត្រូវធ្វើការកំណត់ទៅលើអង្គហេតុដែលត្រូវបានគេទទួលស្គាល់នៅលើពិភពលោក អាស្រ័យហេតុនេះ វាហួសពីការជជែកវែកញែក ។

ជាឧទាហរណ៍ អង្គហេតុនៃទីតាំងភូមិសាស្ត្រនិងប្រវត្តិសាស្ត្រតែងតែត្រូវបានតុលាការធ្វើកំណត់សម្គាល់ ។ នៅក្នុងករណីចាំបាច់ការកំណត់ដោយតុលាការទៅលើអង្គហេតុទូទៅបានធ្វើឲ្យភ័ស្តុតាងដែលមានក្លាយជាមិនចាំបាច់ ។ ទោះបីជាយ៉ាងណាក៏ដោយការកំណត់ដោយតុលាការទៅលើអង្គហេតុដែលត្រូវបានសម្រេចគឺជាយន្តការពិសេសមួយនៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិហើយវាបានផ្ដល់ជាផ្លូវមួយដើម្បីការពារផលប្រយោជន៍របស់តុលាការ ។ តុលាការបានធ្វើការកំណត់អង្គហេតុដែលត្រូវបានសម្រេចនៅក្នុងដំណើរការនីតិវិធីមុនៗដោយឆន្ទានុសិទ្ធិ ទោះបីជាដំណើរការនីតិវិធីទាំងនោះមានជាប់ពាក់ព័ន្ធនឹងភាគីដទៃក៏ដោយ ។ អាស្រ័យហេតុនេះ នៅពេលដែលតុលាការធ្វើការកំណត់ទៅលើអង្គហេតុដោយមធ្យោបាយនេះ វាអាចបង្កើតជាការសន្និតមួយដែលអាចនឹងត្រូវបានយកមកដេញដោលនៅពេលជំនុំជម្រះ ។ ដូច្នេះ សិទ្ធិរបស់ភាគីត្រូវបានការពារ ខណៈពេលដែលប្រសិទ្ធភាពនៃតុលាការត្រូវបានបង្កើនឡើង ។

យុត្តិសាស្ត្រអន្តរជាតិក៏បានបង្កើតដែនកំណត់ក្នុងការកំណត់អង្គហេតុដែរ ។ ជាឧទាហរណ៍ នៅពេលសម្រេចថាតើត្រូវធ្វើការកំណត់ទៅលើអង្គហេតុដែលត្រូវបានសម្រេចពីមុនរួចមកហើយ តុលាការត្រូវពិចារណាទៅលើកត្តាផ្សេងៗដូចជាថាតើជាអង្គហេតុអាចមានសារសំខាន់ចំពោះច្បាប់ឬក៏អត់ថាតើអង្គហេតុមានជាប់ពាក់ព័ន្ធនឹងសកម្មភាព ការដឹកនាំ ឬស្ថានភាពផ្លូវចិត្តរបស់ជនត្រូវចោទឬក៏អត់ និងថាតើត្រូវពន្យារពេលសើរើសំណុំរឿងឬក៏អត់ ។ ទោះបីជាមានការពេញចិត្តនឹងលក្ខណៈវិនិច្ឆ័យជាច្រើនដែលត្រូវបានបង្កើតឡើងដោយអ្វីដែលធ្លាប់កើតមានពីមុនក៏ដោយ ក៏តុលាការប្រហែលជាត្រូវពិចារណាថា តើការកំណត់ដោយតុលាការទៅលើអង្គហេតុអាចផ្តល់យុត្តិធម៌ដែរឬទេ ។

ជាទូទៅ ការកំណត់ដោយតុលាការទៅលើអង្គហេតុដែលរួមមានចរិកលក្ខណៈច្បាប់តែងតែត្រូវបានគេចៀសវាងមិនយកមកប្រើ ។ នៅក្នុងសេចក្តីសម្រេចរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាលើករណី ការីម៉េរ៉ា ឆ្នាំ២០០៦ សាលាឧទ្ធរណ៍បានប្រើប្រាស់ការកំណត់ដោយតុលាការទៅលើអំពើប្រល័យពូជសាសន៍នៅរ៉្វាន់ដាថាជាការយល់ដឹងទូទៅ ។ តុលាការបានពឹងផ្អែកទៅលើ «សៀវភៅ អត្ថបទ របាយការណ៍ សារព័ត៌មាន សេចក្តីសម្រេចនិងរបាយការណ៍របស់អង្គការសហប្រជាជាតិ សេចក្តីសម្រេចរបស់តុលាការជាតិនិងរបាយការណ៍របស់អង្គការក្រៅរដ្ឋាភិបាលនិងរដ្ឋាភិបាលជាច្រើន» ដើម្បីកំណត់ថាតុលាការ «មិនចាំបាច់ស្វែងរកឯកសារបន្ថែម» ពីព្រោះអំពើប្រល័យពូជសាសន៍នៅរ៉្វាន់ដាគឺជា «អង្គហេតុដែលជាក់ស្តែងដូចជាអង្គហេតុដទៃ» ។ សេចក្តីសម្រេចនេះទទួលបានការរិះគន់ជាច្រើន ពីព្រោះអំពើប្រល័យពូជសាសន៍នៅរ៉្វាន់ដាគឺជាការកំណត់ច្បាប់មួយដែលតម្រូវឲ្យមានការអះអាងបញ្ជាក់ទៅលើធាតុដែលមានចេតនាពិសេស ដូច្នេះវាមិនស័ក្តិសមឲ្យតុលាការធ្វើការកំណត់ទេ ។ មានអ្នកខ្លះបានស្នើថា ការផ្តល់សម្អាងរបស់តុលាការក៏មានលក្ខណៈមិនត្រឹមត្រូវដែរពីព្រោះភ័ស្តុតាងពឹងផ្អែកទៅលើរឿងរ៉ាវដែលអាចយកមកអះអាងតែនៅក្នុងបរិបទសង្គម និងមនុស្ស ហើយវាតែងតែសំដៅទៅលើឧក្រិដ្ឋកម្មទ្រង់ទ្រាយធំដែលពឹងផ្អែកទៅលើមូលហេតុនៃការរើសអើងនិងមិនត្រូវបានគេជឿថាអាចគ្របដណ្តប់ទាំងអស់ទៅលើស្ថានភាពនៃនិយមន័យច្បាប់ទេ ។

**សក្តានុពលនៃដំណើរការនីតិវិធី**

អ.វ.ត.ក អាចទទួលបានផលប្រយោជន៍ពីការប្រើប្រាស់ការកំណត់ដោយតុលាការជានីតិវិធីភ័ស្តុតាង ។ ដំបូង តុលាការប្រហែលជាយល់ថាវាមានសារប្រយោជន៍ក្នុងការកំណត់អង្គហេតុដែលពាក់ព័ន្ធនឹងដំណើរការនីតិវិធី ។ ជាក់ស្តែង យុត្តាធិការបណ្តោះអាសន្នសង្ខេបរបស់ អ.វ.ត.ក ពី ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ទៅដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ បានប្រើប្រាស់ការកំណត់ដោយតុលាការទៅលើអង្គហេតុប្រវត្តិសាស្ត្រពីព្រោះព្រឹត្តិការណ៍នៃរបបខ្មែរក្រហមត្រូវបានអ្នកស្រាវជ្រាវ បញ្ញវន្ត និងអ្នកប្រវត្តិសាស្ត្រជាច្រើនចងក្រងទុករួចទៅហើយ ។ អាស្រ័យហេតុនេះ តុលាការអាចពឹងផ្អែកស្ទើរតែទាំងស្រុងទៅលើអង្គហេតុទាំងនេះនៅក្នុងដំណើរការនីតិវិធីជាច្រើន ។

ជាងនេះទៅទៀត ទោះបីជាតុលាការមានយុត្តាធិការមានកំណត់ ហើយប្រហែលជាប្រើប្រាស់សំណុំរឿងតិចតួចជាងតុលាការអន្តរជាតិផ្សេងទៀត ឧក្រិដ្ឋកម្មដែលតុលាការនឹងយកមកកាត់ទោសទំនងជារួមបញ្ចូលបរិបទជាក់ស្តែងដែលដដែលៗ ឬបញ្ហាច្បាប់និងឧក្រិដ្ឋកម្ម ។ នេះប្រហែលជាអនុញ្ញាតឲ្យមានការប្រើប្រាស់ការកំណត់ដោយតុលាការទៅលើអង្គហេតុដែលត្រូវបានសម្រេចនៅក្នុងដំណើរការនីតិវិធីកាលពីមុន ។ ឧទាហរណ៍ ប្រសិនបើអង្គហេតុដែលត្រូវបានសម្រេចនៅក្នុងករណី ០០១ មានជាប់ពាក់ព័ន្ធនឹងករណី០០២ ឬដំណើរការនីតិវិធីផ្សេងទៀត អ.វ.ត.ក ប្រហែលជាត្រូវសម្រេចប្រើប្រាស់ការកំណត់ដោយតុលាការដែលត្រូវបានសម្រេចរួចអាចបង្កើតជាការសន្សំមួយនិងអាចត្រូវបានដេញដោលនៅពេលជំនុំជម្រះ ។

ដូច្នេះ ការកំណត់ដោយតុលាការផ្តល់នូវឱកាសសម្រាប់ពន្លឿនដំណើរការជំនុំជម្រះក្តីនៅ អ.វ.ត.ក និងអាចការពារសិទ្ធិរបស់ជនត្រូវចោទ ។ ប្រសិនបើមានការអនុវត្តឲ្យស្របទៅតាមបទដ្ឋានអន្តរជាតិ ភាគីដែលមានផលប្រយោជន៍ប្រហែលជាអាចទ្រាំទ្រនឹងថេរវេលានៃដំណើរការនីតិវិធីតុលាការក៏ទំនងជាអាចរក្សាស្ថិរភាពផ្នែកហិរញ្ញវត្ថុ ហើយយុត្តិធម៌ក៏អាចត្រូវបានបង្កើតឡើងដែរ ។ **ឆាត ឃីផាលធ្រីក**

# ការជំរុញឱ្យមានការផ្សះផ្សា

## ១) តើការផ្សះផ្សាគ្រាន់តែជាពាក្យស្លោកមួយឬ?

អតីតអគ្គលេខាធិការអង្គការសហប្រជាជាតិបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងឯកសារផ្លូវការនៅឆ្នាំ១៩៩៩ថាការអនុវត្តការផ្សះផ្សាគឺជាការស្វែងរកយុត្តិធម៌ពីអំពើដ៏សាហាវឃោរឃៅ និងការទទួលខុសត្រូវពីរបបកម្ពុជាប្រជាធិបតេយ្យ ។ ប៉ុន្តែនៅពេលដែលយើងក្រឡេកមើលទៅដំណើរការនេះ យើងសង្កេតឃើញថាការអនុវត្តការផ្សះផ្សាមិនទាន់ត្រូវបានអនុវត្តន៍បានទាំងស្រុងនៅឡើយទេ ។ យើងនៅតែយល់ឃើញបែបនេះដដែល ប្រសិនបើយើងទទួលស្គាល់ការបង្កើតអង្គភាពជនរងគ្រោះនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានៅឆ្នាំ២០០៨ ។

ជាឧទាហរណ៍ សារ៉ា ថូម៉ាស ដែលធ្វើការជាមួយគម្រោងជួយជនរងគ្រោះដាក់ពាក្យបណ្តឹងទៅតុលាការរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្ហាញពីការអស់សង្ឃឹមរបស់ខ្លួនទៅលើសេចក្តីសម្រេចរបស់តុលាការនៅក្នុងសវនាការអង្គបុរេជំនុំជម្រះចំពោះករណីអៀង សារី ពីថ្ងៃទី៣០ ខែមិថុនា ដល់ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៨ ថាបានកាត់បន្ថយសិទ្ធិចូលរួមរបស់ជនរងគ្រោះ ។ ចំពោះបុគ្គលិករបស់អង្គជំនុំជម្រះយុត្តិធម៌ប្រហែលជាការងារដ៏លំបាកមួយដែលពិបាកនឹងដោះស្រាយ ។

ម្យ៉ាងវិញទៀត អង្គការក្រៅរដ្ឋាភិបាលនៅកម្ពុជាបានធ្វើដំណើរជុំវិញប្រទេសដើម្បីដាស់ការចងចាំរបស់ប្រជាជនដោយផ្តល់ដំណឹងដល់អ្នកទាំងនោះអំពីយុត្តិធម៌ដែលនឹងត្រូវអនុវត្តន៍ដោយអង្គជំនុំជម្រះ ។ ជាសំណាងល្អ ខ្ញុំមានឱកាសចូលរួមក្នុងការពិភាក្សាមួយចំនួនជាមួយអង្គការក្រៅរដ្ឋាភិបាលរបស់កម្ពុជាហើយខ្ញុំចាប់អារម្មណ៍នឹងទស្សនៈនៃការផ្សះផ្សាដែលបានលើកឡើងនៅក្នុងការពិភាក្សាទាំងនោះ ។ ដោយសារតែខ្ញុំធ្លាប់នៅអាហ្វ្រិកខាងត្បូងបានប៉ុន្មានឆ្នាំហើយសិក្សាអំពីការផ្លាស់ប្តូរសង្គមនិង «ការផ្សះផ្សា និងការពិត» របស់ប្រទេសនោះខ្ញុំឆ្ងល់ថាតើប្រជាជនដែលធ្លាប់ជួបប្រទះជម្លោះនិងចងចាំអំពីអតីតកាលរបស់ខ្លួនអាចទទួលយកការផ្សះផ្សាដោយរបៀបណា?

ដោយសារតែបញ្ញវន្តបរទេសមួយចំនួនដែលខ្ញុំបាននិយាយជាមួយបានបង្ហាញពីចម្ងល់របស់ខ្លួនចំពោះទស្សនៈនៃការផ្សះផ្សាពីព្រោះទស្សនៈនេះធំធេងពេកសម្រាប់ប្រជាជនកម្ពុជា ដូច្នេះអ្នកទាំងនោះបានយល់ស្របនឹងការប្រើប្រាស់ឃ្លានេះជាពាក្យស្លោកទៅវិញ ។

ទោះបីជាយ៉ាងណាក៏ដោយ តើការគិតថាការផ្សព្វផ្សាយអំពី «ការផ្សះផ្សាជាតិ» ឬការផ្សះផ្សានៅកម្រិតសង្គមមិនអាចនាំមកនូវឥទ្ធិពលដែលអាចមើលឃើញឬ? ខ្ញុំមិនគិតដូច្នោះទេ ។

ដោយហេតុនេះ ខ្ញុំនឹងបង្ហាញពីការយល់ដឹងរបស់ខ្ញុំអំពីសង្គមទៅលើឥទ្ធិពលនៃការផ្សព្វផ្សាយការផ្សះផ្សាជាសាធារណៈ ។ ខ្ញុំនឹងលើកឡើងពីការយល់ដឹងរបស់ខ្ញុំមួយចំនួនអំពីការផ្លាស់ប្តូរសង្គមនៅអាហ្វ្រិកខាងត្បូង ។

## ២. តើអ្វីគឺជាភាពខុសគ្នារវាងការគិតអំពីការផ្សះផ្សានៅកម្រិតបុគ្គលនិងនៅកម្រិតសង្គម?

ខ្ញុំនឹងចាប់ផ្តើមបកស្រាយពីពាក្យផ្សះផ្សា ។ វាគឺជាបាតុភូតផ្លូវចិត្តរបស់បុគ្គល ហើយវាតម្រូវឲ្យមាននៅក្នុងបរិបទសង្គម ។ វិធីសាស្ត្រមូលដ្ឋានរបស់អ្នកដែលគាំទ្រចលនាផ្សះផ្សារបស់ប្រជាជនគឺពឹងផ្អែកទៅលើទស្សនៈនៃ «ការនិយាយចេញមកក្រៅជាសាធារណៈអំពីបទពិសោធន៍របស់ខ្លួនប្រាប់ទៅអ្នកដទៃ» ។ ការធ្វើបែបនេះក៏អាចហៅថា «ការប្រាប់ពីការពិត» ហើយវាអាចរួមបញ្ចូលនូវពាក្យសម្តីរបស់ជនដែលដល់ ។ តែងតែមានការរំពឹងទុកថាជំហានដែលគេចង់បានដូចជា «ការនិយាយអំពីការពិត» ទៅកាន់អ្នកដទៃ (ជាសាធារណៈ) ការព្យាបាលនិងការសម្រេចនូវគោលដៅនៃការផ្សះផ្សា» នឹងដំណើរការទៅមុខ ។ ប៉ុន្តែនេះមិនមែនជាចំណុចសំខាន់ទេ ។ ជាឧទាហរណ៍ បព្វជិតសកម្មជនអាហ្វ្រិកខាងត្បូង ម៉ៃឃើល ឡេបស៊ី ដែលបានពិការភ្នែកម្ខាងនិងដៃទាំងពីរដោយសារគ្រាប់បែកដែលលាក់នៅក្នុងកញ្ចប់ដែលផ្ញើមកពីអាជ្ញាធរអាប៉ាថេត (អាហ្វ្រិកខាងត្បូងដែលធ្លាប់មានការរើសអើងរបស់ជនជាតិស្បែកសទៅលើជនជាតិស្បែកខ្មៅ) បានព្រមានអំពី

ការអនុវត្តន៍ទស្សនៈការព្យាបាលនិងផ្សះផ្សាថាវាលឿនពេកសម្រាប់ជនរងគ្រោះ ។

ព្រីស ស៊ីឡា បាននិយាយថា «ប្រសិនបើអ្នកមានរបួស អ្នកត្រូវស្រាយបង់រុំរបួសចេញលាងសម្អាតរបួសនិងរុំបង់ម្តងទៀត ។ ប៉ុន្តែចុះប្រសិនបើប្រជាជនដោះសម្លៀកបំពាក់នៅមុខគណៈកម្មការស្វែងរកការពិតហើយមិនមានឱកាសគ្រប់គ្រាន់សម្រាប់យកសម្លៀកបំពាក់មកស្លៀកពាក់វិញ.... ។ យើងមិនគួរគិតថាវាប្រើប្រាស់ពេលវេលាប្រាំនាទីសម្រាប់ព្យាបាលទេ» ។

ប្រសិនបើយើងទៅជួបពេទ្យចិត្តសាស្ត្រដើម្បីព្យាបាលជំងឺផ្លូវចិត្ត អ្នកព្យាបាលនឹងរក្សាការសម្ងាត់និងផ្តល់ការពិគ្រោះដដែលៗ នៅក្នុងបរិយាកាសដែលមានការលើកទឹកចិត្ត ។ អ្នកព្យាបាលមិនព្យាយាមរំពុកពីការចងចាំរបស់យើងភ្លាមៗទេ ។ ប៉ុន្តែ «ការប្រាប់ពីការពិត» (ដែលជំរុញដោយសង្គម) នៅទីសាធារណៈមិនអាចធានានូវទ្រង់ទ្រាយនេះរហូតទេ ។

នេះគឺជាការលំបាកមួយក្នុងការប្រាប់ពីការពិតនិងផ្សះផ្សាជាបុគ្គលនៅក្នុងទីសាធារណៈ ។ ប៉ុន្តែមានការយល់ឃើញថាការផ្សះផ្សាជាតិគឺជាការពិតដ៏ពិសេសមួយដែលគួរតែមានការទទួលស្គាល់ផ្សេងពី «ការផ្លាស់ប្តូរសង្គមដែលកើតមាននៅកម្រិតបុគ្គល» ។ យោងទៅតាមទស្សនៈនេះយើងត្រូវតែយកចិត្តទុកដាក់ចំពោះចំណុចមួយចំនួនខាងក្រោមដើម្បីយល់ដឹងពីការផ្សះផ្សាជាតិ ។ ទីមួយ ទស្សនៈនេះត្រូវតែរួមបញ្ចូលជាមួយភាពផ្សេងគ្នានៃការបកស្រាយទៅលើមនុស្សរួមទាំងអ្នកដែលគ្មានអត្តសញ្ញាណ ។ ទីពីរ យើងតម្រូវឲ្យពិចារណាទៅដល់កូនចៅជំនាន់ក្រោយដើម្បីជាពន្លឺដល់រឿងនេះ ។ កត្តាទាំងនេះបានបង្ហាញឲ្យឃើញថាវាមានការលំបាកក្នុងការវាយតម្លៃទៅលើការផ្សះផ្សាផ្លូវចិត្តនៅកម្រិតសង្គម ។ វាមានន័យថា យើងមិនអាចកំណត់លក្ខណៈវិនិច្ឆ័យដើម្បីវាយតម្លៃទៅលើកម្រិតជោគជ័យនៃការផ្សះផ្សាជាតិបានទេ ។

### ៣) ការផ្សះផ្សាគឺជាលក្ខខណ្ឌសង្គមនិងនយោបាយ

បញ្ញវន្តវិទ្យាសាស្ត្រនយោបាយមួយចំនួនបានសំដៅពាក្យផ្សះផ្សាជាតិទៅលើលក្ខខណ្ឌនយោបាយ បន្ទាប់ពីមានជម្លោះជាងជាងសំដៅទៅលើស្ថានភាពផ្លូវចិត្តរបស់ប្រជាជន ។ បន្ទាប់មកកត្តាមួយចំនួនដូចជា ការកែប្រែវិធាននៃច្បាប់ឲ្យល្អឡើងវិញ ការសហការណ៍របស់អតីតសត្រូវនៅក្នុងរដ្ឋាភិបាលនិងការអនុវត្តដំណើរការបោះឆ្នោតជាលក្ខណៈប្រជាធិបតេយ្យអាចត្រូវបានយកមកប្រើប្រាស់ជាសូចនាករដាក់ស្តែងដើម្បីវាយតម្លៃទៅលើកម្រិតដែលការផ្សះផ្សាជាតិអាចសម្រេចទៅបាន ។

នេះគឺជាមធ្យោបាយមួយដើម្បីស្វែងយល់ពីការផ្សះផ្សានៅកម្រិតរួម ជាពិសេសគឺដំណើរការនយោបាយនៅក្នុងសង្គម ។ បញ្ញវន្តទាំងនេះបានលើកឡើងជាសំណួរផ្សេងទៀតថានៅពេលដែលយើងមិនសួរថា «តើប្រជាជននៅក្នុងសង្គមនោះកំពុងតែផ្សះផ្សាជាមួយគ្នាឬ» «តើសង្គមនោះកំពុងតែផ្សះផ្សាឬ»? ឬ «តើយើងអាចវាយតម្លៃជាវិជ្ជមានថាសង្គមនោះទទួលបានការផ្សះផ្សាបានដែរឬទេ»?

ជាឧទាហរណ៍ ចនដួល លីដឺរាច បានផ្តល់ការបកស្រាយជាក់ស្តែងជាងមុនទៅលើប្រភេទនៃការផ្សះផ្សាដែលរៀបរាប់នៅខាងលើថា «ការផ្សះផ្សាតំណាងឲ្យកន្លែងមួយដែលជាចំណុចប្រសព្វរវាងអតីតកាលពិតនិងអនាគតកាល» ។

លីដឺរាច បានសង្កត់ធ្ងន់ទៅលើសារសំខាន់នៃកន្លែងនេះដោយលើកឡើងពីភាពចាំបាច់សម្រាប់ឲ្យអតីតសត្រូវរៀបចំបច្ចុប្បន្នសាឡើងវិញម្តងទៀត ។ «ការភ្ជាប់ទំនាក់ទំនងអ្នកទាំងនោះជាមួយគ្នាដោយទំនាក់ទំនងជាមនុស្ស», «ការបង្ហាញពីភាពបាក់ស្បាតឬកំហឹងប្រាប់ទៅអ្នកដទៃ», «ការទទួលស្គាល់», និង «ការចែករំលែកអំពីចក្ខុវិស័យរបស់ខ្លួនទៅអនាគត» គឺជាធាតុផ្សំនៃការផ្សះផ្សា ។

នៅក្នុងការចូលរួមសិក្ខាសិលាបណ្តុះបណ្តាលគ្រូកម្ពុជាអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាបាននិយាយថា គ្រូខ្លះព្យាយាមគិតថាកម្មាភិបាលខ្មែរក្រហមគឺជាបិសាច ។ គ្រូទាំងនេះចង់មើលរូបថតរបស់អតីតខ្មែរក្រហម ប៉ុន្តែក្រោយពីបានបានមើលរូបថតរួច អ្នកទាំងនោះមិនពេញចិត្តនឹងរូបថតនោះទេ ពីព្រោះមុខមាត់របស់មេដឹកនាំទាំងនោះប្រៀបដូចជាមនុស្សយើង ។ លោក ឆាំង យុ បានសង្កត់ធ្ងន់ទៅលើសារសំខាន់នៃការប្រើប្រាស់រូបថតរបស់អតីតមេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យសម្រាប់ជំរុញឲ្យមានការផ្សះផ្សា ។ ការប្រើប្រាស់រូបថតរបស់អតីតសត្រូវបែបនេះក៏ធ្លាប់មានគេ

ប្រើប្រាស់ដែរ ។ ការយល់ដឹងនេះមិនបានយកការផ្សះផ្សាធ្វើជាគោលដៅដែលអាចឲ្យអ្នកទាំងអស់គ្នាតម្រង់ទៅរកនោះទេ វាបែរជាបង្ហាញថាការផ្សះផ្សាគឺជាសកម្មភាពវិជ្ជមាន ។ ការឲ្យនិយមន័យការផ្សះផ្សាថាជាអន្តរអំពើរបស់ប្រជាជនគឺជាជំហានដាក់ស្តែងមួយសម្រាប់ធ្វើឲ្យពាក្យនេះក្លាយទៅជាការពិត ។

ទោះបីជាយ៉ាងណាក៏ដោយ និយមន័យបែបនេះប្រហែលជាតម្រូវឲ្យមានការអភិវឌ្ឍទស្សនៈរបស់អ្នកដែលមានជាប់ពាក់ព័ន្ធទាំងអស់ ។ អាស្រ័យហេតុនេះ ខ្ញុំនឹងបង្ហាញពីទស្សនៈមួយទៀតស្តីពីការផ្សះផ្សាដែលគិតអំពីទុក្ខគ្រោះដែលអាចកើតមាននិងភាពស្មុកស្មាញក្នុងការយល់ស្របទាំងស្រុងនឹងទស្សនៈនេះ ។

ឆាលី វីឡា-វាយសិនហ៊្សីអូ អតីតប្រធានអង្គភាពស្រាវជ្រាវនៃគណៈកម្មការស្វែងរកការពិតនិងផ្សះផ្សាបានរៀបរាប់ពីអារម្មណ៍របស់ប្រជាជននៅពេលចូលរួមក្នុងដំណើរការនេះថា ៖ «ប្រជាជនអាហ្វ្រិកខាងត្បូងភាគច្រើនមិនយល់ច្បាស់អំពីការផ្សះផ្សានោះទេ ទើបធ្វើឲ្យអ្នកទាំងនោះមានការស្មុកស្មាញថាតើត្រូវទទួលស្គាល់ឬមិនអើពើនឹងភាពចាំបាច់នៃការផ្សះផ្សា» ។

គាត់បានអះអាងថាទោះបីជានៅក្នុងស្ថានភាពបែបនោះឬដោយសារតែស្ថានភាពនោះការអនុវត្តការផ្សះផ្សាជាផ្លូវការអាចផ្តល់ផលប្រយោជន៍ជាច្រើន ។ «ការផ្សះផ្សាបានបន្ធូរស្ថានភាពនៃព្រឹត្តិការណ៍ដែលបានបង្កើតឡើង ។ ការផ្សះផ្សាគឺជាជំហានដំបូងដើម្បីបំបាត់កំហឹង ។ វាបាន «ផ្តល់ពេលវេលាសម្រាប់និយាយ» ប៉ុន្តែវាមិនបានធានាថា ការនិយាយនេះនឹងផ្តល់ផលប្រយោជន៍រយៈពេលយូរឬអត់ទេ» ។

វីឡា-វាយសិនហ៊្សីអូ គឺជាគ្រូគង្វាលសាសនាគ្រិស្តនិងបានចូលរួមក្នុងសភាជាតិអាហ្វ្រិកនៅក្នុងរបប អាប៉ារថេត ទោះបីជាលោកមានដើមកំណើតនៅអឺរ៉ុបក៏ដោយ ។ ដោយមើលទៅលើប្រវត្តិរបស់គាត់ គាត់មិនបានចាត់ទុកការផ្សះផ្សាជានយោបាយឬការមិនជាប់ពាក់ព័ន្ធនឹងសីលធម៌ឬការផ្លាស់ប្តូរស្ថានភាពផ្លូវចិត្តទាំងស្រុងទេ ។ គាត់បានយល់ស្របថាការពិតដែលថាប្រជាជនជាច្រើនមិនទទួលស្គាល់ពាក្យនេះ ។ ប៉ុន្តែ ទស្សនៈរបស់វីឡា-វាយសិនហ៊្សីអូ បានបង្ហាញពីទស្សនៈសំខាន់មួយចំនួននៅពេលដែលគិតទៅដល់ការជំរុញការផ្សះផ្សានៅក្នុងសង្គម ។ នេះពីព្រោះតែទស្សនៈរបស់គាត់ធ្វើឲ្យយើងដឹងពីប្រសិទ្ធភាពក្នុងការរក្សាការពិតនិងការផ្សះផ្សាដែលជាគោលដៅមួយរបស់សង្គម ។

ការរៀបចំការផ្សះផ្សាដែលជាការងារសង្គមអាចជា «ការបន្ធូរដល់ស្ថានភាពដែលបានកើតឡើង» និងការដឹកនាំមធ្យោបាយថ្មីក្នុងការផ្សះផ្សាអតីតសត្រូវ ។ ចំណុចសំខាន់នៃគំនិតនេះអាចនឹងកាន់តែត្រឹមត្រូវនៅពេលដែលយើងគិតទៅដល់ស្ថានភាពសង្គមរបស់កម្ពុជាដែលនៅមានអតីតទាហានខ្មែរក្រហមនិងកូនចៅរបស់អ្នកទាំងនោះ ។

## ៤) តួនាទីក្នុងការជំរុញឲ្យមានការផ្សះផ្សានៅក្នុងសង្គម

ជាសង្ខេប វាមានការលំបាកក្នុងការឲ្យនិយមន័យការផ្សះផ្សាសង្គមឲ្យស្របទៅនឹងការផ្លាស់ប្តូរគំនិតរបស់ប្រជាជន ។ ទោះបីជាយ៉ាងណាក៏ដោយ យើងអាចរំពឹងរកមធ្យោបាយថ្មីសម្រាប់ផ្សះផ្សាអតីតសត្រូវប្រសិនបើអាចចាប់ផ្តើមធ្វើការដោយរៀបចំការផ្សះផ្សាទៅជាគោលដៅសង្គមមួយ ។ គោលដៅនេះមិនមានទំនាក់ទំនងដោយផ្ទាល់ទៅនឹងយុត្តិធម៌ក្នុងតុលាការ ឬសំណងជាថវិកាហើយមិនអាចធានានូវការព្យាបាលរបួសផ្លូវការយរបស់ជនរងគ្រោះទេ ។ ការដាក់ឲ្យមានការផ្សះផ្សាជាសាធារណៈអាចនឹងធ្វើឲ្យមានប្រតិកម្មជាពាក្យសម្តីដែលរួមមានការគាំទ្រនិងការរិះគន់ហើយវាប្រហែលជាអាចធ្វើឲ្យមានអន្តរអំពើរវាងគ្នាទៅវិញទៅមក ។ ប៉ុន្តែការផ្សះផ្សានេះប្រហែលជាមិនកើតមានទេប្រសិនបើសង្គមគិតតែអំពីគោលការណ៍នៃយុត្តិធម៌ ពីព្រោះជនដែលនឹងមិនទទួលស្គាល់នូវអ្វីដែលខ្លួនបានធ្វើក្នុងអតីតកាលនិងការទទួលខុសត្រូវដូច្នេះ ជនរងគ្រោះនឹងត្រូវប្រឈមមុខនឹងសម្ពាធរូបីនិងអរូបីនៅពេលដែលរៀបរាប់ពីអតីតកាលរបស់ខ្លួន ។

អាស្រ័យហេតុនេះ នៅក្នុងការប្រើប្រាស់ការផ្សះផ្សាជាគំរូសង្គមដ៏ល្អមួយយើងមិនគួរព្យាយាមផ្តល់និយមន័យដល់ទស្សនៈការផ្សះផ្សាឬកំណត់លក្ខណៈវិនិច្ឆ័យច្បាស់លាស់សម្រាប់អនុវត្តដើម្បីសម្រេចឲ្យបានជោគជ័យនោះទេ ពីព្រោះការព្យាយាមធ្វើបែបនេះអាចនឹងនាំទៅរកស្ថានភាពដែលមិនអាចដំណើរការទៅមុខបាន ។ យើងគួរតែដឹងពីលទ្ធផលដែលកើតចេញពីភាពមិនច្បាស់លាស់នៃទស្សនៈនេះ ។

**អារេប ថូស៊ីហៅរ៉ូ**

# នៅមុនថ្ងៃវិនិច្ឆ័យទោស ឌុច

*នៅថ្ងៃច័ន្ទទី២៦ ខែកក្កដា ឆ្នាំ២០១០ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងធ្វើការប្រកាសនូវការវិនិច្ឆ័យរបស់ខ្លួនចំពោះសំណុំរឿង កាំង ហ្កេកអ៊ាវ ហៅ ឌុច ដែលជាអ្នកកាន់កាប់មន្ទីរស-២១នៅទីក្រុងភ្នំពេញក្នុងអំឡុងនៃរបប ប៉ុល ពត ។ គេហទំព័រឃ្លាំមើលតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម* **(www.cambodiatribunal.org)** *នឹងធ្វើការផ្សព្វផ្សាយទាំងស្រុងស្តីពីព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រនេះ ដោយចាប់ផ្តើមនៅព្រឹកថ្ងៃទី២៦ ខែកក្កដា ហើយបន្តផ្សព្វផ្សាយរហូតពេញមួយសប្តាហ៍បន្ទាប់ចំពោះព្រឹត្តិការណ៍ដែលកើតឡើងនៅប្រទេសកម្ពុជា ។ យើងនឹងមានអ្នកឆ្លើយឆ្លងសារព័ត៌មានចំនួនពីររូបប្រចាំនៅទីក្រុងភ្នំពេញនិងនៅក្នុងបន្ទប់សវនាការដើម្បីធ្វើបទសម្ភាសន៍ជាមួយបុគ្គលសំខាន់ៗរួមទាំងជនរងគ្រោះផងដែរ ។*

*តើអ្វីទៅដែលជាសារសំខាន់នៃព្រឹត្តិការណ៍ក្នុងការវិនិច្ឆ័យរបស់ អ.វ.ត.ក ខាងមុខនេះ ស្តីពីការទទួលខុសត្រូវរបស់បុគ្គលសំខាន់ម្នាក់នៅក្នុងរបបខ្មែរក្រហមដោយមិនខ្វល់ពីលទ្ធផលថាតើជាសាលក្រមសម្រេចឲ្យគ្មានទោស ឬមានទោសបុយ៉ាងណា?*

*ប្រទេសកម្ពុជាលែងឈរសម្ងំស្ងៀមនៅក្នុងចំណោមឧក្រិដ្ឋកម្មដ៏ឃោរឃៅបំផុតនៅក្នុងសតវត្សរ៍ទី២០ទៀតហើយ ដែលធ្លាប់ជាជាតិមួយមានការភ័យខ្លាចចំពោះភាពយុត្តិធម៌ ។ ជាការពិតណាស់ ការដាក់ឲ្យមានការទទួលខុសត្រូវទាំងស្រុងចំពោះការស្លាប់របស់ប្រជាជនកម្ពុជាជាងមួយលានប្រាំពីរសែននាក់នោះគឺជារឿងមួយដែលមិនអាចទៅរួច ។ ប៉ុន្តែ ទោះបីជាយ៉ាងនេះក៏ដោយ ការវិនិច្ឆ័យទោសមកលើ ឌុច គឺអាចក្លាយទៅជាសញ្ញាណមួយដ៏ខ្លាំងក្លាបញ្ជាក់ជូនទៅជនរងគ្រោះដែលរួចរស់មានជីវិតនិងក្រុមគ្រួសាររបស់ពួកគេថា យ៉ាងហោចណាស់គឺមានការគិតគូរយកមេដឹកនាំខ្លះឲ្យមកទទួលខុសត្រូវផងដែរ ។ ម្យ៉ាងទៀតតុលាការនេះនឹងអាចមានសក្តានុពលក្នុងការជះឥទ្ធិពលឲ្យតុលាការផ្សេងៗនៅក្នុងប្រទេសកម្ពុជាទាំងមូលកាន់តែមានទម្ងន់និងភាពសុច្ចរិតឡើងដែលតុលាការខ្លះនោះនៅតែងាយនឹងកើតមានអំពើពុករលួយដដែល ។*

*យើងអាចធ្វើការសរុបសេចក្តីដោយសមហេតុសមផលនៅត្រង់ចំណុចនេះបានថា ការជំនុំជម្រះក្តី ឌុច គឺបានអនុលោមទៅតាមបទដ្ឋានអន្តរជាតិដែលដំណើរការសមស្របនៃច្បាប់ ដូច្នេះការកាត់ទោសនេះគឺយុត្តិធម៌ ហើយម្យ៉ាងទៀត សិទ្ធិរបស់ ឌុច ក្នុងនាមជាចុងចោទនោះក៏ត្រូវបានការពារយ៉ាងល្អផងដែរ ។ ការពិបាកនឹងធ្វើការសម្រេចចិត្តដែលអង្គជំនុំជម្រះត្រូវលើកឡើងនៅក្នុងការវិនិច្ឆ័យរបស់ខ្លួននោះគឺអាកប្បកិរិយាផ្ទុយគ្នានៃយុត្តិសាស្ត្រការពារក្តីរបស់ ឌុច ។ ដំបូង ឌុច បានសារភាពទទួលខុសត្រូវទាំងអស់ចំពោះការធ្វើទារុណកម្មនិងការស្លាប់នៅគុកទួលស្លែងក្នុងគោលបំណងដើម្បីឲ្យមានការបន្ធូរបន្ថយទោសក្នុងករណីសាលក្រមសម្រេចឲ្យមានពិរុទ្ធភាព ។ ប៉ុន្តែ ក្រោយមក នៅវេលាចុងក្រោយនៃការផ្តល់ពាក្យពេចន៍បញ្ចប់ ឌុច រួមជាមួយនឹងមេធាវីខ្មែរការពារក្តីរបស់ខ្លួនបានសុំឲ្យមានការរួចទោសទៅវិញ ។ ការស្នើសុំនេះគឺបានឆ្លុះបញ្ចាំងពីភាពប្រឫកប្រល់រវាងមេធាវីការពារក្តីជាតិនិងអន្តរជាតិ ។*

*តាមការពិត ឌុច នាពេលថ្មីៗនេះបានបណ្តេញមេធាវីការពារក្តីអន្តរជាតិរបស់ខ្លួនចេញពីតំណែង ដែលនេះបញ្ជាក់ថា ឌុច នៅតែប្រកាន់ខ្ជាប់នូវការស្នើសុំឲ្យរួចទោសរបស់ខ្លួនដដែល ។ បន្ទាប់ពីដំណើរការសវនាការដ៏យូរក្នុងការផ្តល់សក្ខីកម្មនិងភ័ស្តុតាងដែលចង្អុលបង្ហាញពីកម្រិតនៃការទទួលខុសត្រូវសម្រាប់អំពើឃោរឃៅដែលកើតឡើងនៅគុកទួលស្លែង ហើយដែលរួមទាំងការទទួលស្គាល់កំហុសរបស់ ឌុច ខ្លួនឯងផ្ទាល់ផងនោះ វាប្រាកដជារឿងមួយដែលគួរឲ្យភ្ញាក់ផ្អើលហើយ ប្រសិនបើចៅក្រមធ្វើការពិចារណាទៅលើការស្នើសុំនោះ ។*

*ការជំនុំជម្រះក្តី ឌុច គឺសមនឹងថវិកាដែលបានចំណាយជាពិសេសសម្រាប់ជនរងគ្រោះដែលបានស្លាប់នៅទីនោះអស់ជាង១៤.០០០នាក់ ។ ជារឿយៗគឺតែងតែមានការពិបាកសម្រេចចិត្តទាក់ទងនឹងការចំណាយថវិកាដ៏ច្រើនសន្ធឹកសន្ធាប់*

ដែលប្រឈមដោយតុលាការឧក្រិដ្ឋកម្មសង្គ្រាមដែលបង្កើតឡើងកាលពីដប់ប្រាំពីរឆ្នាំមុននេះ ។ ប្រទេសកម្ពុជាពិតប្រាកដណាស់គឺមិនមែនជាករណីពិសេសនោះទេទាក់ទងនឹងបញ្ហានេះ ។ ប៉ុន្តែយុត្តិធម៌អន្តរជាតិពិតជាថ្លៃខ្លាំងណាស់ដោយសារតែមានការកាប់សម្លាប់យ៉ាងរង្គាលនិងអ្វីដែលទាមទារឲ្យបញ្ជាក់ថាមេដឹកនាំនយោបាយនិងយោធាធ្វើការដឹកនាំអ្នកផ្សេងឲ្យអនុវត្តនូវឧក្រិដ្ឋកម្មដ៏ឃោរឃៅណាមួយ ។ កេរដំណែលដែលបន្សល់ដោយ អ.វ.ត.ក នោះនឹងមានសារសំខាន់ណាស់សម្រាប់មនុស្សជំនាន់ក្រោយរបស់ប្រទេសកម្ពុជា ដូចជាអ្វីដែលតុលាការនៅនូរ៉មប៊ឹកនិងតុលាការយោធាតូក្យូបានធ្វើឡើងនៅកន្លែងផ្សេងៗទៀតកាលពីប៉ុន្មានទសវត្សរ៍មុនបន្ទាប់ពីសង្គ្រាមលោកលើកទីពីរ ។

តាមការពិត ការវិភាគមួយនៃការចំណាយថវិកាលើការជំនុំជម្រះក្តីរបស់ អ.វ.ត.ក បញ្ជាក់ថា ការជំនុំជម្រះទាំងនេះសម្រាប់ការធ្វើទារុណកម្មនិងការស្លាប់របស់ប្រជាជនរាប់ម៉ឺននាក់នេះបានចំណាយអស់តិចខ្លាំងណាស់បើយើងប្រៀបធៀបទៅនឹងការចំណាយរបស់តុលាការក្នុងស្រុកចំពោះការកាត់សេចក្តីឃាតករម្នាក់នៅក្នុងប្រព័ន្ធតុលាការរបស់បស្ចិមប្រទេសរីកចម្រើនផ្សេងៗនោះ ។ វាក៏ជាជំនឿខុសឆ្គងមួយដែរក្នុងការគិតថាថវិកាដែលផ្តល់ទៅឲ្យ អ.វ.ត.ក ក្នុងការកាត់ទោសមេដឹកនាំខ្មែរក្រហមដែលនៅរស់មានការចូលរួមនិងត្រួតពិនិត្យដោយអន្តរជាតិប្រហែលជាត្រូវបានផ្តល់ឲ្យដោយជំនួយបរទេសទៅលើប្រព័ន្ធយុត្តិធម៌ក្នុងស្រុករបស់ប្រទេសកម្ពុជា ។ ខ្ញុំជឿជាក់ថា ការវិនិច្ឆ័យមកលើ ឌុច នឹងអាចបង្កើននូវការចាប់អារម្មណ៍យ៉ាងខ្លាំងពីសំណាក់ប្រទេសជំនួយផ្សេងៗដើម្បីផ្តល់ជាថវិកាស្ម័គ្រចិត្តបន្ថែមជាជំនួយដល់ អ.វ.ត.ក ក្នុងការបន្តអនុវត្តនូវអាណត្តិដ៏សំខាន់របស់ខ្លួននេះ ។

ឌុច នឹងមិនប្រហែលជាចុងចោទខ្មែរក្រហមតែម្នាក់គត់ដែលត្រូវបាននាំយកមកកាត់ទោសនៅចំពោះមុខ អ.វ.ត.ក នោះទេ ។ ទោះបីប្រសិនបើនៅក្នុងការជំនុំជម្រះករណី០០២ មេដឹកនាំខ្មែរក្រហមជាន់ខ្ពស់ម្នាក់ៗក្នុងចំណោមទាំងបួននាក់នោះត្រូវបានកាត់សេចក្តីឲ្យគ្មានទោសក៏ដោយ ក៏ខ្ញុំនៅរំពឹងទុកថាយុត្តិធម៌ពិតប្រាកដនឹងត្រូវបានផ្តល់ឲ្យដោយអង្គជំនុំជម្រះនេះដែរ ។ ចំពោះការពិតដែលថា អ.វ.ត.ក បានតម្រូវឲ្យបុគ្គលម្នាក់ៗធ្វើការរៀបចំខ្លួនសម្រាប់ការជំនុំជម្រះ ដែលអ្នកទាំងនោះ ត្រូវតែការពារខ្លួនឯងដើម្បីប្រឆាំងទៅនឹងការចោទប្រកាន់របស់ព្រះរាជអាជ្ញាក៏ដោយ ក៏វាជាជោគជ័យមួយសម្រាប់យុត្តិធម៌និងសម្រាប់ការកត់ត្រាជាប្រវត្តិសាស្ត្រនៅក្នុងប្រទេសកម្ពុជា ។

ឌុច មិនមែនជាមនុស្សដែលទទួលថ្នាក់នោះទេ ព្រោះការជំនុំជម្រះក្តី០០២នៅតែបន្តតាមដានដដែល ដែលក្នុងនោះថ្នាក់លើរបស់គាត់នឹងត្រូវទទួលខុសត្រូវដែរ ។ វាក៏អាចទៅរួចដែរចំពោះការកើតមាននូវការជំនុំជម្រះក្តីលើករណី០០៣ ឬប្រហែលជាករណី០០៤ទៅលើចុងចោទផ្សេងទៀតដែលប្រហែលជាមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់ ទោះបីជាមានការរារាំងពីការសាយភាយឥទ្ធិពលនយោបាយក៏ដោយ ។ ទោះបីជាយ៉ាងណាក៏ដោយការជំនុំជម្រះក្តី ឌុច គឺបានផ្តល់នូវមូលដ្ឋានមួយសម្រាប់បញ្ហាសំខាន់ខ្លះៗទាក់ទងនឹងអំពើឃោរឃៅរបស់ប៉ុល ពត ហើយក៏អាចនឹងសម្របសម្រួលការជំនុំជម្រះក្តីលើកក្រោយៗទៀតដែរ ។ ឌុច បានក្លាយទៅជានិមិត្តសញ្ញាមួយនៃឧក្រិដ្ឋកម្មដ៏សាហាវរបស់របបប៉ុល ពត រួចមកហើយ ប៉ុន្តែខ្ញុំជឿជាក់ថា ឌុច នឹងមិនមែនជាមនុស្សតែម្នាក់គត់នោះទេនៅពេលដែលរឿងរ៉ាវទាំងអស់នេះត្រូវបានបញ្ចប់ ។ អ្នកផ្សេងទៀតគឺបានត្រៀមខ្លួនរួចហើយដើម្បីចែករំលែកនូវរឿងរ៉ាវដែលបានកើតឡើងនោះជាមួយនឹង ឌុច ។

ការសាកល្បងក្នុងការវិនិច្ឆ័យរបស់អង្គជំនុំជម្រះមកលើ ឌុច ប្រហែលថាតើវាមានលក្ខណៈសមហេតុផលយ៉ាងដូចម្តេចក្នុងការពិនិត្យលើបញ្ហាច្បាប់ និងដំណើរការស្របច្បាប់ផ្សេងៗជាច្រើនដែលបានលើកឡើងនៅអំឡុងពេលនៃការជំនុំជម្រះនិងថាតើវាសមស្របជាមួយនឹងការវិនិច្ឆ័យត្រឹមត្រូវរបស់តុលាការឧក្រិដ្ឋកម្មសង្គ្រាមផ្សេងទៀតដែរឬទេ ។ យើងអាចរំពឹងទុកនូវការវិនិច្ឆ័យមួយដ៏វែងអន្លាយដែលនឹងត្រូវបានត្រួតពិនិត្យអស់ជាច្រើនឆ្នាំដើម្បីឲ្យវាបានសម្រេច ។

វេលានេះគឺជារយៈពេលដ៏យូរមួយដែលខិតជិតមកដល់សម្រាប់ប្រជាជនកម្ពុជា និងសហគមន៍អន្តរជាតិ ។ យុត្តិធម៌ត្រូវបានពន្យារពេលជាយូរណាស់មកហើយនៅក្នុងប្រទេសកម្ពុជា ប៉ុន្តែ យុត្តិធម៌នោះនឹងមិនត្រូវបានបដិសេធចោលនោះទេ ។

**ដេវីដ សេហ្វ័រ**

# ប្រតិកម្មរបស់អ្នកភូមិនៅខេត្តកណ្ដាលចំពោះការចាក់បញ្ចាំងការចេញសេចក្ដីសម្រេចលើករណី ឌុច

***អ្នកភូមិសម្លឹងមើលទៅចៅក្រម និល ណុន អានសេចក្ដីសម្រេចលើករណី ឌុច***

*ខណៈពេលដែលសេចក្ដីសម្រេចលើករណី កាំង ហ្គេកអ៊ាវ (ហៅ ឌុច) បានលេចឡើងនៅក្នុងចិត្តរបស់ប្រជាជនកម្ពុជាបន្តិចម្ដងៗ អ្នកភូមិនៅខេត្តកណ្ដាលដែលមិនបានមើលការផ្សាយបន្តផ្ទាល់ទាក់ទងនឹងការចេញសាលក្រមបានប្រមូលផ្ដុំគ្នានៅក្នុងវត្តដើម្បីទស្សនាការចាក់ផ្សាយនូវសេចក្ដីសម្រេចម្ដងទៀត ។ ការចាក់ផ្សាយនេះត្រូវបានធ្វើឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជាពីព្រោះវាជាផ្នែកមួយនៃគម្រោងផ្សព្វផ្សាយតាមមូលដ្ឋានដែលក្នុងនោះរួមមានការចាក់ផ្សាយបន្តផ្ទាល់ និងការចាក់ផ្សាយម្ដងទៀតនូវការអានសេចក្ដីសម្រេចនៅក្នុងវត្ត សាលារៀន និងហាងកាហ្វេនៅក្នុងខេត្តចំនួនប្រាំពីរ ។ ការចាក់ផ្សាយនេះគឺជាសកម្មភាពថ្មីក្នុងចំណោមកិច្ចខិតខំប្រឹងប្រែងដែលធ្វើឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងគោលបំណងបង្កើននូវការយល់ដឹងអំពីប្រវត្តិសាស្ត្រ និងអំពើសាហាវឃោរឃៅនៃរបបកម្ពុជាប្រជាធិបតេយ្យដែលកើតឡើងនៅក្នុងប្រទេស ។*

***ក្មេងប្រុសតាមដានមើលក្រុមអ្នកសារព័ត៌មានប៉ុស្តិ៍ប៊ីប៊ីស៊ីដោយភាពចង់ដឹង***

*ការចាក់ផ្សាយម្ដងទៀតដែលមានការចូលរួមដោយក្រុមអ្នកឃ្លាំមើលសាលាក្ដីខ្មែរក្រហមនៅវត្តកោះអណ្ដែត ស្រុកកោះធំបានទាក់ទាញប្រជាជនកម្ពុជាដែលមានវ័យចំណាស់មួយភាគធំដូចជាប្រធានភូមិដែលជាអ្នកភូមិនៅក្នុងតំបន់ និង ហ៊ឹម ហ៊ុយ ដែលជាអតីតអ្នកយាមគុកទួលស្លែង (មន្ទីរស-២១) របស់ខ្មែរក្រហម ។ នៅពេលនោះក៏មានការចូលរួមរបស់ក្រុមអ្នកថតមកពីទូរទស្សន៍ប៊ីប៊ីស៊ីដែរ ។ គួរឲ្យសោកស្ដាយដែលក្រុមយុវជនមិនអាចមកមើលការចេញសាលក្រមដែលផ្សាយបន្តផ្ទាល់តាមទូរទស្សន៍ឬការចាក់ផ្សាយម្ដងទៀតដោយមជ្ឈមណ្ឌលឯកសារកម្ពុជាដោយសារតែការប្រឡងសញ្ញាបត្រទុតិយភូមិដែលមានរយៈពេលបីថ្ងៃ ។ មានប្រជាជនជាច្រើនបានគិតថាការជួនគ្នានេះគឺជាកំហុសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។*

*បន្ទាប់ពីអ្នកតំណាងមជ្ឈមណ្ឌលឯកសារកម្ពុជាបានបកស្រាយពន្យល់ពីការងាររបស់តុលាការ អ្នកភូមិបានអង្គុយយ៉ាងស្ងៀមស្ងាត់នៅពីមុខផ្ទាំងសំពត់សដ៏ធំមួយនៅកណ្ដាលទីធ្លាវត្តនិងយកចិត្តទុកដាក់ស្ដាប់ប្រធានអង្គជំនុំជម្រះ ចៅក្រម និល ណុន សង្ខេបពីឧក្រិដ្ឋកម្មរបស់ ឌុច និងប្រកាសពីវាសនារបស់គាត់ ។ នៅផ្នែកខាងក្រោយមានទៀននៅលើតុដើម្បីបំភ្លឺ ។ បន្ទាប់ពី*


អ្នកភូមិមើលទស្សនាវដ្ដី


អ្នកភូមិកំពុងមើលការផ្សាយបន្តផ្ទាល់

ការផ្សាយចប់ អ្នកភូមិម្នាក់បានក្រោកឈរឡើងហើយនិយាយថាឪពុករបស់គាត់គឺជាជនរងគ្រោះម្នាក់ក្នុងចំណោមជនរងគ្រោះជាច្រើនដែលបានបាត់ខ្លួននៅស-២១ ។ គាត់បានបង្ហាញពីការមិនពេញចិត្តនឹងសាលក្រមពីព្រោះគាត់ចង់ឲ្យដាក់ទោសធ្ងន់បំផុតគឺឃុំឃាំងនៅក្នុងពន្ធនាគារអស់មួយជីវិត ។ គាត់បានសង្កត់ធ្ងន់ថា ទោះបីជាការកាត់ទោសធ្ងន់ជាងនេះ ក៏វាមិនអាចឲ្យឪពុករបស់គាត់ត្រឡប់មកវិញ និងបំបាត់ការឈឺចាប់របស់គាត់នៅពេលសព្វថ្ងៃនេះដែរ ។ អ្នកភូមិផ្សេងទៀតបានសម្តែងនូវការយល់ចិត្តគាត់ ។

បន្ទាប់មក ហ៊ឹម ហ៊ុយ បានលើកឡើងពីអតីតអ្នកជិតខាងរបស់គាត់ ។ ក្នុងនាមជាប្រធានអ្នកយាមនៅទួលស្លែង ហ៊ុយ ក៏ត្រូវទទួលខុសត្រូវខ្លះចំពោះការស្លាប់របស់ជនរងគ្រោះនៅស-២១ និងជើងឯកដែរ ។ គាត់បានប្រាប់អ្នកភូមិពីរឿងរ៉ាវដែលពាក់ព័ន្ធនឹងខ្មែរក្រហមនិងសកម្មភាពរបស់ ឌុច ។ ហ៊ុយ បានផ្តល់សក្ខីកម្មប្រឆាំងនឹង ឌុច និងយល់ស្របថា ឌុច គួរតែទទួលបានការកាត់ទោសធ្ងន់ជាងនេះ ។

នៅពេលថ្ងៃ បន្ទាប់ពីអ្នកភូមិបានមកដល់វត្ត បុរសចំណាស់ម្នាក់ដែលឈរនៅក្រោយបាននិយាយរំឭកនូវរឿងរ៉ាវដែលខ្មែរក្រហមបង្ខំឲ្យគាត់ធ្វើការធ្ងន់នៅជំរំជិតនោះ ប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រុមអ្នកឃ្លាំមើលសាលាក្តីខ្មែរក្រហម ។ គាត់បាននិយាយពីការធ្វើការងារធ្ងន់និងការស្លាប់របស់បងប្អូនបង្កើតមួយចំនួនបណ្តាលមកពីការធ្វើការងារធ្ងន់និងការធ្វើការហួសកម្លាំង ។ **ម៉េឃើល សាលីបា និង ថៃលើ នីមស៍**

## ដំណើរទស្សនកិច្ចដើម្បីស្វែងយល់ពីការកាត់ទោសមេដឹកនាំខ្មែរក្រហម

មកទល់នឹងពេលបច្ចុប្បន្ន គម្រោងឯកសាររស់របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានអញ្ជើញប្រជាជនមកចូលរួមស្វែងយល់ក្នុងដំណើរការស្វែងរកយុត្តិធម៌នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចំនួនប្រមាណ៦៩០០នាក់រួចមកហើយ ។ នៅដើមឆ្នាំ២០០៩ គម្រោងឯកសាររស់បានឈានមួយជំហានទៀតក្នុងការផ្តល់ឱកាសឲ្យប្រជាជនចូលរួមដោយផ្ទាល់នៅក្នុងដំណើរការកាត់ក្តីមេដឹកនាំខ្មែរក្រហម ។ នៅរៀងរាល់ការបើកសវនាការកាត់ទោសមេដឹកនាំខ្មែរក្រហម មជ្ឈមណ្ឌលឯកសារកម្ពុជានឹងអញ្ជើញអ្នកតំណាងមកពីស្រុកភូមិនានាទូទាំងប្រទេសមកឃ្លាំមើលដំណើរការនេះ ។ បន្ថែមពីលើការចូលរួមស្តាប់សវនាការ អ្នកតំណាងទាំងនោះនឹងបានចូលរួមក្នុងវគ្គបំពាក់បំប៉នដើម្បីទទួលចំណេះដឹងផ្សេងៗទាក់ទងទៅនឹងទ្រង់ទ្រាយនៃតុលាការច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហម តួនាទីនៃសហព្រះរាជអាជ្ញាចៅក្រម និងចៅក្រមស៊ើបអង្កេត ភាពខុសគ្នានៃទម្រង់សវនាការព្រមទាំងទស្សនាខ្សែភាពយន្តឯកសារទាក់ទងទៅនឹងរបបខ្មែរក្រហម ។ អាស្រ័យហេតុនេះ ប្រសិនបើអស់លោកអ្នកមានបំណងចូលរួមក្នុងកម្មវិធីអង្កេតមើលសវនាការឬដំណើរទស្សនកិច្ចដើម្បីស្វែងយល់ពីការកាត់ក្តីមេដឹកនាំខ្មែរក្រហម សូមទាក់ទង ស៊ីរិសាវីណា តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬ ០១២ ៦៨៨ ០៤៦ ។ **សូមអរគុណ**





# ទស្សនៈរបស់និស្សិតខ្មែរម្នាក់ ចំពោះពាក្យ "អង្គការ"

អត្ថបទនេះមានគោលបំណងសិក្សាស្វែងយល់ពីបរិបទជុំវិញការប្រើប្រាស់ពាក្យ «អង្គការ» ដែលគេឮនៅសម័យ ប៉ុល ពត ។ នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ឬសម័យខ្មែរក្រហម ១៩៧៥-១៩៧៩ ពាក្យ «អង្គការ» ត្រូវបានថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាដែលមាននិន្នាការឆ្វេងនិយមប្រើសម្គាល់ការដឹកនាំដោយសមូហភាពគឺមិនមែនបុគ្គលណាម្នាក់ឡើយ ។ «អង្គការ» មានអំណាចខ្លាំងណាស់ក្នុងការសម្រេចចិត្តលើអ្វីៗទាំងអស់រហូតអាចឈានទៅដល់ការសម្លាប់អ្នកណាម្នាក់ដែលត្រូវគេចាត់ទុកថាជា «ខ្មាំង» ។ ជាលទ្ធផល ការចល័តប្រជាជនពីទីក្រុងទៅជនបទ អាពាហ៍ពិពាហ៍ដែលមិនអាចប្រកែកបាន ការយកទៅកសាងការកម្មេច និងការសម្លាប់រង្គាល គឺជាលទ្ធផលនៃអំណាចរបស់ «អង្គការ» បុគ្គល ឬស្ថាប័ន? មនុស្សមែនទែនឬគ្រាន់តែជាពាក្យសម្រាប់បំភ័យអ្នកដទៃ? ការស្រាវជ្រាវកន្លងមកបានបង្ហាញថាមនុស្សភាគច្រើនរួមទាំងខ្មែរក្រហមខ្លួនឯងផងមិនបានស្គាល់និងបានដឹងឲ្យស៊ីជម្រៅថាអ្នកណានៅពីក្រោយ «អង្គការ» និងជាអ្នកបញ្ជា «អង្គការ» ទេ ។

នៅសម័យ បីឆ្នាំ ប្រាំបីខែ ម្ភៃថ្ងៃ កូនទាហានខ្មែរក្រហមធម្មតានិងកម្មាភិបាលដឹកនាំនៅមូលដ្ឋានសូម្បីតែកម្មាភិបាលថ្នាក់ស្រុកមួយចំនួនក៏មិនដែលឮឬយល់ឡើយអំពីពាក្យអង្គការគឺបានត្រឹមតែប្រើពាក្យនេះតៗគ្នាដើម្បីគ្រប់គ្រងតំបន់របស់ខ្លួនប៉ុណ្ណោះ ។ នៅពេលខ្លះ ពាក្យនេះគឺជាបញ្ជារបស់ថ្នាក់មជ្ឈិមក្នុងការសម្រេចអ្វីមួយ ។ ក្នុងបរិបទបែបនេះគេប្រើពាក្យនេះគឺដើម្បីកម្ទេចខ្មាំង ។ តែនៅក្នុងហេតុផលខ្លះទាហានឬកម្មាភិបាលណាម្នាក់បានប្រើប្រាស់ពាក្យនេះវាជាលេសសម្រាប់សម្លាប់អ្នកណាដែលខ្លួនស្អប់ឬអ្នកដែលធ្លាប់បានជិះជាន់លើខ្លួនកាលពីសម័យ លន់ នល់ ឬក៏ឆក់ប្លន់ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន ។ មកទល់សព្វថ្ងៃនេះគេនៅមិនទាន់មានការបកស្រាយណាមួយដែលមានការឯកភាពគ្នារវាងអ្នកជំនាន់នោះនិងអ្នកជំនាន់ក្រោយទៅលើប្រវត្តិសាស្ត្រដែលជាប់ទាក់ទងនឹងនយោបាយនេះទេ ជាពិសេសមុខងារនៃពាក្យ «អង្គការ» នេះ ហើយការប្រើពាក្យដែលមានឥទ្ធិពលនៅក្នុងរបបវាលពិឃាតនោះនៅតែជាអាថ៌កំបាំងជានិច្ច ។

បន្ទាប់ពីការដួលរលំនៃរបបវាលពិឃាតឬគុកឥតជញ្ជាំងនៅដើមឆ្នាំ១៩៧៩មរតកតែមួយគត់នៃរបបនោះសម្រាប់អ្នកនៅរស់រានជីវិតគឺជាការប៉ះទង្គិចផ្លូវចិត្តដែលកើតមានចំពោះប្រជាពលរដ្ឋស្ទើរតែគ្រប់រូប ។ ស្របពេលនឹងការព្យាបាលរបួសផ្លូវចិត្តសម្រាប់ជីវិតដែលនៅសេសសល់ក្តីសង្ឃឹមតែមួយគត់របស់អ្នកទាំងនោះគឺបានរស់នៅដោយសុខសន្តិភាព ហើយគ្រប់រូបភាពនៃរបបខ្មៅងងឹតដែលមិនគួរឲ្យជឿនោះនឹងកើតឡើងក្នុងប្រវត្តិសាស្ត្រមនុស្សលោកសាជាថ្មីទៀត ។



លលាដ៍ក្បាលអ្នកដែលបានស្លាប់នៅជើងឯក

**ថេង ប៊ុនយាថា**

# ឪពុករបស់ខ្ញុំកាលពីកុមារភាព

របបកម្ពុជាប្រជាធិបតេយ្យគឺជាទំព័រប្រវត្តិសាស្ត្រដ៏ខ្មៅងងឹតមួយដែលប្រជាពលរដ្ឋខ្មែរបានឆ្លងកាត់ ។ ទោះបីជារបបនេះបានកន្លងផុតទៅអស់រយៈពេលបីទសវត្សរ៍និងតុលាការកំពុងតែកាត់ទោសមេដឹកនាំនៃរបបនេះក៏ដោយ ក៏ប្រជាជនទាំងអស់នៅតែនឹកឃើញពីការសម្លាប់យ៉ាងសាហាវព្រៃផ្សៃមកលើប្រជាជនខ្មែរជានិច្ច ។

កាលនៅពីខ្ញុំនៅតូច ឪពុកម្តាយរបស់ខ្ញុំតែងតែរៀបរាប់រឿងរ៉ាវរបស់គាត់នៅក្នុងរបបខ្មែរក្រហមឲ្យបានដឹងថា ក្រោយពីយោធាខ្មែរក្រហមទទួលបានជ័យជម្នះទាំងស្រុងនៅខែមេសាឆ្នាំ១៩៧៥ ប្រជាជនក្នុងរដ្ឋធានីភ្នំពេញមូលទាំងអស់សប្បាយរីករាយជាខ្លាំងនិងទះដៃអបអរសាទរស្វាគមន៍ទៀតផង ។ ប៉ុន្តែបីបួនម៉ោងក្រោយមក ភាពសប្បាយរីករាយនេះបានប្រែទៅជាភាពក្រៀមក្រំនិងភ័យខ្លាចទៅវិញ ព្រោះខ្មែរក្រហមបានប្រកាសឲ្យប្រជាជនទាំងអស់រៀបចំអីវ៉ាន់ចាកចេញពីទីក្រុងភ្នំពេញក្នុងរយៈពេលបីថ្ងៃដោយកុហកថា យន្តហោះអាមេរិកាំងនឹងមកទម្លាក់គ្រាប់បែកលើទីក្រុងភ្នំពេញឥឡូវហើយ ។ ពេលនោះដោយសារតែស្ថានភាពមិនសូវគឹងតែងខ្លាំងគ្រួសាររបស់ឪពុកខ្ញុំព្រមទាំងម្តាយធំរបស់ខ្ញុំមិនទាន់ចាកចេញពីក្រុងភ្លាមទេ ។ ប៉ុន្តែ ក្រោយពីឃើញយោធាខ្មែរក្រហមបី-បួននាក់ប្រដាប់ដោយអាវុធគ្រប់ដៃនិងស្រែកគំរាមថា «បើនរណាទទឹងត្រូវចាត់ទុកថាជាខ្មាំងរបស់អង្គការហើយត្រូវតែកម្ទេចចោល» គ្រួសាររបស់ពុកខ្ញុំ ក៏ប្រញាប់ប្រញាល់រៀបចំអីវ៉ាន់ចាកចេញជាបន្ទាន់ រួចធ្វើដំណើរឆ្ពោះទៅខេត្តបាត់ដំបង ។ ចំណែកគ្រួសាររបស់ម្តាយធំខ្ញុំនិងបងប្រុសរបស់គាត់ពីរនាក់ទៀតត្រូវជម្លៀសទៅកាន់សហករណ៍ឆ្ងាយពីគេ ។



ម៉ម សុវណ្ណ និងឪពុកថតនៅឆ្នាំ១៩៩៣

តាមផ្លូវធ្វើដំណើរឪពុកម្តាយរបស់ខ្ញុំមានការតក់ស្លុតជាខ្លាំងព្រោះគាត់ឃើញមានសាកសពជាច្រើននៅតាមផ្លូវដោយខ្លះដាច់ដៃនិងខ្លះដាច់ជើង ។ បន្ទាប់ពីចំណាយពេលធ្វើដំណើរជាច្រើនថ្ងៃគ្រួសាររបស់ឪពុកខ្ញុំ ក៏ធ្វើដំណើរមកដល់ខេត្តបាត់ដំបង ។

នៅទីនោះ ខ្មែរក្រហមបានបែងចែកប្រជាជនជម្លៀសទាំងអស់ឲ្យធ្វើការទៅតាមកងរៀងៗខ្លួន ។ ដោយសារតែឪពុករបស់ខ្ញុំនៅក្មេង ខ្មែរក្រហមបានចាត់តាំងឲ្យគាត់ចូលក្នុងកងកុមារចំណែកបងស្រីរបស់គាត់ម្នាក់ទៀតចូលកងនារី ។ គាត់បន្តថាការងាររបស់គាត់ក៏មិនខុសពីការងាររបស់ក្រុមកុមារដទៃទៀតឡើយគឺដើរប្រមូលលាមកសត្វមកធ្វើជាជីចាប់ពីព្រឹកព្រលឹមរហូតដល់យប់ដែលការងារនេះមិនសូវមានលក្ខណៈធ្ងន់ធ្ងរដូចប្រជាជនដែលពេញកម្លាំងឬមនុស្សពេញវ័យឡើយ ។ ប៉ុន្តែការហូបចុកនិងការព្យាបាលជំងឺគឺដូចជាប្រជាជនដទៃទៀតដែរដោយក្នុងសហករណ៍ត្រូវ

ហូបបបរាវៗដែលមានតែគ្រាប់អង្ករពីរ-បីគ្រាប់និងពេលឈឺមានតែថ្នាំមូលៗពណ៌ខ្មៅ (ថ្នាំអាចម៍ទន្សាយ) សម្រាប់ព្យាបាលជំងឺប៉ុណ្ណោះ ។

លើសពីនេះទៅទៀត ដោយសារតែការអប់រំនិងបំពាក់បំប៉នឲ្យស្រឡាញ់និងជឿជាក់លើអង្គការ គ្មាននរណាម្នាក់ហ៊ានប្រឆាំងឬជំទាស់នឹងបញ្ជារបស់អង្គការឡើយ បើមិនអ៊ីចឹងទេនឹងសម្លាប់ចោលជាមិនខាន ។ ចំណែកទំនាក់ទំនងនៅក្នុងគ្រួសារត្រូវកាត់ផ្តាច់ទាំងស្រុងដោយអង្គការតែងតែលើកឡើងថា «ឪពុកម្តាយរបស់យើងទាំងអស់គ្នាគឺជាអង្គការ ហើយមានតែអង្គការទេទើបជាអ្នកមានគុណរបស់យើងគ្រប់គ្នា» ។ ហេតុដូច្នេះហើយ បងប្អូនរបស់គាត់ទាំងពីរនាក់មិនសូវបានជួបគ្នាប៉ុន្មានទេ ព្រោះតែខ្លាចនិងអង្គការដឹងនិងហៅទៅកសាង ។

ក្រោយពីរបបខ្មែរក្រហមដួលរលំទៅ ទើបគ្រួសាររបស់ខ្ញុំបានត្រឡប់មកស្រុកកំណើតវិញ ។ ទោះបីជាខ្ញុំមិនកើតទាន់របបខ្មែរក្រហមក៏ដោយ ក៏ប៉ុន្តែបទពិសោធន៍របស់គាត់ធ្វើឲ្យខ្ញុំចង់ដឹងរឿងរ៉ាវជាច្រើនទាក់ទងនឹងរបបនេះ ជាពិសេសក្នុងនាមខ្ញុំជាយុវជនជំនាន់ក្រោយ ខ្ញុំនឹងខិតខំប្រឹងប្រែងថែរក្សាប្រវត្តិដ៏ជូរចត់នេះនិងចូលរួមចំណែកក្នុងការអភិវឌ្ឍកសាងសង្គមបច្ចុប្បន្នឲ្យកាន់តែចម្រើនរុងរឿងទុកសម្រាប់ក្មេងជំនាន់ក្រោយៗទៀត ដើម្បីកុំឲ្យប្រវត្តិដ៏ឃោរឃៅនេះត្រឡប់មកវិញម្តងទៀត ។

**ម៉ម សុវណ្ណ**

## គម្រោងអប់រំពីអំពើប្រល័យពូជសាសន៍

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបោះពុម្ពសៀវភៅ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ១៩៧៥-១៩៧៩» និង «សៀវភៅណែនាំគ្រូបង្រៀន» ដែលមានជាភាសាខ្មែរ និងអង់គ្លេស ។ ប្រសិនបើសាធារណជនចង់អាន សូមមើលតាមរយៈគេហទំព័រ

*http://dccam.org/Projects/Genocide/Khmer.htm*

*http://dccam.org/Projects/Genocide/pdf/DC-Cam_%2 0Teacher_Guidebook_Kh.pdf*



ម៉ម សុវណ្ណ ឆ្នាំ២០១០

# យុត្តិធម៌និងការឈឺចាប់

*គោរពជូនលោកនាយកនិងសហការីនៃមជ្ឈមណ្ឌលឯកសារកម្ពុជាជាទីគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ*



ហាវ សោភា

នាងខ្ញុំ ហាវ សោភា សូមថ្លែងអំណរគុណចំពោះលោកនាយកនិងសហការីដែលបានចូលរួមយ៉ាងសកម្មដើម្បីស្វែងរកយុត្តិធម៌ដល់ជនរួមជាតិដែលបានបាត់បង់ជីវិតក្នុងរបបកម្ពុជាប្រជាធិបតេយ្យដោយក្នុងនោះក៏មានឪពុករបស់ខ្ញុំនិងសាច់ញាតិជាច្រើនទៀតដែលបានស្លាប់ទាំងអយុត្តិធម៌ ។

ជិតបីទសវត្សរ៍មកហើយ ខ្ញុំនិងម៉ែមិនដែលបានដឹងថាឪពុកបាត់បង់ជីវិតនៅទីណាទេដោយបានត្រឹមតែដឹងថាគាត់ព្រាត់ពីគ្រួសារទៅនៅក្នុងរបបខ្មៅងងឹតនោះហើយក៏មិនដែលបានរំពឹងថានឹងរកយុត្តិធម៌ជូនគាត់ដែរ ។ ប៉ុន្តែ នៅទីបំផុតដូចសុភាសិតមួយនិយាយថា «នៅលើពិភពលោកនេះគ្មានអាថ៌កំបាំងទេ» ដោយនៅចុងឆ្នាំ២០០៦ ខ្ញុំក៏ទទួលបានឯកសារបញ្ជីអ្នកទោសនៅទួលស្លែងពីមជ្ឈមណ្ឌលឯកសារកម្ពុជាដែលធ្វើឲ្យខ្ញុំសែនរន្ធត់ចិត្តជាខ្លាំងនិងនឹកស្រមៃដល់អតីតកាលដែលខ្ញុំរង់ចាំដោយក្តីសង្ឃឹមត្រូវបានរលាយបាត់ ។ ខ្ញុំនឹកដល់ឪពុកនឹកដល់ទារុណកម្មដ៏ឃោរឃៅនៅគុកទួលស្លែងចិត្តខ្ញុំសែនឈឺចាប់... ។ល ។

ថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ១៩៧៦ ខ្ញុំបានបើកភ្នែកមើលឃើញពិភពលោកនេះ ខ្ញុំមិនដែលបានឃើញមុខឪពុកទេ ។ ខ្ញុំមិនដែលបានឃើញស្នាមញញឹមរបស់ឪពុកខ្ញុំ មិនដែលបានទទួលអំណោយអនុស្សាវរីយ៍ពីឪពុក មិនដែលបានទទួលការលើកទឹកចិត្តពីឪពុក មិនដែលបានទទួលការថ្នមបំពេពីឪពុក ខ្ញុំមិនដែលមានឪពុកជូនទៅសាលារៀន.....ដែលទាំងអស់នេះមិនមែនជាការខុសឆ្គងរបស់ឪពុកទេតែមកពីគាត់បានបាត់បង់ជីវិតទៅហើយ ទើបកូននិងភរិយាត្រូវរស់ដូចកូនសត្វគ្មានសំបុក ។ ម៉ែតស៊ូធ្វើឪពុកផងជាម្តាយផង ។ ម៉ែដ៏ល្អខំក្រាកឈរទាំងឈឺចាប់ផ្លូវចិត្តដែលកប់ជ្រៅក្នុងបេះដូងរបស់ម៉ែ ។ ដើម្បីកូនម៉ែមិនដែលត្អូញត្អែរថានឿយហត់ឡើយ ។ ម៉ែបានត្រឹមតែនិយាយថា បើឪពុកនៅរស់យើងមិនលំបាកដូចសព្វថ្ងៃនេះទេ ។ ដោយសាររបបខ្មៅងងឹតនេះទើបកែប្រែជីវិតយើងឲ្យរស់ក្នុងស្ថានភាពមួយដ៏អាក្រក់ ។

ឪពុកធ្លាប់និយាយថា បើស្រុកសាន្តត្រាណគាត់ឈប់ធ្វើទ័ពហើយរកស៊ីវិញ ។

ម៉ែស្រណោះសម្តីឪពុកណាស់ដោយមិនដែលគិតថាគាត់ត្រូវស្លាប់យ៉ាងអយុត្តិធម៌បែបនោះឡើយ ។ ឪពុកតស៊ូរំដោះប្រទេសឲ្យរួចផុតពីនឹមបរទេសដោយសង្ឃឹមថានឹងបានរស់នៅលើទឹកដីសុវណ្ណភូមិដោយសុខសាន្ត ។ នៅទីបំផុត គាត់ទទួលបានត្រឹមពាក្យ «ក្បត់បក្ស» ពីមាត់ប៉ុណ្ណោះ ដោយគាត់ត្រូវស្លាប់ដោយមិនដឹងថាកូនកើតមកស្រីឬប្រុស ឪពុកម្តាយនិងបងប្អូនស្លាប់ឬរស់នៅទីណា ។ នេះហើយជាផលប្រយោជន៍ដែលខ្មែរក្រហមផ្តល់ជារង្វាន់ជូនឪពុក ។ ខ្ញុំស្អប់របបនេះណាស់ ព្រោះបានធ្វើឲ្យខ្ញុំត្រូវព្រាត់ពីឪពុក ។ ឪពុកជាក្តីសង្ឃឹម ឪពុកជាមេដឹកនាំឲ្យកូនរឹងមាំ ឪពុកជាគ្រូដើមអប់រំកូនឲ្យតស៊ូក្នុងជីវិត ឪពុកជាអ្នកផ្តល់ក្តីស្រឡាញ់ដល់គ្រួសារ ។ នៅទីបំផុត ឪពុកត្រូវព្រាត់ទៅជារៀងរហូត ។ ទាំងនេះហើយដែលនាងខ្ញុំបំភ្លេចមិនបាន ។

ខ្ញុំមិនដែលភ្លេចឪពុក ខ្ញុំតែងគិតថាឪពុករស់នៅជាមួយខ្ញុំនិងម៉ែហើយលោកតែងតែសម្លឹងមករកយើងរាល់ថ្ងៃ ខ្ញុំតែងតែបួងសួងសូមឲ្យវិញ្ញាណក្ខន្ធរបស់ពុកបានរួចផុតពីកន្លែងដែលគេប្រល័យជីវិត ហើយសូមឪពុកទៅកាន់សុគតិភព ។ ទាំងនេះគ្រាន់ការរំពឹកតាមបែបពុទ្ធសាសនានោះទេ ប៉ុន្តែបើតាមច្បាប់ខ្ញុំត្រូវតែចូលរួមរកយុត្តិធម៌នៅពេលដែលតុលាការខ្មែរក្រហមបានបង្កើតឡើង ។ ទាំងនេះហើយដែលជំរុញឲ្យនាងខ្ញុំដាក់ពាក្យបណ្តឹងតាម

រយៈមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ទោះបីជាខ្ញុំមិនរំពឹងទៅលើយុត្តិធម៌ខ្ពស់ពេក ប៉ុន្តែខ្ញុំសង្ឃឹមលើសុភវិនិច្ឆ័យរបស់តុលាការថាលោកយល់នូវការឈឺចាប់របស់ប្រជាជាតិ ហើយនាងខ្ញុំនឹងរង់ចាំនូវការកាត់ក្តីមួយដែលយើងអាចទទួលយកបានហើយថាតើអ្នកណាខ្លះដែលពាក់ព័ន្ធនឹងការស្លាប់របស់ប្រជាជនជាងមួយលាននាក់ដូច្នេះ?

ខ្ញុំតែងសួរខ្លួនឯងថា តើហេតុអ្វីក៏មេដឹកនាំទាំងនោះសម្លាប់ជាតិឯងដូច្នេះ? គេធ្វើបែបនេះដើម្បីអ្វី? ហើយមនុស្សដែលគេសម្លាប់នោះសុទ្ធតែក្បត់ឬ? ចុះអ្នកដែលទើបជាមនុស្សដែលស្មោះត្រង់នឹងបក្សមែនទេ? ចម្លល់ទាំងអស់នេះវាមិនខុសនឹងជនរួមជាតិទាំងអស់ទេ ។ គេមិនដែលនឹកស្តាយក្រោយនូវកំហុសឆ្គងរបស់ពួកគេទេ ។ គេបន្សល់ទុកក្មេងកំព្រាប៉ុន្មាននាក់ស្ត្រីមេម៉ាយដែលរស់នៅក្នុងស្ថានភាពដ៏លំបាកទាំងផ្លូវចិត្តផ្លូវកាយនិងផ្នែកសេដ្ឋកិច្ចរហូតដល់ពេលបច្ចុប្បន្ន និងខ្លះទៀតក៏មានជំងឺផ្លូវចិត្តដ៏ធ្ងន់ធ្ងរទៀត ព្រោះតែការដឹកនាំដ៏មហាឃោរឃៅរបស់ពួកអមនុស្សធម៌ប៉ុន្មាននាក់នេះ ។

នាងខ្ញុំបានដាក់ពាក្យបណ្តឹងទៅតុលាការខ្មែរក្រហមមិនដែលគិតថា ចង់បានសំណងជាលុយកាក់ ឬលាភសក្ការៈអ្វីទេគឺដោយសារតែការបាត់បង់ជីវិតពុកដែលមិនអាចដូរជាមាសប្រាក់បាននិងមិនអាចកាត់ថ្លៃបានឡើយ ។

អ្វីដែលខ្ញុំចង់បានគឺយុត្តិធម៌ជូនពុក ព្រោះពុកស្លាប់ដោយអយុត្តិធម៌បំផុត ពុកស្លាប់ដោយមិនដឹងខ្លួនសោះថាខុសអ្វីឡើយនិងមិនបានទទួលការកាត់ក្តីមួយដ៏យុត្តិធម៌ទេ ។

ដូច្នេះ នាងខ្ញុំក៏សូមឧទ្ទិសដល់វិញ្ញាណក្ខន្ធពុកសូមឲ្យពុកបានដឹងឮផងថា កូនស្រីរបស់ពុកម្នាក់នេះមិនព្រងើយកន្តើយចំពោះការបាត់បង់ជីវិតរបស់ពុកឡើយ ។ កូននឹងរកយុត្តិធម៌ជូនពុក ។ សូមពុកទទួលយកយុត្តិធម៌ដែលនឹងកើតមានក្នុងពេលដ៏ខ្លីខាងមុខនេះ ហើយការឈឺចាប់របស់ម៉ែនិងខ្ញុំនឹងបានរសាយនៅពេលតុលាការប្រកាសសាលក្រមដែលយើងអាចទទួលយកបាន ។ ប៉ុន្តែ បើសាលក្រមមិនយុត្តិធម៌ទេនោះនឹងធ្វើឲ្យជនរងគ្រោះរឹតតែឈឺចាប់លើសដើមទៅទៀតព្រោះម្នាក់ៗសង្ឃឹមលើប្រធានចៅក្រមថា នឹងរកយុត្តិធម៌ឲ្យជនរងគ្រោះទាំងអស់រស់នៅនិងអ្នកដែលបានស្លាប់ក្នុងរបបខ្មែរក្រហម ។

ជាទីបញ្ចប់ នាងខ្ញុំសូមថ្លែងអំណរគុណដល់លោកនាយកនិងសហការីម្តងទៀតដែលលោកបានជួយដល់រូបនាងខ្ញុំនិងជនរងគ្រោះទាំងអស់ ជាពិសេសជួយរកមេធាវីល្អៗសម្រាប់ជនរងគ្រោះទាំងផ្នែកផ្លូវចិត្ត ។ លោកបានផ្តល់ផ្លូវឲ្យនាងខ្ញុំបានឈានរកយុត្តិធម៌ហើយ ក៏ជាប្រទីបមួយដែលបានបំភ្លឺឲ្យពិភពលោកឃើញកម្ពុជាច្បាស់កាលពីជាងសាមសិបឆ្នាំមុនថា តើកម្ពុជាមានរឿងអ្វីកើតខ្លះលើប្រជាជននៃប្រទេសនេះ ។

ចុងក្រោយ នាងខ្ញុំសូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិដែលថែរក្សាកម្ពុជាសូមលោកជួយថែរក្សាលោកនាយកនិងសហការីធ្វើដំណើរទៅទីណាកន្លែងណាប្រកបតែសេចក្តីសុខ សុវត្ថិភាពជានិច្ចនិរន្តរ៍និងជូនពរសូមមានសុខភាពល្អ សុភមង្គល រីកចម្រើនគ្រប់កិច្ចការងារនិងសម្រេចគ្រប់ភារកិច្ច ។

***បញ្ជីឈ្មោះសាច់ញាតិរបស់នាងខ្ញុំដែលបានបាត់បង់ជីវិតនៅរបបខ្មែរក្រហម ៖***

- លោកតា ចិន ហាវ ស្លាប់នៅសហករណ៍ចាហ្លួយ ខេត្តពោធិ៍សាត់
- លោកយាយ សោម ខៃ ស្លាប់នៅសហករណ៍ចាហ្លួយ ខេត្តពោធិ៍សាត់
- អ៊ំប្រុស ចិន ហ៊ា និងភរិយា ព្រមទាំងកូន៤នាក់ស្លាប់នៅសហករណ៍ចាហ្លួយខេត្តពោធិ៍សាត់
- លោកឪពុក ចិន ស៊ា ហៅ ហាវ ហាន ស្លាប់នៅទួលស្លែង
- លោកពូ ចិន ឆុន និងភរិយា ព្រមទាំងកូន៦នាក់ស្លាប់នៅសហករណ៍ចាហ្លួយ ខេត្តពោធិ៍សាត់
- លោកពូ ចិន សំអាត និងភរិយា ព្រមទាំងកូន៣នាក់ស្លាប់នៅសហករណ៍ចាហ្លួយខេត្តពោធិ៍សាត់
- លោកពូ រាជ សុជាត ស្លាប់នៅខេត្តស្វាយរៀង
- លោកអ៊ំ រាជ សាអែម និងភរិយា ព្រមទាំងកូន ៦នាក់
- លោកអ៊ំ ញ៉ែម គីមសួ ស្លាប់នៅខេត្តកំពង់ធំ
- លោកពូ ញ៉ែម គីមសៀង ស្លាប់នៅភ្នំពេញ
- លោកពូ ញ៉ែម ចន្ទី ស្លាប់នៅខេត្តកំពង់ធំ ។

**ហាន សោភា**

# សេចក្ដីប្រកាសស្វែងរកគ្រួសារ

ខ្ញុំបាទឈ្មោះ ឈុន អៀង ហៅ ទូច រស់នៅភូមិព្រៃកហូរខាងកើត ឃុំព្រៃកហូរ ស្រុកតាខ្មៅ ខេត្តកណ្ដាល ។ ខ្ញុំសូមប្រកាសស្វែងរកបងស្រីឈ្មោះ ចេង ឈុន ហៅ ស្រេង និងប្ដីឈ្មោះ ងួន អេង ហៅ តានី (វិស្វករអគ្គិសនី) និងកូនប្រុសស្រីចំនួន៥នាក់ឈ្មោះ ៖ ១) ងួន សោយុទ្ធ អាយុប្រហែល៤២ឆ្នាំ (ប្រុស) ២) ងួន វុត្ថា អាយុប្រហែល៤០ឆ្នាំ (ប្រុស) ៣) ងួន វុត្ថាវនី អាយុប្រហែល៣៨ឆ្នាំ (ស្រី) ៤) ងួន រតនបុប្ផា អាយុប្រហែល៣៦ឆ្នាំ (ស្រី) និងកូនប្រុសម្នាក់ទៀតដែលខ្ញុំពុំបានចាំឈ្មោះ ។ ប្រសិនបើបងប្អូនណាបានឃើញ ឬស្គាល់ឈ្មោះខាងលើនេះ សូមមេត្តាទាក់ទងមកខ្ញុំបាទតាមរយៈទូរស័ព្ទលេខ ០៩២ ៣៥ ៩៣ ៣០ ឬអាសយដ្ឋានខាងលើ ឬមជ្ឈមណ្ឌលឯកសារកម្ពុជា ប្រអប់សំបុត្រលេខ១១០ ភ្នំពេញ ឬទូរស័ព្ទលេខ (៨៥៥) ០២៣ ២១១ ៨៧៥ ។ **សូមអរគុណ!**

# សេចក្ដីប្រកាសរកឈ្មោះបងប្រុស និងគ្រួសារ

នាងខ្ញុំឈ្មោះ កែវ ដានី (ពុយ ដានី) និងប្ដីឈ្មោះ កែវ ប៊ុនលី រស់នៅ ៧៦ Rue Rene Laennec 67200 Strasbourg- France មានឪពុកឈ្មោះ ពុយ ងួនជី ម្ដាយឈ្មោះ ឡឹង ញាន ។ នាងខ្ញុំសូម ប្រកាសស្វែងរកបងប្រុស និងគ្រួសារឈ្មោះ ១) ពុយ តៃនី (ប្ដី) ២) គៅ យីង (ប្រពន្ធ) ៣) ពុយ រំពៃ (កូន) ៤) ពុយ វពីង (កូន) ៥) ពុយ រំពត់ ឬ រំព័រ (កូន) ។

ប្រសិនបើបងប្អូនណាបានឃើញសេចក្ដីប្រកាសនេះ សូមទាក់ទងមកខ្ញុំតាមរយៈអាសយដ្ឋានខាងលើ ឬមជ្ឈមណ្ឌលឯកសារកម្ពុជា ប្រអប់សំបុត្រលេខ១១០ ភ្នំពេញ ឬទូរស័ព្ទលេខ (៨៥៥) ០២៣ ២១១ ៨៧៥ ។ **សូមអរគុណ!**

# សេចក្ដីស្វែងរកបងប្រុស

ខ្ញុំឈ្មោះ កែវ ប៊ុនលី រស់នៅ ៧៦ Rue Rene Laennec 67200 Strasbourg-France សូមប្រកាសរកបងប្រុសឈ្មោះ កែវ ប៊ុនថុន ជាទាហានជំនាន់ លន់ នល់ បានទៅរៀននៅសហរដ្ឋអាមេរិកនៅឆ្នាំ១៩៧៣ រហូតឆ្នាំ១៩៧៦ ក៏បានទៅសិក្សានៅប្រទេសបារាំងទៀត រួចត្រឡប់ចូលមករស់នៅស្រុកខ្មែរវិញ ដោយជិះយន្តហោះចិន ។ រហូតមកដល់សព្វថ្ងៃនេះ គាត់បាត់ដំណឹងរហូត ។

ប្រសិនបើបងប្អូនណាបានឃើញសេចក្ដីប្រកាសនេះ សូមទាក់ទងមកខ្ញុំតាមរយៈអាសយដ្ឋានខាងលើ ឬ អ៊ីមែល ៖ keodaniel@free.fr. ។ **សូមអរគុណ!**

# សេចក្ដីប្រកាសរកប្អូនប្រុស

នាងខ្ញុំឈ្មោះ នាក់ ហេង សព្វថ្ងៃរស់នៅភូមិភ្នំតូច ឃុំស្ដេចគង់ខាងត្បូង ស្រុកបន្ទាយមាស ខេត្តកំពត ឪពុកខ្ញុំឈ្មោះ សោម យេន (ស្លាប់) និងម្ដាយឈ្មោះ អ៊ុន សឹម (ស្លាប់) ។ ខ្ញុំមានបងប្អូនពីរនាក់ គឺខ្ញុំនិងប្អូនប្រុសម្នាក់ទៀតឈ្មោះ នាក់ ធី (បាត់ខ្លួន) ។ ខ្ញុំសូមស្វែងរកប្អូនប្រុសឈ្មោះ នាក់ ធី ដែលបាត់ខ្លួនពេលធ្វើជានិរសារនៅព្រំដែនវៀតណាមនៅមុនឆ្នាំ១៩៧៥ ។ នៅពេលនោះ ធី ទើបតែមានអាយុប្រហែលជា១៤ឬ១៥ឆ្នាំប៉ុណ្ណោះ បានចេញពីផ្ទះទៅធ្វើជានិរសារជាមួយមីងឈ្មោះ ពៅ ជាអ្នកនាំចូល ។ ក្រោយមកខ្ញុំក៏បាត់ដំណឹង ធី រហូត ។ ប្រសិនបើប្អូនបានឃើញសេចក្ដីប្រកាសនេះ ឬបងប្អូនណាស្គាល់ ឬឮដំណឹងអំពីឈ្មោះខាងលើនេះ សូមមេត្តាផ្ដល់ព័ត៌មានមកនាងខ្ញុំតាមរយៈទូរស័ព្ទលេខ ០១៧ ៩២៩ ៩៦១ ឬមេភូមិភ្នំតូចឈ្មោះ មិន ឈុំ ឬទំនាក់ទំនងមកមជ្ឈមណ្ឌលឯកសារកម្ពុជា ។ **សូមអរគុណ!**

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ នៅក្នុងរបបខ្មែរក្រហម




មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាងមួយលាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ អេង កុកថាយ ទូរស័ព្ទលេខ ០១២ ៩៥៥ ៨៥៨ ឬ អ៊ីម៉ែល ៖ truthkokthay@dccam.org ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។




***សូមផ្តល់ព័ត៌មានដូចខាងក្រោមៈ***

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍ៈ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ៈ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍ៈ លេខទូរស័ព្ទ អាស័យដ្ឋាន) ។

***ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោមៈ***

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។




ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវេ ស៊ុយដែត និងសហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម/៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា : ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 129, September 2010 ◆ Funded by Denmark, Norway, Sweden, and USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.